# ខែមិថុនា ឆ្នាំ២០២០

## មេខ្យល់ចំនួន២នាក់ ដែលនាំពលរដ្ឋខ្មែរទៅធ្វើការដោយខុសច្បាប់នៅប្រទេសថៃ ត្រូវបាន សមត្ថកិច្ចខេត្តសៀមរាប ឃាត់ខ្លួន

http://www.matimohachunnews.com/ May 31, 2020

ខេត្តសៀមរាប៖ លោកវរសេនីយ៍ឯក ជា ហេង នាយការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប បានឲ្យដឹងថា មេខ្យល់ចំនួន០២នាក់ រួមមាន ៖ ១. ឈ្មោះ ទួន ទី ភេទប្រុស អាយុ៣៦ឆ្នាំ និង ២. ឈ្មោះ តិច សត់ ភេទប្រុស អាយុ២៣ឆ្នាំ រស់នៅភូមិគោកដូង ឃុំត្រីញ័រ ស្រុកពួកខេត្តសៀមរាប ត្រូវបានសមត្ថកិច្ចនគរបាលខេត្តសៀមរាបឃាត់ខ្លួន កាលពីវេលាម៉ោង១០ និង៣០នាទី ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២០ម្សិលមិញនេះ តាមបញ្ជាលោក កើត វណ្ណារ៉េត ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តសៀមរាប ដោយជាប់សង្ស័យនាំពលរដ្ឋខ្មែរចំនួន១៥នាក់ ទៅធ្វើការដោយខុសច្បាប់នៅប្រទេសថៃ ។

លោកវរសេនីយ៍ឯក ជា ហេង បានបញ្ជាក់ទៀតថា តាមចម្លើយសារភាពរបស់ជនសង្ស័យ បានឲ្យដឹងថា ពួកខ្លួនទាំងពីរនាក់បានទំនាក់ទំនងថៅកែនៅរាក់យ៉ង ក្នុងប្រទេសថៃ ដែលត្រូវការកម្មករទៅធ្វើការនៅទីនោះ ខ្លួនក៏ជ្រើសរើសពលករទាំងអស់នេះហើយដោយសន្យាថាមិនបាច់មានលិខិតឆ្លងដែនទេ គឺគេយកម្នាក់ ៣.០០០បាតប្រាក់ថៃពីថៅកែ ហើយរត់ការឆ្លងដែនដល់រាក់យ៉ង ប្រទេសថៃ បានធ្វើការទើបថៅកែកាត់ប្រាក់ខែពីពលករវិញម្នាក់ ៣.០០០បាតប្រាក់ថៃ រីឯពលរដ្ឋខ្មែរទាំង១៥ នាក់បានឆ្លើយថា មេខ្យល់ទាំង ០២នាក់នេះ បានសន្យាថានឹងនាំពួកខ្លួនទាំងអស់គ្នាទៅដល់រាក់យ៉ង ប្រទេសថៃ បានការងារធ្វើ ទើបកាត់ប្រាក់ខែឈ្នួលម្នាក់ ៣.០០០បាតវិញ ហើយការធ្វើដំណើរនេះពុំមានលិខិតឆ្លងដែនទេប៉ុន្តែដល់ព្រំដែនភូមិក្លិនទា ឃុំសឹង្ហ ត្រូវសមត្ថកិច្ចចាប់បានបញ្ជូនមកវិញ។

គួររំលឹកថា តាមរបាយការណ៍របស់លេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តសៀមរាប បានឲ្យដឹងថា កាលពីវេលាម៉ោង ២២៖៣០នាទី ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២០នេះ មានបងប្អូនពលរដ្ឋ ចំនួន ១៩ នាក់ ក្នុងនោះមានកុមារអាយុ ៦ខែម្នាក់ និងអាយុ ៣ឆ្នាំម្នាក់ មានទីលំនៅក្នុងភូមិគោកដូង ឃុំត្រីញ័រ ស្រុកពួក ខេត្តសៀមរាប ត្រូវបានចាញ់បោកមេខ្យល់នាំទៅប្រទេសថៃ ហើយបានយកមកទម្លាក់ចោលឲ្យដេកនៅកណ្តាលព្រៃចំការដំឡូង ស្ថិតនៅចំណុចក្លិនទា ភូមិរុន ឃុំសិង្ហ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ហើយត្រូវបានអ្នកចាំការដំឡូងប្រទះឃើញនឹងបានរាយការណ៍ទៅអាជ្ញាធរភូមិ ហើយត្រូវលោកមេភូមិរាយការណ៍ទៅលោកមេឃុំសិង្ហ និងរដ្ឋបាលស្រុកអូរជ្រៅ ព្រមទាំងជូនពួកគាត់មកដល់សាលាឃុំសិង្ហ ដើម្បីសាកសួរព័ត៌មាន ខណៈពេលនោះលោក ម៉ាន់ ធី អធិការរងនគរបាលស្រុកអូរជ្រៅ បានរាយការណ៍មកក្រុមការងារខេត្តសៀមរាប ប្រចាំការនៅច្រកអន្តរជាតិប៉ោយប៉ែត ដើម្បីធ្វើការទទួល និងដឹកជូនពួកគាត់ត្រឡប់ទៅខេត្តសៀមរាបវិញ ។

របាយការណ៍បានឲ្យដឹងទៀតថា ភ្លាមៗនោះ ដោយមានកិច្ចអន្តរាគមន៍ពីឯកឧត្តម ទៀ សីហា អភិបាលខេត្តសៀមរាប ជាអ្នកបញ្ជាផ្ទាល់ លោកស្រី យូ សុភា អភិបាលរងខេត្ត និងប្រធានក្រុមការងារខេត្តសៀមរាបប្រចាំការនៅច្រកអន្តរជាតិប៉ោយប៉ែត , ច្រករបៀងអូរបីជាន និងច្រករបៀងម៉ាឡៃ បានដឹកនាំក្រុមការងាររួមមាន លោកស្រីឧត្តមសេនីយ៍ត្រី ដួង ថាវរី ស្នងការរងនគរបាលខេត្តសៀមរាប , លោកវរសេនីយ៍ឯក ជា ហេង ប្រធាការិយាល័យប្រឆាំការជួញដូរមនុស្ស នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប , លោក ចាន់ សុផល មេបញ្ជាការរងតំបន់ប្រតិបត្តិការសឹករងសៀមរាប , តំណាងមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ , តំណាងមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ និងតំណាងមន្ទីរអប់រំយុវជន និងកីឡាខេត្តសៀមរាប និង មន្ត្រីសាលាខេត្តសៀមរាប ដោយមានកិច្ចសហការពីលោកអភិបាល នៃគណៈអភិបាលស្រុកអូរជ្រៅផង បានចុះទៅពិនិត្យ និងទទួលបងប្អូនប្រជាពលរដ្ឋខេត្តសៀមរាបទាំង១៩នាក់ ដឹកជញ្ជូនពួកគាត់តាមរថយន្តយោធា របស់បញ្ជាការដ្ឋានតំបន់ប្រតិបត្តិការសឹករង

សៀមរាប ឆ្ពោះទៅសាលាគុរុកោសល្យ និងវិក្រឹត្យការខេត្តសៀមរាប ដើម្បីធ្វើការពិនិត្យសុខភាព និងការដាក់ឲ្យធ្វើចាត់ត្តាទ្បីស័ក ។

ក្នុងឱកាសនោះ លោកស្រី យូ សុភា អភិបាលរងខេត្តសៀមរាប បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអាជ្ញាធរខេត្តបន្ទាយមានជ័យ ពិសេស ឯកឧត្តមអភិបាលខេត្ត លោកអភិបាលស្រុក ក្រុមប្រឹក្សាឃុំ មេភូមិ និងប្រជាការពារភូមិទាំងអស់ក្នុងខេត្តបន្ទាយមានជ័យ ដែលជួយសង្គ្រោះប្រជាពលរដ្ឋខេត្តសៀមរាប ពីមេខ្យល់ដែលនាំចេញឆ្លងដែនដោយខុសច្បាប់ទៅប្រទេសថៃ ជាពិសេសថ្លែងអំណរគុណចំពោះកម្លាំងសមត្ថកិច្ចនិងមន្ត្រីពាក់ព័ន្ធក្នុងខេត្តសៀមរាប ដែលបានរែកមុខរកឃើញ និងឃាត់ខ្លួនមនុស្សដែលជាមុខសញ្ញាជាប់សង្ស័យនាំពលរដ្ឋខ្មែរទៅធ្វើការដោយខុសច្បាប់នៅប្រទេសថៃ ។ ជាមួយគ្នានេះដែរ លោកស្រី យូ សុភា បានអំពាវនាវ និង សំណូមពរដល់ប្រជាពលរដ្ឋទាំងអស់ ត្រូវអត់ធ្មត់មួយរយៈសិន ក្នុងការឆ្លងដែនទៅរកការងារធ្វើក្នុងប្រទេសថៃ ដោយត្រូវរងចាំឲ្យសភាពការណ៍នៃជំងឺកូវីដ១៩ បានស្រាកស្រាន ឬត្រូវបានបញ្ចប់ និង រង់ចាំប្រទេសថៃបញ្ចប់ការដាក់ប្រទេសក្នុងគ្រាអាសន្ន ឬមានការបញ្ជាក់ជាផ្លូវការណាមួយ រវាងប្រទេសកម្ពុជា និងប្រទេសថៃ ក្នុងការបើកដំណើរការច្រកព្រំដែនរវាងប្រទេសទាំងពីរ ពិសេសចំពោះបងប្អូនដែលត្រូវទៅប្រទេសថៃដោយស្របច្បាប់ និងមានឯកសារត្រឹមត្រូវតាមច្បាប់កំណត់របស់ប្រទេសនីមួយៗ ៕ ប្រភព មន្ទីរព័ត៌មានខេត្តសៀមរាប

## បងប្អូនប្រជាពលរដ្ឋចំនួន ១១នាក់ ត្រូវបានអនុញ្ញាតឱ្យត្រលប់ទៅមូលដ្ឋានវិញ បន្ទាប់ពីនៅដាច់ដោយឡែកអស់រយៈពេល ១៤ថ្ងៃ

https://www.information.gov.kh/ AKP ភ្នំពេញ ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២០

អនុគណៈកម្មការប្រឆាំងនឹងជំងឺកូវីដ-១៩ ស្រុកក្រឡាញ់ ខេត្តសៀមរាប បានអនុញ្ញាតឱ្យបងប្អូនប្រជាពលរដ្ឋចំនួន ១១នាក់ ក្នុងនោះស្ត្រី ០៥នាក់ ត្រឡប់ទៅមូលដ្ឋានវិញ នាព្រឹកថ្ងៃសៅរ៍ ៩ កើត ខែជេស្ឋ ឆ្នាំជូតទោស័ក ពុទ្ធសករាជ ២៥៦៤ ត្រូវនឹងថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២០។

លោក សុខ ណារ៉េត អភិបាលរងស្រុកក្រឡាញ់ ខេត្តសៀមរាប តំណាងលោកស្រី ម៉ននី រង្សី អភិបាលនៃគណៈអភិបាលស្រុក និងជាប្រធានអនុគណៈកម្មការប្រឆាំងនឹងជំងឺកូវីដ-១៩ស្រុក ព្រមទាំងក្រុមការងារអនុគណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ-១៩ស្រុក បានជួបសំណេះសំណាល ថ្លែងអំណរគុណដល់បងប្អូនប្រជាពលរដ្ឋ ដែលមានភាពអត់ធ្មត់ក្នុងការចូលរួមអនុវត្តតាមការណែនាំរបស់រាជរដ្ឋាភិបាល ក្រសួងសុខាភិបាល និងការណែនាំរបស់រដ្ឋបាលខេត្តសៀមរាប ក្នុងការអនុវត្តដាក់ឱ្យបងប្អូននៅដាច់ដោយឡែករយៈពេល ១៤ថ្ងៃនេះ រហូតបានបញ្ចប់ដោយជោគជ័យ និងមានសុខភាពល្អ។ លោកអភិបាលរងក៏បានចូលរួមរីករាយចំពោះក្រុមការងារចត្តាឡីស័ក និងបងប្អូនប្រជាពលរដ្ឋដែលបានធ្វើតេស្ដ៏សំណាករកវីរុសកូវីដ-១៩ទាំងអស់នៅមណ្ឌលចត្តាឡីស័កវិទ្យាល័យក្រឡាញ់ដែលមានលទ្ធផលអវិជ្ជមាន។ ជាមួយនេះ លោកក៏បានណែនាំដល់បងប្អូនប្រជាពលរដ្ឋឱ្យបន្តការថែទាំសុខភាពដោយការធ្វើអនាម័យ សម្អាតខ្លួនប្រាណ ដោយសាប៊ូ អាល់កុល អនាម័យម្ហូបអាហារ និងជៀងវាងការជួបជុំមនុស្សច្រើន ការជួបជុំកម្មវិធីផ្សេងៗ ឱ្យបានជាដាច់ខាតក្នុងការបង្ការ ទប់ស្កាត់ជំងឺនេះ ត្រូវពាក់ម៉ាស់ និងរក្សាគម្លាតសុវត្ថិភាព។

លោក សុខ ណារ៉េត បានអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋកុំឱ្យជឿពាក្យល្បួងលួងលោមរបស់មេខ្យល់ថាអាចជូនឆ្លងដែនទៅធ្វើការនៅប្រទេសថៃបាននៅក្នុងកាលៈទេសៈ និងស្ថានភាពនៃការប្រឈមនឹងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩នេះ។ បងប្អូនត្រូវបន្តការពារខ្លួន និងក្រុមគ្រួសារ ព្រមទាំងប្រកបរបរបន្ទាប់បន្សំផ្គត់ផ្គង់ជីវភាព

គ្រួសារប្រចាំថ្ងៃ និងបង្កបង្កើនផលដំណាំដាំដុះ ចិញ្ចឹមសត្វ គ្រាន់បានបេះបោចកំដរឆ្នាំង និងកាត់បន្ថយចំណាយប្រចាំថ្ងៃ៕ ដោយ នីកា (ប្រភព៖ រដ្ឋបាលស្រុកក្រឡាញ់)

## ពិធីចែកអំណោយដល់គ្រួសារខ្វះខាតក្រីក្រ ក្នុងសង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ចំនួន ១៣៩គ្រួសារ

https://grandnewsasia.com/ ថ្ងៃសុក្រ ទី ២៩ ឧសភា ២០២០

កំពង់ឆ្នាំង៖ នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០នេះ លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានក្រុងកំពង់ឆ្នាំង បានអញ្ជើញចែកអំណោយជូនប្រជាពលរដ្ឋងាយរងគ្រោះចំនួន ១៣៩ មកពីសង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង មានការអញ្ជើញចូលរួមពីឯកឧត្តម លោកជំទាវ លោក លោកស្រី សមាជិកក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន។ ពិធីនេះប្រារព្ធធ្វើនៅក្នុងវត្តអារញ្ញការាមដោយមានការនិមន្តចូលរួមពីព្រះសិរីធម្មញាណ សុខ ថាន ព្រះរាជាគណៈថ្នាក់កិតិយស ព្រះធម្មវង្សាធិបតី ព្រះមេគណខេត្តកំពង់ឆ្នាំង លោកស្រី ប៊ិន សុភី អភិបាលរងខេត្ត ព្រមទាំងក្រុមប្រឹក្សាក្រុង គណៈអភិបាលក្រុង និងមន្រ្តីអាជ្ញាធរ សង្កាត់ និងភូមិ។

លោកស្រី ជូ ប៊ុនអេង ក៏បានបញ្ជាក់ជូនប្រជាពលរដ្ឋ ក្នុងការការពារសុខភាព និងធ្វើអនាម័យតាមការណែនាំ របស់គ្រូពេទ្យ និងការផ្សព្វផ្សាយរបស់ក្រសួងសុខាភិបាលជាប់ជានិច្ច ដើម្បីការពារពីមេរោគកូវីដ-១៩។ លោកជំទាវក៏បានអំពាវនាវឱ្យប្រជាពលរដ្ឋទាំងអស់គ្នាត្រូវបង្កើនការផលិតផ្នែកកសិកម្ម តាមរយៈ ការដាំដុះ ការចិញ្ចឹមសត្វជាដើម ចំណែកឯអជ្ញាធរត្រូវតែពង្រឹងឱ្យមានប្រសិទ្ធិភាពនូវ ភូមិ-ឃុំមានសុវត្ថិភាព និងចូលរួមគោរពច្បាប់ចរាចរណ៍ទាំងអស់គ្នា។

លោក ឃិន សារ៉េន អភិបាលក្រុងកំពង់ឆ្នាំង បានឱ្យដឹងថា អំណោយដែលផ្តល់ជូនប្រជាពលរដ្ឋនាឱកាសនោះគឺបានមកពីការចូលរួមដោយផ្ទាល់របស់ព្រះគ្រូ កង សុផល ព្រះគ្រូសូត្រស្តាំវត្តអារញ្ញិការាម ព្រមទាំងសប្បុរសជនជិតឆ្ងាយ ដែលចំណាយថវិកាជាង១៨លានរៀល។

អំណោយដែលបានចែកជូនដល់ប្រជាពលរដ្ឋក្នុងមួយគ្រួសារទទួលបាន៖ អង្ករ ១០ គីឡូក្រាម, មី ១កេស, ទឹកត្រី ១យួរ, ទឹកស៊ីអ៊ីវ ១ យួរ, ត្រីខ ១ យួរ, និងថវិកា ១០ ០០០រៀលផងដែរ៕

## សម្រេចឃុំខ្លួនមេខ្យល់២នាក់ ករណីញុះញង់ឱ្យក្មេងជាអនីតិជនដើរសុំទានគេ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០២០ ម៉ោង ១១:៣១ ឃឹម ប៊ុនណាក់

រាជធានីភ្នំពេញ ៖ ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ លោក សោ សុតា កាលពីល្ងាចថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ បានសម្រេចចេញដីកាឃុំខ្លួនស្រី២ នាក់ជាមេខ្យល់.ញុះញង់ឲ្យក្មេងជាអនីតិជនដើរសុំទានតាមភ្លើងស្តុប.និងផ្លូវសាធារណៈ ដាក់ពន្ធនាគារជាបណ្តោះអាសន្ន ដើម្បីបើកការស៊ើបអង្កេតឈានដល់ការជំនុំជម្រះលើអង្គសេចក្តី ។ អ្វីដែលគេបានសង្កេតឃើញ មុនសមត្ថកិច្ចនាំមេខ្យល់ទាំង២នាក់ទៅឃុំខ្លួន ក៏មានម៉ូតូកង់បីមួយគ្រឿង បានដាក់ក្មេងៗប្រុសស្រីប្រមាណបួនដប់នាក់ ទៅទម្លាក់នៅមុខបរិវេណសាលាដំបូងរាជធានីភ្នំពេញ ដែលពេលនោះពួកគេបានសុំការអនុញ្ញាតិពីឆ្មាំការពារតុលាការ ដើម្បីចូលជួបសួរសុខទុកមេខ្យល់នោះ ប៉ុន្តែមិនត្រូវបានឲ្យចូលជួប ទើបពួកគេនៅពាក់ពពូនងើតករហង់ មុខច្រកទ្វារចេញ ចូលរបស់សាលាដំបូងរាជធានីភ្នំពេញ រហូតដល់ពេលរថយន្តសមត្ថកិច្ចដឹកស្ត្រីទាំងពីរទៅកាន់ពន្ធនាគារ បានពួកគេជិះកង់បីចាកចេញទៅវិញ ។

សូមបញ្ជាក់ថា កាលពីវេលាម៉ោង៩ ព្រឹកថ្ងៃទី២៧ ខែ ឧសភា ឆ្នាំ២០២០ កម្លាំងសមត្ថកិច្ចជំនាញនគរបាល ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន រាជធានីភ្នំពេញ បានចុះអនុវត្តតាមចំណារអនុញ្ញាតិឲ្យ បង្ក្រាបដាក់ស្តែង របស់លោក ម៉ុត ដារ៉ា ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ លើករណីកេងប្រវ័ញ្ចពល កម្មកុមារ ក្នុងរូបភាពបង្ខំឲ្យក្មេងដើរសុំទានតាមភ្លើងស្តុប ឈានដល់ការឃាត់ខ្លួនមេខ្យល់២ នាក់ និងសង្គ្រោះកុមារ រងគ្រោះ៦ នាក់ ។ ជនសង្ស័យជាមេខ្យល់ម្នាក់ឈ្មោះ ឆៃ ធឿន ភេទស្រី អាយុ៥៨ឆ្នាំ ស្នាក់នៅភូមិ អន្លង់៤ សង្កាត់ គោករការ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ និងមុខរបរមិនពិតប្រាកដ ។ និងម្នាក់ឈ្មោះ នួន ទូច ភេទស្រី អាយុ២៨ ឆ្នាំ ស្នាក់នៅភូមិ អន្លង់៤ សង្កាត់គោករការ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ និងមុខរបរមិនពិតប្រាកដ ។

លោកវរៈសេនីយ៍ឯក កែវ ធា ប្រធានការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការ ពារអនីតិជនរាជធានី ភ្នំពេញ បានឲ្យដឹងថា ជនសង្ស័យ២នាក់ និងត្រូវសាងសំណុំរឿងបញ្ជូនទៅកាន់សាលាដំបូងភ្នំពេញ នៅថ្ងៃទី២៨ ខែឧស ភា ឆ្នាំ២០២០ នេះ ចំណែកជនរងគ្រោះត្រូវបានប្រគល់ឲ្យទៅមន្ទីរសង្គម កិច្ច យកទៅគ្រប់គ្រង ។ លោក កែវ ធា បន្តថា ករណីខាងលើនេះសមត្ថកិច្ចយើងបានសង្គ្រោះកុមាររងគ្រោះចំនួន៦នាក់ (ស្រី៣នាក់) ក្នុងនោះ មានទារកចំនួន ២នាក់ប្រុស ដែលជាករណី កេងប្រវ័ញ្ចពលកម្មលើកុមារ (ក្នុងរូបភាពដើរសុំទាន) នៅចំណុចក្នុង ផ្សារបឹងឈូក សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ និងបាននាំទៅកាន់ការិយាល័យ ដើម្បីធ្វើការ សាកសួរ និងកសាងសំណុំរឿងបញ្ជូនទៅតុលាការ ៕

## អាជ្ញាធរខេត្តស្វាយរៀងណែនាំដល់ពលរដ្ឋដែលត្រឡប់ពីក្រៅប្រទេសឱ្យធ្វើចត្តាឡីស័ក និង ថែរក្សាអនាម័យខ្លួនប្រាណ

http://ppd-news.net/ ថ្ងៃចេញផ្សាយ: May 31, 2020

ខេត្តស្វាយរៀង ៖ លោក តូច ប៉ូលីវ៉ា អភិបាលរងខេត្តស្វាយរៀងបានចុះណែនាំដល់ប្រជាពលរដ្ឋ ដែលវិល ត្រលប់ពីក្រៅប្រទេសឱ្យចូលធ្វើចត្តាឡីស័កដាក់នៅដោយឡែករយៈពេល១៤ថ្ងៃ និងថែរក្សាអនាម័យខ្លួនប្រាណឲ្យ បានទៀងទាត់ ដែលជាការចូលរួមអនុវត្តតាមការណែនាំរបស់រាជរដ្ឋាភិបាល ដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩ ទោះបីមួយរយៈចុងក្រោយនេះ កម្ពុជាមានស្ថានភាពល្អប្រសើរក៏ដោយ។ ការថ្លែងដូច្នេះរបស់លោក តូច ប៉ូលីវ៉ា ធ្វើ ឡើងនារសៀលថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២០ ខណៈដែលលោកចុះជួបសំណេះសំណាល ពលករដែលទើបវិល ត្រលប់មកពីក្រៅប្រទេសចូលមកស្រុកកំណើតនៅភូមិព្រៃកា ឃុំឈើទាល និងភូមិត្រោកតូច ឃុំស្វាយធំ ស្រុក ស្វាយជ្រំ ខេត្តស្វាយរៀង វិញ ក៏ដូចជាចុះពិនិត្យទីតាំងចត្តាឡីស័ក ដាក់ខ្លួនដាច់ដោយឡែកនៅតាមផ្ទះផងដែរ។ បន្ថែមលើនេះលោកអភិបាលរងខេត្តបាននាំផ្តាំផ្ញើ ឱ្យមន្ត្រីជំនាញត្រូវតាមដានសុខភាពរបស់ពលករដោយផ្ទាល់ និង ជាប្រចាំ ពិសេសជំរុញពួកគាត់ឲ្យធ្វើអនាម័យសម្អាតខ្លួនប្រាណ ដូចជាការលាងដៃជាមួយសាប៊ូជាប្រចាំឱ្យបានញឹក ញាប់ ការហាត់ប្រាណជាដើម។

លោកបានបញ្ជាក់ប្រាប់ប្រជាពលរដ្ឋ-ពលករឱ្យមានការប្រុងប្រយ័ត្នខ្ពស់គ្រប់ៗ ក្រុមគ្រួសារចំពោះជំងឺកូវីដ១៩ និងចូលរួមទប់ស្កាត់ នូវការឆ្លងរីករាលដាលនៃជំងឺនេះ មិនត្រូវភ្លេចខ្លួននោះទេ។ ទន្ទឹមនោះលោកបានបន្ត ណែនាំដល់អាជ្ញាធរ និងប្រជាពលរដ្ឋត្រូវជំរុញការងារកសិកម្មដាំដុះបន្លែបង្ការ ចិញ្ចឹមសត្វនៅក្នុងមូលដ្ឋាន ជា ពិសេសត្រូវរក្សាទុកនូវស្បៀងអាហារដូចជា អង្ករ អំបិល ប្រហុក ត្រី សាច់ ទុកគ្រាន់ប្រើប្រាស់ទៅថ្ងៃមុខទៀត ប្រសិនបើជំងឺកូវីដនេះនៅតែអូសបន្លាយយូរ។ លើសពីនេះ លោកអភិបាលរងខេត្តក៏បានណែនាំដល់ប្រជាពលរដ្ឋ និងអាជ្ញាធរឱ្យចូលរួមទាំងអស់គ្នាក្នុងការគោរពច្បាប់ចរាចរណ៍ផ្លូវគោកឲ្យបានខ្ជាប់ខ្ជួន និងបន្តអនុវត្តគោលនយោ បាយភូមិឃុំមានសុវត្ថិភាពឲ្យមានប្រសិទ្ធភាពខ្ពស់ផងដែរ៕ ដោយ ៖ ភក្តី

## អាជ្ញាធរខេត្តសៀមរាបបានសម្របសម្រួលនិងទទួលប្រជាពលរដ្ឋឆ្លងដែនខុសច្បាប់ដោយសារចាញ់បោកមេខ្យល់

https://www.facebook.com/SiemReap.provincial/ 31-05-2020

បងប្អូនប្រជាពលរដ្ឋ និងមានកូនតូចៗសរុបចំនួន១៩នាក់ រស់នៅខេត្តសៀមរាប ដែលបានធ្វើដំណើរទៅតាមមេខ្យល់យកទៅទម្លាក់ចោលឲ្យដេកកណ្តាលព្រៃ ដើម្បីលួចឆ្លងដែនខុសច្បាប់ ចូលទៅធ្វើការនៅប្រទេសថៃ ហើយត្រូវបានមេភូមិ រុន ឃុំសិង្ហ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ធ្វើការឃាត់ខ្លួន។ ក្រោយពីបានទទួលដំណឹងពីការឃាត់បានប្រជាពលរដ្ឋខេត្តសៀមរាប ដែលបានធ្វើដំណើរទៅធ្វើការនៅក្រៅប្រទេសដោយឆ្លងដែនខុសច្បាប់ ត្រូវបានលោកស្រី យូ សុភា អភិបាលរងនៃគណៈអភិបាលខេត្ត តំណាងឲ្យ ឯកឧត្តម ទៀ សីហា អភិបាលនៃគណៈអភិបាលខេត្តសៀមរាប រួមទាំងអស់លោក លោកស្រីក្រុមការងារទទួលប្រជាពលរដ្ឋវិលត្រឡប់ពីក្រៅប្រទេស ដើម្បីទៅទទួលបងប្អូនពីអាជ្ញាធរឃុំ សិង្ហ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ។

តាមការបញ្ជាក់របស់លោក ម្លិះ ប៊ុនថន បានឲ្យដឹងថា នៅវេលាម៉ោង ២២ និង ៣០នាទីនារាត្រីថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២០ ដោយទទួលព័ត៌មានពីអ្នកចាំចំការថា មានបងប្អូនពលរដ្ឋ និងកូនតូចៗចំនួន១៩នាក់ មកពីស្រុកពួក ខេត្តសៀមរាប បានធ្វើដំណើរតាមរយៈមេខ្យល់ យកមកទម្លាក់ចោលឲ្យដេកនៅកណ្តាលព្រៃចំការ ចំណុចក្លិនទា ភូមិរុន ឃុំសិង្ហ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ហើយនៅពេលសួរនាំពួកគាត់ថា គឺដោយសារអ្នកបើករថយន្តនោះវង្វេងផ្លូវ ហើយទម្លាក់ពួកគាត់ទុកនៅក្នុងព្រៃ បានបើករថយន្តរត់ចោលបាត់ ហើយត្រូវបានលោក ម្លិះ ប៊ុនថន បានដឹកតាមរថយន្តនាំមកឲ្យសម្រាកនៅផ្ទះរបស់ខ្លួន លុះព្រឹកថ្ងៃទី២៩ ឧសភានេះ បានដឹកយកមកប្រគល់ឲ្យសាលាឃុំសិង្ហ រងចាំអាជ្ញាធរខេត្តសៀមរាប មកទទួលយក ។

ក្នុងឱកាសទទួលបងប្អូនប្រជាពលរដ្ឋទាំង១៩នាក់នោះ លោកស្រី យូ សុភា ក៏បានធ្វើការណែនាំ និង ផ្សព្វផ្សាយ ពីសេចក្តីជូនដំណឹងរបស់រាជរដ្ឋាភិបាល លេខ១៣៩៦ សជណ ស្តីពីការទប់ស្កាត់ប្រជាពលរដ្ឋខ្មែរ កុំឲ្យឆ្លងដែនដោយខុសច្បាប់ ចូលទៅប្រទេសជិតខាង តាមច្រករបៀងនានា និង សុំឲ្យបងប្អូនកុំឲ្យចាញ់ឧបាយកលរបស់មេខ្យល់ ដោយបាននាំឆ្លងដែនខុសច្បាប់ទៅប្រទេសជិតខាង ក្នុងខណៈពេលដែលប្រទេសជិតខាងបានកំពុងដាក់ប្រទេសក្នុងគ្រាអាសន្ន ដើម្បីបង្កា ទប់ស្កាត់ការរីករាលដាលនៃជម្ងឺកូវីដ១៩ ។

លោកស្រីក៏បានលើកផងដែរថា ទោះបីមានភាពធូស្រាលពីជម្ងឺកូវីដ១៩ នៅកម្ពុជាក៏ពិតមែន តែភាពក្តៅគគុកនៅលើពិភពលោកនៅតែបន្តរីករាលដាល សំខាន់នៅប្រទេសជិតខាងយើងនេះ ក៏នៅតែប្រឈមទៅនឹងបញ្ហាជម្ងឺកូវីដ១៩នេះនៅឡើយ ព្រមទាំងបន្តដាក់ប្រទេសរបស់ខ្លួន ក្នុងគ្រាអាសន្នទៀតផង ។ ដោយកត្តានេះហើយបានប្រមុខរាជរដ្ឋាភិបាល និងក្រសួងសុខាភិបាល បន្តវិធានការ ការ ពារជម្ងឺឆ្លងកូវីដ១៩ នឹងត្រូវអនុវត្តគ្មានទីបញ្ចប់ បើសិនជាស្ថានភាពពិភពលោកត្រូវអូសបន្លាយបន្តទៀត ដើម្បីបង្កើន នូវការប្រុងប្រយ័ត្នខ្ពស់ ចំពោះរលកទី២នៃជម្ងឺកូវីដ១៩ កុំឲ្យមានការរីករាលដាល់នៅក្នុងសហគមន៍ ៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី មានពលរដ្ឋខ្មែរវិលត្រឡប់មកពីប្រទេសថៃតាមច្រករបៀង(ស្លាបស្តាំ) របស់ប៉ុស្តិ៍ចំនួន ០៥នាក់

https://www.facebook.com/GDIOfficial/ 31-05-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី នាវេលាម៉ោង ១៥និង៤៥នាទី ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២០ មានពលរដ្ឋខ្មែរ វិលត្រឡប់មកពីប្រទេសថៃ តាមច្រករបៀង (ស្លាបស្តាំ) របស់ប៉ុស្តិ៍ចំនួន ០៥នាក់ ស្រី០២នាក់។ បន្ទាប់មកកម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំ និងពិនិត្យកំដៅជូនពួកគាត់ និងបានសហការប្រគល់អ្នកទាំង ០៥នាក់ខាងលើ ជូនទៅមន្ត្រីចត្តាឡីស័ក ដើម្បីអនុវត្តតាមជំនាញបន្ត។ ដោយឡែកប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែន

អន្តរជាតិភ្នំដី ខាងភាគីថៃ ពុំមានបើកច្រកទ្វារព្រំដែន អនុញ្ញាតឲ្យនាំចូល-ចេញទំនិញនោះទេ គឺអនុញ្ញាតតែចន្លោះពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រតែប៉ុណ្ណោះ៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ២៨នាក់

https://www.facebook.com/GDIOfficial/ 31-05-2020

នៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ផង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ២៨នាក់ ស្រី ១៣នាក់ និងពលរដ្ឋថៃដែលចាកចេញមានចំនួន ០៧នាក់ ស្រី ០៤នាក់ (មានឯកសារចេញពីស្ថានទូតថៃ និងលិខិតបញ្ជាក់សុខភាព)៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៩នាក់

https://www.facebook.com/GDIOfficial/ 30-05-2020

នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ផង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។

ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យមានចំនួន ១៩នាក់ ស្រី ០៦នាក់ និងបានឃាត់ខ្លួនប្រជាពលរដ្ឋខ្មែរ ០១នាក់ ដែលមានបំណងលួចឆ្លងដែនខុសច្បាប់ ចូលទៅកាន់ប្រទេសថៃ តាមព្រៃនៅខាងលិច ច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ប្រហែល ៧០ម៉ែត្រ បន្ទាប់ពីបានអប់រំណែនាំរួច ក៏អនុញ្ញាតឲ្យវិលទៅកាន់លំនៅដ្ឋានវិញ៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី មានពលរដ្ឋខ្មែរ វិលត្រឡប់មកពីប្រទេសថៃ តាមច្រករបៀង (ស្លាបស្ដាំ) របស់ប៉ុស្តិ៍ចំនួន ០៥នាក់

https://www.facebook.com/GDIOfficial/ 30-05-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី នាវេលាម៉ោង ១៥និង៥៥នាទី ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២០ មានពលរដ្ឋខ្មែរ វិលត្រឡប់មកពីប្រទេសថៃ តាមច្រករបៀង (ស្លាបស្ដាំ) របស់ប៉ុស្តិ៍ចំនួន ០៥នាក់ ស្រី ០៣នាក់។ បន្ទាប់មកកម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំ និងពិនិត្យកំដៅជូនពួកគាត់ និងបានសហការប្រគល់អ្នកទាំង ០៥នាក់ខាងលើ ជូនទៅមន្ត្រីចត្តាឡីស័ក ដើម្បីអនុវត្តតាមជំនាញបន្ត។ ដោយឡែកប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី ខាងភាគីថៃ ពុំមានបើកច្រកទ្វារព្រំដែន អនុញ្ញាតឲ្យនាំចូល-ចេញទំនិញនោះទេ គឺអនុញ្ញាតតែចន្លោះពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រតែប៉ុណ្ណោះ៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៣១នាក់

https://www.facebook.com/GDIOfficial/ 29-05-2020

នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៣១នាក់ ស្រី ១៥នាក់ និងពលរដ្ឋថៃចាកចេញចំនួន ០៣នាក់ (មានឯកសារចេញពីស្ថានទូតថៃ និងលិខិតបញ្ជាក់សុខភាព)៕

## ទៀតហើយ ! ពលករខ្មែរ៥៤នាក់ត្រូវថៃចាប់ខ្លួនពេលលួចឆ្លងដែនតាមមេខ្យល់

http://mekong-post.com/ ដោយ មេគង្គ ប៉ុស្តិ៍ ចេញផ្សាយ ថ្ងៃទី 29 May, 2020

**ប៉ោយប៉ែត ៖ សមត្ថកិច្ចចម្រុះរបស់ថៃ បានចាប់ខ្លួនពលរដ្ឋខ្មែរចំនួន ៥៤នាក់ ដែលនៅតែចាញ់បោកមេខ្យល់លួចនាំឆ្លងដែនចូលប្រទេសថៃដោយខុសច្បាប់នៅបន្ទាត់ព្រំដែនស្រុក តាព្រះយ៉ា ខេត្តស្រះកែវ យកតម្លៃក្នុងម្នាក់ ៣.០០០បាត ។**

យោងតាមការចុះផ្សាយរបស់គេហទំព័រក្នុងស្រុករបស់ថៃ (สระแก้ว-77 ខេត) នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ ២០២០ អ្នកសារព័ត៌មានរាយការណ៍ថា កម្លាំងក្រុមប្រតិបត្តិការងារព័ត៌មានចំនួន៥នាក់ រួមជាមួយសមត្ថកិច្ចស្រុកតាព្រះយ៉ា កងទាហាន ,កម្លាំងតម្រួតការពារព្រំដែនទី១, នគបាលអន្តោប្រវេសន៍ខេត្តស្រះកែវ ,តម្រួតទេសចរណ៍ខេត្តស្រះកែវ ទាហានប៉ារ៉ា និងអាជ្ញាធរស្រុកតាព្រះយ៉ា បានសហការគ្នាចាប់ខ្លួនពលរដ្ឋខ្មែរសរុបទាំងអស់ ៥៤នាក់ ក្នុងនោះប្រុស ៣៣នាក់ ស្រី២១នាក់ ខណៈកំពុងលួចឆ្លងចូលទៅប្រទេសថៃ។

សារព័ត៌មានខាងលើរាយការណ៍ថាសមត្ថកិច្ចឃុតខ្មៅចាប់ខ្លួនបានដាក់បទចោទលើបុរសឈ្មោះ ឡា ពឿន អាយុ៤៣ឆ្នាំ សញ្ជាតិខ្មែរ រួមទាំងបក្ខពួកចំនួន ៥៣នាក់ទៀត សរុបទាំងអស់ ៥៤នាក់ ដោយចោទពីបទ"ជាបុគ្គលអន្តោប្រវេសន៍(សញ្ជាតិខ្មែរ)ធ្វើដំណើរចូលមក នឹងស្នាក់នៅព្រះរាណាចក្រថៃ ដោយមិនបានទទួលការអនុញ្ញាត

“តាមច្បាប់អន្តោប្រវេសន៍ឆ្នាំ១៩៧៩ របស់ថៃ។ ក្រោយពីការសួរចម្លើយ ពលរដ្ឋខ្មែរទាំងនោះបានបញ្ជាក់ថា ពួកគេត្រូវការធ្វើដំណើរចូលមកធ្វើការនៅប្រទេសថៃ ព្រោះខាងកម្ពុជា មិនមានការងារឲ្យធ្វើ តែដោយសារមានការបិទព្រំដែន ព្រោះស្ថានការណ៍ខូវីត-19 ទើបជ្រើសយកវិធីលួចឆ្លងដែនចូលមកប្រទេសថៃ តាមរយៈមេខ្យល់នាំមកព្រំដែន ចំណាយថ្លៃឈ្នួលឲ្យមេខ្យល់ក្នុងម្នាក់ប្រមាណ៣.០០០បាត។

យ៉ាងណាក៏ដោយ សម្រាប់បរិវេណចំណុចដែលពលរដ្ឋខ្មែរជាច្រើនលួចឆ្លងដែនចូលប្រទេសថៃ ទើបសមត្ថកិច្ចអាចចាប់ខ្លួនបាន នៅបរិវេណអូរ ក្រោយភូមិបាងឡាង ឃុំតាព្រះយ៉ា ស្រុក តាព្រះយ៉ា ខេត្តស្រះកែវ ក្រោយពីសមត្ថកិច្ចឃុតខ្មៅចាប់ខ្លួន បានធ្វើការចោទប្រកាន់ឲ្យអ្នកដែលត្រូវចាប់ខ្លួនទាំងអស់ជ្រាបហើយ ក៏បានបញ្ជូនពលរដ្ឋខ្មែរទាំងអស់ទៅឲ្យសមត្ថកិច្ចធ្វើកំណត់ហេតុស្រុកតាព្រះយ៉ា អនុវត្តតាមនីតិវិធី៕

## ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២០

### ពលកម្មកុមារលាក់មុខនៅក្នុងឧស្សាហកម្មវាយនភណ្ឌនិងកាត់ដេរសំលៀកបំពាក់

https://www.rfa.org/khmer/ ដោយ សេក បណ្ឌិត 2020-06-01

ដោយសារតែកត្តាជីវភាព កម្មករ-កម្មការិនីជាច្រើនដែលមានអាយុក្រោមច្បាប់កំណត់ បានខ្ចីសៀវភៅគ្រួសាររបស់មិត្តភ័ក្តិ រឺក៏បងប្អូន ដើម្បីមានលទ្ធភាពធ្វើការងារនៅក្នុងរោងចក្រនានា។ សង្គមស៊ីវិលបារម្ភពីការប៉ះពាល់សុខភាព និងការរៀនសូត្ររបស់កុមារដែលបង្ខំចិត្តចូលធ្វើការដោយខុសច្បាប់ ដើម្បីទ្រទ្រង់ជីវភាពគ្រួសារ។

ថ្ងៃទី១ មិថុនា គឺជាខួបលើទី៧១ នៃទិវាកុមារអន្តរជាតិ និងថ្ងៃទី១២ មិថុនា គឺជាខួបលើកទី១៩ នៃទិវាពិភពលោកប្រឆាំងពលកម្មកុមារ។ ប៉ុន្តែសម្រាប់កម្មការិនី ភួង រចនា ដែលបម្រើការងារនៅក្នុងរោងចក្រមួយកន្លែងនៅទីក្រុងភ្នំពេញ ពុំដឹងទេថា អ្វីទៅជាពលកម្មកុមារនោះទេ ដែលកាលពី២ឆ្នាំមុន កញ្ញាបានប្រើសៀវភៅគ្រួសារអ្នកដទៃ ដើម្បីទទួលបានការងារធ្វើជាកម្មការិនីរោងចក្រនោះទេ។

អង្គុយនៅក្នុងអង្រឹងក្រោយផ្ទះក្រោមម្លប់ដើមឬស្សី ក្នុងស្រុកកណ្ដាលស្ទឹង កញ្ញា រចនា ដែលបច្ចុប្បន្ន មានអាយុ ១៦ឆ្នាំហើយនោះ បានឱ្យដឹងថា កញ្ញាបានបម្រើការងារនៅក្នុងរោងចក្រកាលពីនាងមានអាយុ ១៤ឆ្នាំ ហើយដោយសារតែអាយុមិនគ្រប់មិនអាចធ្វើការងារបាន គ្រួសាររបស់កញ្ញាបានយកសៀវភៅគ្រួសារពីបងប្អូនជីដូនមួយទៅប្រើ។ អ្វីដែលកញ្ញាត្រូវធ្វើនៅពេលនោះគឺត្រូវទន្ទិញឈ្មោះ ថ្ងៃខែ ឆ្នាំកំណើតឱ្យចាំស្ទាត់មាត់៖ «មួយគំនរ គេដំឡើងទាំងអស់ហ្នឹង គ្រាន់តែទៅដល់គ្រាន់រដ្ឋបាលគេសួរ អឺ យើងឈ្មោះអី បងប្អូនប៉ុន្មាននាក់អីប៉ុណ្ណឹងហ្នឹង»។ កញ្ញា រចនា ពុំបានដឹងថា ការងាររបស់នាងនៅពេលនោះខុសច្បាប់នោះទេ ហើយមិនមែនមានតែខ្លួនកញ្ញាម្នាក់ឯងនោះទេ មិនគ្រប់អាយុនៅពេលនោះ ដែលធ្វើការក្នុងរោងចក្រដែលកំពុងធ្វើសព្វថ្ងៃនេះ។ កញ្ញា រចនា បានសម្រេចចិត្តបោះបង់ចោលការសិក្សានៅថ្នាក់ទី៨ ដោយសារតែពិបាកក្នុងការធ្វើដំណើរទៅរៀន ហើយម្យ៉ាងទៀតឃើញមិត្តភ័ក្តិអាយុដូចគ្នាបានចូលធ្វើការងាររោងចក្រ បានលុយបានកាក់យកមកឱ្យគ្រួសារ កញ្ញាក៏សម្រេចចិត្តទៅរកការងារធ្វើនៅរកចក្រដែរ ប៉ុន្តែមានការលំបាកខ្លាំងទម្រាំរកឯកសារដើម្បីបង្ហាញខាងរោងចក្រថា មានអាយុគ្រប់ ១៨ឆ្នាំ៖ «តែឥឡូវអត់ដូចមុនទេ ឥឡូវស្រួលសឹងអីពូ ឱ្យតែយើងមានខ្សែ បើយើងមានខ្សែគេអត់សួរនាំច្រើនទេ»។

កម្មការិនី ម្នាក់ដែលបម្រើការងារនៅរោងចក្រមួយកន្លែងក្នុងទីក្រុងភ្នំពេញ ដោយស្នើមិនបញ្ចេញឈ្មោះនិងសំឡេងថា កញ្ញាគឺជាកូនអ្នកស្រុកស្រែ ឪពុកម្ដាយមិនបានយកចិត្តទុកដាក់ក្នុងការធ្វើសំបុត្រកំណើត ហើយនៅពេលដែលកញ្ញាមករកការងារធ្វើនៅភ្នំពេញ គ្មានសំបុត្រកំណើត ប៉ុន្តែមានសៀវភៅគ្រួសារ។ នាងថា ទៅខ្ចីសៀវភៅគ្រួសារមិត្តភ័ក្តិ ដើម្បីធ្វើតេស្តចូលធ្វើការ ព្រោះកាលពី ៥ឆ្នាំមុន ខ្ញុំទើបតែ ១៥ឆ្នាំ។ ឥឡូវអាយុ ២០ឆ្នាំហើយ នាងកំពុងបារម្ភ ចំពោះការទទួលអត្ថប្រយោជន៍ពីប័ណ្ណប.ស.ស ព្រោះឈ្មោះគេ។ កម្មការិនីរូបនេះបានលើកឡើងថា

ភាគច្រើនអ្នកដែលធ្វើការរោងចក្រគឺ គ្មានឱកាសក្នុងការសិក្សា ទីពីរស្ថានភាពគ្រួសារក្រីក្រ អ្នកខ្លះទៀតខ្ជិលរៀនតែម្តង និងជ្រួលជ្រើមតាមគ្នា។

ចំណែកឪពុករបស់យុវជនរងគ្រោះ ឃឹម សុផាត គឺលោក ឃឹម សឿន ដែលកូនបាត់ខ្លួនកាលពី ឆ្នាំ២០១៤ ក្នុងកូដកម្មសុំដំឡើងប្រាក់ខែគោល១៦០ដុល្លារ នៅផ្លូវវេងស្រេង ក្រុងភ្នំពេញ បានឱ្យដឹងថា ពេលកូនរបស់លោកទៅបម្រើការងារនៅក្នុងរោងចក្រ ពុំទាន់គ្រប់អាយុធ្វើការទេ ប៉ុន្តែកូនរបស់គាត់ បានយកឯកសារស្របច្បាប់របស់អ្នកភូមិជិតខាង ដើម្បីយកទៅធ្វើតេស្តចូលធ្វើការ។ លោកឱ្យដឹងទៀតថា លោកបណ្តោយឱ្យកូនទៅធ្វើការទាំងនៅក្មេងដើម្បីបានប្រាក់ខ្លះ ទ្រទ្រង់ជីវភាពគ្រួសារ ព្រោះកាលនោះគ្រួសាររបស់លោកស្ថិតក្នុងស្ថានភាពលំបាក៖ «កូនខ្ញុំទៅធ្វើការរោងចក្រលោកគ្រូ អាយុ ១៦ ឆ្នាំ។ វាមិនទាន់គ្រប់អាយុ ខ្ចីឈ្មោះគេចូល លោកគ្រូ! យកទាំងសៀវភៅគ្រួសារ ទាំងសំបុត្រកំណើតគេទៅ លោកគ្រូ!។ កាលហ្នឹងខ្ចីគ្នាចុះឡុងៗដែរកាលមុន»។ លោកបញ្ជាក់ទៀតថា កាលសម័យនោះ នៅពេលទៅរកការងារធ្វើរោងចក្រ ពួកគេមិនខ្វល់ថា គ្រប់អាយុ ឬអត់នោះទេ ព្រោះពួកគេអាងខ្ចីសៀវភៅគ្រួសារ របស់មិត្តភ័ក្តិយកទៅបង្ហាញពួករោងចក្រ ដោយពុំចាំបាច់ធ្វើលិខិតបញ្ជាក់ពីអាជ្ញាធរភូមិឃុំនោះទេ។ ម្យ៉ាងទៀតខាងរោងចក្រក៏មិនតឹងរ៉ឹង នៅពេលគេពិនិត្យឯកសារ៖ «រោងចក្រកាលនោះវា មានទេ ឱ្យតែបានគ្រប់អាយុ គេឱ្យចូលតែម្តងកាលហ្នឹង»។

លោកនាយករដ្ឋមន្ត្រីហ៊ុន សែន បានចេញសារលិខិតអបអរសារទរខួបលើទី៧១ ទិវាកុមារអន្តរជាតិ១មិថុនា ខួបលើកទី១៩ និងទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២មិថុនា ឆ្នាំ២០២០ ដោយជំរុញក្រសួងស្ថាប័នត្រូវបន្តអនុវត្តសញ្ញាស្នូលនៃ អង្គការអន្តរជាតិខាងការងារ ដើម្បីលុបបំបាត់គ្រប់ទម្រង់នៃពលកម្មកុមារ លើកកម្ពស់ការយល់ដឹង បណ្តុះបណ្តាល និងផ្សព្វផ្សាយអំពីការប្រើប្រាស់ពលកម្មកុមារគ្រប់សកម្មភាពសេដ្ឋកិច្ច និងពង្រឹងវិធានការអធិការកិច្ចពលកម្មកុមារ ព្រមទាំងកៀរគរធនធាន និងចលនាសាធារជន ក្នុងការស្វែងរកដំណោះស្រាយសមស្រប ដើម្បីជួយសង្គ្រោះពលកម្មកុមារ។

ចំណែក អ្នកនាំពាក្យក្រសួងការងារ លោក ហេង សួរ បានថ្លែងថា បើយោងទៅតាមច្បាប់ ស្តីពីការងារ កម្ពុជា និងយោងទៅលើអនុសញ្ញាអន្តរជាតិខាងការងារ គឺកុមារដែលមានអាយុពី ១២ ដល់ ១៥ឆ្នាំ អនុញ្ញាតឱ្យធ្វើការងារដែលស្រាលៗ ហើយមានរយៈពេលមិនលើស ១២ម៉ោងក្នុង១សប្តាហ៍ រឺមិនលើស ៤ម៉ោងក្នុងមួយថ្ងៃ ហើយការងារមិនត្រូវប៉ះពាល់ទៅដល់ម៉ោងរៀនសូត្រ និងមិនមែនជាកិច្ចការងារដែលប្រើប្រាស់កម្លាំងដ៏ធ្ងន់ធ្ងរ។ លោកថា ដោយឡែកកុមារដែលលើសពី ១៥ឆ្នាំ ទៅ១៨ គឺអនុញ្ញាតឱ្យធ្វើការងារធម្មតា ប៉ុន្តែ ត្រូវមានការអនុញ្ញាតពី អធិការការងារជាមុន និងត្រូវមានការយល់ព្រមពីអាណាព្យាបាល ហើយមិនត្រូវធ្វើការចន្លោះម៉ោង ១០យប់ ដល់ម៉ោង៥ភ្លឺ និងមិនអនុញ្ញាតឱ្យធ្វើការថែមម៉ោងនៅថ្ងៃអាទិត្យ រឺនៅថ្ងៃឈប់សម្រាកនោះឡើយ៖ «សហគ្រាសដែលរំលោភទៅលើបញ្ញត្តពាក់ព័ន្ធនៅនឹងការប្រើប្រាស់ពលកម្ម កុមារនេះគឺត្រូវពិន័យតាមច្បាប់ ស្តីពីការងារផង ហើយបើសិនជាការរំលោភនេះ បន្តដោយកើតឡើងជាដដែលៗ គឺម្ចាស់សហគ្រាស គឺអាចប្រឈមទៅនឹងទោសទណ្ឌដទៃផ្សេងទៀត ដែលមានចែងនៅក្នុងច្បាប់ព្រហ្មទណ្ឌ ហើយនិងរដ្ឋប្បវេណីផងដែរ ជាពិសេសបើសិនជាមានគ្រោះថ្នាក់ការងារណាមួយកើតឡើងដែលបណ្តាលមកពីការធ្វេសប្រហែសរបស់ម្ចាស់សហគ្រាស អី រឺមួយរោងចក្រទាំងអស់នោះ»។

អាយុស្របច្បាប់ធ្វើការបាននៅរោងចក្រក្នុងប្រទេសកម្ពុជា គឺ ១៥ឆ្នាំ ប៉ុន្តែច្បាប់នេះចែងថា "យុវជន" ក្មេងជំទង់អាយុចន្លោះ១៥ ឆ្នាំដល់១៧ឆ្នាំ មិនអាចធ្វើការលើសម៉ោង ឬក៏ធ្វើការធ្ងន់បានទេ ហើយត្រូវមានពេលឈប់សម្រាកយ៉ាងហោចណាស់ ១៣ម៉ោងក្នុងវេននីមួយៗ។

នាយកប្រតិបត្តិ មជ្ឈមណ្ឌលសម្ពន្ធភាពការងារ និងសិទ្ធិមនុស្ស លោក មឿន តុលា បានឱ្យដឹងថា ដោយសារភាពក្រីក្រមានជាទូទៅក្នុងប្រទេសនេះ ចៀសមិនផុតទេ ដែលគ្រួសារមួយចំនួននឹងជ្រើសរើសបញ្ជូនកូន

ស្រីរបស់ខ្លួនទៅធ្វើការនៅតាមរោងចក្រ ទាំងពួកគេនៅក្មេងនៅឡើយ។ លោកបានបន្ថែមថា ម្យ៉ាងទៀតគឺភាពងាយស្រួលក្នុងការខ្ចីឯកសារគ្នាទៅវិញទៅមកនៅក្នុងសហគមន៍ បើទោះបីជាគាត់មិនទាន់គ្រប់អាយុគាត់អាចធ្វើការនៅក្នុងរោចក្រ។ មួយវិញទៀតគឺខាងរោងចក្រធ្វើមិនដឹងមិនលឺចំពោះរឿងដែលកម្មករធ្វើការមិនគ្រប់អាយុខណៈដែលរោងចក្រទាំងនោះរំលោភច្បាប់ ដោយមិនផ្តល់កិច្ចការពារត្រឹមត្រូវដល់កម្មករក្មេងៗទាំងនោះ៖ «យើងត្រូវអនុវត្តន៍ច្បាប់ឱ្យបានពេញលេញនៅក្នុងវិស័យការងារហ្នឹង ដូចជាបើសិនជា អ៊ីក្រុមហ៊ុនណាដែលជួល ពលករ រឺក៏កម្មករ នៅក្រោមអាយុ១៨ឆ្នាំហ្នឹង ត្រូវតែអនុវត្តតាមគោលការណ៍ដែលច្បាប់បានចែងហ្នឹង មានន័យថា ត្រូវឱ្យគាត់ធ្វើការនៅចំនួនម៉ោងណាមួយហើយ អ៊ីរៀបចំកញ្ចប់ណាមួយឱ្យគាត់អាចមានពេលទៅរៀនសូត្រ ទៅអ៊ីចូលការសិក្សា ណាស់ បន្តការសិក្សា បើសិនជាយើងអនុវត្តន៍បែបហ្នឹងគឺវា វាអាចដោះបាន»។

កន្លងទៅ រដ្ឋមន្ត្រីក្រសួងការងារ លោក អ៊ិត សំហេង បានចេញលិខិតព្រមានប្រាប់ទៅម្ចាស់នាយកសហគ្រាស គ្រឹះស្ថាន ថា ក្រសួងសង្កេតឃើញថា មានបញ្ហាប្រឈមមួយចំនួន អំពីអត្តសញ្ញាណរបស់កម្មករនិយោជិក ដូចជាការខ្ចីឈ្មោះអ្នកដទៃប្រើ ការខុសឈ្មោះ ការខុសភេទ ការខុសថ្ងៃខែឆ្នាំកំណើត ការខុសទីកន្លែងកំណើតជាដើម ដែលអាចបង្កឱ្យលេចចេញនូវបាតុភាពមិនប្រក្រតីនានា ធ្វើឱ្យភាគីពាក់ព័ន្ធមានការព្រួយបារម្ភចំពោះផលប៉ះពាល់តាមច្បាប់ ទាក់ទងនឹងការក្លែងឯកសារ ការបាត់បង់អតីតភាពការងារ ការបណ្តេញចេញពីការងារ ការចោទប្រកាន់ចំពោះការប្រើប្រាស់ពលកម្មកុមារ និងចំណុចផ្សេងៗទៀត។

កន្លងទៅអង្គការពលកម្មអន្តរជាតិ(ILO)បានរកឃើញថា មានកុមារចំនួនជាង៧៥ម៉ឺននាក់ ៧៥៥.២៤៥ កំពុងធ្វើការក្នុងប្រទេសកម្ពុជា។ ក្នុងនេះមានចំនួនជិត ៤៣ម៉ឺននាក់(៤២៩.៣៨០) ឬស្មើ(៥៦.៩%) ត្រូវបានចាត់ទុកថាជាកម្មករកុមារ ហើយមានចំនួនជាង២៣ម៉ឺននាក់ (២៣៦.៤៩៨នាក់) ឬស្មើ (៣១.៣%) បានធ្វើការក្នុងលក្ខខ័ណ្ឌគ្រោះថ្នាក់ដែលអ្នកទាំងនោះត្រូវបានរងផលប៉ះពាល់ពីសារធាតុ ឬសម្ភារៈគីមី៕

## ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅតែបន្តវិធានការការពារកុមារ ទោះបី ស្ថិតក្នុងស្ថានភាពណាក៏ដោយ

https://www.information.gov.kh/ ថ្ងៃទី 1 ខែ មិថុនា ឆ្នាំ 2020 វិទ្យុជាតិកម្ពុជា៖ លោកស្រី ប៉ុង សុភាវី

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅតែបន្តវិធានការការពារកុមារ ទោះបីស្ថិតនៅក្នុងស្ថានភាពណាក៏ដោយ ដើម្បីធានាថាកុមារពិតជាមិនមានការកេងប្រវ័ញ្ចលើកម្លាំងពលកម្ម។

លោក ពេជ្រ បញ្ញា ប្រធានផ្នែកគណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារនៃក្រសួងការងារនិងបណ្តុះបណ្តាវិជ្ជាជីវៈ បានមានប្រសាសន៍ឲ្យដឹងថា ក្រសួងការងារ បានចាត់វិធានការ៣ដំណាក់កាលក្នុងការការពារកុមារ គឺដំណាក់កាលទី១ មុនជំងឺកូវីដ-១៩ ផ្ទុះឡើង ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈតាមរយៈយន្តការអធិការកិច្ចបានចុះទៅផ្សព្វផ្សាយ ចុះធ្វើអធិការកិច្ចសាមញ្ញ និងអធិការកិច្ចពិសេស នៅតាមបណ្តាសហគ្រាសគ្រឹះស្ថានដែលស្ថិតនៅក្រោមច្បាប់ស្តីពីការងារ អំពីការលើកកម្ពស់លក្ខខណ្ឌការងារ លក្ខខណ្ឌអនាម័យនិងសន្តិសុខការងារ លក្ខខណ្ឌបេឡាជាតិរបបសន្តិសុខសង្គម និងការលុបបំបាត់ពលកម្មកុមារនៅតាមបណ្តាសហគ្រាសគ្រឹះស្ថាន។

ដំណាក់កាលទី២ អំឡុងពេលវិបត្តិកូវីដ១៩ ក្រសួងការងារ ក៏បានចុះផ្សព្វផ្សាយក៏ដូចជាចាត់វិធានការផ្លូវច្បាប់ចំពោះសហគ្រាសគ្រឹះស្ថានសិប្បកម្មផលិតឥដ្ឋនៅទូទាំង២៥រាជធានីខេត្តដែល ប្រើប្រាស់កុមារដែលមានអាយុក្រោមច្បាប់កំណត់ចូលទៅក្នុងខ្សែសង្វាក់ផលិតកម្ម ក្រសួងនឹងចាត់វិធានការផ្លូវច្បាប់មានទាំងទោស មានបទល្មើសតាមច្បាប់ស្តីពីការងារ មានទាំងបទល្មើសព្រហ្មទណ្ឌ។ និងដំណាក់កាលទី៣ ក្រោយពីការបញ្ចប់កូវីដ១៩ ទៅក្រសួងនឹង នៅតែបន្តលើកកំពស់ការយល់ដឹង ការថែទាំសុខភាពនិងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទៅដល់កុមារនិងក្រុមគ្រួសារកុមារដែលងាយរងគ្រោះ។

លោកបានឲ្យដឹងថាបន្តថា ដើម្បីចូលរួមកិច្ចការពារកុមារក្នុងអំឡុងពេលនៃការរាតត្បាតជំងឺកូវីដ-១៩ នេះ ក្រសួងការងារបានចុះផ្សព្វផ្សាយនៅតាមបណ្តាសហគ្រាសគ្រឹះស្ថានស្តីពីវិធានការណែនាំរបស់ក្រសួងសុខាភិបាល។ « ដើម្បីចូលរួមអបអរសាទរក្នុងទិវា ១ មិថុនា ក៏ដូចជាទិវាខួបលើកទី ១៩ នៃកុមារពិភពលោកប្រកម្មពលកម្មកុមារ ១២មិថុនា ក៏ដូចជាដើម្បីចូលរួមកិច្ចការពារកុមារក្នុងអំឡុងពេលនៃការរាតត្បាតជំងឺកូវីដ-១៩ នេះ ក្រសួងការងារបានចុះផ្សព្វផ្សាយនៅតាមបណ្តាសហគ្រាសគ្រឹះស្ថានអំពីការទប់ស្កាត់និងវិធីសាស្ត្រការពារ ទៅតាមសារាចរការណែនាំរបស់ក្រសួងសុខាភិបាល គឺយើងចុះទៅតាមបណ្តាសហគ្រាសគ្រឹះស្ថានដែលស្ថិតនៅក្នុងរាជធានីខេត្ត ដោយចុះផ្សព្វផ្សាយអំពីវិធីសាស្ត្រការពារការសម្អាតដៃនឹងសាប៊ូ អាកុល ជាពិសេសគឺកំលាតនៅកន្លែងធ្វើការ ឲ្យនៅដាច់ដោយឡែកពីគ្នាដើម្បីយើងការពារការឆ្លងរាលដាលនៃជំងឺកូវីដ-១៩»។ លោកបានបញ្ជាក់ថា សម្រាប់ សហគ្រាសគ្រឹះស្ថានដែលបានសុំព្យួរការងារ ដោយមូលហេតុនៃការរាតត្បាតជំងឺកូវីដ-១៩នេះ គឺរាជរដ្ឋាភិបាលបានចំណាយថវិកាជូនកម្មករនិយោជិកដែលសុំព្យួរការងារក្នុងម្នាក់ ៤០ដុល្លារ ហើយនិងការឧបត្ថម្ភពីនិយោជកចំនួន ៣០ដុល្លារ៕

## ចុះប្រមូលស្ត្រីរកស៊ីផ្លូវភេទឈរនៅតាមរបង ក្រោមដើមឈើ និងជួរមាត់ទន្លេ រួមទាំងអ្នកគកជេរ(អ្នកចាប់ម៉ូយ) បាន៧នាក់

https://khmerpress.news/ 02-06-2020

រាជធានីភ្នំពេញ ៖ កម្លាំងសណ្តាប់ធ្នាប់ខណ្ឌដូនពេញ ចុះប្រមូលស្ត្រីរកស៊ីផ្លូវភេទ ដែលឈរនៅតាមរបង និងក្រោមដើមឈើ រួមទាំងអ្នកគកជេរ(អ្នកចាប់ម៉ូយ) ជុំវិញរមណីយដ្ឋាន វប្បធម៌ប្រវត្តិសាស្ត្រវត្តភ្នំ ។ ដោយអនុវត្តតាមបទបញ្ជាដ៏មុឺងម៉ាត់របស់លោក សុខ ពេញវុធ អភិបាលនៃគណៈអភិបាលខណ្ឌដូនពេញ នៅយប់ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២០ លោក យស យុទ្ធី អភិបាលរងខណ្ឌដូនពេញ បានដឹកនាំកម្លាំងប្រជាការពារខណ្ឌ បើកប្រតិបត្តិការចុះប្រមូលស្ត្រីរកស៊ីផ្លូវភេទ រួមទាំងអ្នកគកជេរ(អ្នកចាប់ម៉ូយ) នៅជុំវិញរមណីយដ្ឋា វប្បធម៌ប្រវត្តិសាស្ត្រវត្តភ្នំ។ ជាលទ្ធផល នៃការបង្ក្រាបនេះ កម្លាំងប្រជាការពារខណ្ឌ បានធ្វើការប្រមូលស្ត្រីរកស៊ីផ្លូវភេទរួមទាំងអ្នកគួកជេរ(អ្នកចាប់ម៉ូយ)សរុបចំនួន០៧នាក់(ស្រី) បញ្ជូនមកសាលាខណ្ឌដូនពេញ ដើម្បីរៀបចំឯកសារបញ្ជូនបន្តទៅ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានីភ្នំពេញ៕ ប្រភព៖ Khmer Note

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៣២នាក់

https://www.facebook.com/GDIOfficial/ 01-06-2020

នៅថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆងចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៣២នាក់ ស្រី ១៥នាក់ និង

ពលរដ្ឋថៃដែលចាកចេញមានចំនួន ០១នាក់ ស្រី ០១នាក់ (មានឯកសារចេញពីស្ថានទូតថៃ និងលិខិតបញ្ជាក់សុខភាព)៕

## គិតចាប់ពីថ្ងៃទី១០ ខែមីនា មកដល់ថ្ងៃទី០១ ខែមិថុនាឆ្នាំ២០២០តួលេខសរុបដែលបានទទួលប្រជាពលរដ្ឋខ្មែរ ត្រឡប់មកពីប្រទេសថៃមានចំនួន ១៣,៧៦៥នាក់ ហើយ

https://www.facebook.com/tvkchannel7/ ទូរទស្សន៍ជាតិកម្ពុជា ទទក - TVK 01-06-2020

ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលរដ្ឋខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃរបស់អាជ្ញាធរខេត្តសៀមរាប នៅថ្ងៃចន្ទ ទី០១ ខែមិថុនា ឆ្នាំ២០២០នេះ នៅតែទៅបន្តរង់ចាំទទួលប្រជាពលរដ្ឋខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃដដែល។ នៅថ្ងៃនេះទទួលបានចំនួនសរុប ៤១នាក់ ស្រីចំនួន ១៨នាក់ ដែលចូលមកតាមច្រកដូងខេត្តបាត់ដំបង, តាមច្រកប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ និងច្រកអូរស្មាច់ ខេត្តឧត្តរមានជ័យ ។

គិតចាប់ពីថ្ងៃទី១០ ខែមីនា មកដល់ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២០នេះ តួលេខសរុបដែលបានទទួលប្រជាពលរដ្ឋខ្មែរ ចូលតាមច្រកទាំងបីខាងលើ មានចំនួន ១៣,៧៦៥នាក់ ស្រីចំនួន ៥,៩៧៦នាក់ ក្នុងនោះបានពិនិត្យសុខភាពបឋមបានចំនួន១៣,៧៦៥នាក់ ស្រី ៥,៩៧៦នាក់ គឺពិនិត្យសុខភាពបានទាំងអស់។

សូមបញ្ជាក់ជូនថា ប្រជាពលករខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃក្នុងមួយថ្ងៃៗ មានចន្លោះពីជាង ១០០នាក់រហូតដល់ជាង ៣០០នាក់ សម្រាប់ទូទាំងប្រទេសកម្ពុជា ៕ ប្រភព: របាយការណ៍រដ្ឋបាលខេត្តសៀមរាប កែសម្រួលដោយ លីវ សុខុន

## នគរបាលប៉ុស្តិ៍បុសលាវចុះផ្សព្វផ្សាយអប់រំប្រជាពលរដ្ឋតាមខ្នងផ្ទះ

http://cambodiapolice.com/policekh/ 2:31 pm 2 មិថុនា 2020

ក្រចេះ ៖ នាព្រឹកថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២០ កម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលបុសលាវ បានធ្វើការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋតាមខ្នងផ្ទះក្នុងភូមិបុសលាវក្រោម ឃុំបុសលាវ ស្រុកចិត្របុរី ខេត្តក្រចេះ ក្នុងនោះបានធ្វើការផ្សព្វផ្សាយនូវចំណុចចំនួនដូចខាងក្រោម ៖

-ផ្សព្វផ្សាយសេចក្តីចូលរួមអំពាវនាវចូលរួមគាំទ្រយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់នៅកម្ពុជា។

-ផ្សព្វផ្សាយ រួមគ្នាបង្ការទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀន ។

-ចែក សារសម្រាប់អប់រំអំពីផលប៉ះពាល់គ្រោះថ្នាក់នៃគ្រឿងញៀន ។

-ផ្សព្វផ្សាយ រួមគ្នាបង្ការទប់ស្កាត់បទល្មើសបញ្ហាចោរកម្ម គ្រប់ប្រភេទ ។

-ផ្សព្វផ្សាយ រួមគ្នាបង្ការការប្រើអំពើហិង្សាទាក់ទងនឹងយេនឌ័រ,អំពើជួញដូរស្ត្រីនិងកុមារ ។

-ផ្សព្វផ្សាយច្បាប់ចរាចរណ៍ផ្លូវគោក ។

-ផ្សព្វផ្សាយ អំពីការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ។

-អំពីគ្រោះអគ្គីភ័យ ។

-នៅក្នុងនោះកម្លាំងយើងបានធ្វើការផ្សព្វផ្សាយនូវលក្ខណៈសម្បត្តិទាំង៩យ៉ាងរបស់គោលនយោបាយភូមិឃុំមានសុវត្ថិភាព និងវិធីបង្ការទប់ស្កាត់វីរុស កូវីដ-19 ។

មានប្រជាពលរដ្ឋចូលរួមសរុបចំនួន ៣១នាក់ស្រី ១៥នាក់ និងចែកខិតប័ណ្ណចំនួន៣១សន្លឹកផងដែរ ៕

## ពលករខ្មែរ ដែលជាប់នៅម៉ាឡេស៊ី ប្រហែលត្រូវចាំដល់ខែកក្កដា ទើបមានជើងហោះហើរ

https://thmeythmey.com/ 01, Jun 2020 , 11:01 am ដោយ: ថ្មីៗ

អង្គការសង្គម-ស៊ីវិល៣៣ បានរួមគ្នាអំពាវនាវឲ្យរដ្ឋាភិបាលកម្ពុជា ប្រញាប់ជួយនាំនិស្សិតនិងពលករខ្មែរ ប្រមាណ១៥០នាក់ ដែលកំពុងជាប់នៅម៉ាឡេស៊ី មកកម្ពុជាវិញ។ ពួកគេ មិនអាចមកកម្ពុជានាពេលនេះ ដោយសារតែគ្មានជើងហោះហើរ។

លោក ស៊ីន ចាន់សិរីវុត្ថា អ្នកនាំពាក្យរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ប្រាប់សារព័ត៌មានថ្មីៗថា ប្រហែលជាដល់ដើមខែកក្កដា ឆ្នាំ២០២០ ទើបកម្ពុជានិងម៉ាឡេស៊ី អាចមានជើងហោះឡើងវិញ។ លោក បន្តថា រដ្ឋាភិបាលកម្ពុជា មិនមានគម្រោងបញ្ជូនយន្តហោះពិសេសទៅយកពួកគាត់ឡើយ។ អ្នកនាំពាក្យរូបនេះ មានប្រសាសន៍ថា៖«មានតែពួកគាត់រង់ចាំ ដល់មានជើងហោះហើរវិញ។ នេះ ក៏ជាកង្វល់របស់រដ្ឋាភិបាលដែរ»។

តាមរយៈសេចក្តីថ្លែងការណ៍ ធ្វើឡើងនៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ អង្គការ-សង្គមស៊ីវិល ចាត់ទុកថា ការជួយពលករនិងនិស្សិតខ្មែរទាំងនោះ គឺស្របនឹងមាត្រា៤០ នៃរដ្ឋធម្មនុញ្ញកម្ពុជា ដែលចែងពីការការពារសិទ្ធិរបស់ពលរដ្ឋកម្ពុជា ក្នុងការតាំងទីលំនៅនៅឯបរទេសនិងការវិលត្រឡប់មកប្រទេសកម្ពុជាវិញ ហើយក៏ជាកាតព្វកិច្ចរបស់កម្ពុជា ក្រោមសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិផងដែរ។ ការសុំកិច្ចអន្តរាគមន៍របស់អង្គការ-សង្គមស៊ីវិលនានាពេលនេះ គឺធ្វើឡើងបន្ទាប់ពីរដ្ឋាភិបាលកម្ពុជា ប្រកាសថា ប្រជាពលរដ្ឋខ្មែរនៅក្រៅប្រទេស អាចវិលត្រឡប់មកកម្ពុជាវិញ ដោយមិនចាំបាច់តម្រូវឲ្យមានលិខិតបញ្ជាក់សុខភាពថាគ្មានជំងឺកូវីដ១៩នោះទេ តែពួកគេ ត្រូវទៅពិនិត្យសុខភាពពេលមកដល់កម្ពុជា។

ពលរដ្ឋកម្ពុជាប្រមាណ១៥០នោះ គ្រោងវិលមកកម្ពុជាវិញ តាំងពីដើមខែមេសា ឆ្នាំ២០២០ តែកាលនោះ រដ្ឋាភិបាលកម្ពុជា មិនអនុញ្ញាត ព្រោះបារម្ភខ្លាចឆ្លងឬចម្លងជំងឺកូវីដ១៩ ពេលធ្វើដំណើរ។ ក្រោយមក រដ្ឋាភិបាលកម្ពុជា ប្រកាសថា ពលរដ្ឋខ្មែរនៅម៉ាឡេស៊ីឬនៅប្រទេសផ្សេងទៀត អាចវិលមកកម្ពុជាវិញ តែត្រូវមានលិខិតបញ្ជាក់ថាគ្មានជំងឺកូវីដ១៩។ ពលរដ្ឋខ្មែរមួយចំនួន ក្នុងចំណោមពលរដ្ឋខ្មែរប្រមាណ១៥០នាក់នៅម៉ាឡេស៊ី អះអាងថា ពួកគេ មិនមានប្រាក់ ដើម្បីធ្វើតេស្តរកជំងឺកូវីដ១៩ឡើយ។ ពួកគេ ត្អូញត្អែរថា ការរាលដាលជំងឺកូវីដ១៩ ធ្វើឲ្យពួកគេ រស់នៅក្នុងប្រទេសម៉ាឡេស៊ីយ៉ាងត្រដាបត្រដួស ព្រោះគ្មានការងារធ្វើ។ ពួកគេ ប្រាប់ថា ការធ្វើតេស្តរកជំងឺកូវីដ១៩ ត្រូវចំណាយប្រាក់ប្រមាណ១៥០ដុល្លារ។ រហូតដល់រដ្ឋាភិបាលកម្ពុជា ប្រកាសមិនយកលិខិតបញ្ជាក់សុខភាព ក៏ពួកគេ នៅតែមិនអាចវិលត្រឡប់មកកម្ពុជាវិញ ដោយសារតែគ្មានជើងហោះហើរ៕

## សិង្ហបុរីប្រញាប់ប្រញាល់សាងសង់លំនៅដ្ឋាន សម្រាប់ពលករចំណាកស្រុក៦ម៉ឺននាក់ បន្ទាប់ពីផ្ទុះវីរុស

---

http://kampucheathmey.com/ 2/6/2020 1:19 Pm

រដ្ឋាភិបាលសិង្ហបុរី កំពុងប្រញាប់ប្រញាល់ ដើម្បីបង្កើតលំនៅដ្ឋានបន្ថែមសម្រាប់ពលករចំណាកស្រុកប្រមាណ៦០,០០០នាក់ នៅត្រឹមដំណាច់ឆ្នាំនេះខណៈដែលខ្លួនព្យាយាមកាត់បន្ថយដង់ស៊ីតេនៅក្នុងអន្តេវាសិកដ្ឋានដែលគេបានឃើញការផ្ទុះឡើងដ៏ធំនៃការឆ្លងវីរុសកូរ៉ូណា។ ប្រទេសដែលមានប្រជាជន៥.៧លាននាក់មួយនេះ មានករណីឆ្លងជាង៣៥,០០០ករណី ដែលជាកម្រិតខ្ពស់បំផុតមួយក្នុងតំបន់អាស៊ីដែលភាគច្រើនដោយសារតែការឆ្លងនៅក្នុងកន្លែងស្នាក់នៅមានគ្រែចង្អៀត ដែលផ្ទុកមនុស្សជាង៣០ម៉ឺននាក់ ភាគច្រើនជាកម្មករមកពីអាស៊ីខាងត្បូង។ ប្រទេសសិង្ហបុរីនឹងបង្កើតកន្លែងទំនេរបន្ថែមតាមរយៈរចនាសម្ព័ន្ធបណ្តោះអាសន្នដែលអាចដាក់បញ្ចូលគ្នាបានយ៉ាងលឿនតាមទម្រង់មួយ។ ក្រសួងហត្ថពលិក និងអភិវឌ្ឍន៍ជាតិបាននិយាយកាលពីថ្ងៃចន្ទថា វាក៏នឹងត្រូវ

ដាក់ជាបណ្ដោះអាសន្ននូវអចលនទ្រព្យរដ្ឋដែលមិនប្រើប្រាស់ដូចជាអតីតសាលារៀននិងរោងចក្រទំនេរផងដែរ។ រដ្ឋាភិបាលបាននិយាយថា អន្តេវាសិកដ្ឋានគឺជាវិធីសាស្ត្រដាក់ស្តែងមួយចំពោះពលករចំណាកស្រុកដែលកំពុងរស់នៅក្នុងប្រទេសសិង្ហបុរីប៉ុន្តែខ្លួនកំពុងស្វែងរកការកែលម្អស្តង់ដារកន្លែងស្នាក់នៅ។

## ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២០

## អាជ្ញាធរថៃបញ្ជូនពលរដ្ឋខ្មែរ៤នាក់ មកកម្ពុជាវិញ ក្រោយជាប់គុកជាច្រើនឆ្នាំពីបទឆ្លងដែនខុសច្បាប់

http://www.freshnewsasia.com/ 2020-06-02

(**ឧត្តរមានជ័យ**)៖ អ្នកទោសខ្មែរចំនួន៤នាក់ ត្រូវបានអាជ្ញាធរថៃ បញ្ជូនខ្លួនមកឱ្យអាជ្ញាធរខ្មែរវិញ តាមច្រកអន្តរជាតិជាំស្ថិតក្នុងភូមិជើងភ្នំ ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ បន្ទាប់ពីបានជាប់ឃុំឃាំងក្នុងទឹកដីថៃ អស់រយៈពេលជាច្រើនឆ្នាំពីបទឆ្លងដែនខុសច្បាប់។

បើតាមរបាយការណ៍របស់សមត្ថកិច្ចច្រកទ្វារអន្តរជាតិជាំ បានបញ្ជាក់ឱ្យដឹងថា នៅវេលាម៉ោង១៤៖១០នាទី ថ្ងៃទី០២ ខែមិថុនាឆ្នាំ២០២០នេះ អាជ្ញាធរថៃ បានបញ្ជូប្រជាពលរដ្ឋខ្មែរ ចំនួន០៤នាក់ តាមច្រកអន្តរជាតិជាំ ដែលមានឈ្មោះដូចខាងក្រោម៖

*ទី១៖ ឈ្មោះ សូត្រ ប៊ិច ភេទប្រុស អាយុ៣៦ឆ្នាំ រស់នៅភូមិទួលពង្រ ឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ចាប់ខ្លួនថ្ងៃទី១៦ ខែ០១ ឆ្នាំ២០១៨។

*ទី២៖ ឈ្មោះ ធន ម៉ៅ ភេទប្រុស អាយុ៣២ឆ្នាំ រស់នៅភូមិទួលចារ ឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ចាប់ខ្លួនថ្ងៃទី០៧ ខែ០៥ ឆ្នាំ២០១៨។

*ទី៣៖ ឈ្មោះ ម៉េត ជា ភេទប្រុស អាយុ៣៩ឆ្នាំ រស់នៅភូមិទំនប់អភិវឌ្ឍន៍ ឃុំអូរស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ចាប់ខ្លួនថ្ងៃទី២៦ ខែ០៨ ឆ្នាំ២០១៧។

*ទី៤៖ ឈ្មោះ សាយ សិទ្ធ ភេទប្រុស អាយុ៣៣ឆ្នាំ រស់នៅភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ចាប់ខ្លួនថ្ងៃទី២៦ ខែ០៨ ឆ្នាំ២០១៧។

សមត្ថកិច្ចបានបញ្ជាក់ទៀតថា អ្នកទាំង៤នេះ ត្រូវបានថៃចោទពីបទឆ្លងដែនខុសច្បាប់ ចូលកាប់ឈើក្រញូងតាមច្រកជប់រុន ស្ថិតក្នុងភូមិសាស្ត្រឃុំព្រះប្រឡាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ និងបានយកទៅឃុំឃាំងនៅស្រុកខាន់ថាឡាក់ ខេត្តស៊ីសាកេត ប្រទេសថៃ។ បន្ទាប់ពីបានវាស់កំដៅ និងសម្អាតខ្លួនប្រាណដោយទឹកអាល់កុល ដើម្បីការពារជំងឺកូវីដ១៩រួចមក សមត្ថកិច្ចបានធ្វើការអប់រំណែនាំឱ្យបញ្ឈប់សកម្មភាពឆ្លងដែនខុសច្បាប់តទៅទៀត និងឱ្យវិលត្រឡប់ទៅលំនៅដ្ឋានវិញរៀងៗខ្លួន៕

## ប្រជាពលរដ្ឋមិនត្រូវឆ្លងដែនដោយខុសច្បាប់ទៅរកការងារធ្វើឡើយ នៅពេលទប់ស្កាត់កូវីដ១៩

https://kohsantepheapdaily.com.kh/article/ ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០២០ ម៉ោង ០៩:០៦ ប៊ុន ធឿន

ខេត្តបន្ទាយមានជ័យ៖ លោកជំទាវ ម៉ៅ ម៉ាល័យ បានណែនាំដល់ប្រជាពលរដ្ឋជាប់ជាយដែនមិនត្រូវឆ្លងដែនដោយខុសច្បាប់ទៅរកការងារធ្វើនៅប្រទេសជិតខាងឡើយ ស្របពេលកំពុងទប់ស្កាត់កូវីដ១៩។ លោកជំទាវបានមានប្រសាសន៍បែបនេះ ក្នុងឱកាសប្រគល់ផ្លូវ១ខ្សែ ប្រវែងជាង១គីឡូម៉ែត្រ នៅស្រុកអូរជ្រៅ កាលពីពេលថ្មីៗនេះ។

លោក អ៊ុំ រាត្រី អភិបាលខេត្តបន្ទាយមានជ័យ បានអោយដឹងថា ផ្លូវ១ខ្សែប្រវែង១.០៨៩ម៉ែត្រ និងទទឹង៦ម៉ែត្រ ដែលតភ្ជាប់ពីភូមិប៉ោយចារ ឃុំចង្ហា ស្រុកអូរជ្រៅ ទៅកាន់ទីទួលប្រាសាទដងខ្វាស់ដែលជាអំណោយរបស់លោក កែ គឹមយ៉ាន ឧបនាយករដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងលោកជំទាវ ម៉ៅ ម៉ាល័យ ។ លោកអភិបាលខេត្តបានបញ្ជាក់ថា ផ្លូវ១ខ្សែជាង១.០០០ម៉ែត្រ ដែលតភ្ជាប់ពីភូមិដល់ទីទួលប្រាសាទបូរាណគឺផ្ដល់ប្រយោជន៍បាន២គឺប្រព័ន្ធធារាសាស្ត្រសម្រាប់ផ្គត់ផ្គង់ទឹកដាក់កសិផល និងផ្លូវសម្រាប់ដឹកកសិផល ក្រោយបានផ្លូវហើយត្រូវចូលរួមថែរក្សាអោយបានគង់វង្ស មិនត្រូវកាប់ផ្លូវបូមទឹក បណ្ដាលឱ្យខូចខាត។

លោកជំទាវ ម៉ៅ ម៉ាល័យ បានមានប្រសាសន៍ថា ដោយឃើញជាក់ស្ដែង ផ្លូវនេះកសាងសម្រាប់តភ្ជាប់ពីភូមិទៅទីទួលប្រាសាទ ដើម្បីអោយបងប្អូនប្រជាពលរដ្ឋនាំគ្នាទៅកំសាន្តនៅថ្ងៃបុណ្យ ឬថ្ងៃសំរាកនិងទាក់ទាញភ្ញៀវជាតិ និងអន្តរជាតិបានស្គាល់។ លោកជំទាវតឿនរំលឹកដល់បងប្អូនប្រជាពលរដ្ឋ មិនត្រូវចាញ់បោកមេខ្យល់ទៅចំណាកស្រុកដោយខុសច្បាប់ ហើយប្រថុយប្រថានដែលប្រឈមគ្រោះថ្នាក់គ្រប់ពេលនៅពេលដែលប្រទេសជិតខាងត្រូវបិទព្រំដែនការពារនិងទប់ស្កាត់កូវីដ១៩ យើងត្រូវរកការងារធ្វើក្នុងស្រុក ឬដាំដំណាំកសិកម្មបង្កើនជីវិភាពគ្រួសារប្រសើរជាងចំណាកស្រុកខុសច្បាប់ ៕ (កែសម្រួលដោយ ៖ ធីតា)

## កម្ពុជា-UN សហការគ្នាបន្តទៀត ដើម្បីដោះស្រាយបញ្ហាការងារ និងប្រាក់ចំណូលរបស់ប្រជាពលរដ្ឋ

http://btv.com.kh/nation-news/ 02/06/2020

ភ្នំពេញ៖ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈកម្ពុជា បានចុះកិច្ចព្រមព្រៀងរួមគ្នាជាមួយតំណាងទីភ្នាក់ងាររបស់អង្គការសហប្រជាជាតិចំនួន៤ ដោយមានការគាំទ្រពីទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍនិងកិច្ចសហប្រតិបត្តិការ (SDC) ដើម្បីអនុវត្តកម្មវិធីការងារសមរម្យសម្រាប់យុវជន (DEY) ដំណាក់កាលទី២ ក្នុងការបន្តលើកកម្ពស់ការងារសមរម្យរបស់យុវជន និងកាត់បន្ថយវិសមភាពនៅក្នុងប្រទេស។ ពិធីចុះកិច្ចព្រមព្រៀងនេះបានប្រព្រឹត្តទៅ កាលពីថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២០កន្លងទៅ នៅទីស្ដីការក្រសួង រវាងឯកឧត្តមបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងលោកស្រី Pauline Tamesis អ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំកម្ពុជា។ ដោយឡែក តំណាងទីភ្នាក់ងាររបស់អង្គការសហប្រជាជាតិចំនួន៤ រួមមាន៖ អង្គការអន្តរជាតិខាងការងារ (អាយឡូ), អង្គការសហប្រជាជាតិ (យូនីសស្កូ), អង្គការដើម្បីកុមារ (យូនីសេហ្វ) និងអង្គការអភិវឌ្ឍន៍ឧស្សាហកម្ម (យូនីដូ)។

ប្រភពពីក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បានឱ្យដឹងទៀតថា ថវិកាសរុបសម្រាប់កម្មវិធីខាងលើសរុបចំនួន៨.៤៨លានដុល្លារអាមេរិក ក្នុងនោះ ទឹកប្រាក់ចំនួន ៤លានដុល្លារ ជាថវិកាផ្ដល់ដោយទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍនិងកិច្ចសហប្រតិបត្តិការនិងចំនួន៤.៤៨លានដុល្លារទៀត ជាថវិកាដែលបានមកពីមូលនិធិស្នូលរបស់ទីភ្នាក់ងារ ដែលចូលរួមនៅក្នុងកម្មវិធីនេះពីអ្នកផ្ដល់ជំនួយដទៃទៀត ពីវិស័យឯកជន ពីរាជរដ្ឋាភិបាលកម្ពុជា។ គម្រោងនេះ មានរយៈពេល០៤ឆ្នាំ ចាប់ពីខែមករា ឆ្នាំ២០២០ ដល់ខែធ្នូ ឆ្នាំ២០២៣។ កម្មវិធីនេះនឹងផ្ដល់ឱ្យយុវជនដែលបោះបង់ការសិក្សា និងងាយរងគ្រោះនូវកញ្ចប់ការសិក្សាប្រកប ដោយនវានុវត្តន៍ ដែលរួមបញ្ចូលនូវជំនាញបច្ចេកទេស ជំនាញសហគ្រិន ជំនាញទន់ និងការធ្វើពាណិជ្ជកម្ម ក៏ដូចជាការណែនាំពីមុខរបរដែលកំពុងមានតម្រូវការ ដើម្បីធានាថាពួកគេអាចបំពេញតាមតម្រូវការទីផ្សារការងារ និងត្រៀមខ្លួនជាស្រេចសម្រាប់ការងារប្រកបដោយគុណភាព។

កម្មវិធីការងារសមរម្យសម្រាប់យុវជនដំណាក់កាលទី២នេះ មានគោលបំណងគាំទ្រដល់ស្ត្រី និងបុរសវ័យក្មេងនៅកម្ពុជា ដើម្បីឱ្យពួកគេកាន់តែអាចទទួលបានឱកាសសមរម្យប្រកបដោយផលិតភាព តាមរយៈការធានាឱ្យ

ពួកគេកាន់តែមានលទ្ធភាពឆ្លើយតបចំពោះតម្រូវការទីផ្សារការងារ និងត្រៀមខ្លួនដើម្បីទទួលបានការងារប្រកបដោយគុណភាព។ ដើម្បីសម្រេចបានលទ្ធផល និងលើកកម្ពស់កិច្ចសហប្រតិបត្តិការឲ្យបានជាអតិបរមានៅក្នុងដំណាក់កាលទី២នេះ កម្មវិធីការងារសមរម្យសម្រាប់យុវជន នឹងផ្តោតជារួមលើគ្រប់សកម្មភាពទាំងអស់ក្នុងវិស័យចំនួន៤ មានដូចជា ទេសចរណ៍ កសិឧស្សាហកម្ម សំណង់ និងកម្មន្តសាល៕

## ពលរដ្ឋខ្មែរ បន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៤៥នាក់

https://www.facebook.com/GDIOfficial/ 02-06-2020

នៅថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៤៥នាក់ ស្រី ២១នាក់៕

## អាជ្ញាធរខណ្ឌដូនពេញ ស្នើឲ្យមន្ទីរសង្គមកិច្ចជួយរកការងារឲ្យស្ត្រីរកស៊ីផ្លូវភេទនៅវត្តភ្នំ

https://www.postkhmer.com/ វ៉ន ដារ៉ា | Publication date 03 June 2020 | 10:29 ICT

**ភ្នំពេញៈ** អាជ្ញាធរខណ្ឌដូនពេញបានស្នើឲ្យមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានីភ្នំពេញសហការជាមួយអង្គការពាក់ព័ន្ធនានា ជួយរកការងារសមរម្យសម្រាប់ស្ត្រីប្រកបរបររកស៊ីផ្លូវភេទដែលត្រូវបានឃាត់ខ្លួននៅតំបន់រមណីយដ្ឋានប្រវត្តិសាស្ត្រវត្តភ្នំ ដើម្បីឲ្យពួកគេបញ្ឈប់របរនេះទៀត បន្ទាប់ពីសមត្ថកិច្ចខណ្ឌប្រមូលពួកគេបាន ៧ នាក់។

នេះបើតាមលោក យស យុទ្ធី អភិបាលរងខណ្ឌដូនពេញដែលបានដឹកនាំកម្លាំងប្រជាការពារខណ្ឌចុះប្រតិបត្តិការប្រមូលស្ត្រីរកស៊ីផ្លូវភេទនៅជុំវិញរមណីយដ្ឋានវត្តភ្នំបានប្រាប់ភ្នំពេញប៉ុស្ដិ៍កាលពីថ្ងៃអង្គារ។ លោកថា ការបង្ក្រាបស្ត្រីប្រកបរបររកស៊ីផ្លូវភេទនេះ អាជ្ញាធរខណ្ឌដូនពេញបានសហការជាមួយមន្ទីរសង្គមកិច្ចបានចុះផ្ទាល់ទាំងអស់គ្នាអង្កេតតាមដានរហូតឈានដល់ប្រមូលស្ត្រីរកស៊ីផ្លូវភេទបានចំនួន ៧ នាក់ ហើយបានបញ្ជូនភ្លាមៗទៅមន្ទីរសង្គមកិច្ចទាំងយប់កាលពីថ្ងៃចន្ទ។ លោកថ្លែងថាៈ «ការបង្ក្រាបប្រមូលពួកគាត់ (ស្ត្រីរកស៊ីផ្លូវភេទ) នេះដោយសារមើលទៅឃើញប៉ះពាល់ដល់សណ្តាប់ធ្នាប់នៅតំបន់រមណីយដ្ឋានវប្បធម៌ប្រវត្តិសាស្ត្រវត្តភ្នំធ្ងន់ធ្ងរពេក គឺជាកន្លែងសក្ការៈបូជា និងតំបន់ទេសចរជាតិអន្តរជាតិទស្សនា។ ប៉ុន្តែពួកគាត់ទៅឈរក្រោមដើមឈើបក់ដៃហៅភ្ញៀវមើលទៅពិតជាប៉ះពាល់ដល់សណ្តាប់ធ្នាប់ខ្លាំងណាស់»។ លោក យុទ្ធី ថ្លែងថា ក្នុងចំណោមស្ត្រីរកស៊ីផ្លូវភេទទាំង ៧ នាក់នេះក៏មានមួយចំនួន អាជ្ញាធរខណ្ឌធ្លាប់ប្រមូល និងឲ្យធ្វើកិច្ចសន្យា បញ្ឈប់សកម្មភាពនេះពីម្តងទៅ ២ ដង និងបញ្ជូនទៅខាងមន្ទីរសង្គមកិច្ចរួចហើយដែរ។ ប៉ុន្តែក្រោយពេលមន្ទីរសង្គមកិច្ចណែនាំតាមបច្ចេកទេសរួចក៏បានឲ្យគាត់ត្រឡប់ទៅផ្ទះវិញហើយមួយរយៈពេលខ្លីពួកគាត់គ្មានការងារធ្វើ ក៏មកប្រកបរបរនេះដដែល។

លោកបានស្នើថាៈ «ខាងមន្ទីរគួរសហការជាមួយអង្គការពាក់ព័ន្ធរកការងារសមរម្យសម្រាប់ពួកគាត់ធ្វើ កុំឲ្យពួកគាត់ចេញមកប្រកបរបររកស៊ីផ្លូវភេទបែបនេះទៀត។ បើសិនមិនរកការងារឲ្យពួកគាត់ធ្វើទេ ពួកគាត់ដូចចកអណ្តែតទឹកអ៊ីចឹងចាប់ថ្ងៃនេះបានមួយរយៈពួកគាត់ក៏ត្រឡប់មកវិញទៀត។ មន្ទីរសង្គមកិច្ច គួរជួយស្វែងរកការងារ

ឲ្យពួកគាត់ធ្វើព្រោះមានការងារច្រើនណាស់ ដែលពួកគាត់អាចធ្វើបាន។ យើងចង់កែតម្រូវពួកគាត់ឲ្យដើរទៅផ្លូវល្អវិញ»។ បើតាមលោក យុទ្ធី សកម្មភាពប្រមូលស្ត្រីរកស៊ីផ្លូវភេទនៅរមណីយដ្ឋានវត្តភ្នំនេះអាជ្ញាធរខណ្ឌដូនពេញបានធ្វើជាប្រចាំ។ នាពេលកន្លងមកអាជ្ញាធរប្រមូលក្នុង ១ ថ្ងៃបានពី ១០ នាក់ទៅ ១៥ នាក់ ប៉ុន្តែឥឡូវនេះនៅសល់តិចតួចទេ។ លោកបញ្ជាក់ថា ការប្រកបរបររបស់ស្ត្រីរកស៊ីផ្លូវភេទនេះ គឺមានមេខ្យល់ជាអ្នកដឹកនាំ សមត្ថកិច្ចក៏កំពុងតាមស្វែងរកមុខមេខ្យល់ផងដែរ។

លោកស្រី មុំ ចាន់ដានី ប្រធានមន្ទីរសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានីភ្នំពេញ ថ្លែងកាលពីម្សិលមិញថា ក្រោយពីសមត្ថកិច្ចខណ្ឌដូនពេញបានបញ្ជូនស្ត្រីប្រកបរបររកស៊ីផ្លូវភេទមកដល់មន្ទីរសង្គមកិច្ច បានទំនាក់ទំនងស្វែងរកគ្រួសារពួកនាង និងហៅអ្នកអាណាព្យាបាលពួកនាងមកប្រឹក្សារួចរាល់ទើបបញ្ជូនពួកនាងទៅកាន់គ្រួសារវិញ។ លោកស្រីថ្លែងថា៖ «អ្នកដែលមានក្រុមគ្រួសារពិតប្រាកដ យើងប្រគល់គាត់ទៅក្រុមគ្រួសារវិញ ដើម្បីជួយដល់ពួកគាត់ ចំពោះអ្នកដែលមិនមានក្រុមគ្រួសារពិតប្រាកដ យើងប្រគល់ឲ្យទៅអង្គការដៃគូនានា ដើម្បីឲ្យពួកគាត់ផ្តល់ជំនាញវិជ្ជាជីវៈ ជូនពួកគាត់ឲ្យពួកគាត់មានបំណិនជីវិតទៅថ្ងៃក្រោយ»។ ចំពោះការលើកឡើងរបស់អាជ្ញាធរខណ្ឌដូនពេញដែលចង់ឲ្យមន្ទីរសង្គមកិច្ចជួយស្វែងរកការងារសមរម្យដល់ស្ត្រីទាំងនេះ លោកស្រី ចាន់ដានី បញ្ជាក់ថា ការបញ្ជ្រាបចំណេះដឹងទាក់ទងនឹងតម្លៃនៃកម្លាំងពលកម្មការងារ និងជំនាញវិជ្ជាជីវៈ បំណិនដល់ស្ត្រីប្រកបរបររកស៊ីផ្លូវភេទគឺមានការលំបាក និងត្រូវការពេលវេលាច្រើនក្នុងការបញ្ជ្រាបដល់ពួកនាង។

លោកស្រីថា៖ «ជួនកាលយើងពន្យល់ណែនាំពួកគាត់ម្តង ពួកគាត់នៅមិនទាន់យល់យើងត្រូវបន្តប្រឹក្សាដល់ពួកគាត់បន្ថែមទៀត រហូតដល់ពួកគាត់ព្រមទទួលយកការផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងបំណិនជីវិតថ្មីសម្រាប់ខ្លួនពួកគាត់»។ លោកស្រី ចាន់ដានី បញ្ជាក់ថា ជំនាញវិជ្ជាជីវៈដែលអង្គការដៃគូនានាផ្តល់ដល់ស្ត្រីប្រកបរបររកស៊ីផ្លូវភេទមានច្រើនប្រភេទគឺអាស្រ័យទៅលើចំណង់ចំណូលចិត្ត ចំណេះជំនាញរបស់ស្ត្រីទាំងនោះ។ ប៉ុន្តែជាទូទៅអង្គការដៃគូ មិនចង់ឲ្យពួកនាងចាប់យកជំនាញដែលលំបាកៗពេកនោះទេ ដោយអង្គការបណ្តុះបណ្តាលជំនាញបែបងាយស្រួល និងមានទីផ្សារការងារដល់ពួកនាងដូចជាជំនាញខាងផ្នែក អ៊ុតសក់ ធ្វើក្រចក និងរៀនធ្វើម្ហូបជាដើម៕

## វេទិកាផ្សព្វផ្សាយអំពីផលប៉ះពាល់នៃការធ្វើចំណាកស្រុកដោយប្រថុយប្រថាន និងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស នៅក្រុងកំពង់ឆ្នាំង

https://gdlf-kh.com/ 2020/06/03/ Sam Sophearum កំពង់ឆ្នាំង

ខេត្តកំពង់ឆ្នាំង៖ នាព្រឹកថ្ងៃពុធ ១៣កើត ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២០នេះ លេខាធិការដ្ឋាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) ខេត្តកំពង់ឆ្នាំង រៀបចំវេទិកាដើម្បីផ្សព្វផ្សាយអំពីផលប៉ះពាល់នៃការធ្វើចំណាកស្រុកដោយប្រថុយប្រថាន និងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ជូនដល់ប្រជាពលរដ្ឋ ក្រោមអធិបតីភាព លោកជំទាវ ប៊ិន សុភី អភិបាលរងខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) ខេត្តកំពង់ឆ្នាំង ដោយមានការចូលរួមពីលោក យិន សារ៉េន អភិបាលក្រុងកំពង់ឆ្នាំង លោកស្រី មាស សុម៉ាលី ស្នងការរងនគរបាលខេត្ត។ វេទិកាផ្សព្វផ្សាយនេះ រៀបចំនៅក្នុងភូមិទី៦ សង្កាត់ខ្សាម ក្រុងកំពង់ឆ្នាំង ក្នុងនោះក៏មានការចូលពីលោក លោកស្រីជាថ្នាក់ដឹកនាំមន្ទីរ អង្គភាព ពាក់ព័ន្ធ, កម្លាំងសមត្ថកិច្ច, មេភូមិ ចៅសង្កាត់, អាជ្ញាធរ, ក្រុមការងាររបស់លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត និងប្រជាពលរដ្ឋជាច្រើនទៀតចូលរួមផងដែរ។

ឆ្លៀតក្នុងឱកាសនោះដែរ លោកជំទាវ ប៊ិន សុភី អភិបាលរងខេត្ត ក៏បានបញ្ជាក់ពីគោលបំណងក្នុងអង្គវេទិកា ក្នុងនោះក្រោមការដឹកនាំចង្អុលទិស របស់ឯកឧត្តមអភិបាលខេត្ត ដោយយកចិត្តទុកដាក់ ជម្រុញពង្រឹងការអនុវត្ត ការងារ ដល់គណៈកម្មាធិការ គ.ខ.ប.ជ ខេត្ត ក្រុមលេខាធិការដ្ឋាន ក្រុមការងារជំនាញអន្តរ មន្ទីរ អង្គភាព

បានអនុវត្តការងារបានយ៉ាងល្អ។ លោកជំទាវក៏បានផ្សព្វផ្សាយដូចជាការក្រើនរំឭកបន្ថែមដល់បងប្អូនប្រជាពលរដ្ឋទាំងអស់ ត្រូវរក្សាអនាម័យ អនុវត្តវិធានការការពារខ្លួនពីជំងឺផ្សេងៗ ជាពិសេសជំងឺកូវីដ១៩ ដែលកំពុងរីករាលដាលទូទាំងសកលលោក។ លោកជំទាវបានបន្តទៀតថា៖ ទោះជាប្រទេសយើងអាចគ្រប់គ្រងការរីករាលដាលនៃជំងឺកូវីដ១៩ នៅដំណាក់កាលទី១ក្តី ប៉ុន្តែបងប្អូនទាំងអស់ត្រូវតែប្រុងប្រយ័ត្ន និងអនុវត្តនូវវិធានការនានាដែលរាជរដ្ឋាភិបាលកម្ពុជា និងតាមការណែនាំរបស់ក្រសួងសុខាភិបាលឱ្យបានជាប្រចាំដើម្បីចូលរួមទាំងអស់គ្នាកុំឱ្យកើតមានជំងឺកូវីដ១៩ នៅក្នុងដំណាក់កាលដែលមានរលកទី២នេះ នៅក្នុងសហគមន៍យើង។ ក្នុងឱកាសនោះផងដែរ លោកជំទាវ បានចែកម៉ាស់ជូនដល់បងប្អូនប្រជាពលរដ្ឋដែលបានចូលរួម ចំនួន ៧៩ម៉ាសផងដែរ ៕

## សូមចូលរួមរំលែកទុក្ខផង បុរសម្នាក់ដែលជាពលករខ្មែរ ធ្វើការនៅប្រទេសកូរ៉េ បានស្លាប់បាត់បង់ជីវិតដោយសារតែ

http://khmerosja.net/ June 1, 2020

មនុស្សម្នាក់ៗគ្មាននរណាចង់ចាកឆ្ងាយពីគ្រួសារខ្លួនឯងនោះទេ តែមកពីជីវភាពក្នុងគ្រួសារមានការខ្វះខាតគ្មានជម្រើស ទើបត្រូវសំរេចចិត្តបែបនេះ ចាកឆ្ងាយពីប្រទេសកំណើតខ្លួន ហើយទៅនៅប្រទេសដទៃដែលខ្លួនមិនស្គាល់សោះដើម្បីធ្វើការរកលុយ ទាំងដែលត្រូវជួបនូវបញ្ហាលំបាកមួយចំនួនដូចជា ការហូបចុក កត្តាអាកាសធាតុ (រដូវក្តៅ និងរដូវធ្លាក់ព្រិល)។ គ្រោះថ្នាក់ក្នុងម៉ោងការងារដោយយថាហេតុណាមួយជាដើមនោះ ដែលទាំងអស់នេះហើយ គឺជាមូលហេតុយ៉ាងចំបង ដែលសុទ្ធសឹងតែអាចឈានដល់ការបាត់បង់ជីវិតបានគ្រប់ពេលវេលាតែម្តង។ យ៉ាងណាមិញ ពលករកូរ៉េម្នាក់ទៀតហើយបានស្លា ប់បាត់បង់ជីវិតយ៉ាងអាណោចអាធ័មដោយសារតែករណីគ្រោះថ្នាក់ចរាចរណ៍។

បើយោងតាមរយៈគណនីហ្វេសប៊ុកឈ្មោះ Park Sujin បានមានការរៀបរាប់ឲ្យដឹងថា៖«សូមចូលរួមរំលែកទុក្ខផងបងប្រុសដែលស្លា ប់ដោយសារគ្រោះថ្នាក់ចរាចរណ៍ បើសាច់ញាតិមានអ្វីអោយខ្ញុំជួយផ្នែកច្បាប់ទាក់ទងនឹងប្រាក់សំណងគ្រោះថ្នាក់ចរាចរណ៍ អាចទាក់ទងមកដែលមានបទពិសោធន៍ខ្ពស់ក្នុងការដោះស្រាយជូន»។ ទន្ទឹមនឹងនេះដែរ បើយោងតាមប្រភពព័ត៌មានពីគណនីហ្វេសប៊ុកឈ្មោះ Thona បានប្រាប់ឲ្យដឹងថា៖«ដំណឹងមរណៈភាព បងប្អូនខ្មែរយើងកាលពីថ្ងៃទី២០២០-០៥-៣០ បានជួបគ្រោះថ្នាក់ចរាចរណ៍នៅតំបន់ធន់អាន់ ដឹកទៅមន្ទីរពេទ្យតលូវទទួលមរណៈភាពហើយ គាត់ជាអ្នកស្រុកនៅកៀនស្វាយ ខេត្តកណ្តាល គាត់ជាពលករខុសច្បាប់មកធ្វើការនៅកូរ៉េរយៈពេលពីរឆ្នាំជាងហើយ។ សូមអោយបងទៅកាន់សុខគតិភព ប្អូនសូមចូលរួមរំលែកទុក្ខក្រុមគ្រួសារបងផង»។

# ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២០

## លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ ( គ.ជ.ប.ជ ) ប្រារព្ធនូវកម្មវិធីសំណេះសំណាល ស្តីពីការឆ្លើយតបនឹងវិបត្តិកូវីដ ១៩ របស់សហគមន៍ ដែលជួបការលំបាក ដើម្បីទប់ស្កាត់អំពើជួញដូរមនុស្ស

https://www.facebook.com/krongtepnews/ 04-06-2020

(បាត់ដំបង)៖ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍( គ.ជ.ប.ជ )និងលោកជំទាវ ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គជបជ អគ្គលេខាធិការរង រួមនិងអង្គការដៃគូអភិវឌ្ឍ អង្គការ UNFPA (យូអិនអេហ្វភីអេ) និងអាយអូអឹម ប្រារព្ធនៅកម្មវិធីសំណេះសំណាលស្តីពីការឆ្លើយតបនឹងវិបត្តិកូវីដ ១៩

របស់សហគមន៍ដែលជួបការលំបាកដើម្បីទប់ស្កាត់អំពើជួញដូរមនុស្ស និងប្រគល់សម្ភារៈប្រើប្រាស់មួយចំនួន ចំនួន ១០០គ្រួសារ។

ព្រឹកថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២០ អគ្គលេខាធិការដ្ឋាន គជបជ ក្រោមអធិបតីភាពលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ លោកជំទាវ ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គជបជ អគ្គលេខាធិការរង រួមនិងអង្គការដៃគូរអភិវឌ្ឍ អង្គការ UNFPA ( យូអិនអេហ្វភីអេ ) និងអាយអូអឹម ប្រារព្ធនៅកម្មវិធីសំណេះសំណាលស្តីពីការឆ្លើយតបនឹងវិបត្តិកូវីដ ១៩ របស់សហគមន៍ដែលជួបការលំបាកដើម្បីទប់ស្កាត់អំពើជួញដូរមនុស្ស និងប្រគល់សម្ភារៈប្រើប្រាស់មួយចំនួន ចំនួន១០០គ្រួសារ ដោយមួយគ្រួសារទទួលបានអង្ករ១០គីឡូក្រាម ស្ករស ទឹកត្រី ធីបមួយកញ្ចប់ (មានសាប៊ូលាងដៃ សារុង ក្រមា ប្រាសដុសធ្មេញ ថ្នាំដុសធ្មេញ) នៅស្រុកមោងឬស្សី ខេត្តបាត់ដំបង ។ ពិធីមានការចូលរួមពីសំណាក់ ប្រធានក្រុមប្រឹក្សាខេត្ត អភិបាលរងខេត្ត អភិបាលស្រុក អាជ្ញាធរដែនដី តំណាងពីមន្ទីរនានាជុំវិញខេត្ត មានកសិកម្ម អភិវឌ្ឍជនបទ កិច្ចការនារី ធនធានទឹក មន្ត្រីឃុំ/ភូមិ ក្នុងមូលដ្ឋាន។

## អភិបាលស្រុកចន្ទ្រា ដឹកនាំក្រុមការងារចុះសួរសុខទុក្ខពលរដ្ឋចំណាកស្រុកដែលវិលត្រឡប់មកពីប្រទេសវៀតណាម

https://grandnewsasia.com/detail/ 03-06-2020

ស្វាយរៀង៖ នៅព្រឹកថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២០នេះ លោក ថន ថាវុទ្ធា អភិបាលនៃគណៈអភិបាលស្រុកចន្ទ្រា បានដឹកនាំក្រុមការងារ ចុះសួរសុខទុក្ខ និងអប់រំអប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋចំណាកស្រុក ត្រឡប់មកពីប្រទេសវៀតណាម ០១នាក់ ឈ្មោះ នួន គន្ធា ភេទប្រុស អាយុ ៣៦ឆ្នាំ រស់នៅភូមិបារាយណ៍ ឃុំមេសរថ្ងក ស្រុកចន្ទ្រា ខេត្តស្វាយរៀង។ លោកអភិបាលស្រុក បានឱ្យលោកមេភូមិ សហការជាមួយលោកមេឃុំ ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ នាំគាត់មកពិនិត្យនៅមណ្ឌលសុខភាពជារៀងរាល់ថ្ងៃ ហើយឱ្យគាត់រស់នៅដាច់ឡែកពីគេរយៈពេល ១៤ ថ្ងៃ ព្រមទាំងបានឧបត្ថម្ភសម្ភារៈមួយចំនួនរួមមាន អង្ករ ២៥គីឡូក្រាម មី ០១កេស ទឹកស៊ីអ៊ីវ ០១យួរ ទឹកត្រី ០២ដប កន្ទេល០១ ខ្នើយ០១ ភួយ០១ មុង០១ ចាន់ដែក០១ ចានឆ្នាំង ស្លាបព្រា និងវែក សម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ៕

## UN និងទីភ្នាក់ងារស្វីស ចុះហត្ថលេខាលើកម្មវិធីភាពមានការងារសមរម្យសម្រាប់យុវជនវគ្គ ២

https://www.postkhmer.com/ ឡុង គីមម៉ារីតា | Publication date 03 June 2020 | 14:44 ICT

**ភ្នំពេញៈ** អង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា និងទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍន៍ និងសហប្រតិបត្តិការ (SDC) ព្រមទាំងទីភ្នាក់ងារផ្តល់ជំនួយផ្សេងទៀតកាលពីល្ងាចថ្ងៃចន្ទបានចុះហត្ថលេខាលើកម្មវិធី «ភាពមានការងារសមរម្យសម្រាប់យុវជន ឬ DEY» វគ្គ ២ ដែលមានរយៈពេល ៤ ឆ្នាំ ក្នុងគម្រោងទឹកប្រាក់ប្រមាណជាង ៨ លានដុល្លារ។ បើតាមឯកសារដែលត្រូវបានផ្សព្វផ្សាយនៅក្នុងពិធីនេះថវិកាសរុបសម្រាប់កម្មវិធី DEY ដំណាក់កាលទី ២ គឺមាន ៨,៤៨ លានដុល្លារ ក្នុងនោះទឹកប្រាក់ ៤ លានដុល្លារជាថវិកាផ្តល់ដោយ SDC និង ៤,៤៨ លានដុល្លារទៀតជាថវិកាដែលបានមកពីមូលនិធិស្នូលរបស់ទីភ្នាក់ងារដែលចូលរួមនៅក្នុងកម្មវិធីនេះពីអ្នកផ្តល់ជំនួយដទៃទៀតពីវិស័យឯកជនពីរាជរដ្ឋាភិបាលកម្ពុជា។ DEY គឺជាកម្មវិធីមួយដែលត្រូវបានប្រកាសដំណើរការតាំងពីឆ្នាំ ២០១៧ ហើយបានបិទបញ្ចប់ក្នុងដំណាក់កាលទី ១ កាលពីខែធ្នូឆ្នាំ ២០១៩ ដោយមានការគាំទ្រពី SDC រួមនឹងដៃគូគាំទ្រដទៃទៀត។ អង្គការសហប្រជាជាតិប្រចាំនៅកម្ពុជាបានឲ្យដឹងនៅក្នុងសេចក្តីប្រកាសព័ត៌មានពីថ្ងៃចន្ទថា កម្មវិធី

ដំណាក់កាលទី ២ នេះបានចាប់ផ្តើមដំណើរការតាំងពីខែមករា ឆ្នាំ ២០២០ ដែលមានរយៈពេល ៤ ឆ្នាំក្រោមការដឹកនាំ និងរៀបចំដោយការិយាល័យអ្នកសម្របសម្រួល UN ។

នៅក្នុងកិច្ចសហប្រតិបត្តិការនេះក៏រួមមានស្ថាប័នរដ្ឋាភិបាល និយោជក និងកម្មករនិយោជិត ទទួលបានការគាំទ្រពីគម្រោងដំណាក់កាលទី ២ នេះដោយគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងការផ្តល់នូវគន្លឹះមួយចំនួន ដើម្បីអន្តរាគមន៍ក្នុងការឆ្លើយតបទៅនឹងផលប៉ះពាល់នៃជំងឺកូវីដ១៩ក្នុងវិស័យការងារការបណ្តុះបណ្តាល ការអប់រំ និងប្រាក់ចំណូល។ UN បញ្ជាក់ថា៖ «អត្ថប្រយោជន៍ដែលទទួលបានពីគម្រោងថ្មីនេះនឹងទទួលបានយុទ្ធសាស្ត្រព្រមទាំងថវិកាប្រមាណ ៤ លានដុល្លារពីទីភ្នាក់ងារស៊ុីសក្រោមការអភិវឌ្ឍ និងសហការ ខណៈដំណាក់កាលទី ២ នេះនឹងបន្តពង្រីកគំនិតផ្តួចផ្តើមក្នុងវគ្គទី ១ ឲ្យទទួលបានជោគជ័យនៅក្នុងការជួយដល់យុវជនដែលជាស្ត្រី និងបុរសក្នុងការទទួលបានឱកាសការងារសមរម្យ និងផលិតភាពកាន់តែច្រើនឡើង»។

លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈបានថ្លែងនាឱកាសនោះថា គម្រោងនេះនឹងជួយដល់យុវជនក្នុងការទទួលបានឱកាសការងារ និងប្រសិទ្ធភាពការងារកាន់តែប្រសើរ ខណៈពួកគេបានរងផលប៉ះពាល់ពីជំងឺកូវីដ១៩។ លោកថា៖ «ការបន្តគម្រោងនេះដែលមានទឹកប្រាក់ ៤ លានដុល្លារ នឹងជួយគាំទ្រដល់គម្រោងក្នុងការជួយដល់យុវជនឲ្យទទួលបានឱកាសការងារសមរម្យសម្រាប់ឆ្នាំ ២០២០ ដល់ឆ្នាំ ២០២៣ ហើយយើងក៏នឹងបន្តរួមគ្នាក្នុងការផ្តល់ឱកាសដល់កម្ពុជាក្នុងការលើកកម្ពស់ការងារសមរម្យ ជាពិសេសដល់យុវជន»។

កញ្ញា ហុក សុវណ្ណវត្តី តំណាងឲ្យយុវជនដែលទទួលបានការជួយគាំទ្រពីគម្រោងនេះថ្លែងថា ការប្រឈមមុខនឹងជំងឺកូវីដ១៩ មួយរយៈចុងក្រោយនេះបានធ្វើឲ្យយុវជនមួយចំនួនបានបាត់បង់ការលើកទឹកចិត្តដោយសារតែមិនត្រៀមខ្លួនទុកជាមុន ព្រោះតែការផ្អាកសកម្មភាពប្រចាំថ្ងៃដែលធ្លាប់តែធ្វើ។ កញ្ញា បន្តថាក្នុងឱកាសនេះគឺជាពេលដ៏ពិបាកសម្រាប់កម្មករនិយោជិតជាពិសេសសម្រាប់ពលករចំណាកស្រុកដែលធ្លាប់ពឹងអាស្រ័យលើការងារនៅក្រៅប្រទេស។ កញ្ញាបញ្ជាក់ថា៖ «ផលវិបាកនេះមិនទាន់រាប់បញ្ចូលការបិទទ្វារសាលាក្លិបកម្សាន្តនានា ដែលធ្វើឲ្យមនុស្សរាប់សែននាក់មិនមានការងារធ្វើ និងសេវាគាំពារសង្គម។ អ្វីដែលវិជ្ជមាននោះ គឺស្ថានភាពនៅក្នុងប្រទេសកម្ពុជាគឺកាន់តែមានភាពល្អប្រសើរដោយសារតែការខិតខំប្រឹងប្រែងធ្វើការសម្រេចចិត្ត និងការផ្សព្វផ្សាយព័ត៌មានដ៏ត្រឹមត្រូវ។ ខ្ញុំរីករាយ និងសង្ឃឹមថា កម្មវិធីការងារសមរម្យសម្រាប់ដំណាក់កាលទី ២ នេះ នឹងបន្តអនុវត្ត ហើយក៏មានយុវជនដ៏ច្រើននឹងទទួលផលពីគម្រោងនេះ»៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៥២នាក់

https://www.facebook.com/GDIOfficial 03-06-2020

នៅថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៥២នាក់ ស្រី ២៣នាក់៕

## ពលរដ្ឋខ្មែរ ០១នាក់ វិលត្រឡប់មកពីប្រទេសថៃ តាមច្រករបៀង (ស្លាបស្ដាំ) របស់ប៉ុស្តិ៍ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិត្នំដី

https://www.facebook.com/GDIOfficial 03-06-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិត្នំដី នាវេលាម៉ោង ១៥និង០០នាទី ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២០ មានពលរដ្ឋខ្មែរ វិលត្រឡប់មកពីប្រទេសថៃ តាមច្រករបៀង (ស្លាបស្ដាំ) របស់ប៉ុស្តិ៍ចំនួន ០១នាក់។ បន្ទាប់មក កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំ និងពិនិត្យកំដៅជូនពួកគាត់ និងបានសហការប្រគល់បុគ្គលខាងលើ ជូនទៅមន្ត្រីចត្តាឡីស័ក ដើម្បីអនុវត្តតាមជំនាញបន្ត។ ដោយឡែកប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិត្នំដី ខាងភាគីថៃបានបើកច្រកទ្វារព្រំដែន អនុញ្ញាតឲ្យនាំចូល-ចេញទំនិញ ដែលបានកំណត់ ពីវេលាម៉ោង ០៦និង០០នាទី និងបានបិទវិញនៅវេលាម៉ោង ១២និង០០នាទីរសៀល៕

## ប្រទេសថៃអនុញ្ញាតឱ្យពលករចំណាកស្រុកនៅធ្វើការ នៅប្រទេសថៃរហូតដល់ថ្ងៃទី ៣១ ខែកក្កដា

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី 4 ខែ មិថុនា ឆ្នាំ 2020

AKP ភ្នំពេញ ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២០៖ គណៈរដ្ឋមន្ត្រីថៃបានសម្រេចអនុញ្ញាតឱ្យពលករចំណាកស្រុកមកពីប្រទេសកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា នៅធ្វើការនៅក្នុងប្រទេសថៃរហូតដល់ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០២០ ដើម្បីជួយកាត់បន្ថយ សក្តានុពល នៃការរីករាលដាលនៃជំងឺកូវីដ-១៩ និងដើម្បីរក្សាបាននូវកម្លាំងពលកម្មខណៈដែលស្ថានភាពកាន់តែប្រសើរឡើងជាលំដាប់។ កន្លងមកក្រសួងមហាផ្ទៃ និងក្រសួងការងារនៃប្រទេសថៃបានអនុញ្ញាតឱ្យពួកគេស្នាក់នៅ នឹងធ្វើការនៅក្នុងព្រះរាជាណាចក្រនេះរហូតដល់ថ្ងៃទី ៣១ ខែឧសភា ឆ្នាំនេះ។

អ្នកនាំពាក្យរដ្ឋាភិបាលថៃ លោកសាស្ត្រាចារ្យបណ្ឌិត Narumon Pinyosinwat ត្រូវបានដកស្រង់សម្តីដោយការិយាល័យព័ត៌មានជាតិនៃប្រទេសថៃ (NNT) កាលពីថ្ងៃទី៣ ខែមិថុនាថា ដោយវិធានការណ៍ទប់ទល់នឹងជំងឺនេះនៅតែជាធរមាន ក្រសួងការងារបានកោះហៅប្រជុំគ្រប់អង្គភាពផ្សេងៗ។ ពួកគេបានដោះស្រាយថា ពលករចំណាកស្រុកមកពីប្រទេស ជិតខាងទាំងបីអាចស្នាក់នៅនឹងធ្វើការនៅក្នុងប្រទេសថៃចន្លោះពីថ្ងៃទី១ ខែមិថុនា ដល់ថ្ងៃទី៣១ ខែកក្កដា។ ពលករចំណាកស្រុករួមមានពីរក្រុមដែលមួយក្រុមក្នុងនោះមានពលករខ្មែរ ឡាវ និងមីយ៉ាន់ម៉ាដែលមានលិខិតអនុញ្ញាតិការងារដែលចេញក្រោមអនុស្សរណៈនៃការយោគយល់គ្នា (MOU) ស្តីពីបញ្ហាការងារ។

ក្រុមទីពីរ គឺពលករខ្មែរនិងមីយ៉ាន់ម៉ា ដែលកាន់លិខិតឆ្លងដែនស្របតាមមាត្រា ៦៤ នៃច្បាប់ថៃ។ NNT បាននិយាយថា សេចក្តីសម្រេចនេះនឹងកាត់បន្ថយហានិភ័យនៃកម្មករដែលបានចុះកិច្ចសន្យា និងការរីករាលដាលនៃជំងឺកូវីដ-១៩ ការពារការខ្វះខាតកម្លាំងពលកម្មនៅពេលក្រោយ និងគាំទ្រដល់ការស្តារសេដ្ឋកិច្ចឡើងវិញបន្ទាប់ពីស្ថានភាពនៃជំងឺកូវីដ-១៩ មានភាពប្រសើរឡើង៕ (ប្រភព VNA បកប្រែដោយ លោក យា ចិន្តាខន្តី)

# ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២០

## កងកម្លាំងមានសមត្ថកិច្ចពាក់ព័ន្ធកម្ពុជា-ថៃជួបពិភាក្សាលើការងារព្រំដែន

https://www.rasmeinews.com/ June 4, 2020, 7:54 PM

ដោយៈគ្រញូង/បាត់ដំបងៈកាលពីព្រឹកថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២០ ប៉ុស្តិ៍នគរបាលអន្តោប្រវេសន៍ច្រកទ្វារព្រំដែនអន្តរជាតិត្នំដី(គីឡូ១៣)ដឹកនាំដោយលោកវរសេនីយ៍ឯកពៅមុនីជាតិនាយប៉ុស្តិ៍បានទៅជួបពិភាក្សាការងារព្រំដែន។រវាងកងកម្លាំងមានសមត្ថកិច្ចពាក់ព័ន្ធកម្ពុជា-ថៃនៅអាគារទំនាក់ទំនងទាហានឈុតខ្មៅថៃប្រចាំច្រកទ្វារព្រំ

ដែនអន្តរជាតិបានខៅឌីនប្រទេសថៃ។ នៅក្នុងជំនួបពិភាក្សាជុំវិញកិច្ចសហប្រត្តិបត្តិការលើការងារព្រំដែនរវាងកងកម្លាំងមានសមត្ថកិច្ចពាក់ព័ន្ធកម្ពុជា-ថៃធ្វើឡើងតាមការអញ្ជើញរបស់លោកវរសេនីយ៍ឯកRONNARONGSENGMI មេបញ្ជាការវរៈសេនាធំឈុតខ្មៅថៃលេខ១៣ដែលទើបផ្លាស់ចូលកាន់តំណែងថ្មី។ ភាគីកម្ពុជាក៏មានការអញ្ជើញចូលរួមដោយមានលោកអធិការនគរបាលស្រុកសំពៅលូន,លោកមេបញ្ជាការកងវរៈសេនាតូចលេខ១,លោកមេបញ្ជាការវរៈសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧។

ភាគីទាំងពីរក៏បានលើកឡើងនូវខ្លឹមសារសំខាន់ៗ ក្នុងកិច្ចជំនួបពិភាក្សានេះ មាន ១,រួមគ្នាទប់ស្កាត់ ការរីករាលដាលជំងឺកូវីដ-១៩, ២,សហការទប់ស្កាត់ការលួចឆ្លងដែនខុសច្បាប់នានា។ ជាពិសេសស្នើសុំសមត្ថកិច្ចថៃសម្របសម្រួលធ្វើការចាប់បញ្ជូនត្រឡប់មកកម្ពុជាវិញ ចំពោះបងប្អូនប្រជាពលរដ្ឋខ្មែរដែលសមត្ថកិច្ចថៃចាប់ឃាត់ខ្លួនបាននៅពេលឆ្លងកាត់ចូលទៅប្រទេសថៃតាមច្រករបៀងនានា។ ៣,បន្តបង្កើនកិច្ចសហប្រត្តិបត្តិការល្អរវាងភាគីទាំងពីរកម្ពុជា-ថៃ៕S/

## ចុះជួបប្រជាពលរដ្ឋនិងស្ត្រីងាយរងគ្រោះ ប្រមាណ១០០គ្រួសារ នៅស្រុកមោងឫស្សី

https://www.rasmeinews.com/ June 5, 2020, 10:58 AM

*ដោយៈគ្រញូង/បាត់ដំបង* ៖ កាលពីថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២០លោកអ៊ុយ រី ប្រធានក្រុមប្រឹក្សាខេត្តបាត់ដំបងនិងលោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិកាក្រសួងមហាផ្ទៃនិងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំអំពើជួញដូរមនុស្ស បានអញ្ជើញជាអធិបតីក្នុងពិធីសំណេះសំណាលជាមួយបងប្រជាពលរដ្ឋ និងស្ត្រីងាយរងគ្រោះ ចំនួនប្រមាណ១០០គ្រួសារនៅស្រុកមោងឫស្សីខេត្តបាត់ដំបង។

ចូលរួមក្នុងពិធីចុះសួរសុខទុក្ខនេះដែរមានថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ លោក លោកស្រីប្រធានគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារខេត្ត (ដែលហៅកាត់ថា គ.ក.ស.ក) លោកស្រីអភិបាលរងខេត្ត លោកលោកស្រីប្រធាន អនុប្រធានមន្ទីរ អង្គភាព តំណាងអង្គការUNFPA លោកអភិបាលស្រុក មេឃុំ និងអ្នកពាក់ព័ន្ធមួយចំនួនទៀត។

នៅក្នុងពិធីសំណេះសំណាលជាមួយបងប្អូនប្រជាពលរដ្ឋ និងស្ត្រីងាយរងគ្រោះប្រមាណ ១០០គ្រួសារ លោកស្រីជូ ប៊ុនអេង ក៏បាននាំយកអំណោយផ្ទាល់ខ្លួននិងអង្គការUNFPA ចែកជូនបងប្អូនប្រជាពលរដ្ឋក្រីក្រ និងស្ត្រីងាយគ្រោះ ក្នុងមួយគ្រួសារទទួលបាន អង្ករ ១៥គីឡូក្រាម គ្រឿងឧបភោគ បរិភោគ និងសម្ភារៈប្រើប្រាស់ចាំបាច់មួយចំនួន។

សូមជម្រាបថាបន្ទាប់ពិធីសំណេះសំណាលនេះលោកស្រីរដ្ឋលេខាធិការ និងគណៈប្រតិភូ ក៏បានបន្តដំណើរចុះសួរសុខទុក្ខបងប្អូនប្រជាពលរដ្ឋ ដែលកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យបង្អែកស្រុកមោឫស្សី និងបានជូនកញ្ចប់ឃីតដល់អ្នកជម្ងឺដែលកំពុងសម្រាក និងសម្រាលកូនក្នុងមន្ទីរពេទ្យនោះផងដែរ។

ក្នុងឱកាសនោះដែរអង្គការUNFPAក៏បានឧបត្ថម្ភកញ្ចប់ឃីតដល់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារខេត្ត (ដែលហៅកាត់ថា គ.ក.ស.) ចំនួន ២០០ ឃីត សម្រាប់ចែកចាយបន្តដល់បងប្អូនប្រជាពលរដ្ឋគ្រួសារក្រីក្រ និងជាកិច្ចការមនុស្សធម៌នៅមូលដ្ឋានក្នុងខេត្តផងដែរ៕/B

## អភិបាលស្រុកតាំងគោក ខេត្តកំពង់ធំ ចុះសួរសុខទុក្ខពលករមកពីក្រៅប្រទេស និងផ្សព្វផ្សាយជំងឺកូវីដ១៩

http://www.freshnewsasia.com/ 2020-06-05

**(កំពង់ធំ)៖** លោក ហាក់ ម៉ុងហួត អភិបាលស្រុកតាំងគោក ខេត្តកំពង់ធំ នារសៀលថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២០ អមដំណើរដោយលោកស្រីអភិបាលរងស្រុក និងក្រុមការងារ បានចុះសួរសុខទុក្ខពលករមកពីក្រៅប្រទេស និងផ្សព្វផ្សាយអំពីជំងឺកូវីដ១៩ នៅក្នុងឃុំទ្រៀល ឃុំពង្រ ឃុំអណ្ដូងពោធិ៍ ចំនួន៧នាក់ ស្រុកតាំងគោក ខេត្តកំពង់ធំ ព្រមទាំងបានឧបត្ថម្ភ ដល់គ្រួសារទីទ័លក្រផងដែរ។

លោក ហាក់ ម៉ុងហួត បានថ្លែងអំណរគុណដល់អាជ្ញាធរមូលដ្ឋាន និងមន្ត្រីដែលពាក់ព័ន្ធទាំងអស់ ដែលបានផ្សព្វផ្សាយ អំពីវិធានការការពារ ទប់ស្កាត់ការរីករាលដាល នៃជំងឺកូវីដ១៩ របស់រាជរដ្ឋាភិបាល និងគណៈកម្មការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩។ លោកបន្តថា សុខទុក្ខប្រជាពលរដ្ឋជាសុខទុក្ខ របស់ថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់។ លោកអភិបាលស្រុក ក៏បានផ្ដាំផ្ញើដល់ពលករដែលមកពីក្រៅប្រទេសត្រូវដាក់ខ្លួននៅដោយឡែកពីគេ ហើយត្រូវសម្អាត និងរក្សាអនាម័យជាប្រចាំតាមការណែនាំរបស់ក្រុមការងារថ្នាក់ភូមិ ឃុំ ស្រុកនិងក្រសួងសុខាភិបាល ដោយលាងដៃជាមួយនឹងសាប៊ូឱ្យបានញឹកញាប់ អាល់កុល និងដែលលាងដៃ មុនពេល និងក្រោយពេលចាប់កាន់របស់ផ្សេងៗ ព្រមទាំងពាក់ម៉ាស់ ឬក្រម៉ានៅពេលធ្វើដំណើរទៅទីសាធារណៈ ឬទៅផ្សារ ដើម្បីទប់ស្កាត់ការឆ្លងរោគពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត។ លោកក៏បានអំពាវនាវ និងសំណូមពរដល់បងប្អូនពលករសូមចូលរួមអនុវត្តទាំងអស់គ្នា ដើម្បីសេចក្ដីសុខ និងសុវត្ថិភាពសុខភាពផ្ទាល់ខ្លួនផង និងដើម្បីសុវត្ថិភាពសុខភាព សម្រាប់អ្នកដទៃ និងសហគមន៍ទាំងមូលផង នៅក្នុងកាលៈទេសៈ ដែលប្រទេសជាតិកំពុងប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩ ប្រសិនបើមានបញ្ហា ឬសង្ស័យលើសុខភាពមិនប្រក្រតីសូមរាយការណ៍ដល់អាជ្ញាធរ ឬទៅមណ្ឌលសុខភាព។

ជាមួយក្នុងការចុះផ្សព្វផ្សាយពីជំងឺកូវីដ១៩ ដោយរស់នៅមិនមានការប្រមូលផ្ដុំគ្នានៅឡើយ ក្នុងនោះផងដែរ អភិបាលស្រុកបានជំរុញឲ្យមាតាបិតាបង្រៀនកូននៅ តាមផ្ទះជាពិសេសក្រសួងអប់រំបានដាក់ចេញនូវការបង្រៀនតាម online ចាប់ពីថ្នាក់ទី១ដល់ថ្នាក់ទី១២ ទៅតាមដែលអាចធ្វើបាន៕

## ក្រសួងសង្គមកិច្ច ប្រជុំរកដំណោះស្រាយរួម ជួយជនរងគ្រោះដោយអំពើជួញដូរ និងអាជីវកម្មផ្លូវភេទក្នុងកំឡុងនៃការរាតត្បាតជំងឺកូវីដ១៩

http://www.freshnewsasia.com/ 2020-06-05

**(ភ្នំពេញ)៖** លោក ញ៉ឹក វណ្ណារ៉ា រដ្ឋលេខាធិការតំណាងលោក វង សូត រដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា និងជាប្រធានក្រុមការងារការពារជនរងគ្រោះ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ បានដឹកនាំកិច្ចប្រជុំស្ដីពីការពង្រឹងកិច្ចសហប្រតិបត្តិការ និងពិភាក្សាការងារក្នុងអំឡុងពេល COVID -19 នាព្រឹកថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២០ នាទីស្ដីការក្រសួងសង្គមកិច្ច។

កិច្ចប្រជុំនាពេលនេះ ធ្វើឡើងក្នុងគោលបំណងរកដំណោះស្រាយរួមគ្នា ជួយដល់ជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ការគេងប្រវ័ញ្ច គ្រប់ទម្រង់ផ្សេងៗ ទៀត នៃការរំលោភបំពាន ក្នុងកំឡុងពេលមេរោគរាតត្បាតកូវីដ១៩ ដើម្បីទប់ស្កាត់ការរីករាលដាលជំងឺដ៏កាចសហាវនេះ។

ថ្លែងនៅក្នុងកិច្ចប្រជុំនោះ លោក ញ៉ឹក វណ្ណារ៉ា បានលើកឡើងថា ការប្រជុំជាមួយភាគីពាកព័ន្ធនាពេលនេះ គឺដើម្បីរកដំណោះស្រាយសមស្របមួយចំនួន ក្នុងការជួយដល់ ជនរងគ្រោះដោយអំពើជួញដូរ និងអាជីវកម្មផ្លូវភេទក្នុងកំឡុងនៃការរាតត្បាត ជំងឺកូវីដ១៩។ លោកបានបន្តថា ក្នុងខណៈពេលនេះ យើងត្រូវមានវិធានការទប់ស្កាត់ឲ្យ

បានល្អបំផុត ដើម្បីជួយកុំឲ្យជនរងគ្រោះ ជួបការលំបាក ដែលប្រឈមនឹងការឆ្លងជំងឺដ៏កាចសាហាវមួយនេះ ដោយប្រការណាមួយ។ **លោក ញ៉ឹក វណ្ណារ៉ា បានបន្ថែមថា ការប្រជុំនាថ្ងៃនេះ បានពិភាក្សាទៅលើចំណុចសំខាន់ៗមួយចំនួនរួមមាន៖**

*__ទី១៖__ ការផ្លាស់ប្តូរព័ត៌មានពីជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ក្នុងគោលបំណងធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម។

*__ទី២៖__ ការសម្របសម្រួលក្នុងការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម។

*__ទី៣៖__ ការសម្របសម្រួលក្នុងកិច្ចខិតខំប្រឹងប្រែង ផ្តល់ជំនួយផ្នែកច្បាប់ដល់ជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស

*__ទី៤៖__ ការតាមដានត្រួតពិនិត្យ និងការប៉ាន់ប្រមាណលទ្ធផល នៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម៕

## អភិបាលខេត្តថា ថៃបដិសេធបើកច្រកព្រំដែន ថ្វីបើកម្ពុជាព្យាយាមចរចា

https://www.postkhmer.com/ ឡុង គីមម៉ារីតា | Publication date 05 June 2020 | 09:16 ICT

**បន្ទាយមានជ័យៈ** លោក អ៊ុំ រាត្រី អភិបាលខេត្តបន្ទាយមានជ័យបានអះអាងថា រដ្ឋបាលខេត្តបានព្យាយាមចរចាជាមួយភាគីថៃអស់ហើយ ដើម្បីឲ្យកម្មករអូសរទេះ និងអាជីវករកម្ពុជាអាចចេញចូលតាមច្រកព្រំដែនបាន ប៉ុន្តែសំណើនេះ ត្រូវថៃបដិសេធក្រោមហេតុផលជំងឺកូវីដ ១៩ ខណៈស្ទើររាល់ថ្ងៃមានពលរដ្ឋខ្មែរពី ១០ ទៅ ២០ នាក់បានលួចឆ្លងដែនចូលប្រទេសនេះ។ ការអះអាងយ៉ាងដូច្នេះបានធ្វើឡើងនៅក្នុងសន្និសីទសារព័ត៌មានស្តីពី «វឌ្ឍនភាព និងទិសដៅការងារបន្តរបស់រដ្ឋបាលខេត្តបន្ទាយមានជ័យ» រៀបចំដោយអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាលនៅទីស្តីការគណៈរដ្ឋមន្ត្រីដែលមានអ្នកចូលរួមជិត ៤០ នាក់។

លោកបានថ្លែងក្នុងឱកាសនោះថា៖ «ខេត្តបន្ទាយមានជ័យយើង ប្លែកពីគេទូទាំងប្រទេស ហើយបញ្ហាប្រឈមគឺកម្មករអូសរទេះនេះឯង ព្រោះពេលច្រកប៉ោយប៉ែតបើកធម្មតា គាត់ដឹកទំនិញ គាត់យកទៅដឹកជាមួយក្រុមកម្មករអូសរទេះ ដោយមិនសូវប្រើប្រាស់តាមរថយន្តទេ។ ការធ្វើដូច្នេះក៏មានផលប្រយោជន៍ដែរ គឺបានផលប្រយោជន៍ទៅបងប្អូនកម្មករដែលអូសរទេះនោះ ពួកគាត់ជាកម្មករក្រីក្រ និងពិការដែរ»។ លោកបន្តថា ដោយសារមកទល់ពេលនេះ ប្រទេសថៃនៅតែបិទប្រទេសរបស់គេ ដោយសារបញ្ហាកូវីដ ១៩ និងមិនអនុញ្ញាតឲ្យពលរដ្ឋ ឬជនបរទេស ចេញចូលប្រទេសគេទេ បើទោះអាជ្ញាធរកម្ពុជាបានព្យាយាមចរចាយ៉ាងណា ក៏ថៃមិនព្រមដែរ។ លោកបញ្ជាក់ថា៖ «ខ្ញុំនិយាយឲ្យចំ ខ្ញុំបានព្យាយាមទៅប្រជុំផ្ទាល់ជាមួយអភិបាលខេត្តស្រះកែវ និងសមត្ថកិច្ចពាក់ព័ន្ធដើម្បីសំណូមពរថា ពីមុនរទេះ ១ មានគ្នាក៏ ១០ នាក់ដែរ ដើម្បីរុញរទេះនេះទៅបាន ប៉ុន្តែពេលនេះរទេះ ១ មានគ្នាតែ ៤ នាក់ ក៏គេមិនអនុញ្ញាតដែរ ដោយសារតែមនុស្សចូលប្រទេសគេ។ នេះគឺជាការហាមឃាត់ពីខាងភាគីថៃ យើងក្នុងនាមអាជ្ញាធរ ព្យាយាមខំជួយណាស់ ប៉ុន្តែគេមិនអនុញ្ញាតយើងតែប៉ុណ្ណោះ»។

ពាក់ព័ន្ធនឹងការឆ្លងដែនចេញចូលវិញលោក អ៊ុំ រាត្រី បានអះអាងថា បច្ចុប្បន្ននៅតែមានពលរដ្ឋខ្មែរត្រឡប់ពីថៃចន្លោះពី ២០០ នាក់ ទៅ ៣០០ នាក់ក្នុង ១ ថ្ងៃ និងមានពលរដ្ឋកម្ពុជាចន្លោះពី ១០ ទៅ ២០ នាក់ នៅតែព្យាយាមលួចឆ្លងដែនខុសច្បាប់ទៅថៃវិញតាមច្រករបៀងតូចៗ ខណៈសកម្មភាពនេះត្រូវបានហាមឃាត់ និងត្រូវថៃចាប់បញ្ជូនត្រឡប់មកវិញស្ទើររាល់ថ្ងៃ។ លោកថា៖ «១៥៣ គីឡូម៉ែត្រ (ព្រំជាប់ប្រទេសថៃ ក្នុងខេត្តបន្ទាយមានជ័យ) បើខ្ញុំមិនច្រឡំទេ គឺដូចជាមានជាង ៥០ ច្រក (របៀង)។ ប៉ុន្តែច្រកទាំងអស់នេះគឺមិនអនុញ្ញាតឲ្យមនុស្សចេញ-ចូលទេ គឺសម្រាប់សមត្ថកិច្ច គាត់ត្រួតពិនិត្យ និងឈរជើងដែលកន្លែងខ្លះមាននគរបាលព្រំដែន កន្លែងខ្លះកងទ័ពគាត់ឈរជើង ហើយមិនមែនមានន័យថា ការឈរជើងនោះ ប្រជាពលរដ្ឋអាចចេញចូល (ឆ្លងដែន) បានទេ»។ ការប្រកាសបិទច្រក និងពន្យារពេលបិទប្រទេសរបស់រដ្ឋាភិបាលថៃបានធ្វើឲ្យក្រុមកម្មករអូសរទេះរាប់រយនាក់ និងក្រុមអាជីវករមួយចំនួនផងបានប្រកាសធ្វើបាតុកម្មដើម្បីទាមទារឱ្យអាជ្ញាធរខ្មែរអន្តរាគមន៍ទៅភាគីថៃ សុំបើកទ្វារព្រំដែនឡើងវិញ ប៉ុន្តែគម្រោងនេះត្រូវបានអាជ្ញាធរខេត្តបន្ទាយមានជ័យហាមឃាត់ដោយមានទាំងកម្លាំងចាំរាំងផង។

លោក ឱន ពុទ្ធី ប្រធានសមាគមពង្រឹងសេដ្ឋកិច្ចក្រៅប្រព័ន្ធប្រចាំនៅច្រកប៉ោយប៉ែតបានប្រាប់ភ្នំពេញប៉ុស្តិ៍ពីម្សិលមិញថាប្រសិនបើអាជ្ញាធរកម្ពុជាពិតជាបានលើកពីកង្វល់របស់កម្មករទៅកាន់អាជ្ញាធរថៃមែនគឺជារឿងល្អ។ប៉ុន្តែលោកមិនប្រាកដថាអាជ្ញាធរកម្ពុជាពិតជាបានលើបញ្ហានេះទៅចរចាជាមួយថៃនោះទេ ព្រោះថាក្នុងរបាយការណ៍ភាគីថៃមិនមានបញ្ជាក់ពីការទាមទារពីកម្ពុជាក្នុងបញ្ហានេះទេ។ លោកបានបន្តថា៖ «ក្នុងអំឡុងពេលនេះ កម្មករអូសរទេះ និងក្រុមអាជីវកដែលធ្វើអាយុជីវិត និងរបស់ទ្រព្យនៅក្នុងទឹកដីថៃ មិនត្រឹមតែប្រឈមនឹងការឆ្លងជំងឺកូវីដ ១៩ ប៉ុណ្ណោះទេ ពួកគាត់កំពុងជួបប្រទះបញ្ហាខ្វះខាតជីវភាពខ្លាំង ព្រោះតែមិនអាចស្វែងចំណូល ហើយប្រឈមនឹងបំណុលថែមទៀត»។ បន្ថែមពីនេះលោក ពុទ្ធិ បានសំណូមពរឲ្យរដ្ឋាភិបាលកម្ពុជាគួរហាមរថយន្តដឹកទំនិញរបស់ថៃឲ្យតឹងរ៉ឹងជាងនេះ ខណៈទំនិញកម្ពុជាដឹកចូលទៅប្រទេសថៃ មានភាពរឹតត្បិតខ្លាំង ប៉ុន្តែពេលភាគីថៃដឹកមកកម្ពុជាវិញ ហាក់មិនមានការរឹតត្បិតនោះទេ៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរចំនួន ០៥នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងបទល្មើសឆ្លងដែនខុសច្បាប់

https://www.facebook.com/GDIOfficial 04-06-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម នាវេលាម៉ោង ១៦និង០០នាទី ថ្ងៃទី៤ ខែមិថុនា ឆ្នាំ ២០២០ បានទទួលពលករខ្មែរចំនួន ០៥នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងបទល្មើសឆ្លងដែនខុសច្បាប់។ នគរបាលអន្តោប្រវេសន៍ប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរទាំង ០៥នាក់នេះ មាន ១-ឈ្មោះ ឡៀប ស្រីនេន ភេទស្រី អាយុ ២៧ ឆ្នាំ មានទីលំនៅភូមិបាយាប ឃុំសៀងឃ្វាន ស្រុកកំចាយមា ខេត្តព្រៃវែង, ២-ឈ្មោះ រឿន ភារាក់ ភេទប្រុស អាយុ ២៦ឆ្នាំ មានទីលំនៅភមិបាយាប ឃុំសៀងឃ្វាន ស្រុក កំចាយមា ខេត្តព្រៃវែង, ៣-ឈ្មោះ ម៉ក់ ដា ភេទប្រុស អាយុ ២០ឆ្នាំ មានទីលំនៅស្រុកកោះសូទិន ខេត្តត្បូងឃ្មុំ, ៤-ឈ្មោះ គីម ស្រី ភេទស្រី អាយុ ៤៤ឆ្នាំ មានទីលំនៅភូមិដំណាក់ត្របែក ឃុំឫស្សីស្រុក ស្រុកកំពង់តកទ្រាច ខេត្ត កំពត និង៥-ឈ្មោះ សុខ ភក្តី ភេទប្រុស អាយុ ២៦ឆ្នាំ មានទីលំនៅភូមិទី១ ឃុំដងទង់ ស្រុកខេមរភូមិន្ទ ខេត្តកោះកុងក៏មានចូលរួមត្រួតពិនិត្យសុខភាព ពីមន្ត្រីចត្តាឡីស័កប្រចាំមាត់ច្រកផងដែល។ ដោយឡែកខាងភាគីថៃ នៅតែបន្តបិទច្រក មិនឲ្យអ្នកដំណើរ ចេញ-ចូល ចំណែកទំនិញទទួលបានការអនុញ្ញត និងអ្នកបើកបររថយន្តចំនួន ០២នាក់ បានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគីកម្ពុជា-ថៃ បានយ៉ាងត្រឹមត្រូវ៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៤២នាក់

https://www.facebook.com/GDIOfficial 04-06-2020

នៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៤២នាក់ ស្រី ២១នាក់៕

## ពលករខ្មែរ៩នាក់ ត្រូវអាជ្ញាធរថៃចាប់ខ្លួនគ្រាដែលលួចឆ្លងដែនខុសច្បាប់

http://mekong-post.com/ ដោយ មេគង្គ ប៉ុស្តិ៍ ចេញផ្សាយ ថ្ងៃទី 5 June, 2020

**ស្រះកែវ ៖** សមត្ថកិច្ចថៃ បានចាប់ខ្លួនពលករខ្មែរឆ្លងដែនខុសច្បាប់ ដោយសារមេខ្យល់នៅខេត្តស្រះកែវ ជាប់ព្រំដែនកម្ពុជា។ នេះយោងតាមការចុះផ្សាយរបស់គេហទំព័រក្នុងស្រុករបស់ថៃ ចេញផ្សាយនៅថ្ងៃទី៣ ខែមិថុនា ឆ្នាំ ២០២០ នេះ។

សារព័ត៌មានថៃ រាយការណ៍ថា នៅស្រុក តាបព្រះយ៉ា ខេត្តស្រះកែវ កងកម្លាំងទាហានឈុតខ្មៅ សហការជាមួយតម្រួតការពារព្រំដែនទី១២ តម្រួតអន្តោប្រវេសន៍ខេត្តស្រះកែវ រួមគ្នាល្បាតត្រួតពិនិត្យក្នុងតំបន់ទទួលខុសត្រូវ ដើម្បីទប់ស្កាត់ បង្ក្រាប ការលបលួចចូលប្រទេសរបស់ពលករបរទេស នៅក្នុងភូមិសាស្ត្រស្រុក នឹងទង្វើល្មើសច្បាប់តាមប្រកាសច្បាប់គ្រាអាសន្នថា ដោយបារម្ភនឹងការឆ្លងខូវីត-19 សមត្ថកិច្ចប្រតិបត្តិការរាយការណ៍ថា នៅវេលាម៉ោង១៥,៣០នាទី ថ្ងៃទី២ ខែមិថុនា ២០២០កន្លងមក សមត្ថកិច្ចបានចាប់ខ្លួនពលករខ្មែរចំនួន៩នាក់ ក្នុងនោះប្រុស៦នាក់ ស្រី២នាក់ អ្នកបើករថយន្តម្នាក់ ក៏បាននាំខ្លួនទៅសាកសួរ ទើបដឹងថា ក្រុមពលករខាងលើ មានឈ្មោះ ចៀក សាក់រើន អាយុ៣២ឆ្នាំ ជាមេខ្យល់នាំផ្លូវ នៅលើដងផ្លូវហ៊្វេរ ហ ឃុំហ៊្វេរហ ស្រុកទីរួមខេត្ត ឈុនបុរី ប្រើរថយន្តបិកអាប់ ម៉ាកអុី ស៊ូស៊ុ ព៌ណស ពាក់ស្លាកលេខកឈ-6785 ស្រះកែវ ទៅទទួលពលករនៅឯវត្តណង ចាន់ ដោយមករង់ចាំទទួលពលករនៅវត្តខាងលើ តាំងពីម៉ោង០៣,៣០នាទី ណាត់ទទួលឡើងរថយន្តវេលាម៉ោង ០៤,៣០នាទី ។

សូមបញ្ជាក់ថា ក្រោយចាប់ខ្លួនក្រុមពលករដែលជិះរថយន្តដល់ប៉ុស្តិ៍ត្រួតពិនិត្យ ក្នុងភូមិ សុខ សំរាន ឃុំណង វែង ស្រុកគោកឃ្សូង ខេត្តស្រះកែវ ត្រូវសមត្ថកិច្ចចាប់ខ្លួនពីបទនាំពលករបរទេស ព្រមទាំងទទួលសារភាពថាទទួលប្រាក់ឈ្នួលក្នុងម្នាក់២,០០០បាត ដែលពលករទាំងអស់រួមមានឈ្មោះ

១-សេត សេង ប្រុស អាយុ២៩ឆ្នាំ

២-ធឿន ថន ប្រុស អាយុ៣១ឆ្នាំ អ្នកទាំង២ទៅធ្វើការនៅខេត្តឈុន បុរី។

៣-ចន ថៅ ប្រុស អាយុ២២ឆ្នាំ ជាអ្នកប្រដាល់ សាក់ ម៉េត អ្នកប្រដាល់ថៃ ប្រើឈ្មោះថា ចាន់ ចាវ

៤- លុន អុក ប្រុស អាយុ២៧ឆ្នាំ

៥- វុន សីហា ប្រុស អាយុ១៨ឆ្នាំ

៦-ឡុយ អ៊ឹម ប្រុស អាយុ២៩ឆ្នាំ

៧- វុន ចន្ថា ស្រី អាយុ២០ឆ្នាំ

៨-អ៊ុក ឡុត ស្រី អាយុ១៩ឆ្នាំ អ្នកអស់គ្នាទៅធ្វើការកន្លែងសាងសង់ នៅរ៉ាំង ស៊ីត ខេត្តប៉ះធុម ថានី ជនត្រូវចោទទទួលសារភាពថា នឹងត្រូវឲ្យលុយថ្លៃឈ្នួលក្នុងម្នាក់២,០០០បាតទៀតទើបនាំទៅដល់គោលដៅ។

ពាក់ពន្ធ័នឹងពលករខ្មែរដែលលួចចូលប្រទេសថៃដោយខុសច្បាប់ខាងលើ មានការលើកឡើងថា សមត្ថកិច្ចខ្មែរឈរជើងតាមបន្ទាត់ព្រំដែនគិតតែពីបើកផ្លូវឲ្យចូល រីឯសមត្ថកិច្ចថៃគិតតែពីចាប់ៗ ស្ទើររៀងរាល់ថ្ងៃ៕

# ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០

## លោកជំទាវ ជូ ប៊ុនអេង ផ្តាំផ្ញើដល់ប្រជាពលរដ្ឋកុំភ្លេចធ្វើអនាម័យ និងបន្តប្រយុទ្ធប្រឆាំងនឹងមេរោគកូវីដ១៩ ដែលកំពុងតែរាតត្បាត

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី 5 ខែ មិថុនា ឆ្នាំ 2020

**កំពង់ឆ្នាំង៖** លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានក្រុងកំពង់ឆ្នាំង បាននាំយកអំណោយ ផ្តល់ជូនប្រជាពលរដ្ឋនៅក្រុងកំពង់ឆ្នាំង មកពី៤សង្កាត់ រួមមាន៖

សង្កាត់ប្អេរ សង្កាត់ខ្សាម សង្កាត់ផ្សារឆ្នាំង និងសង្កាត់កំពង់ឆ្នាំង សរុបចំនួន៥២គ្រួសារ ដែលជាចាស់ជរាឥតទីពឹង គ្រួសារងាយរងគ្រោះ។ ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម លោកជំទាវ ជាសមាជិក ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានក្រុងកំពង់ឆ្នាំង លោកស្រី ប៊ិន សុភី អភិបាល រងខេត្ត លោក លោកស្រីគណៈកម្មាធិការ គ.ខ.ប.ជ ខេត្ត រួមនិងប្រធានមូនិធិសប្បុរសជននានា ប្រារព្ធពិធីនៅភូមិទី៤ សង្កាត់ខ្សាម នាព្រឹកថ្ងៃសុក្រ ១៥កើត ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២០។

មានមតិសំណេះសំណាល និងសួរសុខទុក្ខដល់បងប្អូនប្រជាពលរដ្ឋក្នុងឱកាសនោះ លោកជំទាវ ក៏បានបញ្ជាក់ជូនពីការវិវត្តរបស់ជំងឺកូវីដ១៩ តាមការប្រកាសរបស់ក្រសួងសុខាភិបាល និងត្រូវប្រុងប្រយ័ត្នខ្ពស់បន្ថែមទៀតក្នុងការការពារសុខភាព និងធ្វើអនាម័យតាមការណែនាំ របស់លោកគ្រូពេទ្យ និងការផ្សព្វផ្សាយរបស់ក្រសួងសុខាភិបាលជាប់ជានិច្ច ពីព្រោះជំងឺឆ្លងកូវីដ១៩ មិនទាន់រលាយ បាត់ពីផែនដីនៅឡើយទេ ហើយមានរលកទី២ជាបន្តទៀត ហើយជំងឺនេះកាចសាហាវណាស់ វាអាចឆ្លងពីមនុស្សម្នាក់ ទៅមនុស្សម្នាក់ និងអាចធ្វើមនុស្សបាត់បង់ជីវិតភ្លាមៗផងដែរ។ លោកជំទាវបានអំពាវនាវឱ្យប្រជាពលរដ្ឋទាំងអស់គ្នាត្រូវបង្កើនការផលិតផ្នែកកសិកម្ម តាមរយៈ ការដាំដុះ ការចិញ្ចឹមសត្វជាដើម ចំណែកឯអាជ្ញាធរត្រូវតែពង្រឹងឱ្យមានប្រសិទ្ធិភាពនូវ ភូមិ-ឃុំមានសុវត្ថិភាព និងចូលរួមគោរពច្បាប់ចរាចរណ៍ទាំងអស់គ្នា។

ក្នុងឱកាសនោះលោកជំទាវក៏បាន កោតសសើរដល់អាជ្ញាធរគ្រប់លំដាប់ថ្នាក់ក្នុងក្រុងកំពង់ឆ្នាំង ដែលបានចូលរួមយ៉ាងសកម្មក្នុងការទប់ស្កាត់ការឆ្លងរីករាលដាលនៃជម្ងឺកូវីដ១៩ ជាពិសេស ការធ្វើចត្តាឡីស័កឱ្យបានហ្មត់ចត់ចំពោះបងប្អូនដែលធ្វើការចំណាកស្រុក នៅពេលដែលត្រលប់ចូលមកស្រុកកំណើតវិញ។ អំណោយដែលត្រូវផ្តល់ជូនប្រជាពលរដ្ឋទាំង៥២គ្រួសារដោយក្នុងមួយគ្រួសារៗ ទទួលបានៈ អង្ករ១០គីឡូក្រាម អំបិល១កញ្ចប់ ស្ករស ១ កញ្ចប់ សាប៊ូ១ដុំ ៕

## មេប៉ុស្តិ៍ក្បាលស្ពាន ដឹកនាំកម្លាំងចុះល្បាតតាមខ្សែរបន្ទាត់ព្រំដែន ដើម្បីទប់ស្កាត់ពលករលួចឆ្លងដែន នាពេលយប់

http://www.matimohachunnews.com/ June 05, 2020

ព្រំដែនកម្ពុជាថៃ៖ ថ្ងៃព្រហស្បតិ៍ ១៤កើត ខែជេស្ឋ ឆ្នាំជូត ទោស័ក ពុទ្ធសករាជ ២៥៦៤ ត្រូវនឹងយប់ថ្ងៃទី ៤ ខែមិថុនា ឆ្នាំ២០២០ លោក សែម សាមឿន មេប៉ុស្តិ៍ក្បាលស្ពាននៃវរៈព្រំដែនគោកលេខ ៨៩១ដឹកនាំកម្លាំងប៉ុស្តិ៍ ចំនួន ៤រូប ចុះល្បាតតាមចំណុចគោលដៅនៃប៉ុស្តិ៍ក្បាលស្ពាន ហើយក្នុងការចុះល្បាតនេះ សមត្ថកិច្ចបានរកឃើញទូកជ័រពណ៌ក្រហមមួយ ដែលចងនៅនឹងមាត់អូរព្រំដែន។ ហើយនៅពេលនោះលោក មេប៉ុស្តិ៍ បានឱ្យកម្លាំងអូសឡើងមកលើគោក។

ប្រភពពីសមត្ថកិច្ចបានឱ្យដឹងថា កាលពីល្ងាចម៉ោងប្រមាណ ៨និង ៣០នាទី ដោយលោកមេប៉ុស្តិ៍បានទទួលសេចក្តីរាយការណ៍ពីប្រជាពលរដ្ឋដែលរស់នៅតាមមាត់អូរព្រំដែនឱ្យដឹងថា មានមេខ្យល់ដែលបំរ៉ុងនាំមនុស្សឆ្លងដែនចេញតាមអូរព្រំដែនចំនួនជាង១០នាក់ ដែលត្រៀមចេញ នៅចំណុចកន្លែងដែល សមត្ថកិច្ចរឹបអូសទូកនោះ តែដោយមេខ្យល់ និងពលករទាំងអស់នោះដឹងខ្លួនជាមុន ក៏ត្រូវបាននាំគ្នាបិទសាប៊ូប្រូចបាត់អស់រលីងនៅសល់តែទូក។

បច្ចុប្បន្ន សមត្ថកិច្ចបានរឹបអូសទូកយកទៅរក្សាទុកនៅប៉ុស្តិ៍ក្បាលស្ពាន នៃវីរៈព្រំដែន គោក៨៩១ ស្ថិតក្នុងភូមិក្បាលកោះសង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដើម្បីសួររកម្ចាស់ទូក៕

## សូមប្រជាពលរដ្ឋកុំចាញ់បោក ការឃោសនាអូសទាញរបស់ក្រុមមេខ្យល់ក្នុងការឆ្លងដែន ដោយខុសច្បាប់

http://www.matimohachunnews.com/ June 06, 2020

ខេត្តបាត់ដំបង៖ នៅក្នុងអំឡុងពេលដែលស្ថានភាពនៃការគំរាមកំហែងដោយករណីCovid-19 នៅតែបន្តមានជារៀងរាល់ថ្ងៃ រីឯការធ្វើដំណើរវិលចូលមកក្នុងប្រទេសវិញរបស់ប្រជាពលរដ្ឋយើងនៅតែមានជាបន្តបន្ទាប់នោះ បានកត់សម្គាល់ឃើញថា មានការលបលួចឆ្លងដែនដោយខុសច្បាប់ ទៅប្រកបមុខរបរ ឬបំពេញការងារផ្សេងៗ នៅក្នុងប្រទេសថៃ ពីសំណាក់ប្រជាពលរដ្ឋ ក៏នៅតែកើតមានជាបន្តបន្ទាប់ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងទប់ស្កាត់ពីសំណាក់អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធក្នុងមូលដ្ឋានយ៉ាងណាក៏ដោយ។

ជាក់ស្ដែងកាលពីរសៀលថ្ងៃទី ៥ ខែ មិថុនា ឆ្នាំ២០២០ វេលាម៉ោង១៣និង៤០នាទី កម្លាំងនគរបាលនៃអធិការដ្ឋាននគរបាលស្រុកសំពៅលូន ដែលមានលោកវរសេនីយ៍ឯក ពេជ្រ សារ៉ែន ជាអធិការនគរបាលស្រុក និងកម្លាំងនគរបាលវរសេនាតូចការពារព្រំដែនគោកលេខ៨១៧ ដែលមានលោកវរសេនីយ៍ឯក ប្រាក់ សាយ ជាមេបញ្ជាការវរៈ បានសហការណ៍ជាមួយកម្លាំងផ្នែកសឹករងស្រុកសំពៅលូន និងកម្លាំងទាហ៊ានឈុនតខ្មៅនៃព្រះរាជាណាចក្រថៃ ក្នុងកងអនុសេនាធំលេខ១៣០៣ ធ្វើការទប់ស្កាត់ទាន់ពេលវេលាចំពោះប្រជាពលរដ្ឋខ្មែរ ដែលបានលបលួចឆ្លងដែនចូលទៅក្នុងទឹកដីថៃ ដោយខុសច្បាប់ក្រោមការបំផុសឃោសនាអូសទាញដោយក្រុម (មេខ្យល់) ផងនោះមានចំនួន៣៨នាក់ ក្នុងនោះស្រីចំនួន១៧នាក់ ហើយត្រូវបានអាជ្ញាធរថៃឃាត់ខ្លួន និងបញ្ជូនមកឱ្យសមត្ថកិច្ចយើងវិញ។

ចំពោះបញ្ហានេះលោកវរសេនីយ៍ឯក ពេជ្រ សារ៉ែន អធិការនគរបាលស្រុកសំពៅលូន បានបញ្ជាក់ថា បន្ទាប់ពីទទួលបាននូវប្រជាពលរដ្ឋទាំង៣៨នាក់នេះ មន្ត្រីសុខាភិបាលដែលប្រចាំការនៅមូលដ្ឋានបានធ្វើការ តាមជំនាញ (ពិនិត្យសុខភាព) រួចរាល់ទើបប្រគល់មកឱ្យនគរបាលស្រុកធ្វើការសាកសួរបំភ្លឺ ហើយក្នុងចំណោមនោះមានក្រុម (មេខ្យល់)ចំនួន០៣នាក់ ដែលជាអ្នកដឹកនាំឱ្យមានការលួចឆ្លងដែនដោយខុសច្បាប់នេះដែលក្នុងចំនួន៣នាក់ ត្រូវបានសមត្ថកិច្ចនគរបាលកសាងសំណុំរឿងបញ្ជូនមកការិយាល័យជំនាញដើម្បីចាត់ការតាមនីតិវិធី រីឯប្រជាពលរដ្ឋចំនួន ៣៥នាក់ បានធ្វើការអប់រំណែនាំពួកគាត់កុំឱ្យចាញ់បោកការឃោសនា អូសទាញពីសំណាក់ក្រុមមេខ្យល់ទៀត រួចបានអនុញ្ញាតឱ្យពួកគាត់វិល ត្រឡប់ទៅលំនៅដ្ឋានវិញ។

ក្នុងនាមស្នងការនៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង សូមធ្វើការអំពាវនាវចំពោះប្រជាពលរដ្ឋយើង សូមកុំឱ្យចាញ់បោកការឃោសនាអូសទាញពីសំណាក់ក្រុម(មេខ្យល់) ដែលនាំបងប្អូនឱ្យចូលទៅក្នុងទឹកដីថៃដោយខុសច្បាប់នេះឱ្យសោះព្រោះនេះគឺជារឿងខុសច្បាប់ហើយក៏ប្រឈមខ្លាំងជាមួយនឹងការណីឆ្លង ជម្ងឺCovid-19ផងដែរ៕

## ពលរដ្ឋខ្មែរ បន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៤៩នាក់

https://www.facebook.com/GDIOfficial 07-06-2020

នៅថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិល

ចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៤៩នាក់ ស្រី ២២នាក់ និងពលរដ្ឋថៃចាកចេញមានចំនួន ០១នាក់ (មានឯកសារចេញពីស្ថានទូតថៃ និងលិខិតបញ្ជាក់សុខភាព)៕

## ពលរដ្ឋខ្មែរ បន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៩៨នាក់

https://www.facebook.com/GDIOfficial 06-06-2020

នៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ផង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៩៨នាក់ ស្រី ៤៧នាក់៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដាំ បានទទួលពលរដ្ឋខ្មែរ ០២នាក់ ពីសមត្ថកិច្ចថៃ ពីបទឆ្លងដែនខុសច្បាប់

https://www.facebook.com/GDIOfficial 05-06-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដាំ នាថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២០ បានទទួលពលរដ្ឋខ្មែរចំនួន ០២នាក់ ពីសមត្ថកិច្ចថៃ ពីបទឆ្លងដែនខុសច្បាប់ ទៅកាប់ឈើនៅប្រទេសថៃ ដែលចេញតាមច្រកអូរស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ៕

## ពលរដ្ឋខ្មែរ បន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៣នាក់

https://www.facebook.com/GDIOfficial 05-06-2020

នៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ផង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៣នាក់ ស្រី ០៥នាក់ និងពលរដ្ឋថៃបានចាកចេញមានចំនួន ០១នាក់ (មានឯកសារចេញពីស្ថានទូតថៃ និងលិខិតបញ្ជាក់សុខភាព)៕

## នគរបាលប៉ុស្តិ៍ក្រគរ និងប៉ុស្តិ៍អូរឫស្សី ចុះធ្វើការផ្សព្វផ្សាយអប់រំដល់ប្រជាពលរដ្ឋនៅតាមខ្នងផ្ទះ និងទីប្រជុំជន ឲ្យចូលរួមបង្ការទប់ស្កាត់បទល្មើស

https://cambodiapolice.com/policekh/ 10:31 am 8 មិថុនា 2020

**ក្រចេះ ៖** ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០នេះ កម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលក្រគរ និងប៉ុស្តិ៍អូរឫស្សី បានចុះធ្វើការផ្សព្វផ្សាយអប់រំដល់ប្រជាពលរដ្ឋនៅតាមខ្នងផ្ទះ និងទីប្រជុំជន ឲ្យចូលរួមបង្កាទប់ស្កាត់បទល្មើសផ្សេងៗនៅក្នុងភូមិសាស្ត្រសង្កាត់ក្រគរ និងសង្កាត់អូរឫស្សី ក្រុងក្រចេះ ខេត្តក្រចេះ។

ខ្លឹមសារផ្សព្វផ្សាយ ៖

-ការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ

-ផលប៉ះពាល់នៃគ្រឿងញៀន

-គ្រោះអគ្គិភ័យ

-ល្បែងស៊ីសងខុសច្បាប់

-ច្បាប់ចរាចរណ៍ផ្លូវគោក និងអនុក្រឹត្យលេខ ៣៩ថ្មី

-ផ្ទាំងរូបភាពបង្ការទប់ស្កាត់ជម្ងឺឆ្លងCovid ១៩

-គ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌមិនទាន់ផ្ទុះ

-គោលនយោបាយភូមិ-ឃុំ មានសុវត្ថិភាព

សរុបចំនួន ០២លើក ប្រជាពលរដ្ឋចូលរួមចំនួន ៧៨នាក់(ស្រី៣៧នាក់) និងចែកខិតប័ណ្ណបានចំនួន ៧៨សន្លឹក៕

## នគរបាលប៉ុស្តិ៍កោះព្រែង ចុះចែកអត្តសញ្ញាណប័ណ្ណ និងផ្សព្វផ្សាយភូមិ-ឃុំមានសុវត្ថិភាពនៅតាមខ្នងផ្ទះ

https://cambodiapolice.com/policekh/ 10:43 am 8 មិថុនា 2020

**ក្រចេះ ៖** ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០នេះ វេលាម៉ោង៨និង២៥នាទីព្រឹក កម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលកោះព្រែង រួមជាមួយលោកមេភូមិក្បាលកោះ ឃុំកោះព្រែង ស្រុកចិត្របុរី ខេត្តក្រចេះ បានចុះចែកជូនអត្តសញ្ញាណបណ្ណ័ និងផ្សព្វផ្សាយភូមិ-ឃុំមានសុវត្ថិភាព នៅតាមខ្នងផ្ទះក្នុងភូមិក្បាលកោះ ឃុំកោះព្រែង រួមមាន ៖

-ផ្សព្វផ្សាយសេចក្តីចូលរួមអំពាវនាវចូលរួមគាំទ្រយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់នៅកម្ពុជា

-ផ្សព្វផ្សាយរួមគ្នាបង្ការទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀន

-ចែកសារសម្រាប់អប់រំអំពីផលប៉ះពាល់គ្រោះថ្នាក់នៃគ្រឿងញៀន

-ផ្សព្វផ្សាយរួមគ្នាបង្ការទប់ស្កាត់បទល្មើសបញ្ហាចោរកម្មគ្រប់ប្រភេទ

-ផ្សព្វផ្សាយរួមគ្នាបង្ការការប្រើអំពើហឹង្សាទាក់ទងនិងយេនឌ័រ អំពើជួញដូរស្ត្រី និងកុមារ

-ផ្សព្វផ្សាយច្បាប់ចរាចរណ៍ផ្លូវគោក

-ផ្សព្វផ្សាយអំពីការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ

-អំពីគ្រោះអគ្គិភ័យ

ជាមួយគ្នានោះកម្លាំងប៉ុស្តិ៍បានធ្វើការផ្សព្វផ្សាយនូវលក្ខណៈសម្បត្តិទាំង៩យ៉ាង របស់គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព និងវិធីបង្ការទប់ស្កាត់វីរុសកូវីដ-១៩ ដែលមានប្រជាពលរដ្ឋចូលរួមសរុបចំនួន ១៥នាក់ ស្រី១០នាក់ ព្រមទាំងបានចែកខិតប័ណ្ណចំនួន ១៥សន្លឹក ផងដែរ៕

# អ័ស្តុតាងដ៏លើសលប់ ពិពណ៌នាពីការរំលោភបំពានលើកុមារ និងការបន្លំប្រាក់ជាច្រើនលានដុល្លារ ដោយអតីតអ្នកដឹកនាំ និងអតីតបុគ្គលិក ភូមិសុវណ្ណកុមារ

http://freshnewsasia.com/ 2020-06-07

**(ភ្នំពេញ)៖** កាលពីខែតុលា ឆ្នាំ២០១៩ សុវណ្ណកុមារ Sovann Komar, LLC ដែលជាអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិបានដាក់ពាក្យបណ្ដឹងព្រហ្មទណ្ឌជុំវិញការរំលោភបំពានលើកុមារធ្ងន់ធ្ងរដោយ លោក សុជា អរុណ និង អតីតបុគ្គលិកនៅភូមិកុមារសុវណ្ណកុមារ ក្នុងរាជធានីភ្នំពេញ។ ពាក្យបណ្ដឹងនេះរៀបរាប់លម្អិតអំពីការរំលោភបំពានធ្ងន់ធ្ងររួមមាន ការវាយដំលើរាងកាយ ការយាយីផ្លូវភេទ និងការធ្វើទារុណកម្ម។

ក្នុងរយៈពេល៨ខែចុងក្រោយនេះ លោក សុជា អរុណ អតីតនាយកប្រតិបត្តិនៃអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិបានប៉ុនប៉ងបង្វែរយុត្តិធម៌តាមរយៈយុទ្ធសាស្ត្រជាច្រើនប៉ុន្តែមិនកំណត់ការបញ្ចុះបញ្ចូលមន្ត្រីជាន់ខ្ពស់រាជរដ្ឋាភិបាល ឱ្យជ្រៀតជ្រែកក្នុងដំណើរការតុលាការប្រឆាំងនឹងលោក សុជា ដោយនាំយកករណីក្លែងបន្លំនៃអំពើប្លន់ប្រដាប់អាវុធប្រឆាំងនឹងមេធាវីសុវណ្ណកុមារ និងប្រើឧបាយកលគ្រប់គ្រងអនីតិជននៅភូមិសុវណ្ណកុមារ។ ទោះយ៉ាងណាក៏ដោយ បណ្ដឹងព្រហ្មទណ្ឌពីរ (២) ត្រូវបានបញ្ជូនទៅតុលាការដើម្បីប្ដឹងប្រឆាំងនឹង លោក សុជា និងបក្ខពួករបស់គាត់ គឺ៖ មួយករណីទាក់ទងនឹងការលួចបន្លំប្រាក់រាប់លានដុល្លារ និងមួយករណីទៀតទាក់ទងនឹងការរំលោភបំពានលើកុមារ។

កាលពីខែសីហា ឆ្នាំ២០១៩ លោក សុជា និងសមាជិកមួយចំនួននៃថ្នាក់គ្រប់គ្រងរបស់អង្គការសុវណ្ណកុមារត្រូវបានបញ្ឈប់ពីបទប្រព្រឹត្តនូវកំហុសដ៏ធ្ងន់ធ្ងរ រួមមានការរំលោភបំពានលើកុមារ ការធ្វើទារុណកម្ម និងការបង្អត់ចំណីអាហារដល់អនីតិជន។ ឪពុកម្ដាយចិញ្ចឹមមួយចំនួនក៏ត្រូវបានបញ្ឈប់ពីបទសមគំនិតជាមួយលោកសុជា។ ក្នុងខែមករាឆ្នាំនេះ អនីតិជនម្នាក់នៃសុវណ្ណកុមារ បានទទួលសារគំរាមពីគណនីហ្វេសប៊ុកក្លែងក្លាយជាច្រើនដែលត្រូវបានប៉ាន់ស្មានថា មានជាប់ទាក់ទងជាមួយ លោក សុជា។ សារទាំងនោះរួមមានការគំរាមកំហែងនៃការយាយីផ្លូវភេទ និងឃាតកម្ម ជាមួយនឹងការទាមទារឱ្យអនីតិជននោះគាំទ្រលោក សុជា ប្រឆាំងនឹងនីតិវិធីរបស់តុលាការដែលគាត់កំពុងប្រឈមមុខនាពេលបច្ចុប្បន្ន។ ហ្វេសប៊ុកបានរកឃើញគណនីមួយចំនួនដែលមានប្រភពចេញពីម្ចាស់តែមួយ ហើយបិទគណនីទាំងនោះចោល។ ថ្នាក់គ្រប់គ្រងថ្មីរបស់សុវណ្ណកុមារ បានសម្រេចចិត្តផ្លាស់ប្ដូរទីលំនៅរបស់អនីតិជននោះដើម្បីរក្សាសុវត្ថិភាពរបស់គាត់។ អនីតិជនដែលបានទទួលសារគំរាម គឺជាសាក្សីដ៏មានសក្ដានុពលក្នុងបណ្ដឹងព្រហ្មទណ្ឌ ដែលកំពុងប្រឆាំងនឹងលោក សុជា និងឪពុកម្ដាយចិញ្ចឹមដទៃទៀត។ សារគំរាមកំហែងដែលអនីតិជនបានទទួលបានជំរុញឱ្យមានការស្រាវជ្រាវទូរស័ព្ទដៃរបស់កុមារ នៅឯសុវណ្ណកុមារ។ លទ្ធផលបានបង្ហាញពីសាររំខានដែលមានជាប់ទាក់ទងនឹង លោក សុជា និងបក្ខពួក។

វាបានបង្ហាញឱ្យឃើញថា លោក សុជា បានស្នើសុំដល់កុមារមួយចំនួនរួមទាំងកូនចិញ្ចឹមផ្ទាល់ខ្លួនរបស់គាត់នៅក្នុងកម្មវិធីនេះផងដែរ ដើម្បីប្រមូលសវនកម្ម និងសម្ភារខុសច្បាប់ ដូចជាការប៉ុនប៉ងធ្វើអត្តឃាតក្លែងក្លាយដោយអនីតិជន ដើម្បីគាំទ្រការប៉ុនប៉ងបញ្ឈប់នីតិវិធីប្រឆាំងនឹងគាត់។ កូនស្រីចិញ្ចឹមរបស់ លោក សុជា ថែមទាំងបានផ្ដល់លេខទូរស័ព្ទ របស់មន្ត្រីរាជរដ្ឋាភិបាល និងទំនាក់ទំនងរបស់ប្រព័ន្ធផ្សព្វផ្សាយដើម្បីកុមារដទៃទៀតវ៉ា ដោយមានការព្រមានមិនឱ្យប្រាប់នរណាម្នាក់ថាលេខទូរស័ព្ទនោះ គឺបានមកពីឪពុកនាង។ លើសពីនេះទៀតនៅក្នុងទូរស័ព្ទទាំងនោះ គេបានរកឃើញនូវវីដេអូនៃព្រឹត្តិការណ៍ ដែលបានរៀបចំរួចប្រកបដោយភាពរំខាននៃកុមារប្រាំបួន (៩) នាក់ ដែលកុមារទាំងនោះផ្ដល់សក្ខីកម្មសរសើរលោក សុជា។ លោក សុជា បានបង្ហាញអាកប្បកិរិយាប្រកបដោយភាពមិនគោរពចំពោះសុវត្ថិភាពរបស់កុមារ ដែលកាលពីមុនស្ថិតក្រោមការមើលថែរបស់គាត់។ ក្នុងការប្រព្រឹត្តដ៏ឃោរឃៅមួយ ដែលត្រូវបានបញ្ជាក់ដោយសាក្សី កុមារពីរ (២) រូបត្រូវបានឃុំឃាំង ធ្វើទារុណកម្ម និងបង្អត់

អាហារប្រមាណជាបីសប្តាហ៍ នៅឯអង្គការក្រៅរាជរដ្ឋាភិបាលនោះ ហើយខំរក្សាជីវិតដោយទទួលទានផ្លែស្វាយពីមែកឈើក្បែរៗ និងអាហារពីឪពុកម្តាយចិញ្ចឹមផ្សេងទៀតដែលលួចយកឲ្យ។

នេះគឺជាការដាក់ទណ្ឌកម្មរបស់ លោក សុជា ចំពោះកុមារម្នាក់ក្នុងចំណោមកុមារដទៃដែលប្រឆាំងនឹងការប្រើប្រាស់មូលនិធិមិនត្រឹមត្រូវ និងភាពមិនសមរម្យក្នុងការមានទំនាក់ទំនងផ្លូវភេទជាមួយនឹងសមាជិកដទៃទៀតក្នុងភូមិ និងប្រតិកម្មរបស់គាត់ចំពោះការវាយធ្វើបាបយ៉ាងព្រៃផ្សៃលើកូនទាំងពីរដោយម្តាយចិញ្ចឹម (គាត់មានទំនាក់ទំនងជិតស្និទ្ធជាមួយ) និងស្វាមីរបស់គាត់។ ភាពបង្អត់អាហាររបស់កុមារទាំងពីរ បានបញ្ចប់នៅពេលឪពុកម្តាយចិញ្ចឹមជាច្រើននាក់នៅក្នុងភូមិបានអំពាវនាវឲ្យ លោក សុជា អនុញ្ញាតឱ្យពួកគេផ្តល់អាហារដល់កុមារទាំងនោះដែលលោកបានផ្តល់លក្ខខណ្ឌតម្រូវឲ្យឪពុកម្តាយចិញ្ចឹមចុះហត្ថលេខាលើលិខិតអនុញ្ញាតិជាផ្លូវការដែលផ្តល់ដោយលោក សុជា។ ឯកសារនេះដែលមានភ្ជាប់ជាមួយនឹងហត្ថលេខារបស់ លោក សុជា ត្រូវបានរកឃើញឡើងវិញ រួមជាមួយនឹងសៀវភៅបញ្ជីដែលត្រូវបានរក្សាទុកដោយចុងចោទម្នាក់គឺ អ្នកស្រី ជាតិ ចាន់ មរកត អតីតគណនេយ្យករដែលបានចងក្រងឯកសារ ស្តីពីថ្ងៃដែលកុមារមិនទទួលបានអាហារ។

កុមារដទៃទៀតដែលប្រឆាំងនឹងសកម្មភាពរបស់ លោក សុជា ក៏ត្រូវបានដាក់ទណ្ឌកម្មដែរ។ យោងតាមគោលការណ៍ដែលបានពិពណ៌នាដោយ លោក សុជា ជា «ការធ្វើការជួបជុំឡើងវិញ» រវាងក្រុមគ្រួសារបង្កើតរបស់ពួកគេ កុមារមួយចំនួនត្រូវបានគេបណ្តេញចេញពីភូមិ។ កុមារីម្នាក់ដែលត្រូវបានបណ្តេញចេញត្រូវបានគេរកឃើញនៅក្នុងស្ថានភាពគួរឱ្យស្ញែងខ្លាចនៅក្នុងតំបន់អនាធិបតេយ្យនៃរាជធានីភ្នំពេញ។ នាងត្រូវបាន លោក សុជា កំណត់ជាគោលដៅដាក់ទណ្ឌកម្ម បន្ទាប់ពីនាងត្រូវបានចោទប្រកាន់ថាបានធ្វើការលួចពីបុគ្គលិកស្រីម្នាក់ដែលគាត់ជិតស្និទ្ធជាមួយ។ កុមារម្នាក់ទៀតដែលត្រូវបាន «ជួបជុំឡើងវិញ» ដោយ លោក សុជា គឺកុមារាអាយុ ១៥ ឆ្នាំម្នាក់ ដែលត្រូវបានគេរកឃើញនៅក្នុងពន្ធនាគារមនុស្សពេញវ័យមួយនៅក្នុងរាជធានីភ្នំពេញ។ លោក សុជា បានលាក់បាំងកន្លែងស្នាក់នៅរបស់គាត់ពីក្រុមស៊ើបអង្កេតនៅឆ្នាំ ២០១៩។ ដោយមានការយល់ព្រមពីពួកគេ អនីតិជនទាំងនោះត្រូវបានវិលត្រឡប់ទៅក្នុងភូមិវិញ។ ចំពោះកុមារពីរនាក់ក្នុងចំនោមកុមារបីនាក់ ដែលបាន «ធ្វើការជួបជុំឡើងវិញ» ដោយ លោក សុជា បានអះអាងថា «ឪពុកម្តាយ» មិនមែនជាឪពុកម្តាយបង្កើតទេ។

ក្រុមច្បាប់ដែលមានអំណាចមេធាវីពីសុវណ្ណកុមារអិលអិលស៊ី កំពុងប្រមូលភស្តុតាងនិងពិនិត្យឯកសារនានាដែលបញ្ជាក់ព័ត៌មានដែលបានចាប់យកនៅក្នុងរបាយការណ៍មុន ដែលធ្វើឡើងដោយស្ថាប័នឯករាជ្យ ហើយត្រូវបានបង្ក្រាបដោយ លោក សុជា និងបក្ខពួក។ បន្ថែមលើសក្ខីកម្ម ភ័ស្តុតាងថ្មីបានលេចចេញមកដែលបង្ហាញពីភាពធ្ងន់ធ្ងរ និងទំហំនៃកាវាយដំធ្វើបាបដែលកុមាររងគ្រោះនៅក្នុងភូមិ។ ភ័ស្តុតាងបង្ហាញថា លោក សុជា អរុណ មានការជួយជ្រោមជ្រែងពីអតីតថ្នាក់ដឹកនាំជាន់ខ្ពស់ និងទីប្រឹក្សាជាច្រើនរូប ដែលធ្លាប់បានគ្រប់គ្រងភូមិដូចជាសក្តិភូមិការបង្កើតឲ្យមានបរិយាកាសវាយដំធ្វើបាប ដែលកុមារជាជនរងគ្រោះទទួលរងនូវការវាយដំធ្វើបាប និងការធ្វេសប្រហែសលើការយកចិត្តទុកដាក់ពីគ្រួសារចិញ្ចឹម ខណៈដែលកុមារដទៃទៀតត្រូវបានគេថែរក្សាយ៉ាងល្អទៅតាមទំនាក់ទំនងដែលពួកគេមានជាមួយ លោក សុជា។

ឪពុកម្តាយចិញ្ចឹមខ្មែរមួយចំនួនធំនៅក្នុងកម្មវិធីនេះបានចេញមុខមកផ្តល់សក្ខីកម្មប្រឆាំងនឹងលោក សុជា អរុណនិងបក្ខពួករបស់គាត់។ បន្ទាប់ពីបញ្ឈប់បុគ្គលិកចាស់ៗ ក្រុមគ្រប់គ្រងថ្មីត្រូវបានបង្កើតឡើងនៅឯសុវណ្ណកុមាររដើម្បីការពារកុមារ។ នៅខែសីហា ឆ្នាំ២០១៩ អ្នកយាមដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់លោក សុជា អរុណ នៅក្នុងភូមិត្រូវបានបញ្ឈប់នៅដោយមានវត្តមានរបស់មេធាវីកម្ពុជា ហើយក្រុមសន្តិសុខថ្មីមួយត្រូវបានបង្កើតឡើង។ អតីតអ្នកយាមទាំងអស់ទទួលបានកញ្ចប់ផ្តាច់ប្រាក់ឈ្នួលសមស្របទៅតាមច្បាប់កម្ពុជា។ លោកសុជា អរុណ និងបក្ខពួកបានព្យាយាមបង្ខូចឈ្មោះបុគ្គលិកថ្មីជាលេសដើម្បីឱ្យអតីតបុគ្គលិកនិងឪពុកម្តាយចិញ្ចឹមហឹង្សាត្រឡប់ទៅភូមិវិញ ប៉ុន្តែវាមិនត្រូវបានអនុញ្ញាត។ បណ្តឹងរដ្ឋប្បវេណី និងព្រហ្មទណ្ឌបន្ថែមទៀតត្រូវបានដាក់នៅថ្ងៃទី ៨

ខែវិច្ឆិកា ទាក់ទងនឹងការក្លែងបន្លំហិរញ្ញវត្ថុធ្ងន់ធ្ងរដែលបានកើតឡើងនៅក្នុងភូមិ ដែលក្នុងនោះលោកសុជា និងបុគ្គលដទៃទៀតត្រូវបានជាប់ពាក់ព័ន្ធ។

សុវណ្ណកុមារ អិលអិលសី Sovann Komar, LLC និងក្រុមប្រឹក្សាកុមារមាស Golden Children Inc កំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយអ្នកជំនាញសុខភាពផ្លូវចិ ត្តនិងបានដាក់ចេញនូវគោលការណ៍ការពារកុមារឱ្យបានពេញលេញ។ «ពួកយើងមានមោទនភាពចំពោះភាពអត់ធ្មត់របស់កូនៗយើង», លោក Kara Heide សមាជិកក្រុមប្រឹក្សាសុវណ្ណកុមារ បានថ្លែងបន្តថា «ក៏ដូចជាសុចរិតភាព និងការលះបង់របស់ក្រុមអ្នកគ្រប់គ្រងថ្មីរបស់ពួកយើង»។ អ្នកឧបត្ថម្ភធំៗនៅពីក្រោយសុវណ្ណកុមារនៅតែប្តេជ្ញាចំពោះចក្ខុវិស័យដើមសម្រាប់សុវណ្ណ កុមារដដែលគឺៈ ដើម្បីបង្កើតគេហដ្ឋានប្រកបដោយសុវត្ថិភាព និងចិញ្ចឹមបីបាច់ថែរក្សាកុមារកំព្រា និងកុមារដែលត្រូវគេបោះបង់ចោលនៅកម្ពុជា ដើម្បីអាចអភិវឌ្ឍន៍ ទៅរកសក្តានុពលពេញលេញរបស់ពួកគេ៕

## ស្ថានទូតកម្ពុជាជួយសង្គ្រោះស្ត្រីខ្មែរ និងកូនតូច រត់ចេញពីប្រទេសចិន ចូលមកវៀតណាម

https://www.cen.com.kh/archives/ June 7, 2020

ភ្នំពេញៈ ស្ថានទូតកម្ពុជាប្រចាំប្រទេសវៀតណាម បានជួយសង្គ្រោះ ស្ត្រីខ្មែរ និងកូនតូច ដែលបានរត់ចេញពីប្រទេសចិន ចូលវៀតណាម ដោយខុសច្បាប់ ក្នុងខេត្តកាវ បាង ដែលមានចម្ងាយ ៣៧០ គីឡូម៉ែត្រ ពីទីក្រុងហាណូយ ។ ស្ថានទូតកម្ពុជាប្រចាំប្រទេសវៀតណាម (Royal Embassy of Cambodia in Vietnam) នៅថ្ងៃទី៧ខែមិថុនាឆ្នាំ២០២០នេះ បានចេញផ្សាយព័ត៌មានថា "កាលពីថ្ងៃទី៤ និងថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២០ បន្ទាប់ពីបានដឹងដំណឹងថាមាន ស្ត្រីខ្មែរ និងកូនតូច បានរត់ចេញពីប្រទេសចិន ចូលវៀតណាម ដោយខុសច្បាប់ ក្នុងខេត្តកាវ បាង ដែលមានចម្ងាយ ៣៧០ គីឡូម៉ែត្រ ពីទីក្រុងហាណូយ ស្ថានទូតកម្ពុជា បានចុះដោះស្រាយទទួល និងជូនដំណើរ ម្តាយ និងកូនតូច ឲ្យវិលត្រឡប់ទៅប្រទេសកម្ពុជាវិញ ពីទីក្រុងហាណូយ តាមរថភ្លើង ហើយនឹងទៅដល់ប្រទេសកម្ពុជា នៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២០"៕ **ដោយៈកូឡាប**

## ពលករខ្មែរ៣នាក់ឆ្លងដែនចូលប្រទេសថៃ ដោយខុសច្បាប់ត្រូវសមត្ថកិច្ចថៃចាប់ខ្លួន

https://www.facebook.com/ ទឹកចិត្ត ពលករ ឆ្លងដែន 04-06-2020

ពលករខ្មែរ៣នាក់ បានឆ្លងដែនចូលប្រទេសថៃតាមច្រករបៀងដោយខុសច្បាប់ ត្រូវសមត្ថកិច្ចថៃ ស្រុកអារ៉ាញ់ ខេត្តស្រះកែវ ចាប់បាននៅល្ងាចមិញនេះ សមត្ថកិច្ចថៃចាប់បញ្ជូនពលករខ្មែរយកទៅដំណើរការតាមផ្លូវច្បាប់។ (អំពីខ្ញុំ ទឹកចិត្ត ពលករ ឆ្លងដែន) 4-6-2020។

# ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២០

## ថៃដោះលែងអ្នកទោស២នាក់ឱ្យមានសេរីភាពឡើងវិញ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០២០ ម៉ោង ០៩:០៩ ឱម សារឿន

ខេត្តឧត្តរមានជ័យ ៖ អ្នកទោសខ្មែរចំនួន២នាក់ដែលក្រុមអាជ្ញាធរថៃចោទពីបទឆ្លងដែនដោយខុសច្បាប់ចូលទៅកាប់ឈើគ្រញូង ត្រូវបានដោះលែងឱ្យមានសេរីភាពវិញ ហើយបញ្ជូនយកមកប្រគល់ឱ្យក្រុមអាជ្ញាធរកម្ពុជាតាមមាត់ច្រកទ្វារអន្តរជាតិជាំ កាលពីវេលាម៉ោង៨ព្រឹកថ្ងៃទី៥ មិថុនា ឆ្នាំ២០២០ ស្ថិតនៅក្នុងភូមិជាំ ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។

អ្នកទោសខ្មែរទាំង២នាក់ខាងលើដែលក្រុមអាជ្ញាធរថៃដោះលែង ក្នុងនោះម្នាក់ឈ្មោះសូ តី ភេទប្រុស អាយុ ២០ឆ្នាំ រស់នៅភូមិអូរឫស្សី ឃុំផ្គាំ ស្រុកត្រពាំងប្រាសាទ ត្រូវថៃចាប់ខ្លួនកាលពីថ្ងៃទី២២ មីនា ឆ្នាំ២០១៩ និងម្នាក់

ទៀតឈ្មោះអ៊ុន តាក់ ភេទប្រុស អាយុ២០ឆ្នាំ រស់នៅភូមិអូរឫស្សី ឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ត្រូវថៃចាប់ខ្លួនថ្ងៃទី១ មករា ឆ្នាំ២០១៩ ពីបទឆ្លងដែនកាប់ឈើគ្រញូង ចូលតាមច្រកអូស្វាយ ជាប់គុកនៅខេត្តស៊ីសាកេត ប្រទេសថៃ។

មន្ត្រីដែលបម្រើការងារនៅមាត់ច្រកទ្វារអន្តរជាតិជាំបានឱ្យដឹងថា បន្ទាប់ពីបានទទួលអ្នកទោសខ្មែរ២នាក់ពីក្រុមអាជ្ញាធរថៃរួចមក សមត្ថកិច្ចកម្ពុជាបានធ្វើការអប់រំ និងឱ្យធ្វើកិច្ចសន្យាបញ្ឈប់ការឆ្លងដែនដោយខុសច្បាប់ជាបន្តទៀត និងបានអនុញ្ញាតឱ្យវិលត្រឡប់ទៅជួបជុំក្រុមគ្រួសារវិញក្នុងថ្ងៃដដែល៕ (កែសម្រួលដោយ ៖ ធីតា)

## ដោយសារតែខ្វះកម្លាំងពលកម្ម ពលរដ្ឋថៃស្នើឲ្យរដ្ឋាភិបាលបើកច្រកព្រំដែនកម្ពុជា-ថៃ

https://kbn.news/archives/ June 8, 2020

**បរទេស៖** ថ្មីៗនេះម្ចាស់ចំការនៅប្រទេសថៃ ជាច្រើននាក់បានធ្វើលិខិតស្នើរសុំឲ្យរដ្ឋាភិបាលឲ្យបើកច្រកព្រំដែនឡើងវិញ ជាពិសេសគឺច្រកព្រំដែនជាប់ជាមួយប្រទេសកម្ពុជា ក្រោមហេតុផលខ្វះកម្លាំងពលកម្មក្នុងការប្រមូលផលដំណាំផ្លែឈើ និងបន្លែសម្រាប់នាំចេញទៅក្រៅប្រទេស។ នេះបើយោងតាមការចុះផ្សាយរបស់សារព័ត៌មាន Khaosod នាព្រឹកថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០។ នៅក្នុងសារលិខិតនោះបានបញ្ជាក់ថា សូមឲ្យរដ្ឋាភិបាលពិនិត្យឡើងវិញចំពោះបញ្ហាដែលបានចោទដូចខាងលើដូចដែលក្រុមម្ចាស់ចំការបានជួបប្រទះ។ ផលដំណាំស្ទើរតែទាំងអស់នៅពេលដែលវាបានផ្តល់ទិន្នផលហើយនោះ គឺពិតជាល្អតែបញ្ហារាំងស្ទះដ៏ធំមួយគឺខ្វះកម្លាំងពលកម្មផ្សេងៗសម្រាប់ប្រមូលផលដឹកជញ្ជូនយកទៅលក់នៅក្នុងទីផ្សារ។

យ៉ាងណាមិញ ដោយមួយរយៈក្រោយនេះមើលឃើញថា ការគ្រប់គ្រងជំងឺកូវីដ១៩ នៅប្រទេសកម្ពុជាសង្កេតឃើញថា មានភាពល្អប្រសើរខ្លាំងណាស់ ជាពិសេសគឺនៅតំបន់បន្ទាត់ព្រំដែនតែម្តងដោយមានការយាមកាមយ៉ាងតឹងរឹងព្រមទាំងមានការត្រួតពិនិត្យច្បាស់លាស់ មានប្រសិទ្ធភាពទៀតផង។ ម្យ៉ាងវិញប្រទេសជុំវិញប្រទេសថៃមានការគ្រប់គ្រងបានយ៉ាងល្អ ដោយគ្មានករណីរកឃើញអ្នកជំងឺនៅក្នុងស្រុកឡើយ ដោយប្រទេសទាំងអស់នោះមានការជួយជ្រោមជ្រែងពីអង្គការសហប្រជាតិផ្ទាល់តែម្តង ដូច្នេះហើយគឺគ្មានអ្វីព្រួយបារម្ភទេ។

ដោយឡែកនៅក្នុងលិខិតបើកចំហរនោះ ក្រុមពួកម្ចាស់ចម្ការបានសរសេររិះគន់រដ្ឋាភិបាលថា ហាងម៉ាស្សាផ្សេងៗអាចបើកបន្តអាជីវកម្មបាន ចុះហេតុអ្វីច្រកព្រំដែន ដែលនៅតាមបន្ទាត់ព្រំដែនមានការការពារខ្ពស់ ខ្យល់បរិសុទ្ធចេញចូលគ្រប់គ្រាន់ និងមានសីតុណ្ហភាពក្តៅខ្លាំង ព្រមទាំងមានការសំរិតសំរាំងខ្ពស់ ហេតុអ្វីមិនអាចបើកបាន? ៕

## ឃាត់ខ្លួនជនជាតិថៃ ២ នាក់ ចិន៤នាក់ និងខ្មែរ ២នាក់ ករណី ឆ្លងដែនខុសច្បាប់ នៅបន្ទាយមានជ័យ

http://www.arey-news.com/archives/ (ថ្ងៃទី 08 June 2020 ម៉ោង 9:30 pm)

បន្ទាយមានជ័យ ៖ កាលពីថ្ងៃទី៧ខែមិថុនា ឆ្នាំ២០២០ កម្លាំងយោធា នៃកងការពារព្រំដែន លេខ៥០៣ របស់កម្ពុជា បានឃាត់ខ្លួនមនុស្ស ៨ នាក់ និងរឹបអូសរថយន្ត ២ គ្រឿង ករណីជនជាតិថៃ ២ នាក់ នាំជនជាតិចិន ៤ នាក់ តាមរថយន្ត ១គ្រឿង ពីថៃ ចូលមកកម្ពុជា ដោយខុសច្បាប់ តាមច្រករបៀង នៃព្រំដែនចម្ការគ ហើយមានជនជាតិខ្មែរ ២ នាក់ បានយករថយន្ត ១គ្រឿង ដើម្បីចាំទទួលបន្ត ។

ឧបទ្ទវហេតុ នៃការនាំជនបរទេសឆ្លងដែន ក្នុងអំឡុងប្រទេសថៃ ក៏ដូចកម្ពុជា បានបិទព្រំដែនប្រទេស ដើម្បីទប់ស្កាត់ការរីករាលដាល នៃជំងឺកូវីដ ១៩ នេះ គឺដំបូង នៅព្រឹកថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២០ មានជនជាតិថៃ ២ នាក់ បាននាំជនជាតិចិន (ជីគោក) ៤ នាក់ ពីប្រទេសថៃ ចូលមកប្រទេសកម្ពុជា តាមរថយន្ត ១គ្រឿង ដោយឆ្លង

កាត់ច្រករបៀង ក្នុងស្រុកគោកធ្លុង ខេត្តស្រះកែវ ដែលខាងកម្ពុជា គឺច្រករបៀងចម្ការគ ភូមិចម្ការគ ឃុំ -ស្រុក ស្វាយចេក ខេត្តបន្ទាយមានជ័យ។ នៅពេលចូលមកដល់ ដែនដីកម្ពុជា (ភូមិសាស្ត្រខាងលើ ដែលឈរជើងដោយ យកងល្បាតទី១ នៃកងការពារព្រំដែន លេខ៥០៣ ) មានជនជាតិខ្មែរ ២ នាក់ បានយករថយន្ត ១ គ្រឿង មកចាំ ទទួលដឹកបន្ត ចូលជ្រៅក្នុងប្រទេសកម្ពុជា តែម្តង។

ជនបរទេស ៦ នាក់ ( ថៃ២នាក់ ចិន៤នាក់) និងជនជាតិខ្មែរ ២ នាក់ ត្រូវបានឃាត់ខ្លួន ហើយប្រគល់អោ យកងរាជអាវុធហត្ថ ខេត្តបន្ទាយមានជ័យ ចាត់ការបន្ត ក្នុងនាមមន្ត្រីនគរបាលយុត្តិធម៌ ។ ឃាត់ខ្លួន ជនជាតិថៃ ជន ជាតិចិន និងជនជាតិខ្មែរ សរុបចំនួន ៨ នាក់ ដោយសារពួកគេ ឆ្លងព្រំដែនខុសច្បាប់ ហើយបំពានបម្រាម ឆ្លងកាត់ ព្រំដែន ក្នុងអំឡុងបិទប្រទេស ដើម្បីហេតុផលប្រយុទ្ធប្រឆាំងនឹងកូវីដ ១៩ ក្នុងនោះ កងទ័ពនៅព្រំដែន ចំណុះ យោធភូមិភាគ៥ បានដកហូតវត្ថុតាង រួមមាន រថយន្ត២គ្រឿង ទូរស័ព្ទ ៨ គ្រឿង ប្រាក់ថៃ ១.៦៦០ បាត ប្រាក់ អាម៉េរិក ៨០ ដុល្លារ ។ សាកសួរធ្វើកំណត់ហេតុរួច ជនជាតិថៃ ជនជាតិចិន និងជនជាតិខ្មែរទាំង ៨ នាក់ និងរថ យន្ត ២ គ្រឿង ត្រូវបានយោធា ប្រគល់ឲ្យកងរាជអាវុធហត្ថ ខេត្តបន្ទាយមានជ័យ ចាត់ការបន្ត តាមនិតិវិធី ៕

## ថៃពន្យារការស្នាក់នៅប្រមាណ ២ ខែ សម្រាប់ពលករចំណាកស្រុក

https://www.postkhmer.com/ នៀម ឆេង | Publication date 08 June 2020 | 15:24 ICT

**ភ្នំពេញៈ** រដ្ឋាភិបាលថៃ ពន្យារការស្នាក់នៅសម្រាប់ពលករចំណាកស្រុកមកពីប្រទេស កម្ពុជា ឡាវ និងមីយ៉ា ន់ម៉ា ដែលធ្វើការនៅប្រទេសថៃពីថ្ងៃទី ១ មិថុនា ដល់ ថ្ងៃទី ៣១ កក្កដា ជាវិធានការទប់ស្កាត់ការរាលដាលជំងឺកូវីដ ១៩។ នេះបើតាមសេចក្តីប្រកាសរបស់នាយកដ្ឋានទំនាក់ទំនងសាធារណៈថៃចេញផ្សាយថ្ងៃទី ៥ មិថុនា។

សេចក្តីប្រកាសសរសេរថា៖ «ការសម្រេចនេះធ្វើឡើងក្នុងគោលបំណងបញ្ចៀសការខ្វះកម្លាំងពលកម្ម និង ដើម្បីគាំទ្រដល់ការបើកដំណើរការសេដ្ឋកិច្ចឡើងវិញ បន្ទាប់ពីស្ថានភាពមានភាពប្រសើរឡើងវិញ និងដើម្បីជួយ រារាំងការចម្លងជំងឺកូវីដ ១៩»។ សេចក្តីប្រកាសឲ្យដឹងថា ការសម្រេចពន្យារនេះធ្វើឡើងដោយទីស្តីការក្នុងកិច្ចប្រជុំ មួយកាលពីថ្ងៃទី ២ មិថុនា បន្ទាប់ពីមានការស្នើសុំពីក្រសួងការងារថៃ ដែលបានយល់ព្រមពន្យារការស្នាក់នៅរបស់ ពលករចំណាកស្រុកពីប្រទេសទាំង ៣ ពីថ្ងៃទី ១ មិថុនា ដល់ ៣១ កក្កដា ឆ្នាំ ២០២០។ ការពន្យារនេះគឺសម្រាប់ ពលករចំណាកស្រុក ដែលមានបណ្ណការងារចេញក្រោមអនុស្សរណៈ នៃការយោគយល់គ្នា ស្តីពីបញ្ហាពលករ និង សម្រាប់ពលករកម្ពុជា និងមីយ៉ាន់ម៉ាដែលមានបណ្ណឆ្លងកាត់ព្រំដែន ស្របតាមចំណុចទី ៦៤ នៃច្បាប់របស់ថៃ។ សេចក្តីប្រកាសបន្តថា៖ «បន្ទាប់ពីថ្ងៃទី ៣១ កក្កដា ពលករបរទេសទាំងនោះត្រូវតែចាកចេញពីព្រះរាជាណាចក្រ ថៃ ក្នុងពេលកំណត់ដែលដាក់ចេញក្នុងការប្រកាសរបស់ក្រសួងមហាផ្ទៃ។ អ្នកដែលរំលោភច្បាប់នឹងត្រូវប្រឈមមុខ នឹងផ្លូវច្បាប់»។

លោក មឿន តុលា នាយកប្រតិបត្តិ មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្សហៅកាត់ថា សង់ត្រាល់ ឲ្យដឹងថា តាមលោកដឹង រដ្ឋាភិបាលថៃបានបន្ថែមការបិទប្រទេសរហូតដល់ចុងខែមិថុនានេះ ដើម្បីទប់ការឆ្លងរាល ដាលជំងឺកូវីដ១៩។ ក្នុងរយៈពេលនេះរដ្ឋាភិបាលថៃពន្យារទិដ្ឋាការឲ្យពលករចំណាកស្រុកស្របច្បាប់ដោយស្វ័យប្រវត្តិ។ លោកបន្តថា តាមនីតិវិធីដែលលោកធ្លាប់ដឹង បន្ទាប់ពីពេលនេះបានផុតទៅ អាជ្ញាធរថៃនឹងផ្តល់ពេលសម្រាប់ឲ្យពល ករទៅពន្យារទិដ្ឋាការរបស់ពួកគេ មុនពេលប្រឈមមុខនឹងការពិន័យ ឬបណ្តេញចេញ។ លោកថា តាមលោកទទួល បានព័ត៌មាន ពលករចំណាកស្រុកពីកម្ពុជានៅថៃមានប្រមាណជិត ២ លាននាក់ បូករួមទាំងអ្នកដែលគ្មានឯកសារ ចំនួនប្រមាណ ២០ ភាគរយ។ លោក ហេង សួរ អ្នកនាំពាក្យក្រសួងការងារមិនអាចទាក់ទងសុំអធិប្បាយបានទេ ម្សិលមិញ៕

## ត្រៀមៗ ថៃបើកឲ្យកម្ពុជាអាចបញ្ជូនពលករជួនទៅធ្វើការនៅប្រទេសខ្លួន ១ម៉ឺននាក់ នៅខែក្រោយ

http://daranews.website/archives/ 08-06-2020

លោក អន ប៊ុនហាក់ ប្រធានសមាគមទីភ្នាក់ងារហេត្តពលកម្មកម្ពុជា បានឲ្យដឹងកាលពីថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ២០២០ កម្ពុជាអាចនឹងបញ្ជូនពលករខ្មែរប្រមាណ១ម៉ឺននាក់ ទៅធ្វើការនៅប្រទេសថៃ នៅដើមខែកក្កដា ឆ្នាំ២០២០ នេះ ដោយសារស្ថានភាពជម្ងឺកូវីដ១៩ មានភាពធូរស្រាលឡើងវិញ។ លោក អន ប៊ុនហាក់ បានបន្តថា តាមដំណឹងថៃ នឹងបើកនៅដើមខែក្រោយ តែរង់ចាំមើលការប្រកាសសិន។ លោកបានបន្ថែមថា យ៉ាងណាក៏ដោយ យើងរង់ចាំមើលការប្រកាសដកបម្រាមដាក់ប្រទេសក្នុងគ្រាអាសន្នជាផ្លូវការពីរាជរដ្ឋាភិបាលថៃ និងមានបើកច្រក ព្រំដែន ជាមួយកម្ពុជាឡើងវិញ និងមានការណែនាំពីក្រសួងការងារថៃ ក៏ដូចជាស្ថានទូតថៃប្រចាំកម្ពុជាជាមុនសិន ទើបយើងអាចបញ្ជូនពលករទៅបាន ព្រោះថា បច្ចុប្បន្ននេះនិយោជកថៃបានទាក់ទងមកថា គេកំពុងខ្វះកម្លាំងពល កម្មច្រើន។

ជាមួយគ្នានេះដែរ លោកបានស្នើឲ្យនិយោជកនៃធ្វើការទំនាក់ទំនងជាមួយរដ្ឋាភិបាលរបស់ខ្លួន ដើម្បីឲ្យដឹង ថានៅពេលបើកច្រកនៅដើមខែកក្កដានេះអាចបញ្ជូនពលករខ្មែរទៅបានឬយ៉ាងណា ព្រោះយើងបានត្រៀមឯកសារ ពាក់ព័ន្ធរួចរាល់អស់ហើយ ទាំងទិដ្ឋាការ និងប័ណ្ណធានារ៉ាប់រងសុខភាពសម្រាប់បញ្ជូនពលករទៅធ្វើការនៅថៃ។ លោកបានឲ្យដឹងទៀតថា ក្រៅពីនេះសមាគមបានស្នើឲ្យទីប្រឹក្សាការងារប្រចាំស្ថានទូតខ្មែរប្រចាំនៅប្រទេសថៃជួយ ទំនាក់ទំងជាមួយក្រសួងការងាររបស់ថៃ ដើម្បីដឹងពីអ្វីជាផែនការ និងគោលនយោបាយរបស់ប្រទេសងាយស្រួល សមាគមត្រៀមខ្លួន និងឆ្លើយតបឲ្យបានទាន់ពេលវេលា។ លោកបានបញ្ជាក់ថា តាមផែនការនៅឆ្នាំ២០២០ នេះកម្ពុជាគ្រោងនឹងបញ្ជូនពលករទៅធ្វើការនៅក្រៅ ប្រទេសប្រមាណ ២០ម៉ឺននាក់ ក្នុងនោះរួមមានប្រទេសថៃ ជប៉ុន សឹង្ហបុរី ហុងកុង និងម៉ាឡេស៊ី ប៉ុន្តែរហូតមកដល់ ពេលនេះបញ្ជូនបានត្រឹមតែ ៥ម៉ឺននាក់ប៉ុណ្ណោះ ដោយសារប្រទេសទាំងនោះមានបញ្ហាជម្ងឺកូវីដ១៩។

សូមរំលឹកថា បច្ចុប្បន្ននេះកម្ពុជាមានពលករកំពុងធ្វើការនៅក្រៅប្រទេសប្រមាណ១លាន ២សែននាក់ ក្នុង នោះប្រទេសថៃមានច្រើនជាងគេ គឺមានរហូត ១លាននាក់ ដោយបានផ្ញើថវិកាមកក្រុមគ្រួសារប្រមាណជា២ពាន់ លានដុល្លា អាមេរិក ក្នុងមួយឆ្នាំៗ ដែលបានជួយលើកស្ទួយដល់សេដ្ឋកិច្ចគ្រួសារ និងសេដ្ឋកិច្ចជាតិកាន់តែប្រសើរ ឡើងថែមទៀត។

## ពលរដ្ឋខ្មែរ បន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៣៨នាក់

https://www.facebook.com/GDIOfficial 08-06-2020

នៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរ ជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិន អនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការពតត្បាតនៃជំងឺឆ្លងកូវីដ១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹម ត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិល ចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៣៨នាក់ ស្រី ១៧នាក់៕

# កម្ពុជា-ទីម័រខាងកើត សន្យារួមគ្នាអភិវឌ្ឍន៍វិស័យការងារឱ្យកាន់តែប្រសើរក្រោយចប់កូវីដ-១៩

http://www.freshnewsasia.com/ 2020-06-09

**(ភ្នំពេញ)៖** រដ្ឋមន្ត្រីក្រសួងការងារកម្ពុជា និងឯកអគ្គរដ្ឋទូតសាធារណរដ្ឋប្រជាធិបតេយ្យទីម័រខាងកើត បានសន្យាអភិវឌ្ឍន៍វិស័យការងាររវាងប្រទេសទាំងពីរឲ្យកាន់តែប្រសើរបន្តទៀត ក្រោយចប់ជំងឺកូវីដ-១៩។ ការបញ្ជាក់ជំហរយ៉ាងដូច្នេះធ្វើឡើងក្នុងជំនួបពិភាក្សាការងាររវាងលោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាមួយឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋប្រជាធិបតេយ្យ ទីម័រខាងកើតប្រចាំកម្ពុជា លោក Ermenegildo Kupa Lopes (អើម៉ឺនីហ្គីលដូ គូប៉ា ឡូប៉េស) នៅទីស្តីការក្រសួងការងារ នាព្រឹកថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២០។ ជំនួបពិភាក្សានេះផ្តោតសំខាន់លើកិច្ចសហប្រតិបត្តិការលើវិស័យការងារដែលកម្ពុជា និងទីម័រខាងកើត បានសហការជាមួយគ្នាយ៉ាងល្អកន្លងមក ហើយបាននិងកំពុងបន្តពង្រឹងពង្រីកបន្ថែមទៀត។

លោករដ្ឋមន្ត្រី អ៊ិត សំហេង បានទទួលស្វាគមន៍ចំពោះលោកឯកអគ្គរាជទូតនៃសាធារដ្ឋប្រជាធិបតេយ្យទីម័រខាងកើតយ៉ាងកក់ក្តៅ និងបានបញ្ជាក់ពីទំនាក់ទំនងល្អរវាងប្រទេស និងប្រជាជនយើងទាំងពីរ ដែលមានធម្មជាតិដ៏ស្រស់ត្រកាល និងប្រវិត្តសាស្ត្រប្រហាក់ប្រហែលគ្នា។

លោកឯកអគ្គរាជទូតបានវាយតម្លៃខ្ពស់ចំពោះគោលនយោបាយឈ្នះ-ឈ្នះរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី ដែលបានបង្រួបបង្រួមជាតិ នាំមកនូវសន្តិភាព និងការអភិវឌ្ឍន៍នៅគ្រប់វិស័យ ដែលអនុញ្ញាតឱ្យប្រជាជនកម្ពុជាមកពីគ្រប់និន្នាការនយោបាយអាចរួមរស់ ប្រកបដោយសុខដុមរមនាជាមួយគ្នា។ លោក Ermenegildo បានថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលកម្ពុជា ដែលតែងតែគាំទ្រដល់បេក្ខភាពរបស់ប្រទេសទីម័រខាងកើត នៅក្នុងក្របខណ្ឌអាស៊ាន។ លោកអគ្គរដ្ឋទូតបានសន្យាថានឹងខិតខំបំពេញបេសកកម្មការទូតឲ្យទទួលបានជោគជ័យ នៅក្នុងការពង្រឹងពង្រីកទំនាក់ទំនងប្រទេសទាំងពីរឲ្យកាន់តែរឹងមាំឡើង។ លោកបានចាត់ទុកកម្ពុជាជាគេហដ្ឋានទី២របស់ខ្លួន និងមានភាពកក់ក្តៅយ៉ាងខ្លាំង ទោះបីពេលនេះពិភពលោកមានបញ្ហាកូវីដ-១៩ តែកម្ពុជាបានគ្រប់គ្រងស្ថានការណ៍ជំងឺនេះ ប្រកបដោយប្រសិទ្ធភាពខ្ពស់។

**គួរបញ្ជាក់ថា ចំពោះកិច្ចសហប្រតិបត្តិការនាពេលកន្លងមក ដែលប្រទេសទាំងពីរបានចុះកិច្ចព្រមព្រៀងជាមួយគ្នាស្តីពី កិច្ចសហប្រតិបត្តិការលើវិស័យការងារ កាលពីថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៦ រួមមាន៖**

*ការផ្លាស់ប្តូរប្រព័ន្ធកម្មវិធីការសិក្សា ជំនាញឯកទេស ការស្រាវជ្រាវ ការសិក្សានិងព័ត៌មានពាក់ព័ន្ធវិស័យនានា រួមទាំងការសិក្សាប្រៀបធៀបលើវិស័យការងារ មុខរបរ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងរដ្ឋបាលការងារ ដូចជាការចរចារជាសមូហភាព ការដាក់ឱ្យអនុវត្ត និងការអនុវត្តច្បាប់ ការដោះស្រាយវិវាទការងារ សន្តិសុខសង្គម ការគាំពារពលកម្ម សេរីភាពខាងសមាគម សុវត្ថិភាព និងសុខភាពការងារ ការគ្រប់គ្រងហត្ថពលកម្មបរទេស និងការផ្លាស់ប្តូរព័ត៌មានទៅលើការពង្រឹងផលិតភាពការងារ។

*ការលើកទឹកចិត្តការផ្លាស់ប្តូរទស្សនៈកិច្ចរវាងមន្ត្រីទទួលបន្ទុក និងមន្ត្រីជំនាញ។

*ការគ្រប់គ្រងទេសន្តរប្រវេសន៍ការងាររវាងប្រទេសទាំងពីរ។

*ការផ្លាស់ប្តូរព័ត៌មាន ដើម្បីទប់ស្កាត់ការជ្រើសរើស និងប្រើប្រាស់ពលករខុសច្បាប់ ក៏ដូចជាការបង្ការ និងប្រយុទ្ធប្រឆាំងការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងការជួញដូរមនុស្ស៕

# ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០

## រួមគ្នាទប់ស្កាត់នៅការរាលដាលមេរោគកូវីដ១៩តាមការណែនាំរបស់ក្រសួងសុខាភិបាល

http://neakmeasnews.com/ Sat,06 June 2020 ( Time 02:35 PM )

(ខេត្តបាត់ដំបង): ខ្មែរប្រុសស្រី៣៨នាក់ចាញ់បោកមេខ្យល់ត្រូវបនកម្លាំងឃោជាឈុតខ្មៅថៃចាប់ខ្លួន និងបញ្ជូនមកឲ្យសមត្ថកិច្ចកម្ពុជាវិញ ខេត្តបាត់ដំបង,ស្រុកសំពៅលូន នៅក្នុងអំឡុងពេលដែលស្ថានភាពនៃការគំរាមកំហែងដោយករណីCovid-19 នៅតែបន្តមានជារៀងរាល់ថ្ងៃរីឯការធ្វើដំណើរវិលចូលមកក្នុងប្រទេសវិញរបស់ប្រជាពលរដ្ឋយើងនៅតែមានជាបន្តបន្ទាប់នោះបានកត់សម្គាល់ឃើញថាមានការលបលួចឆ្លងដែនដោយខុសច្បាប់ ទៅប្រកបមុខរបរឬបំពេញការងារផ្សេងៗនៅក្នុងប្រទេសថៃ ពីសំណាក់ប្រជាពលរដ្ឋក៏នៅតែកើតមានជាបន្តបន្ទាប់ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងទប់ស្កាត់ពីសំណាក់អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធក្នុងមូលដ្ឋានយ៉ាងណាក៏ដោយ។

ជាក់ស្តែងកាលពីរសៀលថ្ងៃទី ៥ ខែ មិថុនា ឆ្នាំ២០២០ វេលាម៉ោង១៣និង៤០នាទី កម្លាំងនគរបាលនៃអធិការដ្ឋាននគរបាលស្រុកសំពៅលូន ដែលមានលោកវរសេនីយ៍ឯក ពេជ្រ សារ៉ែន ជាអធិការនគរបាលស្រុក និងកម្លាំងនគរបាលវរសេនាតូចការពារព្រំដែនគោកលេខ៨១៧ ដែលមានលោកវរសេនីយ៍ឯក ប្រាក់ សាយ ជាមេបញ្ជាការវរៈ បានសហការណ៍ជាមួយកម្លាំងផ្នែកសឹករងស្រុកសំពៅលូន និងកម្លាំងទាហ៊ានឈុនតខ្មៅ នៃព្រះរាជាណាចក្រថៃ ក្នុងកងអនុសេនាធំលេខ១៣០៣ ធ្វើការទប់ស្កាត់ទាន់ពេលវេលាចំពោះប្រជាពលរដ្ឋខ្មែរ ដែលបានលបលួចឆ្លងដែនចូលទៅក្នុងទឹកដីថៃ ដោយខុសច្បាប់ក្រោមការបំផុសឃោសនាអូសទាញដោយក្រុម (មេខ្យល់) ផងនោះមានចំនួន៣៨នាក់ ក្នុងនោះស្រីចំនួន១៧នាក់ ហើយត្រូវបានអាជ្ញាធរថៃឃាត់ខ្លួន និងបញ្ជូនមកឱ្យសមត្ថកិច្ចយើងវិញ។

ចំពោះបញ្ហានេះលោកវរសេនីយ៍ឯក ពេជ្រ សារ៉ែន អធិការនគរបាលស្រុកសំពៅលូន បានបញ្ជាក់ថា បន្ទាប់ពីទទួលបាននូវប្រជាពលរដ្ឋទាំង៣៨នាក់នេះមន្ត្រីសុខាភិបាលដែលប្រចាំការនៅមូលដ្ឋានបានធ្វើការ តាមជំនាញ (ពិនិត្យសុខភាព)រួចរាល់ទើបប្រគល់មកឱ្យនគរបាលស្រុកធ្វើការសាកសួរបំភ្លឺ ហើយក្នុងចំណោមនោះមានក្រុម (មេខ្យល់) ចំនួន០៣នាក់ ដែលជាអ្នកដឹកនាំឱ្យមានការលួចឆ្លងដែនដោយខុសច្បាប់នេះដែលក្នុងចំនួន០៣នាក់ត្រូវបានសមត្ថកិច្ចនគរបាលកសាងសំណុំរឿងបញ្ជូនមកការិយាល័យជំនាញ ដើម្បីចាត់ការតាមនីតិវិធី រីឯប្រជាពលរដ្ឋចំនួន ៣៥នាក់ បានធ្វើការអប់រំណែនាំពួកគាត់កុំឱ្យចាញ់បោកការឃោសនា អូសទាញពីសំណាក់ក្រុមមេខ្យល់ទៀត រួចបានអនុញ្ញាតឱ្យពួកគាត់វិល ត្រឡប់ទៅលំនៅដ្ឋានវិញ។

ក្នុងនាមស្នងការនៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបងសូមធ្វើការអំពាវនាវចំពោះប្រជាពលរដ្ឋយើង សូមកុំឱ្យចាញ់បោកការឃោសនាអូសទាញពីសំណាក់ក្រុម(មេខ្យល់) ដែលនាំបងប្អូនឱ្យចូលទៅក្នុងទឹកដីថៃដោយខុសច្បាប់នេះឱ្យសោះព្រោះនេះគឺជារឿងខុសច្បាប់ហើយក៏ប្រឈមខ្លាំងជាមួយនឹងការណ៍ឆ្លង ជម្ងឺCovid-19ផងដែរ៕

## ពលរដ្ឋខ្មែរចំនួន ០២នាក់ វិលត្រឡប់មកពីប្រទេសថៃ តាមច្រករបៀង (ស្លាបស្តាំ) ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី

https://www.facebook.com/GDIOfficial 09-06-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិភ្នំដី នាវេលាម៉ោង ១៥និង៣០នាទី ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២០ មានពលរដ្ឋខ្មែរ វិលត្រឡប់មកពីប្រទេសថៃ តាមច្រករបៀង (ស្លាបស្តាំ) របស់ប៉ុស្តិ៍ចំនួន ០២នាក់។ បន្ទាប់មក កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំ និងពិនិត្យកំដៅជូនពួកគាត់ និងបានសហការប្រគល់បុគ្គលទាំង ០២នាក់ ខាងលើ ជូនទៅមន្ត្រីចត្តាឡីស័ក ដើម្បីអនុវត្តតាមជំនាញបន្ត។ ដោយឡែកប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិ

ភ្នំដី ខាងភាគីថៃបានបើកច្រកទ្វារព្រំដែន អនុញ្ញាតឲ្យនាំចូល-ចេញទំនិញ ដែលបានកំណត់ ពីវេលាម៉ោង ០៦និង ០០នាទីព្រឹក និងបានបិទវិញនៅវេលាម៉ោង ១២និង០០នាទីរសៀល។

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៦៣នាក់

https://www.facebook.com/GDIOfficial 09-06-2020

នៅថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៦៣នាក់ ស្រី ២៣នាក់។

## ក្រុមការងារទំនាក់ទំនង កម្ពុជា-ថៃ ប្រចាំច្រកទ្វារអន្តរជាតិអូរស្មាច់ បានចូលជួបក្រុមការងារទំនាក់ទំនង ថៃ-កម្ពុជា ដើម្បីទទួលយកប្រជាពលរដ្ឋខ្មែរ ចំនួន០៣នាក់

https://www.facebook.com/GDIOfficial 09-06-2020

ក្រុមការងារទំនាក់ទំនង កម្ពុជា-ថៃ ប្រចាំច្រកទ្វារអន្តរជាតិអូរស្មាច់ បានចូលជួបក្រុមការងារទំនាក់ទំនង ថៃ-កម្ពុជា ដើម្បីទទួលយកប្រជាពលរដ្ឋខ្មែរ ចំនួន០៣នាក់ ដែលត្រូវបានទាហានឈុតខ្មៅថៃចាប់ខ្លួន កាលពីវេលាម៉ោង ១០និង៣០នាទី ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០ ពីបទលួចឆ្លងដែនខុសច្បាប់ ចូលទៅប្រទេសថៃ។ ក្រុមការងារប្រចាំច្រកទ្វារអន្តរជាតិអូរស្មាច់ កាលពីវេលាម៉ោង ១៧និង១៩នាទី ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០ បានឲ្យដឹងថា ប្រជាពលរដ្ឋខ្មែរទាំង ០៣នាក់ មាន ១.ឈ្មោះ យុន សៀវ ភេទស្រី អាយុ ៣៩ឆ្នាំ រស់នៅភូមិដើមជ្រៃ សង្កាត់អូរស្មាច់ ក្រុងសំរោង ខេត្តឧត្តរមានជ័យ, ២.ឈ្មោះ ហម ស្រីណាត ភេទស្រី អាយុ ១៩ឆ្នាំ រស់នៅភូមិគិរីមង្គល សង្កាត់អូរស្មាច់ ក្រុងសំរោង ខេត្តឧត្តរមានជ័យ និង៣.ឈ្មោះ តួ ឡៀវ ភេទស្រី អាយុ ១៧ឆ្នាំ រស់នៅភូមិគិរីមង្គល សង្កាត់អូរស្មាច់ ក្រុងសំរោង ខេត្តឧត្តរមានជ័យ ដែលប្រជាពលរដ្ឋខ្មែរទាំង ០៣នាក់នេះ មានគោលបំណងចូលទៅលក់ឥវ៉ាន់ នៅផ្សារព្រំដែន ឆងចម-អូរស្មាច់។ បន្ទាប់ពីបានធ្វើការអប់រំណែនាំរួចមក កងកម្លាំងនគរបាលប្រចាំច្រក បានប្រគល់ឲ្យទៅផ្នែកសុខាភិបាល ប្រចាំនៅមាត់ច្រកទ្វារអន្តរជាតិអូរស្មាច់ ដើម្បីធ្វើការត្រួតពិនិត្យបន្ត។

## លេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) ខេត្ត ចុះផ្សព្វផ្សាយអំពីផលប៉ះពាល់នៃការធ្វើចំណាកស្រុកដល់បងប្អូនប្រជាពលរដ្ឋក្នុងឃុំជើងគ្រាវ

https://gdlf-kh.com/ 2020/06/10/ Sam Sophearum កំពង់ឆ្នាំង

ខេត្តកំពង់ឆ្នាំង ៖ នាព្រឹកថ្ងៃពុធ ៥រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០នេះ លេខាធិការដ្ឋាន គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) ខេត្តកំពង់ឆ្នាំង បានរៀបចំវេទិកា ដើម្បីផ្សព្វផ្សាយអំពីផលប៉ះពាល់ នៃការធ្វើចំណាកស្រុកដោយប្រថុយប្រថាន និងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ជូនដល់ប្រជាពលរដ្ឋ រស់នៅភូមិសុភី ឃុំជើងគ្រាវ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ក្រោមអធិបតីភាព លោកជំទាវ ប៊ិន សុភី អភិបាលរងខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើ

ជួញដូរមនុស្ស (គ.ខ.ប.ជ) ខេត្តកំពង់ឆ្នាំង។ ដោយមានការចូលរួមពីលោកស្រី ឈឹម សុផល អភិបាលរងស្រុករលាប្អៀរ លោកស្រី មាស សុម៉ាលី ស្នងការរងនគរបាលខេត្តកំពង់ឆ្នាំង លោក លោកស្រីជាថ្នាក់ដឹកនាំមន្ទីរ អង្គភាព ក្នុងគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត, កម្លាំងមានសមត្ថកិច្ច, មេ ឃុំ មេភូមិ, អាជ្ញាធរ, ក្រុមការងាររបស់លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត និងប្រជាពលរដ្ឋជាច្រើនទៀតចូលរួមផងដែរ។ គោលបំណងនៃការរៀបចំវេទិកា គឺដើម្បីឱ្យប្រជាពលរដ្ឋយល់កាន់តែច្បាស់អំពីការធ្វើចំណាកស្រុក ជៀសវាងការធ្វើចំណាកស្រុកដោយប្រថុយប្រថាន តាមការឃោសនា របស់មេខ្យល់អូសទាញ និងដើម្បីបង្ការទប់ស្កាត់អំពើជួញដូរមនុស្សតាមគ្រប់រូបភាពផងដែរ។

ក្នុងឱកាសនោះលោកជំទាវបាន លើកឡើងថាៈ ក្រោមការដឹកនាំចង្អុលបង្ហាញទិស របស់ឯកឧត្តម ឈួរ ច័ន្ទឌឿន អភិបាលខេត្តកំពង់ឆ្នាំង និងជាប្រធានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត ដោយបានជម្រុញ ពង្រឹងការអនុវត្ត ការងារ ដល់គណៈកម្មាធិការ គ.ខ.ប.ជ ខេត្ត ក្រុមលេខាធិការដ្ឋាន និងក្រុមការងារជំនាញ អន្តរ មន្ទីរ អង្គភាព ឱ្យយកចិត្តទុកដាក់ អនុវត្តការងាររួមគ្នា បង្ការទប់ស្កាត់ និងចាត់វិធានការតាមច្បាប់ ឱ្យបានទាន់ពេលវេលា ចំពោះជនល្មើស និងមេខ្យល់ដែលបានប្រើប្រជាភិថុតតាមគ្រប់រូបភាព។ ក្នុងនោះលោកជំទាវបានផ្តាំការសួរសុខទុក្ខ ពីសំណាក់លោកជំទាវ ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ឯកឧត្តម ឈួរ ច័ន្ទឌឿន ប្រធាន គ.ខ.ប.ជ ខេត្ត និងបានធ្វើផ្សព្វផ្សាយ ដល់បងប្អូនប្រជាពលរដ្ឋទាំងអស់៖

១.ឱ្យយល់ពីផលប៉ះពាល់ការធ្វើចំណាកស្រុកដោយប្រថុយប្រថាន ប្រុងប្រយ័ត្ន ចំពោះមេខ្យល់គ្រប់រូបភាព។

២.រាយការណ៍ បន្ទាន់ទៅក្រុមការងារថ្នាក់ស្រុក ឃុំ ភូមិ ប៉ុស្តិ៍ ដែលនៅជិត ចំពោះករណីសង្ស័យ មានជនណា មកឃោសនា។

៣.ចូលរួមសាមគ្គីសហការគ្នា ជួយគ្នាទៅវិញទៅមកដោយមិនមានការរើសអើង។

៤.ចូររួមអនុវត្ត ភូមិឃុំ មានសុវត្ថិភាព។

៥.ត្រូវរក្សាអនាម័យ អនុវត្តវិធានការការពារខ្លួនពីជំងឺផ្សេងៗ ជាពិសេសជំងឺកូវីដ១៩ ដែលកំពុងរីករាលដាលទូទាំងសកលលោក ត្រូវតែប្រុងប្រយ័ត្ន និងអនុវត្តនូវវិធានការនានាដែលរាជរដ្ឋាភិបាលកម្ពុជា និងស្តាប់តាមការណែនាំរបស់ក្រសួងសុខាភិបាលឱ្យបានជាប្រចាំ ដើម្បីចូលរួមទាំងអស់គ្នាកុំឱ្យកើតមានជំងឺកូវីដ១៩ នៅក្នុងដំណាក់កាលដែលមានរលកទី២នេះ នៅក្នុងសហគមន៍យើងជាដាច់ខាត។

លោកជំទាវបានធ្វើការអំពាវនាវឱ្យប្រជាពលរដ្ឋទាំងអស់គ្នាត្រូវបង្កើនការផលិតផ្នែកកសិកម្ម តាមរយៈ ការដាំដុះ ការចិញ្ចឹមសត្វជាដើម ដើម្បីដោះស្រាយបញ្ហាជីវភាព។ ក្នុងនោះលោកជំទាវ រួមជាមួយក្រុមការងារបានចែកសម្ភារ រួមជាមួយថវិកាមួយចំនួនជូនដល់លោកយាយ និងលោកតា ចាស់ជរា មានជំងឺប្រចាំកាយចំនួន០២នាក់ផងដែរ ៕

## កម្ពុជា-ស្វីស បន្តរួមគ្នាអភិវឌ្ឍន៍ប្រព័ន្ធអប់រំបណ្តុះបណ្តាលជំនាញ និងវិជ្ជាជីវៈក្នុងដំណាក់កាលទី២

http://www.freshnewsasia.com/ 2020-06-10

**(ភ្នំពេញ)៖** ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ព្រមទាំងទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍន៍ និងកិច្ចសហប្រតិបត្តិការ (SDC) បានប្តេជ្ញារួមគ្នាអភិវឌ្ឍន៍ទៅលើប្រព័ន្ធបណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈ (TVET) ក្នុងដំណាក់កាលទី២ ស្របពេលដែលគម្រោងទី១ បានរងផលប៉ះពាល់ពីជំងឺផ្លូវដង្ហើមកូវីដ-១៩។ គម្រោងទី២នេះ ជាការបណ្តុះបណ្តាលជំនាញដល់យុវជនក្រីក្រនៅក្នុងសហគមន៍ នៃខេត្តគោលដៅចំនួន៥ នៅភាគឦសាន្តប្រទេសកម្ពុជា រួមមានខេត្តព្រះវិហារ ស្ទឹងត្រែង ក្រចេះ មណ្ឌលគិរី និងរតនគិរី។

ការលើកឡើងដូច្នេះធ្វើឡើងក្នុងជំនួបពិភាក្សាការងាររវាងលោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈជាមួយ គណៈប្រតិភូនៃទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍ និងកិច្ចសហប្រតិបត្តិការ (SDC) ដឹកនាំដោយលោកស្រី Nadia Ottiger នាយិការង ទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍ និងកិច្ចសហប្រតិបត្តិការប្រចាំកម្ពុជា នៅទីស្ដីការក្រសួងការងារ ព្រឹកថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០។ លោក អ៊ិត សំហេង បានសម្ដែងនូវអំណរគុណយ៉ាងជ្រៀលជ្រៅចំពោះរដ្ឋាភិបាលស្វីស ដែលតែងតែគាំទ្រនូវគ្រប់សកម្មភាពក្នុងការលើកកម្ពស់ធនធានមនុស្សក្នុងវិស័យការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈនៅកម្ពុជា។ លោកលើកឡើងថា គម្រោងអភិវឌ្ឍជំនាញនេះ ជាគំនិតផ្ដួចផ្ដើមដ៏ល្អប្រសើរមួយក្នុងការធ្វើសមាហរណកម្មជំនាញនៅប៉ែកឦសានប្រទេស ក្នុងការកសាងធនធានមនុស្ស សម្រាប់កម្ពុជាលើវិស័យមួយនេះ។ លោកបញ្ជាក់ថា គោលដៅនៃគម្រោងនេះគឺ ទាក់ទាញយុវជនក្រីក្រក្នុងសហគមន៍ឱ្យចាប់អារម្មណ៍ទទួលយកការបណ្ដុះបណ្ដាលជំនាញ ដើម្បីបង្កើនធនធានមនុស្ស ក៏ដូចជាបង្កើនប្រាក់ចំណូលសម្រាប់ប្រជាជនកម្ពុជាផងដែរ។

លោកស្រី Nadia Ottiger បានលើកឡើងថា គម្រោងទី២នេះ នឹងធ្វើឱ្យប្រសើរឡើង ទាំងធនធានមនុស្ស និងជីវភាពរបស់ប្រជាពលរដ្ឋ ដែលកំពុងរស់នៅក្នុងសហគមន៍នៃខេត្តទាំង៥ ភាគឦសានប្រទេសកម្ពុជា តាមរយៈទទួលបានជំនាញ និងបង្កើនប្រាក់ចំណូល សម្រាប់ទ្រទ្រង់ជីវភាពបានល្អប្រសើរ។ លោកស្រីបញ្ជាក់ថា រាល់សកម្មភាពគម្រោងទាំងមូល ត្រូវបានគាំទ្រយ៉ាងជិតស្និតពីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ក៏ដូចជាដៃគូនានាទៀត ដើម្បីអភិវឌ្ឍន៍ជំនាញ កាត់បន្ថយការធ្វើទេសន្តប្រវេសន៍ ទន្ទឹមនេះកិច្ចដំណើរការគម្រោង គឺស្របតាមយន្តការ ក៏ដូចជាកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ហើយក៏ជាការឆ្លើយតបទៅនិងតម្រូវការទីផ្សារការងារ និងអ្វីដែលនិយោជកចង់បាននាពេលបច្ចុប្បន្ននេះផងដែរ។ គួរបញ្ជាក់ថា ដំណាក់កាលទី២របស់គម្រោងមួយនេះ ត្រូវចាប់ផ្ដើមអនុវត្តចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០ រហូតដល់ ខែមិថុនា ឆ្នាំ២០២៤ ដែលមានថវិកាសរុបចំនួនប្រមាណ៩លានដុល្លារអាមេរិក។ ចំពោះលទ្ធផលនៃគម្រោងនឹងទទួលបាន ១.នូវប្រព័ន្ធ TVET កម្ពុជាមានប្រសិទ្ធភាពជាងមុន នៅតាមខេត្តគោលដៅ ក្នុងតំបន់ និងសហគ្រាស និង ២.យុវជន បុរស ស្ត្រី និងកម្មករដែលមានជំនាញទាបបានបង្កើនលទ្ធភាពទទួលបានការងារ៕

## ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២០

### ក្រុមការងារទំនាក់ទំនង កម្ពុជា-ថៃ ប្រចាំច្រកទ្វារអន្តរជាតិអូរស្មាច់ បានចូលជួបក្រុមការងារទំនាក់ទំនង ថៃ-កម្ពុជា ដើម្បីទទួលយកប្រជាពលរដ្ឋខ្មែរ ចំនួន១៩នាក់

https://www.facebook.com/GDIOfficial 10-06-2020

ក្រុមការងារទំនាក់ទំនងព្រំដែនថៃ-កម្ពុជា ប្រចាំច្រកអន្តរជាតិ ឆងចម-អូរស្មាច់ បានបញ្ជូនប្រជាពលរដ្ឋខ្មែរចំនួន ១៩នាក់ មកឲ្យព្រះរាជាណាចក្រកម្ពុជា ពាក់ព័ន្ធនឹងករណីលួចឆ្លងដែនខុសច្បាប់ ទៅធ្វើការនៅប្រទេសថៃ ហើយត្រូវបានទាហានថៃ ចាប់ឃាត់ខ្លួន នៅវេលាម៉ោង ១៤និង០០នាទី ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០។

នគរបាលប្រចាំទ្វារបានឲ្យដឹង កាលពីវេលាម៉ោង ១៨និង២០នាទី ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០នេះថា ប្រជាពលរដ្ឋខ្មែរទាំង ១៩នាក់ ស្រី ០៨នាក់ និងក្មេង ០៣នាក់ នេះ មានមកពីខេត្តឧត្តរមានជ័យ ០៤នាក់, ខេត្តបន្ទាយមានជ័យ ០៥នាក់, សៀមរាប ០៧នាក់ និងខេត្តព្រៃវែង ០៣នាក់ បន្ទាប់មកបានបញ្ជូនមកស្នងការរដ្ឋាននគរបាលខេត្ត ដើម្បីធ្វើការអប់រំណែនាំ៕

## នគរបាលប៉ុស្តិ៍ជ្រោយបន្ទាយ នៃអធិការដ្ឋាននគរបាលស្រុកព្រែកប្រសព្វ ចុះអប់រំ ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ

http://cambodiapolice.com/policekh/ 1:58 pm 10 មិថុនា 2020

ក្រចេះ ៖ នៅព្រឹកថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ កម្លាំងនគរបាលប៉ុស្តិ៍រដ្ឋបាលជ្រោយបន្ទាយ បានចុះធ្វើការផ្សព្វផ្សាយអប់រំដល់ប្រជាពលរដ្ឋនៅចំណុចចំបក់ផ្អែមភូមិទួលព្រិច ឃុំជ្រោយបន្ទាយ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ ។ ដោយនគរបាលប៉ុស្តិ៍បានលើយកនូវចំណុចសំខាន់ៗមួយចំនួន ដូចជា ៖

១-ផលប៉ះពាល់នៃគ្រឿងញៀន៩ចំណុច

២-ច្បាប់ចរាចរណ៍ផ្លូវគោកអនុក្រិត្យលេខ៣៩អនក្រឬ

៣-ល្បែងស៊ីសងខុសច្បាប់

៤-គ្រោះថ្នាក់អគ្គីភ័យផ្សេងៗ

៥-គ្រោះថ្នាក់អាវុធយុទ្ធភណ្ឌមិនទាន់ផ្ទុះ

៦-អំពើហិង្សាក្នុងគ្រួសារ

៧-ការជួញដូរផ្លូវភេទស្ត្រីនិងកុមារ

៨-ណែនាំពួកគាត់ឲ្យចេះថែរក្សាទ្រព្យសម្បត្តិដូចជាសត្វគោ ក្របី និងសម្ភារៈផ្សេងៗឲ្យបានត្រឹមត្រូវ ជៀសវាងចោរលួចដើម្បីធ្វើឲ្យភូមិ-ឃុំយើងមានសុវត្ថិភាពល្អ និងបានពន្យល់ដល់ពួកគាត់ឲ្យមានអនាម័យល្អដើម្បីការពារនូវជំងឺCOVID-19ផ្សព្វផ្សាយជាវេទិកាខ្នាតតូចមនុស្សចូលរួម៤៦នាក់ស្រី១៨នាក់ចែកខិត្តបណ្ណ៍៤៦សន្លឹកផងដែរ៕

## ឯកឧត្តម វ៉ា ថន អភិបាលខេត្តក្រចេះអញ្ជើញចូលរួមជាអធិបតីនៃទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ

https://gdlf-kh.com// Sam Sophearum ក្រចេះ 2020/06/11

ខេត្តក្រចេះ ៖ ថ្ងៃពុធ ៥រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត ដោយមានការសហការពីក្រុមហ៊ុនអភិវឌ្ឍកៅស៊ូ ដុងណាយ និងដុងភូ នៅឃុំអូរគ្រៀង ស្រុកសំបូរ ខេត្តក្រចេះ បានរៀបចំពិធីអបអរសាទរខួបលើកទី១៩ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២ មិថុនា និងទិវាកុមារកម្ពុជាឆ្នាំ២០២០ ក្រោមអធិបតីភាព ឯកឧត្តម វ៉ា ថន អភិបាលខេត្តក្រចេះ ដោយមានការអញ្ជើញចូលរួមពីមន្ត្រីរាជការ អាជ្ញាធរពាក់ព័ន្ធ លោកគ្រូ អ្នកគ្រូ ភ្ញៀវជាតិ អន្តរជាតិ កម្មករកម្មការិនីនៃក្រុមហ៊ុនចំការកៅស៊ូដុងណាយ និងដុងភូ ព្រមទាំងមាតាបិតាអាណាព្យាបាលសិស្ស កុមារា កុមារី ប្រមាណ៤០០នាក់។ នៅក្នុងសន្ទរកថាស្វាគមន៍របស់លោក កែវ កុសល ប្រធានមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈបានបញ្ជាក់ថារាជរដ្ឋាភិបាលបានខិតខំយកចិត្តទុកដាក់អនុវត្ត និងសម្រេចបាននូវសមិទ្ធផលជាច្រើន ស្របតាមផែនការសកម្មភាពជាតិស្តីពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ។ ដើម្បីសម្រេចបាននូវគោលដៅដែលរាជរដ្ឋាភិបាលបានដាក់ចេញពាក់ព័ន្ធនឹងការការពារ និងការលើកកម្ពស់សិទ្ធិកុមារ ការទប់ស្កាត់ និងការដកហូតកុមារពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ មន្ទីបានខិតខំយកចិត្តទុកដាក់តាមដានសង្កេត និងចុះធ្វើអធិការកិច្ចការងារក្នុងឆ្នាំ២០២០កន្លងមកនេះបានស្តែង ឲ្យឃើញតាមរយៈការហាមប្រាម និងធ្វើសកម្មភាពបន្ទាន់សម្រាប់ការលប់បំបាត់ទម្រងធ្ងន់ធ្ងរនៃពលកម្មកុមារ និងអាយុអប្បរមាសម្រាប់ចូលធ្វើការងារ សំដៅទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារធ្ងន់ធ្ងរដូចជា ទាសករកុមារ ការជួញដូរកុមារ ពេស្យាចារកុមារ និងការប្រើប្រាស់កុមារក្នុងស្ថានភាពវង់គ្រោះ ។

មានប្រសាសន៍សំណេះសំណាលក្នុងឱកាសនោះឯកឧត្តម វ៉ា ថន អភិបាលខេត្តក្រចេះបាន សម្តែងអំណរគុណចំពោះមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត ដោយមានការសហការពីក្រុមហ៊ុនអភិវឌ្ឍកៅស៊ូ ដុ

ងណាយ និងដុងកូ ដែលបានរៀបចំពិធីឡើងនៅតំបន់ជនបទដាច់ស្រយាលមួយនេះ ដើម្បីឲ្យប្រជាពលរដ្ឋនៅទីនេះបានយល់ដឹងពីពលកម្មធ្ងន់ធ្ងរចំពោះកុមារបណ្តាលឲ្យកុមារបាត់បង់ឱកាស់រៀនសូត្រ ប៉ះពាល់ដល់សុខភាព គំនិតប្រាជ្ញា ស្មារតីធ្វើឲ្យកាយសម្បទាគ្រិន ស្គមស្គាំងជាដើម។ ហើយស្ថានភាពក្រីក្រពិសេសនៅតំបន់ដាច់ស្រយាល មានការបង្ខំឲ្យកុមារត្រូវតស៊ូធ្វើការងារដើម្បីចិញ្ចឹមជីវិតដោយខ្លួនឯង និងជួយដោះស្រាយជីវភាពគ្រួសារផងដែរ ។ ឯកឧត្តមបន្តថា ការប្រារព្ធពិធីនេះឡើង ដើម្បីជួយដល់ប្អូនៗ ក្មួយៗកុមាទូទាំងប្រទេសពិសេសកុមារក្នុងខេត្តក្រចេះទាំងអស់ឲ្យរួចចាកផុតពីពលកម្មដ៏ធ្ងន់ធ្ងរ និងមានឱកាសទទួលបាននូវការអប់រំក្នុងសាលារៀនចំណេះទូទៅគ្រប់ៗគ្នា ។ ឯកឧត្តមអភិបាលខេត្តក៏បានផ្តល់នូវការណែនាំ និងអំពាវនាវដល់មាតាបិតា អាណាព្យាបាល និងនិយោជកនៃ ក្រុមហ៊ុន សហគ្រាស គ្រឹះស្ថានទាំងអស់ត្រូវមានផែនការប្រកបកដោយប្រសិទ្ធភាព ដើម្បីលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ព្រទាំងផែនការដាក់ស្តែងដើម្បីទប់ស្កាត់ពលកម្មកុមារ ដោយដកហូតកុមារចេញពីកន្លែងធ្វើការងារ និងធ្វើសមាហរណកម្មកុមារតាមសហគមន៍វិញ តាមរយៈការផ្តល់ការអប់រំរៀនសូតជាមូលដ្ឋាន ។

ជាចុងបញ្ចាប់ ឯកឧត្តមអភិបាលខេត្តបានផ្តាំផ្ញើដល់បងប្អូនប្រជាពលរដ្ឋអោយមានការប្រុងប្រយ័ត្នការពារការរាតត្បាតនៃជំងឺកូវីដ១៩ រស់នៅប្រកបដោយអានាម័យ មានបរិស្ថានល្អ ក្នុងសហគមន៍គ្មានគ្រឿងញៀន ធ្វើដំណើរត្រូវ គោរពច្បាប់ចរាចរណ៍ ព្រមទាំងរួមគ្នាធ្វើឲ្យភូមិ ឃុំមានសុវត្ថិភាព ។ ហើយឯកឧត្តមក៏បានជូនវត្ថុអនុស្សាវរីរ៍ និងថវិកាមួយចំនួនដល់ក្មួយកុមារ និងបងប្អូនប្រជាពលរដ្ឋដែលបានចូលរួមពិធីផងដែ ៕

## គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានចុះទៅសាកសួរសុខទុក្ខស្ត្រីរងគ្រោះ ដែលមកពីប្រទេសចិន

---

http://kampucheathmey.com/ 11/6/2020 7:40 Am

ក្រចេះ ៖ គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានចុះទៅសាកសួរសុខទុក្ខស្ត្រីរងគ្រោះដែលប្រទេសចិនបានបញ្ជូនមកប្រទេសកម្ពុជាវិញ និងកំពុងដាក់ចត្តាឡីស័ក្ត១៤ថ្ងៃ នៅមន្ទីរពេទ្យបង្អែកឆ្លូង ស្ថិតក្នុងស្រុកឆ្លូង ខេត្តក្រចេះ នារសៀលថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២០។

តាមការរៀបរាប់របស់ស្ត្រីរងគ្រោះឱ្យដឹងថា នាងមានទីលំនៅក្នុងភូមិជ្រោយថ្មក្រោម ឃុំឆ្លូង ស្រុកឆ្លូង បានចាញ់បោកមេខ្យល់នាំទៅធ្វើការដោយខុសច្បាប់កាលពីខែកក្កដា ឆ្នាំ២០១៩។ នាងបានចេញដំណើរតាមច្រកអន្តរជាតិបាវិត និងបានជិះឡានទៅដល់ព្រំដែនវៀតណាម ចិន ព្រមទាំងធ្វើដំណើរដោយថ្មើរជើងឆ្លងទៅប្រទេសចិន។ នាងបានធ្វើការដោយខុសច្បាប់នៅទីនោះ និងបានស្រលាញ់គ្នាជាមួយបុរសចិនរហូតមានផ្ទៃពោះ។ ពេលនាងមានផ្ទៃពោះបាន៥ខែ នាងបានធ្វើដំណើរត្រឡប់មកស្រុកខ្មែរវិញ ដោយជិះឡានតាមច្រកចិន វៀតណាម ហើយត្រូវប៉ូលីសចិនចាប់(ពីព្រោះពុំមានឯកសារស្របច្បាប់) និងជាប់ឃុំនៅខេត្តគាន់ស៊ី ប្រទេសចិនចំនួន៣ខែ មុនពេលនាងបានត្រឡប់មកប្រទេសកម្ពុជាវិញ។ អ្នកជាប់ឃុំនៅទីនោះហូបបាយ១ថ្ងៃ២ ពេលជាមួយឆៃប៉ូវ ប៉ុន្តែសម្រាប់នាងដែលមានផ្ទៃពោះ ត្រូវបានប៉ូលីសចិនឱ្យរស់នៅបន្ទប់សមរម្យ និងផ្តល់អាហារគ្រប់គ្រាន់។ នាងជាប់ឃុំបាន២ខែ ស្ថានទូតខ្មែរបានទៅជួបសួរសុខទុក្ខ និងជួយនាង ហើយរយៈពេលមួយខែក្រោយមក នាងបានវិលត្រឡប់មកប្រទេសកម្ពុជាវិញ។

ដោយសារនាងចេះភាសាចិនខ្លះៗ ប៉ូលីសចិនបានឱ្យនាងជួយបកប្រែស្ត្រីខ្មែរដែលកំពុងជាប់គុកនៅខេត្តគាន់ស៊ី ប្រទេសចិន ចំនួន៧នាក់ទៀត ដែលក្នុងនោះមាន១នាក់ទីលំនៅក្នុងខេត្តកំពង់ឆ្នាំង នឹងវិលត្រឡប់មកប្រទេសកម្ពុជាវិញនៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២០ខាងមុខនេះ។ ចំណែក៦នាក់ទៀតមានទីលំនៅក្នុងខេត្តកំពង់ធំ ពុំទាន់ដឹងពីលទ្ធផលនៃការត្រឡប់មកវិញនៅឡើយ។ នារីរងគ្រោះទាំងនោះ មានខ្លះអាយុ១៦ឆ្នាំ ១៨ឆ្នាំ និងជាង៣០

ឆ្នាំ។ ពួកនាងសុទ្ធតែចាញ់បោកមេខ្យល់និងធ្វើដំណើរឆ្លងកាត់តាមប្រទេសវៀតណាម ដូចស្ថានភាពរបស់នាងដែរ។ សូមបងប្អូនខ្មែរ ឈប់ចាញ់បោកតាមការបញ្ឆោតរបស់មេខ្យល់ក្នុងការនាំទៅធ្វើការនៅក្រៅប្រទេស ដោយខុសច្បាប់៕ អត្ថបទ៖ ឧត្តរ៉ា

## ឃាត់ខ្លួនមេខ្យល់២នាក់ នាំពលករឆ្លងដែនខុសច្បាប់ចំនួន ២៧នាក់ ទៅធ្វើការនៅថៃ

http://peoplenews.asia/ 11-06-2020

ខេត្តបន្ទាយមានជ័យ៖ កម្លាំងវរការពារព្រំដែនគោកប្រចាំខេត្តឧត្តរមានជ័យ សហការជាមួយកម្លាំងនគរបាលក្រុងសំរោង កាលពីថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ បានធ្វើការឃាត់ខ្លួនមេខ្យល់នាំពលកឆ្លងដែនទៅប្រទេសថៃចំនួន ២នាក់ នៅចំណុចភូមិសាស្ត្រអូរខ្លាឃ្មុំ សង្កាត់អូរស្មាច់ ក្រុងសំរោង រួមជាមួយពលករប្រុស ស្រីចាញ់បោកគេចំនួន ២៧នាក់ផង។

លោក ហម ភិរម្យ អធិការនគរបាលក្រុងសំរោង បានឲ្យដឹងថា សម្ថកិច្ចបានឃាត់ខ្លួនមេខ្យល់ទី១ ឈ្មោះ គង់ សារឿន ភេទប្រុស អាយុ ៥០ឆ្នាំ រស់នៅភូមិគីរីមង្គល សង្កាត់អូរស្មាច់ ក្រុងសំរោង និងទី២ ឈ្មោះ ទិត គ័យ ភេទស្រី អាយុ៥១ឆ្នាំ រស់នៅភូមិចំការចេក សង្កាត់អូរស្មាច់ ក្រុងសំរោង អ្នកទាំងពីរនាក់ ជាមេខ្យល់នាំមនុស្សប្រុសស្រី ឆ្លងដែនខុសច្បាប់ទៅធ្វើការនៅប្រទេសថៃ។

រីឯអ្នកចាញ់បោកមេខ្យល់ៗនាក់នេះ ចំនួន ២៧នាក់ មកពីខេត្តឧត្តរមានជ័យចំនួន ៦នាក់ ខេត្តបន្ទាយមានជ័យ ចំនួន ៨នាក់ ខេត្តសៀមរាប ចំនួន ១០នាក់ និងខេត្តព្រៃវែង ចំនួន ៣នាក់។ ក្រោយឃាត់ខ្លួនអ្នកចាញ់បោកមេខ្យល់ទាំងពីរនាក់នេះ ជនរងគ្រោះទាំងអស់ត្រូវសមត្ថកិច្ចអប់រំណែនាំឲ្យវិលត្រឡប់ទៅលំនៅដ្ឋានវិញរៀងៗខ្លួន។ ចំណែកមេខ្យល់ទាំងពីរនាក់ខាងលើត្រូវបានបញ្ជូនមកអធិការដ្ឋាននគរបាលក្រុងសំរោង ដើម្បីធ្វើការសួរនាំបន្ត និងកសាងសំណុំរឿងបញ្ជូនទៅសាលាតំបូងខេត្តឧត្តរមានជ័យចាត់ការតាមផ្លូវច្បាប់។ ដោយជោគជ័យ

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៤៩នាក់

https://www.facebook.com/GDIOfficial 10-06-2020

នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៤៩នាក់ ស្រី ២៥នាក់៕

## សមត្ថកិច្ចថៃ ចាប់ឃាត់ខ្លួនពលរដ្ឋខ្មែរចំនួន ២១នាក់ ដែលលួចឆ្លងដែនចូលប្រទេសខ្លួន ដោយខុសច្បាប់

http://www.matimohachunnews.com/ June 11, 2020

ប្រទេសថៃ៖ សមត្ថកិច្ចថៃ បានចាប់ឃាត់ខ្លួនពលរដ្ឋខ្មែរចំនួន២១ ដែលលួចចូលប្រទេសថៃ ដោយខុសច្បាប់ នៅភូមិសាស្ត្រស្រុកអារញ្ញ ខេត្តស្រះកែវ កាលពីថ្ងៃទី១០ ខែមិនថុនា ឆ្នាំ២០២០។ សមត្ថកិច្ចទាហានឈុតខ្មៅកងវរយទី1206 បានប្រមូលផ្តុំកម្លាំងដោយ សហការជាមួយតម្រួត ខ្លង ណាំសៃ ស្រុកអារញ្ញ ខេត្តស្រះកែវ ចេញ

ល្បាត និងឃ្លាំមើល ដើម្បីទប់ស្កាត់ទង្វើខុសច្បាប់ផ្សេងៗ និងការលួចចូលមកប្រទេសដោយខុសច្បាប់ នៅតាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ។ លុះមកដល់បរិវេណភូមិផានសឹក ឃុំផានសឹក ស្រុកអារញ្ញ ខេត្តស្រះកែវ សមត្ថកិច្ចបានឃើញពលករខ្មែរចំនួន២១នាក់ ក្នុងនោះប្រុស១៥នាក់ និងស្រី៦នាក់ ព្រមទាំងបាល់ឡដាក់សម្ភារៈ ទើបសមត្ថកិច្ចនាំយកទៅទីបញ្ជាការកងរយទាហានឈុតខ្មៅទី1206 ព្រមទាំងរាយការណ៍ជូនថ្នាក់លើ។

សូមបញ្ជាក់ថា សមត្ថកិច្ចបានឱ្យដឹងថា បន្ទាប់ពីធ្វើការឆែកឆេរ ឃើញថា មិនមាននៅឯកសារធ្វើដំណើរ ឬឯកសារអនុញ្ញាតិ ធ្វើការនៅប្រទេសថៃនោះឡើយ និងបន្ទាប់ពីសួរចម្លើយពលករខ្មែរទាំងអស់ខាងលើ បានឱ្យដឹងថា ពួកគេចង់ចូលមកធ្វើការនៅប្រទេសថៃ ដោយសារនៅប្រទេសកម្ពុជាមិនមានការងារធ្វើ និងមិនមានលុយចាយវាយ ស្ទើតែដាច់ពោះស្លាប់ទៅហើយ ទើបមិនខ្លាចវីរុសខូវីត-19ហើយ ទើបសម្រេចចិត្តបបួលគ្នាលបលួចចូលថៃដើម្បីទៅធ្វើការនៅក្រុងបាងកក និងនៅឈុនបុរី ដែលធ្លាប់លួចចូលទៅធ្វើការសំណង់រួចមកហើយ មុនហ្នឹងខូវីត-19រាត្បាត ហេតុត្រូវធ្វើដំណើរត្រឡប់ទៅផ្ទះ នៅឯប្រទេសកម្ពុជាកាលពីកន្លងមក។

យ៉ាងណាក៏ដោយ ក្រោយពីសួរនាំ សមត្ថកិច្ចបានថតរូប ចុះក្នុងកំណត់ហេតុទុកជាភស្តុតាង និងបានពិនិត្យកំដៅ និងយកម៉ាស់អនាម័យមកចែកឱ្យពលករខ្មែរពាក់ មុនហ្នឹងអនុញ្ញាតិឱ្យវិលត្រឡប់មកប្រទេសកម្ពុជាវិញតាមប៉ុស្តិ៍ត្រួតពិនិត្យភូមិណូនម៉ាកមុន ឃុំណូនម៉ាក់មុន ស្រុកគោកឃ្មុំ ខេត្តស្រះកែវ ដើម្បីប្រគល់ឱ្យខាងកម្ពុជា៕

## មិនមែនប្រព្រឹត្តលើក្មេងស្រីតែម្នាក់ឯណា គឺថែម២នាក់ទៀត

https://kohsantepheapdaily.com.kh/ ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០២០ ម៉ោង ១៤:២២ ប៊ុន លីនណា

ខេត្តក្រចេះ៖ បុរសវ័យចំណាស់ម្នាក់ ដែលបានធ្វើសកម្មភាពរំលោភសេពសន្ថវៈលើក្មេងស្រីរងគ្រោះមិនទាន់គ្រប់អាយុចំនួន៣នាក់ ហើយថែមទាំងប្រើទូរស័ព្ទថតប្រដាប់ភេទពួកនាងយករូបភាពទៅចែកចាយទៀតផងនោះ ត្រូវបានតុលាការខេត្តក្រចេះសម្រេចធ្វើការឃុំខ្លួននៅពន្ធនាគារខេត្ត ក្រោយពីកម្លាំងនគរបាលជំនាញប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនបានឃាត់ខ្លួន និងកសាងសំណុំរឿងរយៈពេល៣ថ្ងៃរួចមក។

ចៅក្រមសាលាដំបូងខេត្តក្រចេះ លោកញិល ប៊ុនលី បានសម្រេចធ្វើការឃុំខ្លួនជនសង្ស័យឈ្មោះ អម អៀមអាយុ៥៤ឆ្នាំ មានទីលំនៅភូមិបាត់ហើយ ឃុំស្រែចារ ស្រុកស្នួល នៅពន្ធនាគារខេត្ត ក្រោមបទចោទប្រកាន់ពីបទរំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោស ទាក់ទងទៅនិងជនរងគ្រោះដែលបានប្រព្រឹត្តកាលពីថ្ងៃទី២៨ ខែឧសភា នៅក្នុងស្រុកស្នួល។

លោកស្រីឧត្តមសេនីយ៍ត្រី នៅ រតនា ស្នងការរងទទួលបន្ទុកកិច្ចការងារប្រឆាំងការជួញដូរមនុស្ស និងការពារអនីតតិជន នៃស្នងការដ្ឋាននគរបាលខេត្តក្រចេះបានថ្លែងឲ្យដឹង នៅថ្ងៃទី១១ ខែមិថុនា នេះថា ជនសង្ស័យត្រូវបានចាប់ខ្លួនទៅតាមពាក្យបណ្តឹងរបស់ម្តាយ ក្មេងស្រីរងគ្រោះអាយុ១១ឆ្នាំម្នាក់ នៅពេលនាងបានយករឿងនេះប្រាប់មកឪពុកម្តាយរបស់នាង ក្រោយបានរងការចាប់រំលោភពីជនសង្ស័យជាលើកចុងក្រោយកាលពីថ្ងៃទី៥ មិថុនា។ ក្មេងស្រីរងគ្រោះមានចំនួន៣នាក់ មានអាយុចាប់ពី១០ឆ្នាំដល់១២ឆ្នាំ ក្នុងនោះមានពីរនាក់ជាបងប្អូនបង្កើត។ បើតាមលោកស្រីឧត្តមសេនីយ៍ត្រី ស្នងការរងបានបញ្ជាក់ថា កាលពីចុងខែឧសភា បុរសសង្ស័យបានធ្វើសកម្មភាពរំលោភលើក្មេងស្រីអាយុ១២ឆ្នាំម្នាក់ និងបានយកទូរស័ព្ទថតប្រដាប់ភេទនាងទៀតផង។ នៅពេលធ្វើសកម្មភាពរំលោភនាងជាលើកចុងក្រោយ នាងបម្រុងស្រែកតែនាងមិនហ៊ាន ដោយសារត្រូវជននេះគំរាមបាញ់សម្លាប់នាងចោល។ តែបើទោះជាបែបណា នាងសម្រេចយករឿងទាំងអស់នេះប្រាប់មកឪពុកម្តាយទើបបែកធ្លាយ ហើយនគរបាលក៏ឈានទៅចាប់ខ្លួនជននេះមកសាកសួរ។

លោកស្រីស្នងការរងបានឲ្យដឹងទៀតថា ក្រោយការឃាត់ខ្លួនមកសាកសួរ ជនសង្ស័យបានឆ្លើយថា «**មានក្មេងស្រីរងគ្រោះ នៅក្នុងភូមិពីរនាក់ផ្សេងទៀត ត្រូវរូបគេធ្វើសកម្មភាពចាប់ រំលោភក្នុងសកម្មភាពដូចៗគ្នា**» ។ ក្មេងស្រីរងគ្រោះទាំង៣នាក់បានឆ្លើយប្រាប់នគរបាលថា ពួកនាងបានរងការចាប់រំលោភសេពសន្ថវៈពីជននេះ ជាច្រើនលើកច្រើនសារចាំមិនអស់។ ។ សកម្មភាពរបស់ជននេះ បានធ្វើមកលើពួកនាងនៅពេលឪពុកម្ដាយមិននៅ។ ដោយជនសង្ស័យបានល្បួងពួកនាងឲ្យមើលទូរស័ព្ទ រួចបានធ្វើសកម្មភាពរំលោភតែម្ដង។

## ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២០

### លេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តសៀមរាប បានចុះសួរសុខទុក្ខ និងបានផ្ដល់ជូនស្បៀង និងសម្ភារសិក្សាដល់គ្រួសារកុមារក្រីក្រ ចំនួន ៦០គ្រួសារ ក្នុងខេត្តសៀមរាប

https://www.facebook.com/deputygovernoryousophear/ 12-06-2020

ខេត្តសៀមរាប៖ នៅព្រឹកថ្ងៃពុធ ៥រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤ ត្រូវនឹងថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ លេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តសៀមរាប (គ.ខ.ប.ជ) ដឹកនាំដោយលោកស្រី យូ សុភា អភិបាលរងខេត្តសៀមរាប និងជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ សហការជាមួយអង្គការសកម្មភាពដើម្បីកុមារ (APLE) និងមានការនិមន្តចូលរួមពីព្រះអនុគនក្រុងសៀមរាប មន្ទីរ អង្គភាពពាក់ព័ន្ធ រដ្ឋបាលក្រុងសៀមរាប ក្រុមប្រឹក្សាសង្កាត់គោកចក សង្កាត់សៀមរាប និងសង្កាត់ស្លក្រាមផងដែរ ក្នុងការចុះសួរសុរទុក្ខនិងបានផ្ដល់ជូនកញ្ចប់គាំទ្រជាស្បៀង និងសម្ភារសិក្សាសម្រាប់កុមារ និងគ្រួសារកុមារក្រីក្រ ដែលងាយរងគ្រោះដោយការរំលោភបំពាននានា នៅក្នុងខេត្តសៀមរាប ចំនួន ៦០គ្រួសារ។ សូមជម្រាបថា គ្រួសារទាំង ៦០នេះរួមមានមកពី សង្កាត់សៀមរាប ២២គ្រួសារ សង្កាត់ស្លក្រាម១៨ គ្រួសារ សង្កាត់គោកចក ចំនួន១៤គ្រួសារ ក្នុងក្រុងសៀមរាប និងឃុំចាន់សរ ស្រុកសូទ្រនិគម ចំនួន ០៦ គ្រួសារ ដែលរៀបចំ នៅវត្តពោធិវង្ស ហៅវត្តថ្មី សង្កាត់គោកចក ក្រុង និងខេត្តសៀមរាប។

មានប្រសាសន៍នៅក្នុងពិធីចុះជួបសួរសុខទុក្ខនោះផងដែរ លោកស្រី យូ សុភា អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានថ្លែងអំណរគុណដល់អង្គការសកម្មភាពដើម្បីកុមារ ដែលបានសហការជាមួយលេខាធិការដ្ឋាន គ.ខ.ប.ជ អាជ្ញាធរខេត្ត ក្រុង សង្កាត់ និងព្រះអនុគនក្រុងជាព្រះចៅអធិការវត្ត ក្នុងការរៀបចំផ្ដល់ជូនស្បៀង និងសម្ភារសិក្សា ដល់ប្រជាពលរដ្ឋខេត្តសៀមរាបនាថ្ងៃនេះ ក៏ដូចជាកិច្ចសហការនាពេលកន្លងមកជាច្រើនផងដែរ។ នៅក្នុងស្ថានភាពនៃការទប់ស្កាត់ការរីករាល់ដាលនៃជំងឺកូវីដ១៩ លោកស្រីបានផ្ដាំផ្ញើដល់បងប្អូនប្រជាពលរដ្ឋ អំពីការធ្វើអនាម័យ ការលាងសំអាតដៃជាមួយអាកុល ចេល ឬសាប៊ូឲ្យបានញឹកញាប់ និងថែរក្សាសុខភាពរបស់ខ្លួនតាមការណែនាំរបស់ក្រសួងសុខាភិបាល ឱ្យបានជាប់ជានិច្ច។ បន្ថែមពីនោះ លោកស្រីបានផ្សព្វផ្សាយអំពីការទប់ស្កាត់ការធ្វើចំណាកស្រុកខុសច្បាប់ទៅក្រៅប្រទេស ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងជំរុញឲ្យអាណាព្យាបាលទាំងអស់ត្រូវយកចិត្តទុកដាក់លើការថែរក្សាកូនៗ ការពារកុំឲ្យមានការកេងប្រវ័ញ្ច ណាមួយលើកុមារ ពិសេសការយកកុមារទៅដើរសុំទាន ឬដើរស៊ីឈ្នួលគេ ដោយប្រកាសណាមួយដែលជាហានិភ័យធ្វើឲ្យកុមាររងគ្រោះឬងាយរងគ្រោះដោយការរំលោភបំពានផ្សេងៗ ,។

ជាមួយគ្នានេះ ក្រុមការងារក៏បាននាំយកមកនូវជាស្បៀងនិងសម្ភារ ដើម្បីផ្ដល់ជូនដល់គ្រួសារកុមារក្រីក្រ ចំនួន ៦០គ្រួសារ ដែលជាក្រុមគោលដៅរបស់អង្គការសកម្មភាពដើម្បីកុមារ ក្នុងខេត្តសៀមរាប ដោយក្នុងមួយគ្រួសារទទួលបាន ៖ អង្ករ ២៥គីឡូក្រាម, មី ១កេះ, ត្រីខ១យួរ, ទឹកត្រី១យួរ, ទឹកស៊ីអ៊ីវ ១យួរ, អំបិល ១កញ្ចប់, សាប៊ូដុសខ្លួន ១ប្រអប់, សាប៊ូម្សៅ ១កញ្ចប់, ប្រេងឆា ១ដប, ទឹកអាកុលលាងដៃ ២ដប់, ម៉ាសក្រណាត់ចំនួន ១ដុំ (ចំនួន ៦ម៉ាស)សម្ភារសិក្សា និងថវិកា ចំនួន ៤០,០០០ រៀល ផងដែរ ។

## កិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរ មនុស្សប្រចាំឆមាសទី១ និងទិសដៅបន្តឆមាសទី២ ឆ្នាំ២០២០

https://gdlf-kh.com/ Kao sophy ខេត្តស្វាយរៀង 2020/06/12/

ខេត្តស្វាយរៀង៖ នៅរសៀលថ្ងៃព្រហស្បតិ៍ ៦រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២០ លោកជំទាវ ឯក សុវណ្ណការៈ អភិបាលរងខេត្តស្វាយរៀង តំណាង ឯកឧត្តម ម៉ែន វិបុល អភិបាលខេត្ត បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរ មនុស្សប្រចាំឆមាសទី១ និងទិសដៅបន្តឆមាសទី២ ឆ្នាំ២០២០ របស់គ.ខ.ប.ជ។

អញ្ជើញចូលរួមក្នុងកិច្ចប្រជុំនេះមាន លោកព្រះរាជអាជ្ញារងសាលាដំបូងខេត្ត តំណាងកងកម្លាំងទាំងបី លោក លោកស្រីប្រធាន-អនុប្រធានមន្ទីរ-អង្គភាពពាក់ព័ន្ធ លោក លោកស្រី អភិបាលរង ក្រុង ស្រុក លោក លោកស្រី ប្រធាន អនុប្រធាន និងសមាជិកលេខាធិការដ្ឋានខេត្ត ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អធិការនគរបាល អង្គការដៃគូពាក់ព័ន្ធនានាជាច្រើនរូបទៀត។

លោកជំទាវអភិបាលរងខេត្តមានប្រសាសន៍ថា ដោយមានការគាំទ្រពីឯកឧត្តម ម៉ែន វិបុល អភិបាលនៃគណៈ អភិបាលខេត្ត និងជាប្រធាន គ.ខ.ប.ជ ធ្វើអោយលេខាធិការដ្ឋានខេត្ត ក្រុមការងារ ទាង០៦ និងស្រុក/ក្រុង បានសហការជាមួយអង្គការដៃគូចុះធ្វើការផ្សព្វផ្សាយច្បាប់បង្រ្កាបអំពើជួញ ដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុក និងកិច្ចគាំពារកុមារដល់ប្រជាពលរដ្ឋនៅតាម មូលដ្ឋានសម្រេចបានលទ្ធផលល្អប្រសើរ។ លោកជំទាវបន្តថា ចំណុចសំខាន់ៗដែលធ្វើឲ្យការងារ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សមានដំណើរការ ល្អ ក៏ដោយសារចូលរួមពីគ្រប់សមត្ថកិច្ចពាក់ព័ន្ធទាំងអស់ដែលខិតខំបន្តការយកចិត្តទុកដាក់ក្នុងការ ពិនិត្យមើលទៅលើយន្តការនៃរចនាសម្ព័ន្ធគ្រប់ថ្នាក់ ទៅលើប្រព័ន្ធនីតិវិធីនៃការអនុវត្តលិខិតបទដ្ឋាន គតិយុត្ត និងគោលនយោបាយយុទ្ធសាស្ត្រនានាក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងមានផែនការសកម្មភាពស្របតាមបរិបទសង្គមនៅតាមមូលដ្ឋាន ដោយប្រើមធ្យោបាយសរុប កម្លាំងសរុប វិធានការសរុប ដើម្បីជំរុញផែនការសកម្មភាពអនុវត្តការងារនេះឲ្យមានប្រសិទ្ធភាព និងទទួលបានជោគជ័យ ។

លោកជំទាវបន្ថែមថា អំពើជួញដូរនេះ បានបង្កនូវការគំរាមកំហែង ដោយផ្ទាល់ទៅលើវប្បធម៌ និងប្រពៃណីគ្រួសារ តម្លៃសង្គមកម្ពុជា ដូច្នេះអាជ្ញាធរពាក់ព័ន្ធទាំងអស់ ដូច្នេះអាជ្ញាធរពាក់ព័ន្ធ ត្រូវបន្តពង្រឹងគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ដើម្បីតាមដាននូវសកម្មភាពបទល្មើសជួញ ដូរមនុស្ស និងត្រូវដាក់ផែនការតាមដានគ្រប់ក្រុង ស្រុក និងតាមច្រកទ្វាព្រំដែននានាជាប់ប្រទេស ជិតខាង ក្នុងការទប់ស្កាត់ ការបង្រ្កាបការជួញដូរ មនុស្សឲ្យមានប្រសិទ្ធភាពខ្ពស់។

## ផ្តន្ទាទោសស្រ្តី២នាក់ ដែលកេងប្រវ័ញ្ចពលកម្មកុមារ ក្រោមរូបភាពសុំទាន ដាក់ពន្ធនាគារ១៦ថ្ងៃ

---

http://kampucheathmey.com/ 12/6/2020 9:59 Am

ភ្នំពេញ ៖ ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ នាថ្ងៃទី ១១ មិថុនា ឆ្នាំ២០២០នេះបានប្រកាសសាលក្រមសម្រេចផ្តន្ទាទោសស្ត្រី២នាក់ ដែលកេងប្រវ័ញ្ចលើពលកម្មកុមារដាក់ពន្ធនាគារ៣ខែ តែទោសនេះត្រូវអនុវត្តណ្ឌកម្មក្នុងពន្ធនាគារត្រឹម១៦ថ្ងៃ ទោសសលពីនេះត្រូវព្យួរ ក្រោមការចោទប្រកាន់ពីបទ « កេងប្រវ័ញ្ចពលកម្មកុមារ » ។ ជនជាប់ចោទជាមេខ្យល់ដែលតុលាការផ្តន្ទាទោសទី១ឈ្មោះ ផៃ ធឿន ភេទស្រី អាយុ៥៨ឆ្នាំ ស្នាក់នៅភូមិ អន្ទង់៤ សង្កាត់គោករការ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ និងមុខរបរមិនពិតប្រាកដ ។ ទី២ឈ្មោះ នួន ទូច ភេទស្រី អាយុ២៨ឆ្នាំ ស្នាក់នៅភូមិ អន្ទង់៤ សង្កាត់គោករការ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ។

កាលពីរសៀលថ្ងៃទី២៨ ឧសភា ឆ្នាំ២០២០ កម្លាំងសមត្ថកិច្ចជំនាញនគរបាលការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនរាជធានីភ្នំពេញ បានចុះអនុវត្តតាមចំណារអនុញ្ញាតិឲ្យបង្រ្កាបជាក់ស្តែង របស់លោក ម៉ុត ដារ៉ា ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ លើករណីកេងប្រវ័ញ្ចពលកម្មកុមារ ក្នុងរូបភាពបង្ខំឲ្យក្មេងដើរសុំទានតាមភ្លើងស្តុប ឈានដល់ការឃាត់ខ្លួនមេខ្យល់២ នាក់ និងសង្រ្គោះកុមាររងគ្រោះ៦ នាក់ ។

លោកវរៈសេនីយ៍ឯក កែវ ធា ប្រធានការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការ ពារអនីតិជនរាជធានីភ្នំពេញ បានឲ្យដឹងថា ជនសង្ស័យ២នាក់ និងត្រូវកសាងសំណុំរឿងបញ្ជូនទៅកាន់សាលាដំបូងភ្នំពេញ នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២០ ហើយត្រូវចៅក្រមតុលាការសម្រេចឃុំខ្លួនបណ្តោះអាសន្ន ។ ចំណែកជនរងគ្រោះត្រូវបានប្រគល់ឲ្យទៅមន្ទីរសង្គម កិច្ច យកទៅគ្រប់គ្រង ។ លោក កែវ ធា បន្តថា ករណីខាងលើនេះសមត្ថកិច្ចយើងបានសង្រ្គោះកុមាររងគ្រោះចំនួន៦នាក់ (ស្រី៣នាក់) ក្នុងនោះមានទារកចំនួន ២នាក់ប្រុស ដែលជាករណី កេងប្រវ័ញ្ចពលកម្មលើកុមារ (ក្នុងរូបភាពដើរសុំទាន) នៅចំណុចក្នុងផ្សារបឹងឈូក សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។ ក្រោយជាប់ឃុំឃាំងអស់រយៈពេល១៥ថ្ងៃ តុលាការបានបកសវនាការ ហើយសម្រេចផ្តន្ទាទោសឈ្មោះ ផៃ ធឿន និង នួន ទូច ដាក់ពន្ធនាគារកំណត់ក្នុងឃុំត្រឹម១៦ថ្ងៃប៉ុណ្ណោះ ពោលគឺជនត្រូវចោទនឹងរួចពីពន្ធនាគារនៅថ្ងៃសុក្រនេះ ៕ អត្ថបទ៖ មករា

## កម្ពុជាកំពុងត្រៀមរៀបចំច្បាប់
## ស្តីពីកិច្ចការពារកុមារក្នុងការដោះស្រាយបញ្ហានានារបស់កុមារ

http://btv.com.kh/ 12/06/2020

ភ្នំពេញ ៖ ប្រទេសកម្ពុជា កំពុងត្រៀមរៀបចំច្បាប់ស្តីពី កិច្ចការពារកុមារ ក្នុងគោលបំណងសំខាន់ ដោះស្រាយបញ្ហានានា ដែលកើតឡើងចំពោះកុមារឱ្យកាន់តែមានប្រសិទ្ធភាព។ នេះជាការលើកឡើងរបស់ អ្នកនាំពាក្យក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ ស្របគ្នាទៅនឹង ខួបលើកទី៧១ ទិវាកុមារអន្តរជាតិ១ មិថុនា និងខួបលើកទី១៩ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២ មិថុនា និងទិវាកុមារ កម្ពុជាឆ្នាំ២០២០ ឯកឧត្តម តូច ចាន់នី ជាអ្នកនាំពាក្យក្រសួងសង្គមកិច្ច បានលើកឡើងថា កម្ពុជាកំពុងត្រៀមច្បាប់ ស្តីពីកិច្ចការពារកុមារ ក្នុងគោលបំណងសំខាន់ដោះស្រាយបញ្ហាប្រឈមរបស់ កុមារឱ្យកាន់តែមានប្រសិទ្ធភាព។

ឯកឧត្តម តូច ចាន់នី បញ្ជាក់ថា សព្វថ្ងៃកុមារកម្ពុជានៅប្រឈមបញ្ហាមួយចំនួន ដោយបញ្ហាសំខាន់គួរឱ្យកត់សម្គាល់នាពេលនេះ រួមមាន ការបោះបង់ចោលកុមារ ការចំណាកស្រុករបស់ឪពុកម្តាយ និងអំពើហិង្សាដែលនៅតែមានកើតឡើង ជាពិសេសនៅតំបន់ដាច់ស្រយាល ដែលការអប់រំនៅមានកម្រិត។ ឯកឧត្តមអ្នកនាំពាក្យបន្ថែមដែរថា ថ្មីៗនេះ កម្ពុជាក៏បានដាក់ចេញ គោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ ដែលមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធក្នុងការចូលរួមអនុវត្ត ក្នុងនោះ មានក្រសួងសង្គមកិច្ច ក្រសួងមហាផ្ទៃ រួមទាំងក្រសួងអប់រំជាដើម។ សម្រាប់ឱកាសទិវាកុមារអន្តរជាតិ១ មិថុនា និងខួបលើកទី១៩ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២ មិថុនានេះ សម្តេច ហ៊ុន សែន ក៏បានចេញសារលិខិតសាទរ និងគាំទ្រចំពោះទិវានេះផងដែរ ទោះបីជាឆ្នាំ២០២០នេះ ពុំមានការរៀបចំកម្មវិធីយ៉ាងណាក្តី។ ការមិនរៀបចំកម្មវិធីជួបជុំនេះ គឺដោយសារបញ្ហាជំងឺរាតត្បាត កូវីដ១៩។ ហើយក្នុងស្ថានការណ៍ជំងឺរាតត្បាតនេះ ប្រមុខថ្នាក់ដឹកនាំបានអំពាវនាវឱ្យ ក្រសួង ស្ថាប័នពាក់ព័ន្ធអនុវត្តតាមការណែនាំរបស់ក្រសួងសុខាភិបាលឱ្យបានខ្ជាប់ខ្ជួន ទប់ស្កាត់កុំឱ្យមានការឆ្លងទៅកាន់កុមារ ការជំរុញឱ្យកុមារគ្រប់រូបទទួលបានសេវាអប់រំ អនាម័យនិងទឹកស្អាតស្មើគ្នា និងទាមទារឱ្យគ្រប់វិធានការដែលបានដាក់ចេញត្រូវគិតគូរខ្ពស់ពីឧត្តមប្រយោជន៍របស់កុមារ។ លើសពីនេះ សម្តេចក៏បានអំពាវនាវឱ្យ ក្រសួង ស្ថាប័ន ដៃគូពាក់ព័ន្ធ ក៏ដូចជាអាជ្ញាធរមូលដ្ឋាន ត្រូវចាត់វិធានការការពារកុមារពីអំពើហិង្សាគ្រប់រូបភាព លុបបំបាត់ការកេងប្រវ័ញ្ច លើពលកម្មកុមារគ្រប់ទម្រង់

និងជំរុញឱ្យប្រព័ន្ធផ្សព្វផ្សាយ ត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយពី ការការពារកុមារពីអំពើហិង្សា និងពលកម្មកុមារ ជាពិសេសពង្រឹងការផលិតកម្មវិធីសម្រាប់កុមារ ដែលមានខ្លឹមសារអប់រំទប់ស្កាត់កុមារកុំឱ្យក្លាយជាជនរងគ្រោះ៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៤៤នាក់

https://www.facebook.com/GDIOfficial 11-06-2020

នៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៤៤នាក់ ស្រី ១៩នាក់៕

## កងកម្លាំងថៃប្រមូលពលករខ្មែរនៅក្នុងព្រៃរបោះព្រំដែនព្រោះបារម្ភអត់អាហារ

https://www.rasmeinews.com/ June 11, 2020, 9:38 PM

ដោយ ៖ ប.ជ័យ/ព្រំដែនកម្ពុជា-ថៃ៖ ពលករខ្មែរឆ្លងដែនខុសច្បាប់ ហើយបិះត្រូវចាញ់បោកមេខ្យល់ លើកនេះត្រូវបាន សមត្ថកិច្ចកងកម្លាំង ថៃប្រមូលពីក្នុងក្នុងព្រៃរបោះព្រំដែនព្រោះបារម្ភអត់អាហារ។ ប្រភពពីសមត្ថកិច្ចបានឱ្យដឹងកាលពីថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ថា៖ ពលករខ្មែរមានគ្នា២១នាក់។ ពួកគេបានមកលាក់ខ្លួននៅច្រករបៀងព្រំដែនពីខាងកម្ពុជានៅឡើយទេ (ភូមិសាស្ត្រក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ទល់មុខស្រុកអារញ្ញប្រាថេតខេត្តស្រះកែវ)។ពួកគេមានគោលដៅទៅរកការងារធ្វើនៅការដ្ឋានសំណង់និងកន្លែងធ្វើការនានានៅរាជធានីបាងកក ។

ពួកគេបានមន្ត្រីបានដឹកនាំកម្លាំងចុះឡោមព័ទ្ធនិងឆ្មក់ចូលក្នុងការឃាត់ខ្លួនសរុបមនុស្សចំនួន២១នាក់/ ស្រី ១៥នាក់។ ពលករទាំងនោះថា ពួកគេជាកម្មករស៊ីឈ្នួលរកព្រឹកស៊ីល្ងាច ហើយចង់ទៅរកការងារធ្វើនៅថៃឡើងវិញព្រោះការរស់នៅនៅស្រុកខ្មែរនាបច្ចុប្បន្នគ្មានការងារនាំឱ្យគ្មានលុយគ្មានអីហូបចុក ។ ហេតុនេះការស៊ូទ្រាំខ្លាចជំងឺ Covid19 គឺមានតែដាច់បាយហើយ។ ចឹងហើយបានជាពួកគបានប្រថុយចូលប្រទេសថៃ ដើម្បីទៅរកការងារធ្វើនៅទីក្រុងបាងកក និងខេត្តឈុនបូរី ។ ពួកគេត្រូវបានអ្នករត់ពន្ធមនុស្ស(មេខ្យល់ )នាំចូលធ្វើការងារសំណង់៕S/

## កម្លាំងនគរបាលប៉ុស្តិ៍រដ្ឋបាលចំនួន៣ នៃស្រុកចិត្របុរី ចុះផ្សព្វផ្សាយអប់រំដល់ប្រជាពលរដ្ឋតាមខ្នងផ្ទះ

http://cambodiapolice.com/policekh/ 1:23 pm 12 មិថុនា 2020

ក្រចេះ ៖ នាព្រឹកថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២០ កម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលចំនួន០៣ឃុំបានចុះអប់រំផ្សព្វផ្សាយតាមខ្នងផ្ទះប្រជាពលរដ្ឋ និងធ្វើវេទិកាខ្នាតតូច ស្តីពីផលប៉ះពាល់នៃគ្រឿងញៀន ។

១ -ប៉ុស្តិ៍នគរបាលរដ្ឋបាលថ្មី ៖ បានធ្វើវេទិកាខ្នាតតូច នៅចំណុចសាលាបុណ្យខ្ពុល ភូមិទ្រាប ឃុំថ្មី ស្រុកចិត្របុរី ខេត្តក្រចេះ មានប្រជាពលរដ្ឋចូលរួមចំនួន ២១នាក់ (ស្រី ១១ នាក់) បានចែកខិតប័ណ្ណចំនួន ២១សន្លឹកផងដែរ ។

២-កំលាំងប៉ុស្តិ៍នគរបាលរដ្ឋបាលសំបុក ៖ បានចុះធ្វើការផ្សព្វផ្សាយតាមខ្នងផ្ទះប្រជាពលរដ្ឋនៅភូមិសំបុក ឃុំសំបុក ស្រុកចិត្របុរី ខេត្តក្រចេះ មានមនុស្សសរុប ២៤នាក់(ស្រី ១៤ នាក់) ដោយបានចែកខិត្តប័ណ្ណចំនួន ២៤ សន្លឹក ផងដែរ ។

៣-កំលាំងប៉ុស្តិ៍នគរបាលរដ្ឋបាលថ្មអណ្តើក ៖ បានចុះធ្វើវេទិការខ្នាតតូច នៅភូមិល្អក់ ឃុំថ្មអណ្តើក ស្រុកចិត្របុរី ខេត្តក្រចេះ មានមនុស្សសរុប ៣៥នាក់ (ស្រី ២៣ នាក់) ចែកខិត្តប័ណ្ណចំនួន ៣៥ សន្លឹក ផងដែរ ។

-ផ្សព្វផ្សាយ អប់រំ អំពីវិធីការពារ និងផលប៉ះពាល់នៃជំងឺឆ្លងកូវីដ-១៩

-ផ្សព្វផ្សាយ សេចក្តីចូលរួមអំពាវនាវគាំទ្រយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់នៅកម្ពុជា

-ផ្សព្វផ្សាយ រួមគ្នាបង្ការទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀន

-ចែក សារសម្រាប់អប់រំអំពីផល់ប៉ះពាល់គ្រោះថ្នាក់នៃគ្រឿងញៀន

-ផ្សព្វផ្សាយ រួមគ្នាបង្ការ ទប់ស្កាត់បទល្មើសបញ្ហាចោរកម្ម គ្រប់ប្រភេទ

-ផ្សព្វផ្សាយ រួមគ្នាបង្ការការប្រើអំពើហិង្សាទាក់ទងនឹងយេនឌ័រ,អំពើជួញដូរស្រ្តីនិងកុមារ

-ផ្សព្វផ្សាយគ្រោះថ្នាក់ដោយសារយុទ្ធភ័ណ្ឌគ្រាប់មិនទាន់ផ្ទុះ

-ផ្សព្វផ្សាយ អំពីការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ

-ច្បាប់ចរាចរណ៍ផ្លូវគោក

-អនុក្រឹត្យលេខ៣៩

-អំពីគ្រោះអគ្គីភ័យ ៕

## ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០

### ប៉ូលិសខេត្តឧត្តរមានជ័យឃាត់ខ្លួនមេខ្យល់ ២នាក់នាំពលករទៅធ្វើការនៅប្រទេសថៃខុសច្បាប់

https://www.rfa.org/khmer/ ដោយ ជាតិ ចំណាន 2020-06-12

ប៉ូលិសខេត្តឧត្តរមានជ័យឃាត់ខ្លួនមេខ្យល់ ២នាក់ ដែលជាមេក្លោងនាំពលករខ្មែរទៅធ្វើការងារនៅប្រទេសថៃដោយខុសច្បាប់តាមច្រករបៀងតំបន់ព្រំដែនសង្កាត់អូរស្មាច់ កាលពីរសៀលថ្ងៃទី១១ មិថុនា។ មន្ត្រីអង្គការសង្គមស៊ីវិលទទូចឱ្យសមត្ថកិច្ចផ្តន្ទាទោសមេខ្យល់ទាំងនោះឱ្យបានធ្ងន់ធ្ងរ ដើម្បីកុំឱ្យអ្នកដទៃនាំពលករឆ្លងដែនខុសច្បាប់បន្តទៀត។

អធិការនគរបាលក្រុងសំរោង លោក ហម ភិរម្យ ឱ្យអាស៊ីសេរីដឹងនៅរសៀលថ្ងៃទី១២ មិថុនាថា មេខ្យល់ជនជាតិខ្មែរប្រុសម្នាក់ឈ្មោះ គង់ សារឿន អាយុ ៥០ឆ្នាំ និងស្រីម្នាក់ទៀត គឺឈ្មោះ ទិត្យ កុយ អាយុ ៥១ឆ្នាំ រស់នៅខេត្តឧត្តរមានជ័យ ត្រូវបានចាប់ខ្លួន ខណៈពួកគេកំពុងនាំពលករខ្មែរចំនួន ២៧នាក់ឆ្លងដែនតាមច្រករបៀងក្បែរច្រកទ្វារព្រំដែនអន្តរជាតិអូស្មាច់ ដើម្បីទៅធ្វើការនៅទីក្រុងបាងកក និងនៅខេត្តសុរិន្ទប្រទេសថៃ ដោយខុសច្បាប់។ លោកបញ្ជាក់ថា មេខ្យល់ទាំង២នាក់នេះ បានយកប្រាក់ពីពលករម្នាក់ជិត ២ពាន់បាត (១.៧៥០) ស្មើនឹងជិត ៦០ ដុល្លារអាមេរិក ដើម្បីជាថ្លៃនាំពួកគេឆ្លងដែនទៅដល់ដីថៃ៖ «មួយចំនួនគាត់បាននាំឆ្លងដែនផុតទៅហើយត្រូវបានថៃចាប់បញ្ជូនត្រឡប់មកវិញ មួយចំនួននៅក្រវាត់ព្រំដែនត្រូវបាននគរបាលការពារព្រំដែនឃាត់តាមច្រកព្រំដែនខាងត្បូងខ្លាឃ្មុំស្ថិតក្នុងភូមិសាស្រ្តអូស្មាច់។ មិនមានច្រើនទេ ដោយសារការយកចិត្តដាក់ពីអភិបាលខេត្តបានផ្សព្វផ្សាយណែនាំប្រជាពលរដ្ឋកុំឱ្យឆ្លងដែនទៅប្រទេសថៃព្រោះវាអាចបង្កឱ្យមានការគ្រោះថ្នាក់ ហើយហានិភ័យនឹងការឆ្លងជំងឺកូវីដ១៩»។ លោកបន្តថា ប៉ូលិសបានបញ្ជូនមេខ្យល់ទាំង ២នាក់ ទៅសាលាដំបូងខេត្តឧត្តរមានជ័យ ដើម្បីផ្តន្ទាទោសតាមផ្លូវច្បាប់ហើយនៅព្រឹកថ្ងៃទី១២ មិថុនា។ ចំណែកក្រុមពលករទាំង ២៧នាក់ ត្រូវបានបញ្ជូនត្រឡប់ទៅ

ស្រុកកំណើតវិញភ្លាមៗ នៅក្រោយពេលឃាត់ខ្លួន។ នេះជាលើកទី១ ហើយ ក្នុងឆ្នាំ២០២០ ដែលប៉ូលិសខេត្តឧត្តរមានជ័យចាប់បានមេក្លោងនាំពលករខ្មែរទៅធ្វើការប្រទេសថៃដោយខុសច្បាប់នោះ។

ទោះជាយ៉ាងណា មន្ត្រីសម្របសម្រួលសមាគមការពារសិទ្ធិមនុស្សអាដហុក(Adhoc) ខេត្តឧត្តរមានជ័យ លោក ស្រី ណារ៉េន មានប្រសាសន៍ថា ការចាប់មេខ្យល់តែ ២នាក់ មិនទាន់គ្រប់គ្រាន់នោះទេ ពីព្រោះរឿងនេះអាចមានអ្នកពាក់ព័ន្ធជាច្រើនទៀតទើបអាចដើរប្រមូលប្រជាពលរដ្ឋមកពីខេត្តឆ្ងាយៗ បានច្រើនបែបនេះ។ លោកអំពាវនាវឱ្យអាជ្ញាធរស្រាវជ្រាវរកចាប់មេខ្យល់ដទៃមក ផ្តន្ទាទោសតាមច្បាប់ ដើម្បីទប់ស្កាត់កុំឱ្យពួកគេនាំពលករឆ្លងដែនដោយប្រថុយប្រថានបន្តទៀត។ លោកបញ្ជាក់ថា ការឆ្លងដែនអំឡុងពេលនេះប្រឈមនឹងគ្រោះថ្នាក់ដល់អាយុជីវិតដោយសាររដ្ឋាភិបាលថៃបានដាក់ប្រទេសរបស់គេក្នុងគ្រាមានអាសន្ន ដោយមានសមត្ថកិច្ចថៃយាមការពារតឹងតែងនៅតាមព្រំដែន៖ «ពីព្រោះច្បាប់បានហាមឃាត់ហើយ គាត់នៅតែប្រព្រឹត្តអីចឹង។ ជាពិសេសមែនទែនសុំខាងតុលាការអីឱ្យដាក់ទោសឱ្យធ្ងន់ទៅពីព្រោះដើម្បីបង្ហាញថា ការអនុវត្តច្បាប់ចំពោះជនប្រព្រឹត្តបទល្មើសហ្នឹងឱ្យវារាងចាលលើអ្នកដែលចង់ប្រកបមុខរបរហ្នឹងបន្តទៀត។

សម័យជំងឺកូវីដ១៩ បែបហ្នឹងហើយ នៅតែមានមេខ្យល់នាំប្រជាពលរដ្ឋឆ្លងដែនទៅក្រៅប្រទេសអីចឹងយើងយល់រឿងនេះជាបញ្ហាមួយ ដែលរដ្ឋត្រូវតែយកចិត្តទុកដាក់មែនទែនចំពោះប្រជាពលរដ្ឋខ្លួនឯង ព្រោះរដ្ឋមានកាតព្វកិច្ចមួយជួយការពារបំពេញឱ្យប្រជាពលរដ្ឋ»។ រដ្ឋាភិបាលថៃបានបិទព្រំដែនជាប់កម្ពុជាតាំងពីថ្ងៃទី២៣ មីនា ដើម្បីទប់ស្កាត់ការរាតត្បាតជំងឺលោកផ្លូវដង្ហើមថ្មី ហើយមកទល់ថ្ងៃទី១២ មិថុនាមិនទាន់បើកឡើងវិញនៅឡើយទេ។ អំឡុងពេលអាជ្ញាធរថៃបិទព្រំដែននេះ មានពលករខ្មែរជាច្រើននាក់បានលួចឆ្លងដែនទៅធ្វើការងារនៅប្រទេសថៃដោយខុសច្បាប់ ដោយសារពួកគាត់គ្មានការងារនៅក្នុងស្រុក ហើយត្រូវបានអាជ្ញាធរថៃចាប់ខ្លួនជាបន្តបន្ទាប់។ កាលពីខែឧសភា មានពលករខ្មែរជាង ២០០ (ពីររយនាក់) ត្រូវបានទាហានថៃចាប់ខ្លួននៅខេត្តស្រះកែវ ប៉ុន្តែក្រោយមកអាជ្ញាធរថៃបានបញ្ជូនពួកគេត្រឡប់ទៅកម្ពុជាវិញ តាមច្រករបៀងព្រំដែនក្នុងខេត្តបន្ទាយមានជ័យ៕

## កំលាំងប៉ុស្តិ៍រដ្ឋបាលកន្ទួត ចុះផ្សព្វផ្សាយអំពីវិធីបង្ការ ទប់ស្កាត់ការឆ្លងវីរុសកូវីដ១៩ និងភូមិឃុំមានសុវត្ថិភាព ជូនពលរដ្ឋតាមខ្នងផ្ទះ

http://cambodiapolice.com/policekh/ 10:56 am 14 មិថុនា 2020

ខេត្តក្រចេះ ៖ នៅថ្ងៃទី១៤ ខែ មិថុនា ឆ្នាំ ២០២០ វេលាម៉ោង៨និង៣០នាទី កំលាំងប៉ុស្តិ៍រដ្ឋបាលកន្ទួតចុះផ្សព្វផ្សាយអំពីវិធីបង្ការ ទប់ស្កាត់ការឆ្លងវីរុសកូវីដ១៩ និងភូមិឃុំមានសុវត្ថិភាព ជូនពលរដ្ឋតាមខ្នងផ្ទះ និងសួរសុខទុក្ខនៅចំណុចភូមិស្រែនន ឃុំកន្ទួត ស្រុកចិត្របុរី ។ ការចុះផ្សព្វផ្សាយនោះមានខ្លឹមសារដូចខាងក្រោម ៖

-ផ្សព្វផ្សាយ សេចក្តីអំពាវនាវចូលរួមគាំទ្រយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់នៅកម្ពុជា ។

-ផ្សព្វផ្សាយ រួមគ្នាបង្ការទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀន ។

-ចែក សារសម្រាប់អប់រំអំពីផលប៉ះពាល់គ្រោះថ្នាក់នៃគ្រឿងញៀន ។

-ផ្សព្វផ្សាយ រួមគ្នាបង្ការទប់ស្កាត់បទល្មើសបញ្ហាចោរកម្ម គ្រប់ប្រភេទ

-ផ្សព្វផ្សាយ រួមគ្នាបង្ការការប្រើអំពើហិង្សាទាក់ទងនឹងយេនឌ័រ,អំពើជួញដូរស្ត្រីនិងកុមារ

-ផ្សព្វផ្សាយច្បាប់ចរាចរណ៍ផ្លូវគោក

-ផ្សព្វផ្សាយ អំពីការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ។

-អំពីគ្រោះអគ្គីភ័យ។

-នៅក្នុងនោះកម្លាំងបានធ្វើការផ្សព្វផ្សាយនូវលក្ខណសម្បត្តិទាំង៩យ៉ាងរបស់គោលនយោបាយភូមិឃុំមានសុវត្ថិភាព និង វិធីបង្ការទប់ស្កាត់ វីរុស កូវីដ-19 ។

មានប្រជាពលរដ្ឋចូលរួមសរុបចំនួន ២០នាក់ /ស្រី ១២នាក់ ព្រមទាំងបានចែកខិតប័ណ្ណចំនួន ២០សន្លឹកផងដែរ ៕

## ភាគីថៃបញ្ជូនសពពលករម្នាក់ ដែលគ្រោះថ្នាក់ចរាចរនៅលើដីថៃ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០២០ ម៉ោង ១៨:៥៧ ម៉ុត សារុន

ខេត្តបន្ទាយមានជ័យ ៖ សាកសពពលករខ្មែរម្នាក់ត្រូវបានភាគីថៃធ្វើការបញ្ជូនត្រឡប់តាមច្រកទ្វារ អន្តរជាតិ ប៉ោយប៉ែត រសៀលថ្ងៃទី១១ មិថុនា ២០២០ ក្រោយជួបគ្រោះអកុសល គ្រោះថ្នាក់ចរាចរ (ខ្លះថារថយន្តបុក ខ្លះថាដួលម៉ូតូដោយខ្លួនឯង)។ ជនរងគ្រោះឈ្មោះ ម៉ៅ សុខនី ភេទប្រុស អាយុ២៨ឆ្នាំ ធ្វើការផ្នែកដឹកជញ្ជូនហ្គាស ចែកចាយនៅខេត្តសាមុទ្រប្រាកាន ប្រទេសថៃ និងមានទីលំនៅភូមិភ្នំជញ្ជាំង ឃុំជប់វារី ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។

តាមសាច់ញាតិសពប្រាប់កោះសន្តិភាពថា ជនរងគ្រោះបានជួបគ្រោះអកុសលគ្រោះថ្នាក់ចរាចរ កាលពីល្ងាចថ្ងៃទី៩ មិថុនា ២០២០ ខណៈជនរងគ្រោះបើកម៉ូតូដឹកជញ្ជូនហ្គាសចែកចាយឲ្យគេ។ ប្រភពដដែលបន្តថា គ្មានសាច់ញាតិណាដឹងពីកាពិតថា គ្រោះថ្នាក់ចរាចរខាងលើកើតឡើង ដោយរបៀបណាឡើយ ខណៈប្រភពអ្នកឃើញហេតុការណ៍ប្រាប់ពួកគាត់ថា ជនរងគ្រោះត្រូវ រថយន្តបុកតែចាប់រថយន្តនោះមិនបាន។

សពខាងលើក្រោយភាគីថៃធ្វើការបញ្ជូនដល់កម្ពុជា ក៏ដឹកបន្តតាមរថយន្តសង្គ្រោះរបស់យោធានៃកងពលតូចថ្មើជើងលេខ៥១ ទៅលំនៅដ្ឋាន ដើម្បីធ្វើបុណ្យតាមប្រពៃណី។ តាមមន្ត្រីការិយាល័យទំនាក់ទំនងព្រំដែនកម្ពុជាថៃ ប្រចាំច្រកទ្វារ អន្តរជាតិប៉ោយប៉ែតប្រាប់តាមទូរស័ព្ទថា សពពលករដែលជួបគ្រោះអកុសលផ្សេងៗ លើដីថៃបញ្ជូនមកកម្ពុជាវិញតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតសម្រាប់ខែឧសភា និងមិថុនា មាន៤នាក់ ដោយក្នុងខែឧសភាមាន៣នាក់ និងដើមខែមិថុនាមានម្នាក់គឺសពពលករខាងលើតែម្តង៕ ដោយ ៖ មុត សារុន

## អ្នករកស៊ីវេរលុយពីថៃ៨នាក់ សុំឲ្យស្នងការនគរបាលខេត្តអន្តរាគមន៍

https://kohsantepheapdaily.com.kh/ ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០២០ ម៉ោង ២១:៥៧ ប៊ុន ធឿន

ខេត្តបន្ទាយមានជ័យ ៖ អ្នករកស៊ីវេរលុយពីថៃ៨នាក់ សុំឲ្យស្នងការនគរបាលខេត្តអន្តរាគមន៍ ជួយរកដំណោះស្រាយ ដែលម្ចាស់ហាងប្តូរលុយ និងវេរលុយមិនសងប្រាក់ចំនួន ២ ១៨៤.១២៣បាត បានចូលជួបកាលពីថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២០ នៅស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ។លោកឧត្តមសេនីយ៍ទោ អាត់ ខែម ស្នងការនគរបាលខេត្តបន្ទាយមានជ័យបានប្រាប់ថា៖ អ្នករកស៊ីវេរលុយចំនួន០៨នាក់ បានសុំឲ្យជួយអន្តរាគមន៍រកដំណោះស្រាយចំពោះឈ្មោះ មិត្ត សាវី និងប្តីឈ្មោះ លី ថែន ជាម្ចាស់យីហោ១០៨ ដែលជាកន្លែងប្តូរលុយ និងវេរលុយក្នុងក្រៅប្រទេស ចំណុចភូមិគោរដ្ឋាន សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ដែលបានជំពាក់លុយថ្លៃអបិតិជនឬកូនដៃវេរពីប្រទេសថៃចំនួន២៦៧នាក់ ដែលស្មើទឹកប្រាក់ចំនួន២ ១៨៤.១២៣បាត។

តាមសម្តីតំណាងម្ចាស់លុយ៨នាក់បានប្រាប់ថា៖ មូលហេតុពួកគាត់មកជួបលោកឧត្តមសេនីយ៍ទោ អាត់ ខែម ស្នងការនគរបាលខេត្តបន្ទាយមានជ័យ ជួយអន្តរាគមន៍ដោយឈ្មោះ លី ថែន ជាប្តី ឈ្មោះ មិត្ត សាវី ជាប្រពន្ធ ដែលជាម្ចាស់កន្លែងទទួលវេរលុយនៅផ្សាររ៉ុងក្លឿប្រទេសថៃ បានទទួលលុយ ដែលកូនដៃវេរពីប្រទេសថៃចូល ដែលមានឯកសារវេលុយហើយមិនព្រមបើកលុយឲ្យ ដើម្បីគាត់យកលុយនេះបើកឲ្យគ្រួសារម្ចាស់លុយចំនួន២៦៧នាក់ ដែលមានទឹកប្រាក់សរុបចំនួន២.១៨៤.១២៣បាត។

លោកកឧត្តមសេនីយ៍ទោ អាត់ ខែម បានបញ្ជាក់ថាៈ ចំពោះអ្នកកេស៊ីវេរលុយចំនួន៨នាក់ ដែលសុំជួយអន្តរាគមន៍រឿងជំពាក់លុយវេររបស់កម្មករដែលធ្វើការនៅប្រទេសថៃ ដែលខិតខំប្រឹងធ្វើការងារទាំងយប់ និងថ្ងៃគ្មានថ្ងៃសម្រាកបានលុយផ្ញើឲ្យឪពុកម្តាយ និងក្រុមគ្រួសារ ហើយអ្នកវេរលុយមិនបើកឲ្យទៀត។ រឿងនេះកោះហៅអ្នកដែលជំពាក់លុយឈ្មោះ លី ថៃន ជាប្តី ឈ្មោះ មិត្ត សាវរី ជាប្រពន្ធចូលខ្លួនដោះស្រាយជូនឲ្យបានឆាប់នេះ ជាលុយកម្លាំងញើសឈាមកម្មករ ធ្វើការនៅប្រទេសថៃ៕ ដោយ ៖ ប៊ុន ធឿន

## ពលរដ្ឋខ្មែរ បន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ២៥នាក់

https://www.facebook.com/GDIOfficial 14-06-2020

នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបរយានយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ២៥នាក់ ស្រី ១១នាក់៕

## ពលរដ្ឋខ្មែរ បន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ២១នាក់

https://www.facebook.com/GDIOfficial 13-06-2020

នៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបរយានយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ២១នាក់ ស្រី ១០នាក់៕

## ពលរដ្ឋខ្មែរ បន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៨នាក់

https://www.facebook.com/GDIOfficial 12-06-2020

នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបរយានយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹម

ត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៨នាក់ ស្រី ០៦នាក់៕

## ថៃបានបញ្ជូនពលរដ្ឋខ្មែរ ០១នាក់ ឲ្យមកប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ ពីបទឆ្លងដែនខុសច្បាប់

https://www.facebook.com/GDIOfficial 12-06-2020

នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២០ ខាងភាគីថៃបានបញ្ជូនពលរដ្ឋខ្មែរចំនួន ០១នាក់ ឲ្យមកប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ ពីបទឆ្លងដែនខុសច្បាប់ ទៅកាប់ឈើនៅប្រទេសថៃ ដែលចេញតាមច្រកអូរក្រញូង ខេត្ត ឧត្តរមានជ័យ៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរចំនួន ០៣នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងការឆ្លងដែនខុសច្បាប់

https://www.facebook.com/GDIOfficial 12-06-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម នាវេលាម៉ោង ១៤និង០០នាទី ថ្ងៃទី១២ ខែមិថុនា ឆ្នាំ ២០២០ បានទទួលពលករខ្មែរចំនួន ០៣នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងការឆ្លងដែនខុសច្បាប់ និងមានការចូលរួមត្រួតពិនិត្យសុខភាព ពីក្រុមចត្តាឡីស័កផងដែរ។ កម្លាំងនគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរទាំង ០៣នាក់ នេះ មាន ១-ឈ្មោះ ពេជ មេសា ភេទប្រុស អាយុ ២២ឆ្នាំ មានទីលំនៅភូមិជីមាន ឃុំត្រពាំងព្រីង ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ, ២-ឈ្មោះ សុរិមុន ប៉ាយ ភេទស្រី អាយុ ២១ឆ្នាំ មានទីលំនៅភូមិជីមាន ឃុំត្រពាំងព្រីង ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ និង៣-ឈ្មោះ ឌុល វិន្ទុត ភេទប្រុស អាយុ ២២ឆ្នាំ មានទីលំនៅភូមិ១ ឃុំដងទង់ ស្រុកខេមរភូមិន្ទ ខេត្ត កោះកុង។ បន្ទាប់មកកម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំណែនាំ រួចក៏ប្រគល់ជូនចត្តាឡីស័កដើម្បីអនុវត្តបន្ត។

ដោយឡែកខាងភាគីថៃ នៅតែបន្តបិទច្រក មិនឲ្យអ្នកដំណើរ ចេញ-ចូល ចំណែកទំនិញទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តចំនួន ០១នាក់ ដែលទទួលបានការអនុញ្ញាត និងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានយ៉ាងត្រឹមត្រូវ៕

## កិច្ចជំនួបពិភាក្សាការងាររវាងលេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តសៀមរាប (គខបជ) ជាមួយអង្គការដៃគូ

https://www.facebook.com/deputygovernoryousophear/ 13-06-2020

ខេត្តសៀមរាប៖ នៅសៀល ថ្ងៃព្រហស្បតិ៍ 6 រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព,ស 2564 ត្រូវនឹងថ្ងៃទី11ខែមិថុនា ឆ្នាំ2020 លោកស្រី យូ សុភា អភិបាលរងខេត្ត ជាប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តសៀមរាប បានទទួលជួបពិភាក្សាការងារជាមួយអង្គការសកម្មភាពដើម្បីកុមារ (Aple) អង្គការដែនដីមនុស្សហូរឡង់ប្រចាំនៅកម្ពុជា និងអង្គការជំហានកម្ពុជា នៅរដ្ឋបាលសាលាខេត្តសៀមរាប ។

កិច្ចជំនួបនេះ បានពិភាក្សាការងារពាក់ព័ន្ធនឹងការអន្តរាគមន៍ជួយជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើរំលោភបំពាន ឬការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ នៅក្នុងសហគមន៍។ នៅក្នុងកិច្ចនេះផងដែរ អង្គការដៃគូក៏ធ្វើការថ្លែងអំណរគុណចំពោះរដ្ឋបាលសាលាខេត្តសៀមរាប ពិសេសលេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងសមាជិកនៃមន្ទីរអង្គភាពជំនាញ ដែលតែងតែជួយសម្របសម្រួល ការអន្តរគមន៍ លើករណី

ក្នុងការជួយជនរងគ្រោះបានទាន់ពេលវេលា និងឆ្លើយតបទៅតម្រូវការរបស់ជនរងគ្រោះ ពិសេសគឺមានកិច្ចសហការល្អជាមួយបណ្តាអង្គការដៃគូមិនរដ្ឋាភិបាល ជាតិ អន្តរជាតិ ដើម្បីការពារ និងផលប្រយោជន៍របស់ប្រជាពលរដ្ឋកម្ពុជា។

មានប្រសាន៍ នៅក្នុងកិច្ចជំនួបខាងលើ លោកស្រី យូ សុភា អភិបាលរងខេត្ត បានពិនិត្យ និងផ្តល់ជាអនុសាសន៍លើបញ្ហាប្រឈមមួយចំនួន ដល់អង្គការដៃគូលើ ការអនុវត្តសកម្មភាពក្នុងការផ្តល់សេវាផ្នែកច្បាប់ និងផ្នែកសេវាសង្គមកិច្ច ដល់ជនរងគ្រោះ ឬជនងាយរងគ្រោះឲ្យស្របទៅតាមនីតិវិធីច្បាប់ និងរដ្ឋបាល របស់រាជរដ្ឋាភិបាល ពិសេសត្រូវផ្តល់ព័ត៌មាន និងមានកិច្ចសហការល្អជាមួយអាជ្ញាធរមូលដ្ឋាន និងអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ឲ្យកាន់តែល្អថែមទៀត។

## ស្រួង ភារី មានសិទ្ធិស្នើសុំអន្តរាគមន៍ពីអាជ្ញាធរកូរ៉េខាងត្បូង បើស្ត្រីខ្មែររងការបំពាន

https://thmeythmey.com/ 14, Jun 2020 , 9:59 pm ដោយ: សឿន វណ្ណខេត

កីឡាការិនី ស្រួង ភារី មានសិទ្ធិស្នើសុំកិច្ចអន្តរាគមន៍ ពីក្រសួងសមធម៌យេនឌ័រកូរ៉េ ក្នុងការជួយដោះស្រាយបញ្ហាជូនស្ត្រីខ្មែរ ដែលរស់នៅ និងធ្វើការនៅប្រទេសកូរ៉េ ក្នុងករណីមានការបំពាន។ ការទទួលបានសិទ្ធិនេះ កើតឡើងក្រោយពីកីឡាការិនីមកពីខេត្តត្បូងឃ្មុំរូបនេះ ត្រូវបានកូរ៉េតែងតាំងឲ្យធ្វើជាសមាជិកគណៈកម្មការស្ត្រីនៃក្រសួងសមធម៌យេនឌ័រ និងគ្រួសាររបស់កូរ៉េខាងត្បូង។

កីឡាការិនីស្នូកឃ័រឆ្នើមកម្ពុជា ស្រួង ភារី ត្រូវបានថ្នាក់ដឹកនាំប្រទេសកូរ៉េខាងត្បូង តែងតាំងឲ្យធ្វើជាសមាជិកគណៈកម្មការស្ត្រី នៃក្រសួងសមធម៌យេនឌ័រ និងគ្រួសាររបស់កូរ៉េខាងត្បូង។ បើតាម ភារី មុខតំណែងនេះនាងទទួលបានកាលពីថ្ងៃទី២៧ មិថុនា ឆ្នាំ២០១៩ បន្ទាប់ពី នាង បានរួមចំណែកជួយក្នុងអំពើមនុស្សធម៌ និងសាងស្នាដៃនានាជូនប្រទេសកូរ៉េ និងកម្ពុជា។ ប៉ុន្តែនាង មិនបញ្ជាក់លម្អិតពីស្នាដៃដែលបានសាងទាំងនោះឡើយ។

ទោះបីយ៉ាងនេះក្តី យើងសង្កេតឃើញថា កីឡាការិនីវ័យ៣០ឆ្នាំរូបនេះ តែងតែចំណាយថវិកាផ្ទាល់ខ្លួនដែលបានមកពីការប្រកួតនានាប្រគល់ជូន និងទិញសម្ភារ និងគ្រឿងឧបភោគបរិភោគផ្សេងៗជួយដល់ជនក្រីក្រ និងជនរងគ្រោះនានាទាំងនៅប្រទេសកូរ៉េនិងប្រទេសកម្ពុជា។ នាង តែងតែត្រូវបានទូរទស្សន៍កូរ៉េសម្ភាសពាក់ព័ន្ធនឹងសកម្មភាពមនុស្សធម៌ ប្រវត្តិផ្ទាល់ខ្លួន និងសមិទ្ធផលនានា ដែលនាងសម្រេចបាន។ កត្តាទាំងនេះហើយដែល ភារី ចាត់ទុកជាមូលហេតុ ដែលជួយឲ្យរូបនាងទទួលបានតំណែងជាគណៈកម្មការស្ត្រីនៅប្រទេសកូរ៉េ។ «យើងជាស្ត្រីខ្មែររៀបការនៅប្រទេសកូរ៉េ ហើយយើងបានសាងកេរ្តិ៍ឈ្មោះ និងស្នាដៃនៅប្រទេសកូរ៉េ។ យើង ក៏ជាមនុស្សគំរូមួយសម្រាប់មនុស្សនៅជុំវិញខ្លួន»។ នេះជាការបញ្ជាក់ពីមូលហេតុបន្ថែមរបស់កីឡាការិនី ស្រួង ភារី ដែលបានបន្ថែមថា មុខតំណែងជាសមាជិកគណៈកម្មការស្ត្រីនេះ មិនងាយមានស្ត្រីណាទទួលបាននោះទេ។

សម្រាប់មុខតំណែងនេះ ភារី មានសិទ្ធិចូលរួមកិច្ចប្រជុំធំៗរបស់ក្រសួងសមធម៌យេនឌ័រ និងគ្រួសាររបស់កូរ៉េខាងត្បូង ហើយមានសិទ្ធិលើកជាគំនិត និងសំណើរផ្សេងៗ។ ជាពិសេស នាង មានសិទ្ធិស្នើសុំការអន្តរាគមន៍ពីក្រសួងនេះ ដើម្បីជួយដោះស្រាយបញ្ហានានាជូនស្ត្រីកូរ៉េ និងស្ត្រីខ្មែរ ដែលកំពុងរស់នៅ និងធ្វើការនៅប្រទេសកូរ៉េ ក្នុងករណីពួកគេរងការបំពានពីស្វាមី ឬថៅកែ។ «ពលករគាត់លំបាក ហើយស្ត្រីខ្មែរដែលរៀបការរួចត្រូវប្តីធ្វើបាបចេះ ធ្វើបាបចុះ ពេលយើងស្នើគេ(ក្រសួងសមធម៌យេនឌ័រ និងគ្រួសាររបស់កូរ៉េខាងត្បូង)នឹងចុះទៅជួយ។ មានស្ត្រីខ្មែរខ្លះរៀបការមានកូនចូលសញ្ជាតិខ្មែរផង កូរ៉េផង ហើយត្រូវគេរើសអើងអ៊ីចឹង យើងត្រូវរកវិធីម៉េចកុំឲ្យគេរើសអើង។ បើយើងដឹងថា ស្ត្រី ឬកម្មការិនីទាំងនោះលំបាកមែន ខ្ញុំអាចស្នើសុំ(ការអន្តរាគមន៍)បាន»។ នេះជាការលើកឡើងរបស់កីឡាការិនី ស្រួង ភារី។

កីឡាការិនីមកពីខេត្តត្បូងឃ្មុំរូបនេះ បានចូលប្រឡូកក្នុងវិស័យកីឡាប៊ីយ៉ា និងស្នូកឃ័រនៅឆ្នាំ២០១៣ ដោយផ្តើមចេញពីការនាំរបស់ស្វាមី ជាជនជាតិកូរ៉េខាងត្បូង។ ក្រោយប្រឡូកបានប្រមាណ៥ឆ្នាំ នាង បានឈ្នះ

មេដាយមាសក្នុងការប្រកួតជើងឯកអាស៊ី Asian Championship 3-Cushion Ladies។ បន្ទាប់មកនៅឆ្នាំ២០១៨ កីឡាការិនីរូបនេះ ទទួលបានមេដាយសំរឹទ្ធក្នុងការប្រកួតជើងឯកពិភពលោកនៅប្រទេសតួកគី មុនឈ្នះមេដាយមាសក្នុងការប្រកួតជើងឯកអាស៊ីនៅប្រទេសកូរ៉េខាងត្បូងក្នុងឆ្នាំ២០១៩។ ទោះបីកីឡាការិនី ស្រួង ភាវី មានស្វាមីជាជនជាតិកូរ៉េ និងបានចាកចេញពីកម្ពុជាទៅរស់នៅប្រទេសកូរ៉េខាងត្បូងអស់រយៈពេលជាង១០ឆ្នាំក៏ដោយ តែរាល់ភាពជោគជ័យនៅឆាកអន្តរជាតិ នាង តែងតែងលើកទង់ជាតិ និងតំណាងឲ្យកម្ពុជាជានិច្ច៕

## ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២០

### កិច្ចជំនួបសម្តែងការគួរសមរបស់អង្គការបេសកកម្មយុត្តិធម៌ អន្តរជាតិ (IJM) ជាមួយលេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តសៀមរាប

https://www.facebook.com/deputygovernoryousophear/ 15-06-2020

ខេត្តសៀមរាប ៖ ព្រឹកថ្ងៃចន្ទ ១០រោច ខែ ជេស្ឋ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ លោកស្រី យូ សុភា អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តសៀមរាប បានទទួលជួបជាមួយអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) នៅរដ្ឋបាលសាលាខេត្តសៀមរាប ។

នៅក្នុងកិច្ចជំនួបសម្តែងការគួរសមនេះផងដែរ ក្រុមការងាររបស់អង្គការខាងលើ បានធ្វើការថ្លែងអំណរគុណដល់លេខាធិការដ្ឋាន និងក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តសៀមរាបទាំងអស់ ដែលបានសហការនិងសម្របសម្រួលដែលបានបង្កលក្ខណៈងាយស្រួល ជូនក្រុមការងារអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ ក្នុងការចុះអនុវត្តសកម្មភាពការងារនៅក្នុងខេត្តសៀមរាប កន្លងមកនេះ ហើយអង្គការបានស្នើសុំបន្តកិច្ចសហការដ៏ល្អនេះជាបន្តទៀត លើការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាពិសេសអំពើជួញដូរពលកម្មក្នុងស្រុក និងឆ្លងដែន លើពលរដ្ឋកម្ពុជា។

មានប្រសាសន៍នៅក្នុងកិច្ចជំនួបនេះ លោកស្រី យូ សុភា អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានថ្លែងអំណរគុណដល់ក្រុមការងាររបស់អង្គការ IJM ដែលបានសហការនិងគាំទ្រលើសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើជួញដូរកម្លាំងពលកម្ម លើពលរដ្ឋកម្ពុជា ក្នុងការផ្តល់សេវាផ្នែកច្បាប់ និងសង្គមកិច្ច ពិសេសការគាំទ្រទៅបច្ចេកទេសដល់សមត្ថកិច្ចក្នុងខេត្តសៀមរាប ក្នុងការស៊ើបអង្កេត និងបង្រ្កាបបទល្មើសពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សជាដើមផងដែរ។ លោកស្រីបានបញ្ជាក់បន្ថែមថា លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តសៀមរាប សូមស្វាគមន៍ចំពោះកិច្ចសហការរបស់អង្គការ IJM ក៏ដូចជាបណ្តាអង្គការដៃគូជាតិ អន្តរជាតិ ក្នុងការសហការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងសកម្មភាពនានាដែលធានាដល់ការអភិវឌ្ឍន៍សង្គម ការការពារការទប់ស្កាត់ការរំលោភបំពាននានា និងធានាដល់ផលប្រយោជន៍របស់ពលរដ្ឋកម្ពុជា។

ដើម្បីចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជា ពិសេសជាមួយលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តសៀមរាប លើការងារទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) បានឧបត្ថម្ភ ម៉ាស ចំនួន១កេស និងសោមដៃចំនួន២កេស ដល់លេខាធិការដ្ឋាន ផងដែរ សម្រាប់ក្រុមការងារយកទៅប្រើប្រាស់ក្នុងអំឡុងពេលស្ថានភាពជំងឺកូវីដ១៩ នៅបន្តកើតមាននៅក្នុងប្រទេសកម្ពុជា ក៏ជាបណ្តាប្រទេសនៅក្នុងពិភពលោកផងដែរ។

## លួចឆ្លងដែនទៅទិញអីវ៉ាន់នៅស្រុកថៃខុសច្បាប់ ចាប់បានទាំងមេខ្យល់និងក្មេងៗសរុប៧នាក់

http://kampucheathmey.com/ 15/6/2020 2:47 Pmជាតិទូទៅ

**ឧត្តរមានជ័យ** ៖ បុរស១នាក់ ស្ត្រី២នាក់ រួមទាំងក្មេងប្រុសស្រីចំនួន៤នាក់ សរុប៧នាក់ ត្រូវបានសមត្ថកិច្ចធ្វើការឃាត់ខ្លួន ពាក់ព័ន្ធករណីឆ្លងដែនខុសច្បាប់ចូលទៅស្រុកថៃតាមផ្លូវវៀង ភូមិអូរខ្លាឃ្មុំ សង្កាត់អូរស្មាច់ក្រុងសំរោង ខេត្តឧត្តរមានជ័យ។ សមត្ថកិច្ចបានឲ្យដឹងថា នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ កម្លាំងប៉ុស្តិ៍អណ្តែងមុត វរ ៧០២ ចំនួន០២នាក់ ដឹកនាំដោយលោក អ.ឯក សុខ ផល នាយរងប៉ុស្តិ៍ សហការជាមួយកម្លាំងយោធាចំនួន០២ នាក់ ដឹកនាំដោយលោក អ.ឯក ពៅ សុខា មេបញ្ជាការរងកងអនុសេនាធំលេខ០៣ នៃកងការពារព្រំដែនលេខ ៤០២ យោធភូមិភាគទី៤ ដែលប្រចាំការនៅគោលដៅវត្តអូរខ្លាឃ្មុំ បានចាប់ឃាត់ខ្លួនប្រជាពលរដ្ឋខ្មែរ ចំនួន០៧ នាក់ ក្នុងនោះក្មេង ៤នាក់ នៅចំណុចភូមិអូរខ្លាឃ្មុំ សង្កាត់អូរស្មាច់ ក្រុងសំរោង ខេត្តឧត្តរមានជ័យ។ ពាក់ព័ន្ធករណីលួចឆ្លងដែន ចូលទៅមើលអីវ៉ាន់នៅផ្សារថៃ(ផ្សារឆេងចម) ដែលមានឈ្មោះដូចខាងក្រោម៖

ទី១. ឈ្មោះ ពូល ខ្លឹង ភេទប្រុស អាយុ៥៨ឆ្នាំ រស់នៅភូមិអូរខ្លាឃ្មុំ សង្កាត់អូរស្មាច់ ក្រុងសំរោង ខេត្តឧត្តរមានជ័យ (ជាមេខ្យល់)។

ទី២. ឈ្មោះ យឹម សុភ័ក្រ ភេទស្រី អាយុ៣៧ឆ្នាំ រស់នៅភូមិអូរស្មាច់ សង្កាត់អូរស្មាច់ ក្រុងសំរោង ខេត្តឧត្តរមានជ័យ។

ទី៣. ឈ្មោះ កែវ ស្រីនីន ភេទស្រី អាយុ៤៦ឆ្នាំ រស់នៅភូមិអូរស្មាច់ សង្កាត់អូរស្មាច់ ក្រុងសំរោង ខេត្តឧត្តរមានជ័យ។

រួមទាំងក្មេងទាំងបួនអ្នកទៀតមាន៖ទី១.ឈ្មោះ ម៉េង យាង ភេទប្រុស អាយុ៩ឆ្នាំ(កូនឈ្មោះ កែវ ស្រីនីន)

ទី២. ឈ្មោះ ភាន់ បារាំង ភេទប្រុស អាយុ៨ឆ្នាំ (ក្មួយឈ្មោះ កែវ ស្រីនីន)។

ទី៣. ឈ្មោះ ម៉េង លាភ ភេទស្រី អាយុ២ឆ្នាំ (កូនឈ្មោះ កែវ ស្រីនីន) និង

ទី៤. ឈ្មោះ គិម ជាង ភេទស្រី អាយុ៥ឆ្នាំ (កូនឈ្មោះ យឹម សុភ័ក្រ)។

ប្រជាពលរដ្ឋខាងលើ ត្រូវបានបញ្ជូនទៅឲ្យ ការិយាល័យប្រឆាំងការជួញដូរមនុស្ស នៃស្នងការដ្ឋាននគរបាលខេត្តឧត្តរមានជ័យ៕ **អត្ថបទ៖ ចាន់ ជី**

## នគរបាលស្រុកឆ្លូងចុះអប់រំផ្សព្វផ្សាយប្រជាពលរដ្ឋតាមផ្ទះបានចំនួន៥៦ខ្នង

http://cambodiapolice.com/policekh/ 5:41 pm 15 មិថុនា 2020

ក្រចេះ ៖ នៅព្រឹកថ្ងៃទី១៥ ខែ មិថុនា ឆ្នាំ២០២០ កម្លាំងសណ្តាប់ធ្នាប់ និងផ្នែកប្រឆាំងគ្រឿងញៀន នៃអធិការដ្ឋាននគរបាលស្រុកឆ្លូង សហការជាមួយកម្លាំងនគរបាលប៉ុស្តិ៍រដ្ឋបាលកញ្ជរ បានចុះអប់រំ ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋចុះតាមខ្នងផ្ទះក្នុង ភូមិព្រែកចំឡាក់ ឃុំកញ្ជរ ស្រុកឆ្លូង ខេត្តក្រចេះ អំពី ៖

-សារអប់រំស្តីពីគ្រោះថ្នាក់នៃគ្រឿងញៀន

-ច្បាប់ចរាចរណ៍ផ្លូវគោក អនុក្រឹត្យលេខ៣៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០

-អំពើហិង្សាក្នុងគ្រួសារ

-វិធីបង្ការ និងទប់ស្កាត់បទល្មើសចោរកម្ម

-អំពើហិង្សាលើស្ត្រី និងកុមារ

-វិធីបង្ការ ទប់ស្កាត់គ្រោះអគ្គិភយ័ផ្សេងៗ

-គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព

-ណែនាំប្រជាពលរដ្ឋឲ្យមានការប្រុងប្រយ័ត្នចំពោះគ្រោះថ្នាក់អគ្គីភ័យ

-ផ្សព្វផ្សាយអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌ័មិនទាន់ផ្ទុះ ។

ក្នុងឱកាសនោះផងដែរ បានណែនាំឲ្យប្រជាពលរដ្ឋឲ្យចេះសំអាតខ្លួនប្រាណ មានអនាម័យល្អ លាងដៃនឹងសាប៊ូ អាល់កុលឬជែលឲ្យបានញឹកញាប់ ដើម្បីទប់ស្កាត់ការពាការឆ្លងជំងឺ COVID-19 បានចំនួន៥៦ខ្នងផ្ទះ ក្នុងនោះមានប្រជាពលរដ្ឋចូលរួម ចំនួន ១៥២នាក់ ស្រី ១៤៥នាក់ និងចែកខិតប័ណ្ណបានចំនួន ១៤៥សន្លឹក ៕

## ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលរដ្ឋខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់អាជ្ញាធរខេត្តសៀមរាប

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី 15 ខែ មិថុនា ឆ្នាំ 2020

សៀមរាប៖ នៅថ្ងៃចន្ទ ទី១៥ ខែមិថុនា ឆ្នាំ២០២០នេះ នៅតែទៅបន្តរង់ចាំទទួលប្រជាពលរដ្ឋខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃជាដដែល។ នៅថ្ងៃនេះដែរទទួលបានចំនួនសរុប ៥៧នាក់ ស្រីចំនួន ៣៥នាក់ ដែលចូលមកតាមច្រកដូង ខេត្តបាត់ដំបង, តាមច្រកប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ និងច្រកអូរស្មាច់ ខេត្តឧត្តរមានជ័យ ។ គិតចាប់ពីថ្ងៃទី១០ ខែមីនា មកដល់ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០នេះ សម្រាប់ខេត្តសៀមរាបតួលេខសរុបដែលបានទទួលប្រជាពលរដ្ឋខ្មែរ ចូលតាមច្រកទាំងបីខាងលើមានចំនួន ១៤,៥៥៤នាក់ ស្រីចំនួន ៦,៣៣២នាក់ ក្នុងនោះបានពិនិត្យសុខភាពបឋមបានចំនួន១៤,៥៥៤នាក់ ស្រី ៦,៣៣២នាក់ គឺពិនិត្យសុខភាពបានទាំងអស់។ សូមបញ្ជាក់ជូនថា ប្រជាពលករខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃក្នុងមួយថ្ងៃៗ មានចន្លោះពីជាង ១០០ នាក់រហូតដល់ជាង ៣០០នាក់ សម្រាប់ទូទាំងប្រទេសកម្ពុជា ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប

## ពលរដ្ឋខ្មែរ បន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ២១នាក់

https://www.facebook.com/GDIOfficial 15-06-2020

នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ២១នាក់ ស្រី ១០នាក់៕

## ថៃបានបញ្ជូនពលរដ្ឋខ្មែរចំនួន ០២នាក់ ឲ្យមកប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ ពីបទឆ្លងដែនខុសច្បាប់

https://www.facebook.com/GDIOfficial 15-06-2020

នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ ខាងភាគីថៃបានបញ្ជូនពលរដ្ឋខ្មែរចំនួន ០២នាក់ ឲ្យមកប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិជាំ ពីបទឆ្លងដែនខុសច្បាប់ ទៅកាប់ឈើនៅប្រទេសថៃ ដែលចេញតាមច្រកអូរ៥០ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ៕

## ច្រកព្រំដែនទាំងអស់នៃខេត្តបន្ទាយមានជ័យត្រូវបានបិទ តែបទល្មើសអត់បិទទេ

http://mekong-post.com/ ដោយ Mekong Post ចេញផ្សាយ ថ្ងៃទី 15 June, 2020

**បន្ទាយមានជ័យ ៖ ទោះបីជាច្រកទ្វារនិងច្រករបៀងទាំងអស់ត្រូវបានប្រមុខរាជរដ្ឋាភិបាលនៃទ្វេរភាគីមានកម្ពុជា-ថៃ ប្រកាសបិទទាំងស្រុងទៅហើយក្តី តែគ្រប់បទល្មើសឆ្លងដែនហាក់មានសន្ទុះខ្លាំងក្លាជាងកាលដែលនៅបើក។អ្នករកស៊ីបទល្មើស រត់ពន្ធនិយាយថា ច្រកបិទចឹងស្រួលរកស៊ីនិងចំនេញជាងមុន ព្រោះបទល្មើសខ្លះអាចរកស៊ីផ្តាច់មុខ អោយតែត្រូវជាមួយសមត្ថកិច្ចមាត់ច្រកនិងសមត្ថកិច្ចលើដងផ្លូវ ទោះជាចាប់អោយល្អមើលម្តងម្កាលក៏មិនអីដែរ។**

ជាក់ស្តែងនៅវេលាម៉ោង១និង១៥នាទីរសៀល ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២០ លើផ្លូវកំណាត់ជាតិលេខ៥ ត្រង់ចំណុចចម្ងាយ១០០ម៉ែត្រ ខាងកើតស្ពានទឹកថ្លា ស្ថិតក្នុងភូមិសាស្ត្រ ភូមិបាណយ សង្កាត់ទឹកថ្លា ក្រុង សិរីសោភ័ណ ខេត្តបន្ទាយមានជ័យ កំលាំងនគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ចនៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យសហការជាមួយកម្លាំងមន្ត្រីពេទ្យសត្វ បានស្ទាក់ឃាត់រថយន្តទំនើបមួយគ្រឿង ដែលដឹកគ្រឿងក្នុងជ្រូកសង្ស័យខូចគុណភាព។ រថយន្តដែលស្ទាក់ឃាត់បានមានម៉ាកតូយូតា Srenna ពណ៌ផ្ទៃមេឃ ផលិតឆ្នាំ២០០៤ ពាក់ស្លាកលេខ ភ្នំពេញ 2AB.7392 បើកបរដោយឈ្មោះ សាយ ដឿន ភេទប្រុសអាយុ ៥២ឆ្នាំ រស់នៅក្រុងភ្នំពេញ ។ក្រោយឃាត់សមត្ថកិច្ចបានរកឃើញ គ្រឿងក្នុងជ្រូកចម្រុះ ចំនួន០៩កេះមានទម្ងន់ស្មើ៥៤០គីឡូក្រាម ។

អ្នកបើកបរនិយាយថា ខ្លួនបានទទួលស៊ីឈ្នួលដឹកពីប៉ោយប៉ែតទៅភ្នំពេញក្នុងមួយកេះ៣ម៉ឺនរៀល។ អ្នកឃើញហេតុការណ៍នៃការចាប់និងដុតចោលបានសម្តែងការភ័យខ្លាចនិងរិះគន់ទៅលើសមត្ថកិច្ចពាក់ពន្ធ័ថា គ្រឿងក្នុងជ្រូកទាំងនេះវាមិនអាចហោះឆ្លងព្រំដែននោះទេ ទាល់តែមានការឃុបឃិតជាប្រពន្ធ័ទើបវាអាចចូលមកបាន ។ហើយចំពោះអ្នកដែលមិនបានលាភសក្ការៈពីបទល្មើសឆ្លងដែនប្រឹងស្ទាក់ចាប់ដើម្បីបង្កើនស្នាដៃ ហើយបើបានសើមមាត់សើម ក នឹងគេដែរនោះគឺពិតជាប្រឹងបិទភ្នែកមើលមិនឃើញនោះទេ។

សូមបញ្ជាក់ផងដែរថា ក្រោយច្រកប្រកាសបិទ ដើម្បីទប់ស្កាត់កូវីដ១៩ បទល្មើសឆ្លងចូលជាច្រើនបានហូរចូលដូចទឹកបាក់ទំនប់ក្នុងនោះ គោក្របី ជ្រូក មាន់ទា ទំនិញផ្សេងៗ រួមទាំងរថយន្តចង្កូតស្តាំ សុទ្ធតែបាននាំចូលតាមច្រករបៀង នៃស្រុក ម៉ាឡៃ ប៉ោយប៉ែត អូរជ្រៅ ស្វាយចេក ហើយមានច្រកខ្លះក៏មានការនាំចេញ-នាំចូលមនុស្សផងដែរ៕

# ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២០

## អភិបាលខេត្តកំពង់ឆ្នាំង អញ្ជើញជាអធិបតីក្នុងវេទិកាផ្សព្វផ្សាយអំពីផលប៉ះពាល់នៃការធ្វើចំណាកស្រុកដល់បងប្អូនប្រជាពលរដ្ឋក្នុងស្រុកទឹកផុស

https://grandnewsasia.com/ 16-06-2020

កំពង់ឆ្នាំង៖ នាព្រឹកថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២០ លេខាធិការដ្ឋានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) ខេត្តកំពង់ឆ្នាំង បានរៀបចំវេទិកាដើម្បីផ្សព្វផ្សាយអំពីផលប៉ះពាល់នៃការធ្វើចំណាកស្រុកដោយប្រថុយប្រថាន និងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ជូនដល់ប្រជាពលរដ្ឋរស់នៅឃុំខ្លុងពពក ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ក្រោមអធិបតីភាព លោក ឈួរ ច័ន្ទ ឌឿន អភិបាលខេត្ត និងជាប្រធានគណៈកម្មា ធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត លោកស្រី ប៊ន សុភី អភិបាល រងខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) ខេត្តកំពង់ឆ្នាំង។

ពិធីនេះដែរក៏មានការចូលរួមពីអភិបាលរងខេត្ត អភិបាលស្តីទីស្រុកទឹកផុស លោកស្រីឧត្តមសេនីយ៍ត្រី មាស សុម៉ាលី ស្នងការរង នគរបាលខេត្តកំពង់ឆ្នាំង លោក លោកស្រីជាថ្នាក់ដឹកនាំមន្ទីរ អង្គភាព ក្នុងគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត កម្លាំងមានសមត្ថកិច្ច, មេ ឃុំ មេភូមិ អាជ្ញាធរ ក្រុមការងារ របស់លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត និងប្រជាពលរដ្ឋជាច្រើនទៀតចូលរួមផងដែរ។

លោកស្រី ប៊ិន សុភី អភិបាល រងខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) ខេត្តកំពង់ឆ្នាំង បានបញ្ជាក់ពីគោលបំណងនៃការរៀបចំវេទិកា គឺដើម្បីឱ្យប្រជាពលរដ្ឋយល់កាន់តែច្បាស់អំពីការធ្វើចំណាកស្រុក ជៀសវាងការធ្វើចំណាកស្រុកដោយប្រថុយប្រថាន តាមការឃោសនា របស់មេខ្យល់អូសទាញនិងដើម្បីបង្ការទប់ស្កាត់អំពើជួញដូរមនុស្សតាមគ្រប់រូបភាពផងដែរ។

លោក ឈួរ ច័ន្ទ ឌឿន អភិបាលខេត្តកំពង់ឆ្នាំង និងជាប្រធានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត បានកោតសរសើរ ដល់គណៈកម្មាធិការ គ.ខ.ប.ជ ខេត្ត និងក្រុមលេខាធិការដ្ឋាន និងក្រុមការងារជំនាញអន្តរមន្ទីរ អង្គភាព ដែលបានយកចិត្តទុកដាក់អនុវត្តការងាររួមគ្នា ដើម្បីបង្ការ និងទប់ស្កាត់ ព្រមទាំងចាត់វិធានការតាមច្បាប់ឱ្យបានទាន់ពេលវេលា ចំពោះជនល្មើស និងមេខ្យល់ដែលបានប្រើប្រជាភិថុតតាមគ្រប់រូបភាព។ ក្នុងនោះដែរ លោកអភិបាលខេត្ត ក៏បានផ្តាំផ្ញើការសាកសួរសុខទុក្ខពីលោកឧបនាយករដ្ឋមន្ត្រី ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ), លោកស្រី ជូ ប៊ុនអេង អនុអចិន្ត្រៃយ៍ គ.ជ.ប.ជ និងបានធ្វើផ្សព្វផ្សាយ ដល់បងប្អូនប្រជាពលរដ្ឋទាំងអស់៖

១. យល់ពីផលប៉ះពាល់ការធ្វើចំណាកស្រុកដោយប្រថុយប្រថាន ប្រុងប្រយ័ត្ន ចំពោះមេខ្យល់គ្រប់រូបភាព។

២. រាយការណ៍ បន្ទាន់ទៅក្រុមការងារថ្នាក់ស្រុក ឃុំ ភូមិ ប៉ុស្តិ៍ ដែលនៅជិត ចំពោះករណីសង្ស័យ មានជនណាមកឃោសនា។

៣.ចូររួមសាមគ្គីសហការគ្នា ជួយគ្នាទៅវិញទៅមកដោយមិនឲ្យមានការរើសអើង។

៤. ចូលរួមអនុវត្តន៍ ភូមិឃុំ មានសុវត្ថិភាព។

៣. ត្រូវរក្សាអនាម័យ អនុវត្តវិធានការការពារខ្លួនពីជំងឺផ្សេងៗជាពិសេសជំងឺកូវីដ១៩ ដែលកំពុងរីករាលដាលទូទាំងសកលលោក ត្រូវតែប្រុងប្រយ័ត្ន និងអនុវត្តនូវវិធានការនានាដែលរាជរដ្ឋាភិបាលកម្ពុជា និងស្តាប់តាមការណែនាំរបស់ក្រសួងសុខាភិបាលឱ្យបានជាប្រចាំដើម្បីចូលរួមទាំងអស់គ្នាកុំឱ្យកើតមានជំងឺកូវីដ១៩ នៅក្នុងដំណាក់កាលដែលមានរលកទី២នេះនៅក្នុងសហគមន៍យើងជាដាច់ខាត។

លោកអភិបាលខេត្ត បានធ្វើការអំពាវនាវបន្ថែមទៀតឱ្យប្រជាពលរដ្ឋទាំងអស់គ្នាត្រូវបង្កើនការផលិតផ្នែកកសិកម្ម តាមរយៈ ការដាំដុះ ការចិញ្ចឹមសត្វជាដើម ដើម្បីដោះស្រាយបញ្ហាជីវភាព។ ក្នុងនោះ លោក បានជូនថវិកាប្រជាពលរដ្ឋ ចំនួន ៥០នាក់ ក្នុងម្នាក់ៗទទួលបាន ៣០ ០០០រៀល និងឧបត្ថម្ភដល់ក្រុមការងារ របស់លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត ចំនួន ៤០០ ០០០រៀលផងដែរ៕

## ថៃចាប់បញ្ជូនពលករខ្មែរ ដែលឆ្លងដែនខុសច្បាប់ចំនួន ០១នាក់តាមប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម

https://www.facebook.com/GDIOfficial 16-06-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម នាវេលាម៉ោង ១៧និង០០នាទី ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ ២០២០ ខាងភាគីថៃចាប់បញ្ជូនពលករខ្មែរ ដែនឆ្លងដែនខុសច្បាប់ ចំនួន ០១នាក់ ដោយមានការចូលរួមត្រួតពិនិត្យសុខភាពពីក្រុមចត្តាឡីស័ក។ កម្លាំងនគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរនេះ មាន ឈ្មោះ មហាម៉ាត់ សុក្រី

ភេទប្រុស អាយុ ៤៥ឆ្នាំ មានទីលំនៅភូមិ រ៉ាសួង ឃុំព្រៃកលួង ស្រុកឯកភ្នំ ខេត្តបាត់ដំបង។ បន្ទាប់មកកម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំ និងណែនាំ រួចបញ្ជូនទៅឲ្យក្រុមចត្តាឡីស័ក ដើម្បីអនុវត្តបន្ត៕

## ពលរដ្ឋខ្មែរ បន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៣០នាក់

https://www.facebook.com/GDIOfficial 16-06-2020

នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៣០នាក់ ស្រី ១០នាក់៕

## ថៃឃាត់ពលករខ្មែរ ១៤ នាក់ និងមេខ្យល់ម្នាក់ ដែលលបឆ្លងដែនចូលទឹកដីថៃខុសច្បាប់

---

http://kampucheathmey.com/ 17/6/2020 2:38 Pm

**ប្រទេសថៃ ៖** ពលករខ្មែរសរុបជាង ១០ នាក់ ដែលត្រូវបានមេខ្យល់អូសទាញឲ្យលប់ចូលទៅក្នុងទឹកដីថៃដោយខុសច្បាប់ បំណងទៅធ្វើការនៅក្នុងទីក្រុងបាងកក ប្រទេសថៃ តែត្រូវបានក្រុមតម្រួតថៃធ្វើការចាប់ខ្លួននៅក្នុងខេត្តស្រះកែវ ខណៈដែលពួកគេកំពុងធ្វើដំណើរតាមរយៈរថយន្តឈ្នួលរបស់ថៃ។

យោងតាមផ្សាយព័ត៌មានរបស់សារព័ត៌មានក្នុងស្រុក របស់ប្រទេសថៃ បានបញ្ជាក់ថា នៅវេលាម៉ោង៣រសៀល ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២០ លោក អាទិត្យ យ៉ាកែវ នាយនគរបាលអន្តោប្រវេសន៍ប្រចាំខេត្តស្រះកែវ បានបញ្ជាក់ថា ក្រោយពីលោកបានទទួលនូវសេចក្តីរាយការណ៍ ពីកម្លាំង ក ស របស់លោករួចមក លោកបានចាត់នាយរងរបស់លោក ដឹកនាំកម្លាំងចេញប្រតិបត្តិការតាមបណ្តោយផ្លូវលេខ ៣៣៤៥ ដែលមានទិសដៅពី វឌ្ឍនាណា ខន ទៅប្រាក់យ៉ា។ នៅក្នុងកិច្ចប្រតិបត្តិការនោះ កម្លាំងជំនាញ ដែលបានសហការជាមួយកម្លាំងតម្រួតព្រហ្មទណ្ឌ បានឃាត់រថយន្តមួយគ្រឿង ម៉ាកនីសាន់ ឃ្លុបក្រោយ ពណ៌ខ្មៅ ពាក់ស្លាកលេខ បាងកក ៤៣៧៧ ដើម្បីសាកសួរ និងត្រួតពិនិត្យបន្ទាប់ពីមានការសង្ស័យ ដែលរថយន្តនេះបើកបរដោយឈ្មោះ ខ្វាន់យូ សួងថូ ភេទប្រុស អាយុ៣៣ឆ្នាំ ជាជនជាតិថៃ។

នៅក្នុងរថយន្តនោះគេសង្កេតឃើញថា មានជនជាតិខ្មែរម្នាក់ដែលនៅអង្គុយខាងមុខ និងជាមេខ្យល់ផងមានឈ្មោះ កៅ សាម៉ាត ភេទប្រុស អាយុ៥០ឆ្នាំ ចំណែកនៅក្នុងឃ្លុបរថយន្តខាងក្រោយ មានពលករខ្មែរសរុបចំនួន ១៤នាក់ ក្នុងនោះស្រី ១នាក់ ដែលពួកគេទាំងអស់គ្នាមានបំណងលបចូលដោយខុសច្បាប់ទៅធ្វើការនៅក្នុងទីក្រុងបាងកក។ បច្ចុប្បន្នពួកគេទាំងអស់គ្នា ត្រូវបានក្រុមតម្រួតថៃបញ្ជូនទៅកាន់អង្គភាព ដើម្បីសាកសួរបន្តនិងធ្វើការតាមផ្លូវច្បាប់ ពាក់ព័ន្ធនឹងករណីលបឆ្លងដែនគ្មានច្បាប់អនុញ្ញាត៕ **អត្ថបទ៖ សោ និយមវ័ត្ន**

## កម្ពុជា បន្តយកចិត្តទុកដាក់ ផ្ដល់កិច្ចគាំពារ ដល់ពលរដ្ឋខ្មែរ នៅបរទេស

https://dap-news.com/national/ ByKD102 Posted on June 16, 2020

ភ្នំពេញ៖ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ តាមរយៈស្ថានតំណាងកម្ពុជា នៅក្រៅបរទេស តែងតែផ្ដោតការយកចិត្តទុកដាក់ ក្នុងការសម្របសម្រួល ផ្ដល់កិច្ចគាំពារ និងជួយឧបត្ថម្ភដល់ពលរដ្ឋខ្មែរនៅរទេស ជាពិសេសនៅក្នុងកាលៈទេសៈ នៃការរីករាលដាលនៃជម្ងឺកូវីដ–១៩។ ចាប់តាំងពីមានការផ្ទុះ រាលដាលនៃជម្ងឺកូវីដ–១៩មក គិតត្រឹមចុងខែឧសភា ឆ្នាំ២០២០ ស្ថានទូតកម្ពុជាបានផ្ដល់ ការឧបត្ថម្ភម៉ាសអាល់កុល គ្រឿងឧបភោគ បរិភោគ និងថវិកា ដោយផ្ទាល់ និងតាមរយៈការសហការ ជាមួយសប្បុរសជននានា ជូនដល់ពលរដ្ឋខ្មែរ ជាពិសេស ពលករ–ពលការិនី និងនិស្សិតខ្មែរនៅបរទេស ចំនួនប្រមាណជាង ២០.០០០នាក់ ដែលរួមមាន នៅក្នុងប្រទេសថៃ (ប្រមាណជាង៥.០០០ នាក់) សាធារណរដ្ឋកូរ៉េ (ប្រមាណជាង៥.០០០នាក់) ប្រទេសម៉ាឡេស៊ី (ចំនួន ២.១៤៥គ្រួសារ) ប្រទេសជប៉ុន (ចំនួន១.២៨៩នាក់) អេហ្សីប (ចំនួន១១០នាក់) សិង្ហបុរី (ចំនួន៥៤នាក់) ប្រទេសវៀតណាម (ចំនួន៥១នាក់) និងនៅប្រទេសដទៃទៀតផងដែរ។

នៅក្នុងស្មារតីប្រហាក់ប្រហែលគ្នានេះ ពេញមួយខែឧសភាកន្លងទៅ ស្ថានទូតបានបន្ត ធ្វើអន្តរាគមន៍ជួយសង្គ្រោះ និងរៀបចំមាតុភូមិនិវត្តន៍ពលរដ្ឋខ្មែរ ដែលរងគ្រោះដោយសារការជួញដូរមនុស្ស និងការបំលោភបំពានផ្សេងៗផ្នែកការងារនៅបរទេស បានចំនួន៣៩២នាក់ មកពីប្រទេសថៃ វៀតណាម និងចិន៕

## ILO និង UNICEF ព្រមានថា វិបត្តិជំងឺកូវីដកំពុងជំរុញឲ្យកុមាររាប់លាននាក់លើពិភពលោក ធ្លាក់ចូលក្នុងពលកម្មកុមារ

https://www.postkhmer.com/ វី សុចាន់ | Publication date 17 June 2020 | 10:44 ICT

**ភ្នំពេញ:** អង្គការពលកម្មអន្តរជាតិ (ILO) និង UNICEF បានព្រមានថា វិបត្តិជំងឺកូវីដ ១៩ កំពុងជំរុញឲ្យកុមាររាប់លាននាក់បន្ថែមទៀតនៅលើពិភពលោកជួបហានិភ័យធ្លាក់ចូលទៅក្នុងពលកម្មកុមារ ខណៈដែលកម្ពុជាបាននិងកំពុងកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រក្នុងអំឡុងនៃការរីករាលដាលជំងឺកូវីដ ១៩ ដោយគិតត្រឹមថ្ងៃទី ១ ខែមិថុនា រកឃើញគ្រួសារក្រីក្រចំនួន ៥៦៧ ៥០៥ គ្រួសារ។

យោងតាមរបាយការណ៍របស់ ILO និង UNICEF ក្នុងសេចក្ដីប្រកាសព័ត៌មានចុះថ្ងៃទី ១២ ខែមិថុនាឲ្យដឹងថា ពលកម្មកុមារបានថយចុះចំនួន ៩៤ លាននាក់ចាប់តាំងពីឆ្នាំ ២០០០ តែថា ការថយចុះនេះកំពុងមានហានិភ័យនាពេលនេះ។ សេចក្ដីប្រកាសព័ត៌មានថា៖ «ការប៉ាន់ប្រមាណជាសកលក្នុងឆ្នាំ ២០១៧ បានបង្ហាញថា កុមារចំនួន ១៥២ លាននាក់ ស្ថិតនៅក្នុងពលកម្មកុមារ ទូទាំងសកលលោក»។ សេចក្ដីប្រកាសបន្ថែមថា ជំងឺកូវីដ ១៩ អាចបណ្ដាលឲ្យភាពក្រីក្រកើនឡើងហេតុនេះហើយក៏នឹងធ្វើឲ្យកើនឡើងនូវពលកម្មកុមារផងដែរ ខណៈគ្រួសារកុមារបានប្រើប្រាស់គ្រប់មធ្យោបាយ ដើម្បីរស់រានមានជីវិត។ សេចក្ដីប្រកាសព័ត៌មានថា៖«ខណៈដែលការរាតត្បាតនេះ ធ្វើឲ្យហិនហោចប្រាក់ចំណូលគ្រួសារ បើគ្មានការឧបត្ថម្ភ គ្រួសារជាច្រើនអាចងាកទៅរកពលកម្មកុមារ»។

លោក Guy Ryder អគ្គនាយក ILO ថ្លែងក្នុងសេចក្ដីប្រកាសព័ត៌មានថា៖ «ការគាំពារសង្គម ពិតជាសំខាន់ក្នុងពេលមានវិបត្តិ ដោយការគាំពារនេះត្រូវផ្ដល់ការឧបត្ថម្ភដល់អ្នកដែលងាយរងគ្រោះបំផុត។ ការធ្វើសមាហរណកម្មកង្វល់ពលកម្មកុមារក្នុងគោលនយោបាយកាន់តែទូលំទូលាយ សម្រាប់ការអប់រំ គាំពារសង្គម យុត្តិធម៌ ទីផ្សារការងារ និងសិទ្ធិមនុស្សអន្តរជាតិ និងសិទ្ធិការងារធ្វើឲ្យមានភាពខុសគ្នាច្រើន»។

អ្នកនាំពាក្យក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈលោក ហេង សួរ មិនអាចទាក់សុំសេចក្ដីអធិប្បាយ ជុំវិញករណីនេះបានទេ។ ប៉ុន្តែលោក តូច ចាន់នី អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេសក្រសួងសង្គមកិច្ចថ្លែងថា រ

ដ្ឋាភិបាលបានវិនិយោគលើកុមារ តាមរយៈការផ្ទេរសាច់ប្រាក់ទៅឲ្យស្ត្រីមានផ្ទៃពោះក្រីក្រ និងកុមារអាយុក្រោម ២ ឆ្នាំរយៈពេលប្រហែល ១ ឆ្នាំមកហើយ។

បើតាមទំព័រហ្វេសប៊ុកក្រសួងផែនការចុះផ្សាយកាលពីថ្ងៃទី ១២ ខែមិថុនា ក្រសួងផែនការបានធ្វើបច្ចុប្បន្នភាពកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ ក្នុងអំឡុងពេលនៃការរីករាលដាលជំងឺកូវីដ១៩ គិតត្រឹមថ្ងៃទី១ ខែមិថុនា ឆ្នាំ ២០២០ ដោយរកឃើញគ្រួសារក្រីក្រទូទាំងប្រទេសសរុបចំនួន ៥៦៧ ៥០៥ គ្រួសារ ដែលមានប្រជាជនក្រីក្រសរុបប្រមាណ ២,៣ លាននាក់ (គិតត្រឹមថ្ងៃបញ្ចប់ការអនុវត្តនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រក្នុងអំឡុងនៃការរីករាលដាលជំងឺកូវីដ ១៩ នៅជនបទ)។ ក្រសួងនឹងកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅទីប្រជុំជន ដែលនឹងបញ្ចប់នាចុងខែមិថុនា ឆ្នាំ ២០២០ ដើម្បីផ្តល់នូវកម្មវិធីឧបត្ថម្ភសាច់ប្រាក់របស់រាជរដ្ឋាភិបាលដល់ពួកគេ ដែលនឹងត្រូវអនុវត្តក្នុងពេលឆាប់ៗ។

កាលពីថ្ងៃទី ១ ខែមិថុនា អង្គការ Save the Children និងយូនីសេហ្វបានព្រមានថា បើគ្មានវិធានការបន្ទាន់ទេ កុមារក្រីក្រក្នុងប្រទេសមានប្រាក់ចំណូលកណ្តាលកម្រិតទាបអាចកើនឡើងដល់ជាង ៦៧២ លាននាក់នៅត្រឹមឆ្នាំនេះ។ អង្គការនេះឲ្យដឹងក្នុងសេចក្តីប្រកាសព័ត៌មានកាលពីថ្ងៃទី ១ ខែមិថុនា ឆ្នាំ ២០២០ ថាចាប់តាំងពីពេលដែលមានករណីជំងឺកូវីដ ១៩ មក រាជរដ្ឋាភិបាលកម្ពុជាបានពង្រីកវិសាលភាពកម្មវិធីគាំពារសង្គមរបស់ខ្លួន។ អង្គការទាំងនេះបន្តថា កម្មវិធីឧបត្ថម្ភសាច់ប្រាក់ប្រចាំខែជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ ១៩ ត្រូវបានរៀបចំឡើង ដើម្បីឆ្លើយតបចំពោះតម្រូវការរបស់ក្រុមប្រជាជនដែលងាយរងគ្រោះបំផុត រាប់បញ្ចូលទាំងតម្រូវការរបស់កុមារអាយុពី ០-៥ ឆ្នាំ ជនមានពិការភាព ចាស់ជរា និងអ្នកដែលរស់នៅជាមួយនឹងមេរោគអេដស៍/ជំងឺអេដស៍។

អង្គការថ្លែងថា៖ «កម្មវិធីនេះនឹងផ្តល់ថវិកាបន្ថែមទៅលើកម្មវិធីដែលមានស្រាប់ដូចជាកម្មវិធីឧបត្ថម្ភសាច់ប្រាក់ ដល់ស្ត្រីមានផ្ទៃពោះ និងកុមារអាយុ ០-២ ឆ្នាំ និងកម្មវិធីផ្តល់អាហារូបករណ៍ដល់កុមារដែលកំពុងរៀននៅបឋមសិក្សា និងមធ្យមសិក្សាដែលកំពុងអនុវត្តនាពេលបច្ចុប្បន្ន»៕

## ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២០

### លោកជំទាវ ជូ ប៊ុនអេង អញ្ជើញជាអធិបតី ដឹកនាំកិច្ចប្រជុំពិភាក្សា ពង្រឹងវិធានការទប់ស្កាត់ និងគ្រប់គ្រងការឆ្លងដែនដោយខុសច្បាប់របស់ពលករកម្ពុជា

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី 18 ខែ មិថុនា ឆ្នាំ 2020

AKP បន្ទាយមានជ័យ ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២០៖ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អញ្ជើញជាអធិបតី ដឹកនាំកិច្ចប្រជុំពិភាក្សា ពង្រឹងវិធានការទប់ស្កាត់ និងគ្រប់គ្រងការឆ្លងដែនដោយខុសច្បាប់របស់ពលករកម្ពុជា ដោយមានការចូលពីមន្ត្រីអាជ្ញាធរសមត្ថកិច្ចពាក់ព័ន្ធ នៃខេត្តបន្ទាយមានជ័យ បាត់ដំបង សៀមរាប ឧត្តរមានជ័យ និងអង្គការអន្តរជាតិប្រមាណ ៦៧នាក់ នាថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២០ នៅសាលាខេត្តបន្ទាយមានជ័យ។ ៖ ឈុន សារ៉ាត

### មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃ អញ្ជើញចុះសួរសុខទុក្ខ ប្រជាពលរដ្ឋដែលត្រឡប់មកពីក្រៅប្រទេស ហើយកំពុងធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃ នៅស្រុកក្រឡាញ់ ខេត្តសៀមរាប

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី 18 ខែ មិថុនា ឆ្នាំ 2020

AKP សៀមរាប ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២០៖ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អញ្ជើញជួបសំណេះសំណាល

និងសួរសុខទុក្ខប្រជាពលរដ្ឋ ប្រមាណ១០០នាក់ ដែលបានត្រឡប់មកពីក្រៅប្រទេស ហើយកំពុងធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃ នៅក្នុងវិទ្យាល័យក្រឡាញ់ ស្រុកក្រឡាញ់ ខេត្តសៀមរាប នាព្រឹកថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២០ ព្រមទាំងណែនាំដល់ពួកគាត់ កុំប្រថុយប្រថានធ្វើការឆ្លងដែនដោយខុសច្បាប់ ។ ៖ យុត សៅ

## អនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖ ប្រជាពលរដ្ឋកុំប្រថុយប្រថានធ្វើការឆ្លងដែនដោយខុសច្បាប់ គួរធ្វើការនៅក្នុងប្រទេសប្រសើរជាង

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី 18 ខែ មិថុនា ឆ្នាំ 2020

AKP សៀមរាប ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២០៖ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សបានលើកឡើងថា បច្ចុប្បន្ននេះ ពិភពលោកនៅតែប្រឈមនឹងមេរោគកូវីដ-១៩ ហើយនៅរាល់ការធ្វើដំណើរឆ្លងដែន គឺត្រូវបានធ្វើពិនិត្យពីមន្ត្រីជំនាញយ៉ាងយកចិត្តទុកដាក់ និងត្រូវធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃ ផងដែរ។ ថ្លែងទៅកាន់ប្រជាពលរដ្ឋចំនួន ១០០នាក់ ដែលបានត្រឡប់មកពីក្រៅប្រទេស ហើយកំពុងធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃ ដែលស្ថិតនៅក្នុងវិទ្យាល័យក្រឡាញ់ ស្រុកក្រឡាញ់ ខេត្តសៀមរាប នៅព្រឹកថ្ងៃទី១៨ខែមិថុនា ឆ្នាំ២០២០ លោកជំទាវ ជូ ប៊ុនអេង បានគូសបញ្ជាក់ថា ខណៈដែលកំពុងតែប្រឈមនឹងបញ្ហាមេរោគកូវីដ-១៩ នេះ យើងឃើញថា មានប្រជាពលរដ្ឋកម្ពុជាមួយចំនួននៅតែមានការលួចឆ្លងដែនដោយខុសច្បាប់តាមរយៈការចាញ់បោកមេខ្យល់។

លោកជំទាវបានណែនាំឱ្យប្រជាពលរដ្ឋដែលមានបំណងឆ្លងដែនដោយខុសច្បាប់គួរបញ្ឈប់ជាបន្ទាន់ ព្រោះការលួយឆ្លងដែនបច្ចុប្បន្ននេះ គឺបានធ្វើឱ្យបងប្អូនប្រឈមនឹងបញ្ហាជាច្រើន ដូចជា ងាយឆ្លងមេរោគកូវីដ-១៩ ចាញ់បោកមេខ្យល់ខាតបង់ប្រាក់កាស ហើយពេលឆ្លងចូលប្រទេសគេដោយខុសច្បាប់ ពេលគេចាប់បាននឹងធ្វើបាប់គ្រប់សព្វបែបយ៉ាង។ លោកជំទាវបានបន្តថា រដ្ឋាភិបាលកម្ពុជាមិនហាមឃាត់ប្រជាពលរដ្ឋឱ្យទៅធ្វើការក្រៅប្រទេសនោះទេ ប៉ុន្តែបងប្អូនត្រូវចាំឱ្យស្ថានភាពជំងឺកូវីដចប់សិន ហើយត្រឡប់ទៅធ្វើការក្រៅប្រទេសវិញតាមរយៈក្រសួងការងារ ឬក្រុមហ៊ុនដោយស្របច្បាប់។ លោកជំទាវរដ្ឋលេខាធិការបានបន្ថែមថា ស្ថានភាពបច្ចុប្បន្ននេះ បងប្អូនគួរងាកមកធ្វើការងារនៅក្នុងស្រុកសិនល្អជាង ដូចជាការដាំបន្លែបង្ការ ធ្វើស្រែ និងការងារផ្សេងៗជាច្រើនដែលប្រទេសយើងមាន។

លោកស្រី ម៉ននី រង្សី អភិបាលស្រុកក្រឡាញ់ ខេត្តសៀមរាបបានឱ្យដឹងថា ចាប់តាំងពីថ្ងៃទី១០ ខែមេសា ឆ្នាំ២០២០ រហូតមកដល់ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២០នេះ នៅស្រុកក្រឡាញ់មានប្រជាពលរដ្ឋបានធ្វើចត្តាឡីស័កក្នុងវិទ្យាល័យក្រឡាញ់មានចំនួន៦៥៤នាក់ ស្រី ២៩៤នាក់។ លោកស្រីបានបន្តថា អ្នកបានបញ្ចប់ការធ្វើចត្តាឡីស័កមកដល់ថ្ងៃនេះមានចំនួន៥០៥នាក់ ស្រី២២៦នាក់ ក្នុងនោះ កុមារា ៣១នាក់ កុមារី ២៥នាក់ និងស្ត្រីមានផ្ទៃពោះ ១២នាក់។ លោកស្រីអភិបាលស្រុកបានបន្ថែមទៀតថា បច្ចុប្បន្ននៅសល់ចំនួន១៤៩នាក់ ស្រី ៦៨នាក់ កំពុងស្នាក់នៅមណ្ឌលចត្តាឡីស័ក ហើយរៀងរាល់ថ្ងៃនេះ ក៏នៅតែមានបងប្អូនប្រជាពលរដ្ឋធ្វើចំណាកស្រុកមកពីប្រទេសថៃជាបន្តបន្ទាប់៕ ដោយ៖យុត សៅ

## មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃ ជំរុញឱ្យអាជ្ញាធរសមត្ថកិច្ចពាក់ព័ន្ធទាំងអស់ ពង្រឹងវិធានការទប់ស្កាត់ការឆ្លងដែនខុសច្បាប់របស់ពលករកម្ពុជា

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី 18 ខែ មិថុនា ឆ្នាំ 2020

AKP បន្ទាយមានជ័យ ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២០៖ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សបានជំរុញដល់អាជ្ញាធរដែន

ជីសមត្ថកិច្ចពាក់ព័ន្ធទាំងអស់ត្រូវបង្កើនពង្រឹងវិធានការទប់ស្កាត់ការឆ្លងដែន ដោយខុសច្បាប់របស់ពលករកម្ពុជាឱ្យមានប្រសិទ្ធភាពថែមទៀត។ ការជំរុញរបស់លោកជំទាវនេះបានធ្វើឡើង នៅក្នុងកិច្ចប្រជុំពិភាក្សា ដើម្បីពង្រឹងវិធានការទប់ស្កាត់ និងគ្រប់គ្រងការឆ្លងដែនដោយខុសច្បាប់របស់ពលករកម្ពុជា នៅសាលាខេត្តបន្ទាយមានជ័យ កាលពីថ្ងៃពុធ ១២រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២០ ដោយមានការចូលពីមន្ត្រីអាជ្ញាធរសមត្ថកិច្ចពាក់ព័ន្ធខេត្តបន្ទាយមានជ័យ បាត់ដំបង សៀមរាប ឧត្តរមានជ័យ និងអង្គការអន្តរជាតិ ។

លោកជំទាវ ជូ ប៊ុនអេង បានថ្លែងការកោតសរសើរថ្នាក់ដឹកនាំ មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធនៅតាមបណ្ដាខេត្ត ជាពិសេសមន្ត្រី និងកងកម្លាំង នៃអង្គភាព និងស្ថាប័ននានាដែលកំពុងបំពេញភារកិច្ចនៅតាមបណ្ដាច្រកទ្វារព្រំដែនដែលបានប្រឹងប្រែងក្នុងការទប់ស្កាត់និងគ្រប់គ្រងការឆ្លងដែនដោយខុសច្បាប់ទៅប្រទេសថៃរបស់ពលករកម្ពុជាក្នុងពេលដែលស្ថានភាពនៅតាមព្រំដែនត្រូវបានរឹតបន្តឹងបិទច្រក ដើម្បីបង្ការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩។ លោកជំទាវបានចាត់ទុកការខិតខំប្រឹងប្រែងបំពេញភារកិច្ចនេះ គឺធ្វើឱ្យកម្ពុជា រក្សាបានសុខសុវត្ថិភាពសណ្ដាប់ធ្នាប់សាធារណៈ ធានាការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។ ទន្ទឹមនេះ គ្រប់ស្ថាប័ន អង្គភាពទាំងអស់ បាននិងកំពុងរួមសាមគ្គីគ្នា ប្រយុទ្ធនឹងសង្គ្រាមជំងឺកូវីដ-១៩ ដើម្បីជានាការពារសេចក្ដីសុខជូនប្រជាពលរដ្ឋ ដែលនេះហើយគឺជាឧត្តមគតិ ស្រឡាញ់ជាតិ និងប្រជាជន។

លោកជំទាវ ជូ ប៊ុនអេង ក៏បានជំរុញដល់អាជ្ញាធរសមត្ថកិច្ចពាក់ព័ន្ធត្រូវបន្តអប់រំណែនាំដល់ប្រជាពលរដ្ឋដែលទើបតែវិលត្រឡប់មកពីក្រៅប្រទេសវិញត្រូវដាច់ឱ្យនោះដោយឡែកពីអ្នកដទៃរយៈពេល១៤ថ្ងៃ និងបន្តតាមដានសុខភាពខ្លួនឯង។ជាមួយគ្នានេះ ប្រសិនបើបងប្អូនមានអាការៈក្ដៅខ្លួន ឬក្អកផ្ដាសាយសង្ស័យថាខ្លួនមានផ្ទុកនូវវីរុសកូវីដ-១៩ ត្រូវប្រញាប់ទាក់ទងទៅអាជ្ញាធរមូលដ្ឋានផ្ទាល់ ឬសូមទំនាក់ទំនងទៅកាន់លេខទូរស័ព្ទ១១៥ឬមន្ទីរពេទ្យដែលនៅជិតលោកអ្នកបំផុត៕ ដោយ៖ ឈុន សារ៉ាត

## ដំណើរចុះសួរសុខទុក្ខ និងសំណេះសំណាលជាមួយបងប្អូនប្រជាពលរដ្ឋខេត្តសៀមរាប ស្រុកក្រឡាញ់ដែលទើបវិលត្រឡប់មកពីការធ្វើចំណាកស្រុកនៅប្រទេសថៃ

https://www.facebook.com/deputygovernoryousophear/ 18-06-2020

ខេត្តសៀមរាប៖ ព្រឹកថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២០ ប្រតិភូគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ដឹកនាំដោយលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ អមដំណើរដោយថ្នាក់ដឹកនាំ អគ្គលេខាធិការ គ.ជ.ប.ជ រដ្ឋបាលសាលាខេត្ត ដោយមានការអញ្ជើញចូលរួមរបស់ លោកស្រី យូ សុភា អភិបាលរងខេត្ត ជាតំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម ទៀ សីហា អភិបាលនៃគណៈអភិបាលខេត្តសៀមរាប ថ្នាក់ដឹកនាំមន្ទីរអង្គភាពពាក់ព័ន្ធ លោកស្រី អភិបាល ស្រុក អាជ្ញាធរមូលដ្ឋាន តំណាងយុវជនស.ស.យ.ក និងតំណាងពីអង្គការអោយអូអឹម ផងដែរ នៅមណ្ឌលចត្តាឡីស័ក វិទ្យាល័យក្រឡាញ់ ស្រុកក្រឡាញ់ ខេត្តសៀមរាប។

មានប្រសាសន៍ ក្នុងពិធីសំណេះសំណាលជាមួយពលករទេសន្តរប្រវេសន៍ (ចំណាកស្រុកក្រៅប្រទេស) ដែលទើបវិលត្រឡប់ពីប្រទេសថៃ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានថ្លែងលើកទឹកចិត្ត និងជំរុញដល់បងប្អូនប្រជាពលរដ្ឋខាងលើ ឲ្យចូលរួមសហការជាមួយរដ្ឋាភិបាលកម្ពុជា លើការងារទប់ស្កាត់ការរីករាលដាលជំងឺកូវីដ១៩ ដោយបងប្អូនត្រូវតែធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃបន្ទាប់ពីបងប្អូនត្រឡប់ពីក្រៅប្រទេស, ត្រូវរក្សាគម្លាត ធ្វើអនាម័យឲ្យបានជាប់ជាប្រចាំតាមការណែនាំរបស់ក្រសួងសុខាភិបាល, បងប្អូនត្រូវផ្អាកការធ្វើចំណាកស្រុកទៅក្រៅប្រទេសមួយរយៈសិន ពិសេសត្រូវបញ្ឈប់ការធ្វើចំណាកស្រុកខុសច្បាប់តាមរយៈមេខ្យល់ ដោយប្រថុយប្រថាន ដែលជាហានិភ័យនាំមកនូវគ្រោះថ្នាក់ដាយថាហេតុណាមួយ

ដល់បងប្អូន។ លោកជំទាវបានបន្ថែមទៀតថា ដោយស្ថានភាពនៃការរីករាលនៃជំងឺកូវីដ១៩ កំពុងតែកើតឡើងនៅលើពិភពលោក ដូចនេះសូមបងឲ្យបងប្អូន រស់នៅក្នុងមូលដ្ឋានរបស់ខ្លួនជាមួយនឹងការដាំដុះសម្រាប់បរិភោគ និងសម្រាប់លក់ដូរផង។

បន្ថែមពីនោះ ដើម្បីកាត់បន្ថយទៅធ្វើការងារនៅក្រៅប្រទេស បងប្អូនអាចរកការងារធ្វើនៅក្នុងប្រទេស តាមរយៈមជ្ឈមណ្ឌលការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬតាមរយៈមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាបក៏បាន។ មួយវិញទៀត លោកជំទាវបានជំរុញឲ្យអាជ្ញាធរខេត្ត ស្រុក ពិនិត្យលើស្ថានភាពរបស់គ្រួសារប្រជាពលរដ្ឋដែលទើបវិលត្រឡប់មកពីក្រៅប្រទេស និងសហការជាមួយអ្នកពាក់ព័ន្ធ ក្នុងការដោះស្រាយលើបញ្ហាជីវភាព ការផ្តល់ជាជំនាញវិជ្ជាជីវៈ និងផ្សព្វផ្សាយអំពីឱកាសការងារក្នុងស្រុក។ លោកជំទាវ ក៏បានថ្លែងអំណរគុណដល់អាជ្ញាធរខេត្តសៀមរាប អាជ្ញាធរស្រុកក្រឡាញ់ សមត្ថកិច្ច អង្គការដៃគូជាតិ អន្តរជាតិ និងគ្រប់អ្នកពាក់ព័ន្ធទាំងអស់ដែលខិតខំ និងយកចិត្តទុកដាក់ខ្ពស់លើការងារមនុស្សធម៌ ពិសេសការងារទប់ស្កាត់ការីករាលដាលនៃជំងឺកូវីដ19នៅកម្ពុជា។

នៅក្នុងដំណើរទស្សនកិច្ចនិងចុះសួរសុខទុក្ខនេះផងដែរ ប្រតិភូបាននាំយកមកជាមួយនូវសម្ភារប្រើប្រាស់មួយចំនួន ដែលមានការចូលរួមឧបត្ថម្ភពី អង្គការ UNFPA និងអង្គការ IOM ជូនដល់បងប្អូន ចំនួន១០០នាក់ ផងដែរ ដោយក្នុងនោះ ម្នាក់ៗទទួលបាន សាប៊ូលាងដៃ សាប៊ូដុសខ្លួន សាប៊ូម្សៅ ដេលលាងដៃ សារុង ក្រមា ប្រាសដុសធ្មេញ ថ្នាំដុសធ្មេញ មុង និងសម្ភារមួយចំនួនទៀត និងបានផ្តល់ជូនម៉ាស ជេល និងអាកុល ដល់ក្រុមគ្រូពេទ្យប្រចាំការនៅមណ្ឌលវិទ្យាល័យក្រឡាញ់ផងដែរ។

## ពលករកម្ពុជាជិត១០ម៉ឺននាក់ បានត្រឡប់មកស្រុកកំណើតវិញ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០២០ ម៉ោង ២១:៥១ ប៊ុន ធឿន

ខេត្តបន្ទាយមានជ័យ ៖ ពលករកម្ពុជាជិត១០ម៉ឺននាក់បានត្រឡប់មកស្រុកកំណើតវិញ និងនៅប្រទេសថៃជាង១លាននាក់នៅពេលដែលថៃបិទច្រកទ្វារព្រំដែន លោកជំទាវ ជូ ប៊ុនអេង លើកឡើងក្នុងកិច្ចប្រជុំនៅនៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២០ នៅសាលប្រជុំសាលាខេត្ត បន្ទាយមានជ័យ។ ក្នុងកិច្ចប្រជុំមានការចូលរួមពីមន្ត្រីក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ និងមន្ត្រីកម្លាំងស្ថាប័នខេត្តជាប់ព្រំដែនបានចូលរួមជាច្រើនរូប។

ឯកឧត្តម អ៊ុំ រាត្រី អភិបាលខេត្តបន្ទាយមានជ័យ មានប្រសាសន៍រាយការណ៍ថា៖ ជាការណែនាំពីរាជរដ្ឋាភិបាលកម្ពុជា ដើម្បីពង្រឹង និងវិធានការទប់ស្កាត់ និងការគ្រប់គ្រងការឆ្លងដែនដោយខុសច្បាប់របស់ពលករកម្ពុជានៅពេលដែលប្រទេសថៃបិទច្រកទ្វារព្រំដែនកម្ពុជា.ថៃ។ ឯកឧត្តមបានបញ្ជាក់ថា ខេត្តបន្ទាយមានជ័យ មានជ័យពលករខ្មែរដែលត្រឡប់ពីប្រទេសថៃវិញគឺតត្រឹមថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២០ មានចំនួន២៦.៣៩៦នាក់ ស្រី១២.០២៥នាក់ ដោយធ្វើការត្រួតពិនិត្យសុខភាព១០០% និងបានធ្វើតេស្តសំណាកមានចំនួន១.៦៣១នាក់ អវិជ្ជមាន១.៦២៦នាក់ វិជ្ជមាន៥នាក់ព្យាបាល ជាសះស្បើយ៥នាក់។ ឯកឧត្តម អ៊ុំ រាត្រី បានបញ្ជាក់ថា៖ ប្រជាពលរដ្ឋនៅក្រៅពីខេត្តមានជ័យ វិលត្រឡប់ពីប្រទេសថៃគឺតត្រឹមថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២០មានចំនួន៨.៣៥៩នាក់ ស្រី៣.៥០២នាក់។ ក្នុងនោះមានចូលតាមច្រកអូរបីជាន់ ស្រុកអូរជ្រៅមាន ចំនួន៨.៣៤៧នាក់ ស្រី៣.៤៩៧នាក់ ចូលតាមច្រកបឹងបេងស្រុកម៉ាឡៃមានចំនួន១២នាក់ ស្រី០៥នាក់ ហើយក្រសួងការពារជាតិ នៃកងពលលេខ៩០ បានជួយរថយន្តដឹកពលករទៅតាមមូលដ្ឋាន មានចំនួន៥០គ្រឿង។

ក្នុងឱកាសនោះដែរលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការ និងជាអនុប្រធាន អចិន្ត្រៃយ៍នៃ គ.ជ.ប.ជ មានប្រសាសន៍ថា៖ ក្នុងឱកាសដែលភាគីថៃបិទច្រកទ្វារព្រំដែន កម្ពុជា.ថៃ ដើម្បីទប់ស្កាត់កូវីដ-១៩ ហើយពលករកម្ពុជាដែលត្រឡប់មកស្រុកកំណើតវិញសរុប ទូទាំងប្រទេសមានប្រមាណជិត១០ម៉ឺននាក់ ហើយមានពលករកម្ពុជា នៅ

ក្នុងប្រទេសថៃ មានជាង១លាននាក់។ លោកជំទាវបានបញ្ជាក់ថា៖ ជាការណែនាំខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជា និងសម្តេចក្រឡាហោម ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានដាក់វិធានការដល់អាជ្ញាធរ និងកងកម្លាំង ដែលឈរជើងតាមបន្ទាត់ព្រំដែន ត្រូវអនុវត្តន៍ផែនការទប់ស្កាត់ និងគ្រប់គ្រងការឆ្លងដែនដោយខុសច្បាប់ របស់ពលរដ្ឋកម្ពុជា។ ហើយចាត់វិធានចំពោះមេខ្យល់ដែលបកប្រាស់ប្រជាពលរដ្ឋចំណាកស្រុកខុសច្បាប់ និងណែនាំដល់ប្រជាពលរដ្ឋបានយល់ដឹងត្រូវបញ្ឈប់ការធ្វើចំណាកស្រុក ដោយខុសច្បាប់ការពារសុវត្ថិភាពជូនបងប្អូនប្រជាពលរដ្ឋ៕ ប៊ុន ធឿន

## ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានចុះហត្ថលេខាលើអនុស្សារណៈនៃកិច្ចព្រមព្រៀង (MoU) ជាមួយអង្គការឆាលហ្វាន់

https://www.facebook.com/ អគ្គនាយកដ្ឋានបច្ចេកទេស 18-06-2020

(ភ្នំពេញ)៖ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានចុះហត្ថលេខាលើអនុស្សារណៈនៃកិច្ចព្រមព្រៀង (MoU) ជាមួយអង្គការឆាលហ្វាន់ ដើម្បីជួយក្នុងវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដោយផ្តោតសំខាន់លើ ការជួយការពារកុមាររងគ្រោះ និងងាយរងគ្រោះ។ អង្គការឆាលហ្វាន់នេះ មានសុពលភាពនៃកិច្ចព្រមព្រៀងគម្រោងជាមួយក្រសួងសង្គមកិច្ច មានរយៈពេល០៣ឆ្នាំ ដែលមានថវិកាអនុវត្តគម្រោងសរុប ៦៨៩,៧៤០ ដុល្លាអាមេរិក។

ពិធីចុះហត្ថលេខានៃកិច្ចព្រមព្រៀង (MoU) នាពេលនេះបានរៀបចំឡើងជាផ្លូវការ នាថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ ក្រោមអធិបតីភាពឯកឧត្តម តូច ចាន់នី អគ្គនាយក នៃអគ្គនាយកដ្ឋានបច្ចេកទេស ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តម វង សូត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមានការរួមពីថ្នាក់ដឹកនាំក្រសួងនិងថ្នាក់ដឹកនាំអង្គការឆាលហ្វាន់ រួមនឹងមន្ត្រីរាជការពាក់ព័ន្ធរបស់ក្រសួងសង្គមកិច្ចជាច្រើនរូបទៀតផងដែរ។

នៅក្នុងឱកាសនោះ ឯកឧត្តម តូច ចាន់នី បានលើកឡើងថា ការចូលរួមសហការរបស់អង្គការដៃគូ ពិតជាសំខាន់ខ្លាំងណាស់ ក្នុងការលើកកម្ពស់វិស័យសង្គមកិច្ចនៅកម្ពុជា។ បន្ថែមពីលើនោះ ឯកឧត្តម តូច ចាន់នី បានស្នើឲ្យក្រុមការងារក្រសួង និងអង្គការដែលសហការនាពេលនេះរួមគ្នា ដើម្បីធ្វើការងារ ដោយយកចិត្តទុកដាក់ឲ្យខ្លាំងបំផុត តាមដែលអាចធ្វើបាន។ សម្រាប់ក្រសួងសង្គមកិច្ចវិញ នៅតែស្វាគមន៍ជានិច្ចជាមួយ ដៃគូពាក់ព័ន្ធ និងអង្គការនានា ដើម្បីជួយដល់កុមាររងគ្រោះនៅកម្ពុជា ឲ្យមានជីវភាព និងជីវិតរស់នៅ ល្អប្រសើរថែមមួយកម្រិតទៀត។

គួរបញ្ជាក់ថា អង្គការឆាលហ្វាន់ ដែលបានចុះហត្ថលេខា លើកិច្ចព្រមព្រៀង ជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នាពេលនេះ សុទ្ធសឹងតែដែលបានចូលរួមចំណែកជួយការពារកុមាររងគ្រោះពីការជួញដូរមនុស្ស ករណីកេងប្រវ័ញ្ចលើកុមារ ការរំលោភបំពានផ្លូវភេទ ការជួញដូរផ្លូវភេទ និងការជួញដូរកម្លាំងពលកម្មកុមារស្នាក់ក្នុងមណ្ឌល កុមារនៅតាមសហគមន៍ កុមារទំនាស់នឹងច្បាប់ កុមារតាមផ្លូវសាធារណៈជាដើម។

ជាមួយគ្នានោះ ឯកឧត្តម តូច ចាន់នី បានក្រើនរំលឹកដល់អង្គការឆាលហ្វាន់ ដែលបានចុះកិច្ចព្រមព្រៀង (MOU) នាពេលនេះ សូមបន្តអនុវត្ត វិធីការពារជំងឺកូវីដ-១៩ តាមការណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាក្រសួងសុខាភិបាល និងសេចក្តីណែនាំរបស់ក្រសួងសង្គមកិច្ច កន្លងមក៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៨នាក់

https://www.facebook.com/GDIOfficial 18-06-2020

នៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ១៨នាក់ ស្រី ០៨នាក់ និងពលរដ្ឋថៃចាកចេញមានចំនួន ០៥នាក់ មានឯកសារចេញពីស្ថានទូតថៃ និងលិខិតបញ្ជាក់សុខភាព៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដាំ បានទទួលពលរដ្ឋខ្មែរចំនួន ០១នាក់ ពីសមត្ថកិច្ចថៃ ពីបទឆ្លងដែនខុសច្បាប់

https://www.facebook.com/GDIOfficial 18-06-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដាំ នាថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២០ បានទទួលពលរដ្ឋខ្មែរចំនួន ០១នាក់ ពីសមត្ថកិច្ចថៃ ពីបទឆ្លងដែនខុសច្បាប់ ទៅកាប់ឈើនៅប្រទេសថៃ ដែលចេញតាមច្រកអូរស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៧៤នាក់

https://www.facebook.com/GDIOfficial 17-06-2020

នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៧៤នាក់ ស្រី ៣៨នាក់៕

## វេទិកាលើកកម្ពស់ការយល់ដឹងស្តីពី កិច្ចបង្ការការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ

https://www.facebook.com/deputygovernoryousophear/ 18-06-2020

ខេត្តសៀមរាប៖ នៅរសៀលថ្ងៃពុធ ១២ រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ២០២០ គណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) ខេត្តសៀមរាប សហការជាមួយមន្ទីរអប់រំយុវជននិងកីឡាខេត្ត និងអង្គការសកម្មភាពដើម្បីកុមារ (APLE) ដែលទទួលបានជំនួយឧបត្ថម្ភពី

អង្គការដែនដីមនុស្សហូរឡង់ប្រចាំនៅកម្ពុជា បានរៀបចំកម្មវិធីលើកកម្ពស់ការយល់ដឹងស្តីពី " កិច្ចបង្ការការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ" ដល់យុវជនកាកបាទក្រហម និងយុវជនកាយរិទ្ធ កម្ពុជាខេត្តសមរាប។ វេទិកាលើកកម្ពស់ការយល់ដឹងនេះ ដើម្បីផ្តល់ការយល់ដឹងអំពីសុវត្ថិភាពអ៊ីនធឺណិត និងរបៀបក្នុងការកាត់បន្ថយហានិភ័យនៃអំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ក្នុងកំឡុងរាតត្បាតនៃជម្ងឺកូវីដ ១៩ ។ ដើម្បីរួមចំណែកជាមួយរាជរដ្ឋាភិបាល ក្នុងការកាត់បន្ថយហានិភ័យនៃជម្ងឺរាតត្បាតនៃជំងឺកូវីដ19 ក្រុមការងារអង្គការ បានផ្តល់ជូននូវម៉ាស និងចែលលាងដៃដល់យុវជន សម្រាប់រក្សាអនាម័យចាំបាច់ និងវិធីរក្សាអនាម័យនានាផងដែរ ។

ថ្លែងនៅក្នុងពិធីបើកវេទិកា លោក មិត សុវណ្ណ អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ជាប្រធានក្រុមការងារបង្ការទប់ស្កាត់នៃលេខាធិការដ្ឋាន គ ខ ប ជ និងជាតំណាងដ៏ខ្ពង់ខ្ពស់លោកស្រី យូ សុភា អភិបាលរងនៃគណៈអភិបាលខេត្តជាប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការជួញដូរមនុស្ស បានជំរុញដល់ថ្នាក់ដឹកនាំសាលារដ្ឋក្នុងខេត្ត និងយុវជនខាងលើដែលចូលរួមកម្មវិធីនេះ ឲ្យធ្វើការផ្សព្វផ្សាយដល់សិក្សានុសិស្ស មិត្តភ័ក្ត បងប្អូនឲ្យមានការយល់ដឹងអំពីការរំលោភបំពាន ឬការកេងប្រវ័ញ្ចលើកុមារ តាមប្រព័ន្ធអនឡាញ និងហានិភ័យនៃការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត ។ សូមចូលរួមទាំងអស់គ្នា ដើម្បីការពារ និងទប់ស្កាត់ការរំលោភបំពាន និងការកេងប្រវ័ញ្ចលើកុមារលើគ្រប់រូបភាព។

## ស្ថានទូតកម្ពុជាប្រចាំប្រទេសវៀតណាមបានសង្គ្រោះនារីខ្មែរចំនួន4រូបដែលចាញ់បោកមេខ្យល់នាំទៅលក់នៅប្រទេសចិន

https://www.facebook.com/theccpcr/ 17-06-2020

ស្ថានអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋសង្គមនិយមវៀតណាម សហការជាមួយអាជ្ញាធរមានសមត្ថកិច្ចខេត្តឡាងសឺនវៀតណាម សង្គ្រោះនារីរងគ្រោះ 4 រូបដែលចាញ់បោកមេខ្យល់នាំទៅលក់នៅប្រទេសចិនដោយឆ្លងកាត់ព្រំដែនខុសច្បាប់ចូលវៀតណាម និងបញ្ជូនទៅដាក់មជ្ឈមណ្ឌលដាច់ដោយឡែករយៈពេល 14 ថ្ងៃព្រមទាំងបានរៀបចំបែបបទបញ្ជូនត្រឡប់ទៅកម្ពុជាវិញតាមរថភ្លើងពីទីក្រុងហាណូយនាថ្ងៃទី 17 ខែមិថុនា នឹងទៅដល់ទីក្រុងហូជីមិញវេលាម៉ោង 5:00 ព្រឹកថ្ងៃទី 19 ខែមិថុនាឆ្នាំ 2020 ដែលនៅទីនោះស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំក្រុងហូជីមិញជួយសម្រួលការធ្វើដំណើរបន្តដល់ច្រកទ្វារព្រំដែនអន្តរជាតិបាវិត។ នេះបើយោងតាមសេចក្តីជូនព័ត៌មានរបស់ស្ថានទូតកម្ពុជាប្រចាំប្រទេសវៀតណាម។

## មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តស្វាយរៀង មកទទួលពលរដ្ឋខ្មែរ ចំនួន 0៩នាក់ ដែលបានទៅប្រកបមុខរបរខុសច្បាប់ នៅប្រទេសវៀតណាម

https://www.facebook.com/GDIOfficial 18-06-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិបាវិត នាវេលាម៉ោង ១១និង០០នាទី ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ ២០២០ បានពិនិត្យឃើញតំណាងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តស្វាយរៀង មកទទួលពលរដ្ឋខ្មែរ ចំនួន ០៩នាក់ ដែលបានទៅប្រកបមុខរបរខុសច្បាប់ នៅប្រទេសវៀតណាម។ ដោយមានការសំណូមពរពីតំណាងមន្ទីរខេត្ត ស្នើសុំស្ថាប័នចត្តាឡីស័ក នាំយកពលរដ្ឋខាងលើ រក្សាទុកដាច់ ដោយឡែកចំនួន ១៤ថ្ងៃ នៅមន្ទីរពេទ្យស្រុកចន្ទ្រា ខេត្តស្វាយរៀង៕

# ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២០

## អាជ្ញាធរខេត្តបាត់ដំបង ឱ្យដឹងថា សកម្មភាពពលរដ្ឋលួចឆ្លងដែនទៅថៃ បានស្ងប់ស្ងាត់បន្តិចហើយ

http://btv.com.kh/nation-news/ 19/06/2020

បាត់ដំបង ៖ ការលួចឆ្លងដែនដោយខុសច្បាប់ របស់ពលរដ្ឋខ្មែរ ទៅប្រទេសថៃ តាមច្រករបៀងនានា ជាប់នឹងខេត្តបាត់ដំបង បានស្ងប់ស្ងាត់ បន្ទាប់ពីមានការរឹតបន្តឹង ទាំងខាងភាគីកម្ពុជា និងថៃ ដើម្បីបង្ការទប់ស្កាត់ការឆ្លងរីករាលដាល នៃមេរោគកូវីដ១៩។

ឧត្តមសេនីយ៍ទោ អ៊ុច សុខុន ស្នងការនគរបាលខេត្តបាត់ដំបង បានប្រាប់BTV តាមទូរស័ព្ទ នៅព្រឹកថ្ងៃទី១៩ ខែមិថុនានេះថា នារយៈកាលចុងក្រោយនេះ ការលួចឆ្លងដែនទៅថៃ ជាប់ព្រំដែនខេត្តបាត់ដំបង របស់ពលរដ្ឋខ្មែរ ពុំមាននោះទេ ព្រោះទាំងខាងកម្ពុជា ទាំងខាងថៃ បានទប់ស្កាត់យ៉ាងតឹងរឹងដូចគ្នា ប៉ុន្តែមានលួចឆ្លងដែន នៅខាងខេត្តបន្ទាយមានជ័យ ហើយអាជ្ញាធរថៃ បានចាប់បញ្ជូនមកកម្ពុជាវិញតាមច្រករបៀងជាប់នឹងខេត្តបាត់ដំបង ។ លោកស្នងការ បានបន្តថា ការឆ្លងដែនពីថៃ មកកម្ពុជា តាមច្រករបៀងនានា ពិសេសច្រកនៅជាប់នឹងស្រុកកំរៀង មានរាល់ថ្ងៃ ដែលថ្ងៃខ្លះ ជាង១០០នាក់ និងថ្ងៃខ្លះ ក្រោម១០០នាក់ ដោយពេលពួកគេចេញមក ត្រូវបានគ្រប់គ្រងយ៉ាងល្អ ទាំងការពិនិត្យសុខភាព និងសម្រួលការងារផ្សេងៗ។ លោកឧត្តមសេនីយ៍ទោ អ៊ុច សុខុន បានបញ្ជាក់ថា កន្លងមក សមត្ថកិច្ចការពារព្រំដែន ជាប់ខេត្តបាត់ដំបង ធ្លាប់បានឃាត់ខ្លួនមេខ្យល់ម្នាក់ ដែលបាននាំពលរដ្ឋខ្មែរ បម្រុងលួចឆ្លងដែនទៅប្រទេសថៃ តែត្រូវទប់ស្កាត់ទាន់ ហើយមេខ្យល់ម្នាក់នោះ ត្រូវបានបញ្ជូនទៅតុលាការ ដើម្បីចាត់ការតាមនីតិវិធីច្បាប់។

ដោយសារបញ្ហាជំងឺកូវីដ១៩ អាជ្ញាធរថៃ បានបិទច្រក ជាមួយកម្ពុជា មិនឲ្យពលរដ្ឋឆ្លងកាត់ ដូចមុននោះទេ ដោយអនុញ្ញាតឲ្យតែការដឹកទំនិញ ចេញចូលប៉ុណ្ណោះ ហើយសម្រាប់ខេត្តបាត់ដំបង ការដឹកទំនិញនោះ គឺបានតែច្រកដូង ស្ថិតក្នុងស្រុកកំរៀង និងច្រកភ្នំដី ស្ថិតក្នុងស្រុកសំពៅលូន ប៉ុន្តែទោះមានការដាក់បម្រាមឆ្លងដែនក៏ដោយ ក៏នៅតែមានពលរដ្ឋខ្មែរមួយចំនួន ព្យាយាមលួចឆ្លងដែនទៅថៃ តាមច្រករបៀងមួយចំនួន ដែលស្ថិតក្នុងស្រុកកំរៀង និងស្រុកសំពៅលូន និងត្រូវបានសមត្ថកិច្ចការពារព្រំដែនឃាត់ខ្លួនជាញឹកញាប់ និងបានបញ្ជូនមកស្រុកកំណើតវិញ ។ អត្ថបទ ៖ បាន សុខរិទ្ធ

## អភិបាលស្រុកតាំងគោក ចុះផ្សព្វផ្សាយពីវិធានការទប់ស្កាត់ជំងឺកូវីដ-១៩ ដល់ពលករដែលទើបមកពីបរទេស

http://kampucheathmey.com/ 19/6/2020 4:53 Pm

ភ្នំពេញ ៖ លោក ហាក់ ម៉ុងហួត អភិបាលស្រុកតាំងគោក និងសហការី បានបន្តចុះសួរសុខទុក្ខ និងផ្សព្វផ្សាយពីវិធានការទប់ស្កាត់ ការរីករាល នៃជំងឺកូវីដ-១៩ ដល់បងប្អូនពលករដែលទើបត្រឡប់មកពីបរទេស ហើយកំពុងធ្វើចត្តាឡីស័កនៅតាមផ្ទះរៀងៗខ្លួន រយៈពេល១៤ថ្ងៃ ចំនួន០៥នាក់ ស្ថិតក្នុងឃុំច្រនាង ឃុំអណ្ដូងពោធិ៍ និងឃុំសូយោង ស្រុកតាំងគោក ខេត្តកំពង់ធំ។ ក្នុងនោះ ព្រមទាំងបាននាំយកនូវអំណោយរបស់សប្បុរសជនទៅចែកជូនដល់ជនទីទ័លក្រមួយចំនួនផងដែរ កាលពីព្រឹកថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២០នេះ។

នៅក្នុងឱកាសនោះ លោកអភិបាលស្រុក ក៏បានក្រើនរំលឹកដល់អាជ្ញាធរភូមិ-ឃុំ ត្រូវចុះឲ្យបានជាប់ជាប្រចាំជាមួយបងប្អូនប្រជាពលរដ្ឋយើង ដើម្បីបានដឹងពីសុខទុក្ខ និងតម្រូវការជាក់ស្ដែងរបស់ពួកគាត់ ងាយស្រួលក្នុងការឆ្លើយតបបានទាន់ពេលវេលា។ ជាពិសេសត្រូវឧស្សាហ៍ក្រើនរំលឹកដល់ប្រជាពលរដ្ឋយើង កុំឲ្យភ្លេចខ្លួន និងធ្វេស

ប្រហែលចំពោះជំងឺcovid-19 នេះឲ្យសោះ ព្រោះថាពិតពលោកមិនទាន់រកឃើញនូវថ្នាំព្យាបាលណាមួយពិតប្រាកដនៅឡើយទេ។ ដូច្នេះ សូមបងប្អូន ត្រូវចូលរួមអនុវត្តតាមការណែនាំរបស់ក្រសួងសុខាភិបាលឲ្យបានជាប្រចាំ គឺហូបស្អាត ផឹកស្អាត និងរស់នៅស្អាត។

ជាមួយគ្នានោះដែរ លោកអភិបាលស្រុក ក៏បានផ្តាំផ្ញើដល់បងប្អូនប្រជាពលរដ្ឋយើង ដោយមិនត្រូវរស់នៅប្រមូលផ្តុំគ្នានោះទេ។ ម្យ៉ាងទៀត សូមបងប្អូនចូលរួមគោរពច្បាប់ចរាចរណ៍ទាំងអស់គ្នា ដើម្បីសុខសុវត្ថិភាពខ្លួនឯង និងគ្រួសារ ក៏ដូចជាសង្គមជាតិទាំងមូលផងដែរ៕ អត្ថបទ ៖ ឧត្តរ៉

## ពលករខ្មែរជិត៥០នាក់ ឆ្លងដែនខុសច្បាប់ ត្រូវអាជ្ញាធរថៃ ចាប់បញ្ជូនមកកម្ពុជាវិញ

https://www.cen.com.kh/ June 20, 2020

ព្រំដែនកម្ពុជាថៃ ៖ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានឲ្យដឹងថា ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០ បានទទួលពលករខ្មែរ ឆ្លងដែនខុសច្បាប់ ពីអាជ្ញាធរថៃ ចំនួន ៤៥នាក់ និងពលរដ្ឋថៃចាកចេញមានចំនួន ១៧នាក់។

ដោយឡែកពលករខាងលើ ដែលអាជ្ញាធរថៃចាប់បញ្ជូនមកពី ខេត្តសុងខ្លា ភាគខាងត្បូង នៃប្រទេសថៃ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំណែនាំ អំពីច្បាប់ឆ្លងកាត់ព្រំដែន និងការទប់ស្កាត់ ការពារជម្ងឺឆ្លង Covid-19 បន្ទាប់មកប្រគល់ជូនក្រុមចត្តាឡីស័ក យកទៅសម្រាកនៅមន្ទីរពេទ្យបង្អែកប៉ោយប៉ែត ជាបណ្តោះអាសន្ន ដើម្បីពិនិត្យ និងតាមដានសុខភាពពួកគាត់បន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំ ដំណើរការជាធម្មតា។

នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ធងចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។

ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៤៨នាក់ ស្រី ២២នាក់ និងពលរដ្ឋថៃចាកចេញមានចំនួន ១នាក់ ស្រី មានឯកសារចេញពីស្ថានទូតថៃ និងលិខិតបញ្ជាក់សុខភាព៕ **ដោយៈកូឡាប**

## ប៉ុស្តិ៍នគរបាលរដ្ឋបាល កោះទ្រង់, ក្រចេះ បានចុះផ្សព្វផ្សាយ គោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព

http://cambodiapolice.com/policekh/ 11:46 am 20 មិថុនា 2020

ក្រចេះ ៖ នៅព្រឹកថ្ងៃទី20 ខែមិថុនា ឆ្នាំ2020 កម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាល កោះទ្រង់, ក្រចេះ បានចុះផ្សព្វផ្សាយគោលនយោបាយភូមិ-ឃុំ មានសុវត្ថិភាព និងចែកលិតប័ណ្ណចំនួន 86សន្លឹក។ ការចុះផ្សព្វផ្សាយនេះមានខ្លឹមសារដូចខាងក្រោម ៖

-សេចក្តីអំពាវនាវគាំទ្រយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ និង សារសំរាប់ប្រើប្រាស់អប់រំគ្រោះថ្នាក់នៃគ្រឿងញៀន។

– អពីគ្រោះអគ្គីភ័យ

-ការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ និង ការប្រើប្រាស់អាវុធខុសច្បាប់

-គោលនយោបាយភូមិ-ឃុំ មានសុវត្ថិភាព

-អំពើអាណាចារ្យ ការជួញដូរមនុស្សស្ត្រី និងកុមារ និង អំពើហិង្សាក្នុងគ្រួសារ

-ច្បាប់ចរាចរណ៍ផ្លូវគោកអនុក្រឹត្យលេខ39 អនក្រ.បកចុះថ្ងៃទី17 ខែមីនា ឆ្នាំ2020

-បិទផ្ទាំងរូបភាពខិតបណ្ណ័បង្ការទប់ស្កាត់ការរាតត្បាតជំងឺកូវីដ19

-ណែនាំដល់ប្រជាពលរដ្ឋអោយធ្វើស្លាកលេខម៉ូតូ និង ពាក់មួកសុវត្ថិភាពអោយបានគ្រប់ៗគ្នា តាមខ្នងផ្ទះចំនួន 02លើក ចំនួនមនុស្ស 86នាក់ ស្រី 63នាក់ ចែកលិតប័ណ្ណចំនួន 86សន្លឹក ៕

## ថៃចាប់ពលករខ្មែរ៣១នាក់ រួមទាំងមេខ្យល់៣នាក់ ដែលលួចឆ្លងដែនខុសច្បាប់តាមច្រករបៀង ក្នុងភូមិជោគជ័យ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ

http://www.matimohachunnews.com/ June 21, 2020

ខេត្តបន្ទាយមានជ័យ៖ កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០ សារព័ត៌មានថៃបានរាយការណ៍ថា កម្លាំងយោធាអង្គភាពចំពោះកិច្ចតា ព្រះយ៉ា សហការជាមួយអាជ្ញាធរស្រុកគោកឃ្សូង និងនគបាលអន្តោប្រវេសន៍ ខេត្តស្រះកែវ បានចាប់ខ្លួនពលករខ្មែរ និងមេខ្យល់ នៅបរិវេណចំណុចត្រួតពិនិត្យភូមិ ថៃសាមគ្គី ឃុំណងមួង ស្រុកគោកឃ្សូង ខេត្តស្រះកែវ ដែលក្នុងនោះមានប្រុស១៨នាក់ ស្រី១៣នាក់ សរុបទាំងអស់៣១នាក់ រួមទាំងវត្ថុតាងរថយន្តចំនួន៣គ្រឿង ម៉ាកនិសាន់ ណាវ៉ា ព៌ណស ពាក់ស្លាកលេខកง-7144ស្រះកែវ,និសាន់ណាវ៉ា ព៌ណខ្មៅ ពាក់ស្លាកលេខ2ฒม-1459 ក្រុងថេប ក្រៅពីនោះនៅមានរថយន្តតូយ៉ូតា វីហ្គូ ព៌ណស ពាក់ស្លាកលេខกว-7714នុនបុរី។

សូមជំរាបថា អ្នកសារព័ត៌មានរាយការណ៍បន្តថា សមត្ថកិច្ចបានដាក់កម្លាំងឃ្លាំមើលឃើញរថយន្តទាំង៣គ្រឿងខាងលើ បើកឆ្លងកាត់ចំណុចត្រួតពិនិត្យរបស់កម្លាំងមូលដ្ឋានភូមិគោកសាមគ្គី និងមានអ្នកជិះពេញរថយន្តទើបឱ្យសញ្ញាឈប់ត្រួតពិនិត្យឃើញអ្នកបើករថយន្តទី១ឈ្មោះ យោថា ណាកខៀវ អាយុ៣៤ឆ្នាំ ជនជាតិថៃ, អ្នកបើករថយន្ត ទី២ឈ្មោះ ខ:ណាកន និយមថាស អាយុ៣៩ឆ្នាំ និងអ្នកបើករថយន្តទី៣ឈ្មោះ ស្មាស់ តាថៃ អាយុ៤២ឆ្នាំ ។ បន្ទាប់ពីពិនិត្យរថយន្តទាំង៣គ្រឿង រកឃើញពលករខ្មែរប្រុស-ស្រី អង្គុយណែនពេញរថយន្ត ដោយប្រើផ្ទាំងកៅស៊ូគ្របពីលើ ដើម្បីបន្លំភ្នែកសមត្ថកិច្ច។

យ៉ាងណាក៏ដោយ ក្រោយពីត្រួតពិនិត្យ សមត្ថកិច្ចបាននាំខ្លួនពលករខ្មែរទាំងអស់ទៅសួរចម្លើយនៅស្រុកគោកឃ្សូង ដោយជនអ្នកបើករថយន្តខាងលើបានសារភាពថា មានមេខ្យល់ឲ្យមកទទួលពលករខ្មែរ ដើម្បីដឹកយកទៅធ្វើការសំណង់នៅក្រុងបាងកក និងខេត្តក្បែរនោះ ដោយយកតម្លៃក្នុងម្នាក់៣,០០០បាត ដោយពលករខ្មែរទាំងអស់ ប្រើវិធីដើរថ្មើជើងឆ្លងព្រំដែនតាមច្រករបៀងក្នុងភូមិ ណង យ៉ាកែវ ប្រឈមជាមួយភូមិជោគជ័យ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ របស់កម្ពុជា។ បន្ទាប់ពីធ្វើការឃាត់ខ្លួន សមត្ថកិច្ចក៏បានបញ្ជូនពលករខ្មែរទាំង៣១នាក់ រួមទាំងមេខ្យល់ខ្មែរ៣នាក់ និងតៃកុងរថយន្តថៃ៣នាក់ ទៅឱ្យសមត្ថកិច្ចជំនាញ ដើម្បីអនុវត្តតាមនិតិវិធីច្បាប់បន្ត៕

## តុលាការអាមេរិកកាត់ទោសបុរសនៅរដ្ឋ Kentucky ម្នាក់ឲ្យជាប់គុក២១ឆ្នាំពីបទបំពានផ្លូវភេទក្មេងស្រីនៅកម្ពុជា

https://khmer.voanews.com/ 19 មិថុនា 2020 សាយ មុន្នី

លោក Micky Rife បុរសអាមេរិកាំងម្នាក់ក្នុងរដ្ឋ Kentucky ត្រូវបានចាប់ខ្លួនកាលពីខែមករា ឆ្នាំ២០១៩ ពីបទប្រព្រឹត្ត និងប៉ុនប៉ងប្រព្រឹត្តការបំពានផ្លូវភេទក្មេងស្រីពីរនាក់នៅប្រទេសកម្ពុជា។ (រូបថតដោយ Franklin County Regional Jail)

វ៉ាស៊ីនតោន៖ តុលាការមួយក្នុងសហរដ្ឋអាមេរិក កាលពីថ្ងៃព្រហស្បតិ៍ បានកាត់ទោសបុរសអាមេរិកាំងម្នាក់ក្នុងរដ្ឋKentucky ឲ្យជាប់ពន្ធនាគារ ២១ ឆ្នាំ ពីបទប្រព្រឹត្តនិងប៉ុនប៉ងប្រព្រឹត្តការបំពានផ្លូវភេទក្មេងស្រីពីរនាក់ ក្នុងពេលដែលបុរសរូបនេះបានធ្វើដំណើរ និងស្នាក់នៅក្នុងប្រទេសកម្ពុជា។ នេះបើយោងតាមសេចក្តីប្រកាសព័ត៌មានរបស់ក្រសួងយុត្តិធម៌អាមេរិក ដែលវីអូអេទទួលបាននៅថ្ងៃនេះ។

លោក Gregory F. Van Tatenhove ចៅក្រមនៃតុលាការតំបន់សហរដ្ឋអាមេរិកទទួលខុសត្រូវលើរដ្ឋ Kentucky បានសម្រេចកាត់ទោសលោក Micky Rife វ័យ៣៦ឆ្នាំ ជាប់ពន្ធនាគារ ២១ឆ្នាំ និងឲ្យស្ថិតក្រោមការពិនិត្យរបស់តុលាការ រយៈពេល២០ឆ្នាំថែមទៀត។

លោក Rife បានសារភាពថា នៅចន្លោះឆ្នាំ ២០១២ និង ២០១៨ ក្នុងអំឡុងពេលលោកធ្វើដំណើរ និងស្នាក់នៅក្នុងប្រទេសកម្ពុជា លោកពិតជាបានលូកលាន់ ឬប៉ះពាល់ប្រដាប់ភេទក្មេងស្រីពីរនាក់ អាយុក្រោម១២ឆ្នាំ ហើយការប្រព្រឹត្តបែបនេះ កើតឡើងច្រើនជាងម្តង។

បើតាមព័ត៌មានក្នុងស្រុក លោក Micky Rife គឺជាអតីតគ្រូបង្រៀនម្នាក់ក្នុងប្រទេសកម្ពុជា ដែលត្រូវបានបណ្តេញចេញពីការងារ ក្រោយពីមានការរាយការណ៍ និងការស៊ើបអង្កេតទៅលើការប្រព្រឹត្តរបស់លោក។ លោក Micky Rife ត្រូវបានចាប់ខ្លួន កាលពីខែមករា ឆ្នាំ២០១៩។ នេះបើតាមបណ្តាញព័ត៌មាន Khmer Times។

សំណុំរឿងនេះ គឺជាលទ្ធផលការងាររបស់គម្រោងសុវត្ថិភាពកុមារភាព (Project Safe Childhood) របស់ក្រសួងយុត្តិធម៌ ដើម្បីប្រយុទ្ធប្រឆាំងនឹងការរំលោភបំពាននិងការកេងប្រវ័ញ្ចផ្លូវភេទកុមារ៕

## ប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ១០៦នាក់

https://www.facebook.com/GDIOfficial 21-06-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារមិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ១០៦នាក់ ស្រី ៤៥នាក់ កុមារ ០៧នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៦៣នាក់

https://www.facebook.com/GDIOfficial 21-06-2020

នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ផង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ១៩។

ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៦៣នាក់ ស្រី ៣១នាក់ និងពលរដ្ឋថៃចាកចេញ មានចំនួន ០៤នាក់ ស្រី ០២នាក់ មានឯកសារចេញពីស្ថានទូតថៃ និងលិខិតបញ្ជាក់សុខភាព៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៤៨នាក់

https://www.facebook.com/GDIOfficial 22-06-2020

នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៤៨នាក់ ស្រី ២២នាក់ និងពលរដ្ឋថៃចាកចេញមានចំនួន ០១នាក់ ស្រី ០១នាក់ មានឯកសារចេញពីស្ថានទូតថៃ និងលិខិតបញ្ជាក់សុខភាព៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត បានទទួលពលករខ្មែរ ឆ្លងដែនខុសច្បាប់ ពីអាជ្ញាធរថៃ ចំនួន ១៣នាក់

https://www.facebook.com/GDIOfficial 19-06-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២០ បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីអាជ្ញាធរថៃ ចំនួន ១៣នាក់ និងពលរដ្ឋថៃចាកចេញមានចំនួន ០១នាក់។ ដោយឡែកពលករខាងលើ ដែលអាជ្ញាធរថៃចាប់បញ្ជូនមកពី ខេត្តសុងខ្លា ភាគខាងត្បូង នៃប្រទេសថៃ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍បានធ្វើការអប់រំណែនាំ អំពីច្បាប់ឆ្លងកាត់ព្រំដែន និងការទប់ស្កាត់ ការពារជម្ងឺឆ្លង Covid-19 បន្ទាប់មកប្រគល់ជូនក្រុមចត្តាឡីស័ក យកទៅសម្រាកនៅមន្ទីរពេទ្យបង្អែកប៉ោយប៉ែត ជាបណ្តោះអាសន្ន ដើម្បីពិនិត្យ និងតាមដានសុខភាពពួកគាត់បន្ត។ ជាមួយគ្នានេះដែរ អាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំ ដំណើរការជាធម្មតា៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៤០នាក់

https://www.facebook.com/GDIOfficial 19-06-2020

នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ១៩។

ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៤០នាក់ ស្រី ២៤នាក់៕

## ថ្ងៃនេះថៃចាប់បានពលករខ្មែរទៀតហើយ

https://www.facebook.com/ *ទឹកចិត្ត ពលករ ឆ្លងដែន* 21-6-2020

មិញៗនេះ អាជ្ញាធរថៃចាប់បានពលករខ្មែរចំនួន5នាក់ យោងតាមការបញ្ជាក់ពីអាជ្ញាធរថៃបានដឹងថា ពលករខ្មែរចូលប្រទេសថៃតាមច្រករបៀង តាមរយះមេខ្យល់ពលករខ្មែរបានបង់លុយអោយមេខ្យល់ក្នុងម្នាក់ 3000 បាតទៅ 3500បាត ក្នុងម្នាក់ មេខ្យល់បានសន្យាថា នឹងនាំពលករខ្មែរជូនដល់កន្លែងធ្វើការនៅពេលកំពុងនាំពលករខ្មែរឆ្លងដែនចូលប្រទេសថៃមេខ្យល់ឃើញអាជ្ញាធរថៃរត់ដេចខ្លួនបាត់។ ហេតុកាណ៏នេះបានកើតឡើងល្ងាចមិញនៅត្រង់ចំនុចឃុំណងមិក ស្រុកគោកខ្វង ខេត្តស្រះកែវ ប្រទេសថៃ។ (អំពីខ្ញុំ ទឹកចិត្ត ពលករ ឆ្លងដែន)

# ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២០

## លោកឧត្តមសនីយ៍ទោស្នងការ "ឆមាសទី១ ឆ្នាំ២០២០នេះ ស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ ទទួលបានលទ្ធផលបង្ក្រាបជាក់ស្តែងមានការកើនឡើង ៨៩ភាគរយ"

http://cambodiapolice.com/policekh/ 2:07 pm 22 មិថុនា 2020

**ព្រះសីហនុ៖** នាព្រឹកថ្ងៃចន្ទ ២កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស២៥៦៤ ត្រូវនឹងថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២០នេះ នៅស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផល កិច្ចប្រតិបត្តិការរក្សាសន្តិសុខសណ្តាប់ធ្នាប់សង្គមប្រចាំឆមាសទ១ ឆ្នាំ២០២០ នៃស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ ក្រោមអធិបតីភាពលោកឧត្តមសេនីយ៍ទោ ជួន ណារិន្ទ ស្នងការនគរបាលខេត្ត កិច្ចប្រជុំនេះក៏មានការចូលរួមអំពីអស់លោក លោកស្រីឧត្តមសេនីយ៍ វរៈសេនីយ៍ស្នងការរង នាយ នាយរង និងអធិការក្រុងស្រុកផងដែរ។

យោងតាមរបាយការណ៍បូកសរុបដែលអានដោយលោកឧត្តមសេនីយ៍ត្រី អ៊ឹម វលក្ខណ៍ ស្នងការរង ផែនសេនាធិការ បានអោយដឹងថា ក្នុងឆមាសទី១ ឆ្នាំ២០២០នេះ គ្រោះថ្នាក់ចរាចរណ៍ បើប្រៀបធៀបឆមាសទី១ ឆ្នាំកន្លងទៅ ហាក់ដូចជាមានការថយចុះ អត្រាស្លាប់មានការថយចុះ៣១ភាគរយ ទាំងនេះនៅតែជាបញ្ហាប្រឈមដែលតម្រូវអោយប្រមូលផ្តុំគ្នាកាត់បន្ថយ។ ចំពោះគ្រោះអគ្គីភ័យនៅតែមានការកើតឡើង ដោយតម្រូវអោយមានការផ្សព្វផ្សាយអោយមានការប្រុងប្រយ័ត្នខ្ពស់ បង្ហាត់បង្រៀនបន្ថែមការសង្គ្រោះបឋមនៅពេលមានអគ្គីភ័យកើតឡើង។ ជារួមនោះគ្រឿងញៀននៅតែជាបញ្ហានិងប្រធានបទដែលត្រូវដោះស្រាយនៅក្នុងឆមាសទី១ ឆ្នាំកន្លងទៅ និងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទបង្ក្រាបបាន១៣ករណី ឃាត់ខ្លួន១៥នាក់ ពាក់ព័ន្ធជនបរទេស៣ករណី ជនជាតិចិន។ ស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ ជាលទ្ធផលបង្ក្រាប បាន១៦៦ ករណី ឃាត់ខ្លួន ៣៣៧នាក់ ពាក់ព័ន្ធជនបរទេស ៤៤ករណី ឃាត់ខ្លួន១៥០នាក់ ស្រី១នាក់ មាន៣សញ្ជាតិ។

លោកឧត្តមសេនីយ៍ទោ ជួន ណារិន្ទ ស្នងការនគរបាលខេត្ត បានមានប្រសាសន៍ថា គាំទ្រលើរបាយការណ៍ឆមាសទី១ នេះ និងកោតសរសើរដល់កងកម្លាំងជំនាញទាំងអស់ តែទោះជាសភាពការណ៍បទល្មើសមានការកើនឡើង ក៏ពិតមែនដោយមានការចង្អុលបង្ហាញពីអគ្គស្នងការដ្ឋាននគរបាលជាតិ នាយកដ្ឋានជំនាញ គណៈបញ្ជាការឯកភាពរដ្ឋបាលខេត្ត ព្រមទាំងមានការចូលរួមពីមហាជនល្អ ក្នុងការសហការណ៍ផ្តល់ព័ត៌មានពាក់ព័ន្ធបទល្មើសគ្រប់ប្រភេទ បានពង្រឹងកិច្ចការប៉ុស្តិ៍រដ្ឋបាលដើម្បីរួមចំណែក បង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសគ្រប់ប្រភេទ ដែល

កើតឡើងក្នុងមូលដ្ឋាន ធ្វើអោយស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ ទទួលបានលទ្ធផលបង្ក្រាបជាក់ស្តែងមានការកើនឡើង ៨៩ភាគរយ ។

លោកឧត្តមសេនីយ៍ស្នងការ ក៏បានជំរុញបន្ថែមលើការរៀបចំលើគម្រោង ដែលទាក់ទងនិងគ្រោះមហន្តរាយ សម្រាប់គ្រប់គងរបស់ស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ ស្របតាមខ្លឹមសារសេចក្តីសម្រេចរបស់រដ្ឋបាលខេត្ត ។ ធ្វើផែនការត្រៀមបម្រុងទុក សម្រាប់ប្រតិបត្តិការឆ្លើយតបបានទាន់ពេលវេលាពេលមានគ្រោះមហន្តរាយកើតឡើងក្នុងខេត្តនេះ ។ ក្នុងនោះដែរលោកឧត្តមសេនីយ៍ស្នងការបានធ្វើការក្រើនរំលឹកអោយបងប្អូនមន្ត្រីក្រោមឱវាទត្រូវយកចិត្តទុកដាក់អោយបានខ្ពស់បន្ថែមលើការអនាម័យទាំងនៅកន្លែងធ្វើការ ទាំងគ្រួសារ និងទីសាធារណៈដើម្បីជៀសផុតពីជំងឺរាតត្បាតអាសន្នរោគផ្សេងៗ ជាពិសេសជំងឺ កូវីដ១៩ ៕

## ពលរដ្ឋខ្មែរ បន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៤២នាក់

https://www.facebook.com/GDIOfficial 22-06-2020

នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៤២នាក់ ស្រី ១៩នាក់៕

## ប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ៣៩នាក់

https://www.facebook.com/GDIOfficial 22-06-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារ មិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ៣៩នាក់ ស្រី ១៧នាក់ និងកុមារ ០៦នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## កម្ពុជា និងថៃ នៅមិនទាន់ឯកភាពគ្នាបើកច្រកប៉ោយប៉ែត-ខ្លងលឹកឡើងវិញទេ

http://kampucheathmey.com/ 23/6/2020 12:33 Pm

ច្រកអន្តរជាតិប៉ោយប៉ែត-ខ្លងលឹក ក្នុងខេត្តបន្ទាយមានជ័យ និងខេត្តស្រះកែវ នៅក្សោការបិទដដែល។ នេះបើយោងតាមកិច្ចប្រជុំពិភាក្សាការងារ រវាងអភិបាលខេត្ត បន្ទាយមានជ័យ និងខេត្តស្រះកែវ នៅព្រឹកថ្ងៃទី២៣ ខែ

មិថុនានេះ។ លោក អ៊ុំ រាត្រី អភិបាលខេត្តបន្ទាយមានជ័យ បានប្រជុំជាមួយ លោក វ៉ារ៉ាផាន់ សុវាណុន H.E .WORAPHAN SUWANNUN អភិបាលខេត្តស្រះកែវ ព្រះរាជាណាចក្រថៃ តាមរយៈប្រព័ន្ធបញ្ជូនសារសម្លេង រូបភាព ( Video Conference ) ។ របៀបវារៈនៃកិច្ចប្រជុំមានៈ

១.ការបើកច្រកនៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០ ឬបន្តបិទច្រក

២.ពិភាក្សាសុំឲ្យមានការចេញ~ចូលលក់ដូរត្រឹមផ្សាររុងក្លឿ

៣.ពិភាក្សាករណីពលករ(ចេញ~ចូល)

៤.បញ្ហាផ្សេងៗ ។

ជាលទ្ធផល ឆ្លងកិច្ចពិភាក្សាយ៉ាងយកចិត្តទុកដាក់ អភិបាលខេត្តបន្ទាយមានជ័យ និង អាជ្ញាធរថៃ បានឯកភាពជាគោលការណ៍ ឲ្យមានការចូលទៅផ្សាររុងក្លឿ ពិនិត្យទំនិញ និងដឹកទំនិញឥវ៉ាន់មកវិញ តាមរយៈរថយន្ត ចំនួន ៥០ ឡាន មនុស្សក្នុង១ ឡាន ២នាក់ ដោយមានការ បំពេញបែបបទ ពិនិត្យសុខភាព តាមការណែនាំ និងវិធានការក្រសួងសុខាភិបាល ដោយពុំអនុញ្ញាតឲ្យមានការចូលទៅលក់ដូរនោះទេ ។ ហើយរយៈពេល នៃការចូលទៅផ្សារនោះ គឺចាប់ពីម៉ោង ៨:០០ ដល់ម៉ោង ១០ នាទីព្រឹកឲ្យចូលឲ្យអស់ នៅវេលាម៉ោង១៣:០០ នាទីរសៀលចេញពីទឹកដីថៃវិញ។ ចំពោះការអនុញ្ញាតឲ្យចូលទៅនៅថ្ងៃណា ពេលណានោះ មិនទាន់កំណត់នោះទេ រង់ចាំការជូនដំណឹងពីរាជរដ្ឋាភិបាលថៃ។

-ករណីបើកឬបិទច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត~ខ្លងលឹក គឺរក្សាការបិទដដែល នឹងមិនទាន់មានព័ត៌មានផ្លូវការណាមួយ ត្រូវបើកនាពេលឆាប់ៗនោះទេ ។

-ករណីប្រជាពលរដ្ឋខ្មែរដែលចេញពីថៃ មកមាតុប្រទេសវិញគឺមានការសម្របសម្រួល ដោយរក្សា ឯកភាពឲ្យចេញតាមច្រកអូរបើជាន់ដដែល ។ អត្ថបទ៖ជលសា

## ប៉ុស្តិ៍នគរបាលរដ្ឋបាលកន្ទួត ចុះផ្សព្វផ្សាយប្រជាពលរដ្ឋ ស្តីពី គោលនយោបាយភូមិឃុំមានសុវត្ថិភាព

http://cambodiapolice.com/policekh/ 12:02 pm 23 មិថុនា 2020

ខេត្តក្រចេះ ៖ នាព្រឹកថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ២០២០ ប៉ុស្តិ៍នគរបាលរដ្ឋបាលកន្ទួត ចុះផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ស្តីពី គោលនយោបាយភូមិឃុំមានសុវត្ថិភាព តាមខ្នងផ្ទះចំនួន០៩ខ្នងផ្ទះ និងមានប្រជាពលរដ្ឋចូលរួមចំនួន២៣នាក់ (ស្រី១១នាក់) និងបានចែកខិត្តប័ណ្ណចំនួន ២៣សន្លឹក ។ ការចុះផ្សព្វផ្សាយធ្វើឡើងស្ថិតនៅត្រង់ចំនុច ភូមិអាលច ឃុំកន្ទួត ស្រុកចិត្របុរី ខេត្តក្រចេះ ។ កិច្ចផ្សព្វផ្សាយនេះរួមមាន ៖

១.ផ្សព្វផ្សាយច្បាប់ចរាចរណ៍ផ្លូវគោកអនុក្រិត្យលេខ៣៩

២.ចូលរួមបង្ការទប់ស្កាត់ការជួញដូរចែកចាយនិងប្រេ៊ីប្រាស់គ្រឿងញៀនខុសច្បាប់

៣.ផលប៉ះពាល់នៃគ្រឿងញៀន

៤.ល្បែងស៊ីសងគ្រប់ប្រភេទ

៥.អំពើហឹង្សាក្នុងគ្រួសារ ការជួញដូរមនុស្ស អាជីវកម្មផ្លូវភេទ លើស្ត្រីនិងកុមារ

៦.គ្រាប់យុទ្ធភណ្ឌ័មិនទាន់ផ្ទុះ(សំណល់សល់ពីសង្គ្រាម )

៧.លក្ខណៈសម្បត្តិ៩យ៉ាង(គោលនយោបាយភូមិឃុំមានសុវត្ថិភាព )

៨.អោយប្រជាពលរដ្ឋជួយសំអាតអនាម័យការពារជំងឺឆ្លងកូវីដ១៩

៩.ការបង្ការទប់ស្កាត់គ្រោះថ្នាក់ដោយអគ្គីភ័យ ៕

# ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០

## ក្រុមអាជ្ញាធរថៃបញ្ជូនអ្នកទោសខ្មែរ ជាបន្តបន្ទាប់ប្រគល់ឱ្យកម្ពុជា

https://kohsantepheapdaily.com.kh/ ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០២០ ម៉ោង ១៩:៤៣ ឱម សារឿន

ខេត្តឧត្តរមានជ័យ ៖ អ្នកទោសខ្មែរ២នាក់ត្រូវបានក្រុមអាជ្ញាធរថៃធ្វើ ការដោះលែងឱ្យមានសេរីភាព វិញជាបន្តបន្ទាប់រយៈពេល២ថ្ងៃជាប់ៗគ្នាគឺនៅថ្ងៃទី២១ និងថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២០ តាមមាត់ច្រកទ្វារអន្តរជាតិជាំ ស្ថិតនៅក្នុងភូមិជាំ ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ អ្នកទោសខ្មែរដែលក្រុមអាជ្ញាធរថៃបានធ្វើការសម្រេចដោះលែងឱ្យមានសេរីភាពវិញ ទី១-ឈ្មោះ ផា កាក់ ភេទប្រុស អាយុ២៩ឆ្នាំ រស់នៅភូមិពរពក ឃុំពរពក ស្រុកស្ទោង ខេត្តកំពង់ធំ ថៃចាប់ខ្លួននៅថ្ងៃទី២៦ មេសា ២០១៧ ក្រុមអាជ្ញាធរថៃដោះលែងនៅថ្ងៃទី២១ មិថុនា។ និង ម្នាក់ទៀតឈ្មោះ ធី ដេត ភេទប្រុស អាយុ២៣ឆ្នាំ រស់នៅភូមិទួលប្រសើរ ឃុំបាក់អន្លូង ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ, ថៃចាប់ខ្លួនថ្ងៃទី៧ កុម្ភៈ ២០១៨ ហើយដោះលែងនៅថ្ងៃទី២២ មិថុនា ២០២០។ ទាំង២នាក់ជាប់គុកនៅស្រុកខាន់តាឡាក់ ខេត្តស៊ីសាកេត ប្រទេសថៃ។

មន្ត្រីដែលបម្រើការងារនៅមាត់ច្រកទ្វារអន្តរជាតិបានឱ្យដឹងថា នៅមាត់ច្រកទ្វារអន្តរជាតិជាំ ក្រុមអាជ្ញាធរថៃបញ្ជូនអ្នកទោសខ្មែរជាញឹកញាប់ផងដែរ ដោយជាប់ពាក់ព័ន្ធពីបទឆ្លងដែនកាប់ឈើគ្រញូង ភាគច្រើនដោយឡែកអ្នកឆ្លងដែនធ្វើចំណាកស្រុក រកការងារធ្វើនៅក្នុងប្រទេសថៃស្ទើរតែពុំមាននោះទេ តែទោះជាបែបណានោះអ្នកទោសខ្មែរ២នាក់ រូបនេះក្រោយពីបានទទួលពីក្រុមអាជ្ញាធរថៃ សមត្ថកិច្ចបានធ្វើការអប់រំ និងឱ្យធ្វើកិច្ចសន្យាបញ្ឈប់ឆ្លងដែនខុសច្បាប់បន្តទៀត និងឱ្យវិលត្រឡប់ទៅជួបជុំក្រុមគ្រួសារក្នុងថ្ងៃដដែល។

គួរំលឹកថា អ្នកទោសខ្មែរដែលក្រុមអាជ្ញាធរថៃបញ្ជូនខ្លួនយកមកប្រគល់ឱ្យក្រុមអាជ្ញាធរកម្ពុជាចំនួន២នាក់នេះ ដោយមិនមែនជាលើកទី១នោះទេកន្លងមកក្រុមអាជ្ញាធរថៃបានធ្វើការដោះលែងអ្នកទោស ខ្មែរបញ្ជូនខ្លួនប្រគល់ឱ្យកម្ពុជាជាបន្តបន្ទាប់ផងដែរ៕ ដោយ ៖ ឱម សារឿន

## មនុស្ស១០នាក់ចាញ់បោកមេខ្យល់នាំឆ្លងដែន ត្រូវសមត្ថកិច្ចការពារព្រំដែនឃាត់ខ្លួន

http://nokorwatnews.com/ 23-06-2020

ខេត្តបាត់ដំបង ៖ កម្លាំងសមត្ថកិច្ចនគរបាលវរៈការពារព្រំដែនគោក លេខ៨១៧ សហការជាមួយកម្លាំងយោធាសឹករងស្រុកសំពៅលូន រួមនឹងមន្ត្រីយោធាទំនាក់ទំនងព្រំដែន នៅព្រឹកថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២០ បានធ្វើការស្ទាក់ចាប់ពលករខ្មែរចំនួន១០នាក់ ដែលលួចឆ្លងដែនទៅថៃខុសច្បាប់ នៅចំណុចភូមិគីឡូ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង ។

ពលរដ្ឋខ្មែរទាំង១០នាក់នោះមាន៖

១,ឈ្មោះ ពេញ ហាយ ភេទប្រុស អាយុ២៧ឆ្នាំ ខេត្តតាកែវ ។

២,ឈ្មោះសៀប ឡា ភេទប្រុស អាយុ២៥ឆ្នាំ ខេត្តកំពង់ឆ្នាំង ។

៣,ឈ្មោះ ចាន់ ថា ភេទប្រុស អាយុ២១ឆ្នាំ កំពង់ចាម។

៤,ឈ្មោះ ស្រី លីន ភេទស្រី អាយុ១៨ឆ្នាំ កំពង់ចាម។

៥,ឈ្មោះ សៀន សាន់ ភេទប្រុស អាយុ២១ឆ្នាំ សៀមរាប។

៦,ឈ្មោះ ស ផល្លា ភេទប្រុស អាយុ៣៩ឆ្នាំព្រៃវែង។

៧,ឈ្មោះ លី កញ្ញា ភេទប្រុស អាយុ៣០ឆ្នាំ ព្រៃវែង។

៨,ឈ្មោះ ស៊ី ម៉ាច ភេទស្រី អាយុ២៨ឆ្នាំ ព្រៃវែង។

៩,ឈ្មោះ កញ្ញា ផារី ភេទស្រីអាយុ៣៤ឆ្នាំ ព្រៃវែង។

១០,ឈ្មោះ សម្បត្តិ បណ្ណា ភេទស្រីអាយុ៣ឆ្នាំ ព្រៃវែង។

ពួកគាត់និយាយថា ដោយសារអត់ការងារធ្វើទើបពួកគាត់សម្រេចចិត្តធ្វើចំណាកស្រុកទៅរកការងារធ្វើនៅប្រទេសថៃតាមមេខ្យល់ម្នាក់ជាអ្នកនាំផ្លូវ តែមិនទាន់ឆ្លងផុតព្រំដែនផងត្រូវសមត្ថកិច្ចចាប់ខ្លួនបាត់ទៅហើយ។ ក្រោយការឃាត់សមត្ថកិច្ចបាននាំពលករខ្មែរខាងលើនោះយកទៅដើម្បីបន្តស្រាវជ្រាវរកចាប់មេខ្យល់យកមកផ្តន្ទាទោសតាមច្បាប់ ៕ ដោយៈ ប្រាថ្នា

## នគរបាលខេត្តកំពង់ស្ពឺ ផ្សព្វផ្សាយនិងណែនាំអោយម្ចាស់សណ្ឋាគារ ផ្ទះសំណាក់កន្លែងម៉ាស្សា ទីតាំងសប្បាយដ្ឋានត្រូវបន្តកិច្ចសហការជាមួយសមត្ថកិច្ច

http://cambodiapolice.com/policekh/ 4:28 pm 23 មិថុនា 2020

**កំពង់ស្ពឺៈ**ដោយអនុវត្តតាមគោលការណ៍មតិដឹកនាំដ៏ខ្ពង់ខ្ពស់ លោកឧត្តមសេនីយ៍ទោ សម សាមួន ស្នងការនគរបាលខេត្តកំពង់ស្ពឺ ការិយាល័យប្រឆាំងការជួញដូរមនុស្សនិង ការពារអនីតិជន នៃស្នងការដ្ឋាននគរបាលកំពង់ស្ពឺ លោកស្រីវរសេនីយ៍ទោ មួន មល្លិកា នាយការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន ដឹកនាំកម្លាំងចុះសហការជាមួយកម្លាំងអធិការ នៃអធិការដ្ឋាននគរបាលក្រុងច្បារមន បានធ្វើបច្ចុប្បន្នភាពនៅតាមសណ្ឋាគារ ផ្ទះសំណាក់ ហាងម៉ាស្សា កោសជប់ កន្លែងសប្បាយដ្ឋាន និងទីតាំងពាក់ព័ន្ធការបំរើភ្ញៀវមួយចំនួនទៀត។

ក្នុងការចុះផ្សព្វផ្សាយនិងណែនាំអំពីវិធានការមួយចំនួនជូនដល់ម្ចាស់ទីតាំង សណ្ឋាគារ ផ្ទះសំណាក់ កន្លែងសប្បាយដ្ឋាននិងទីតាំងមួយចំនួនទៀត លោកស្រី នាយការិយាល័យ ក្នុងនាមជំនាញប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន បានណែនាំអោយគ្រប់បណ្តាអ្នកទទួលខុសត្រូវទាំងអស់ដែលមានភារកិច្ចក្នុងការគ្រប់គ្រងនៅតាមបណ្តាគោលដៅត្រូវយកចិត្តទុកដាក់អនុវត្តតាមខ្លឹមសារលិខិតនិងបទបញ្ញាតិទាំងឡាយដែលមានសុពលភាព និងការឈានទៅអនុវត្តនីតិវិធីច្បាប់ដូច្នេះគម្បីត្រូវសហការជាមួយអាជ្ញាធរពាក់ព័ន្ធពិសេសកំលាំងនគរបាលក្នុងការផ្តល់ព័ត៌មាន រាយការណ៍ទប់ស្កាត់សកម្មភាពបំពានច្បាប់ទាំងឡាយដែលនាំឲ្យមានពិរុទ្ធភាពពាក់ព័ន្ធដល់ម្ចាស់ទីតាំងជាដើម ៕

## ប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ៣០នាក់

https://www.facebook.com/GDIOfficial 23-06-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារ មិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ៣០នាក់ ស្រី ១៩នាក់ និងកុមារ ០៣នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិព្រំ បានទទួលពលករខ្មែរ ឆ្លងដែនខុសច្បាប់ពីសម្ថកិច្ចថៃ ចំនួន ៦៦នាក់

https://www.facebook.com/GDIOfficial 23-06-2020

នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២០ ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិព្រំ បានសហការជាមួយ អាជ្ញាធរដែនដី និងស្ថាប័នពាក់ព័ន្ធ ទទួលពលករខ្មែរ ដែលបានទៅធ្វើការខុសច្បាប់ ពីសម្ថកិច្ចថៃ នៅច្រកបានផាកាត

ចូលប្រទេសតាមច្រកទ្វារព្រំដែនអន្តរជាតិព្រំ មានចំនួន ៦៦នាក់។ បន្ទាប់មកមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាព វាស់កំដៅ រួចក៏បាននាំពួកគាត់ ទៅដាក់ក្នុងមណ្ឌលសុខភាពរបស់ខេត្តប៉ៃលិន ដើម្បីតាមដានសុខភាពបន្តទៀត៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៣២នាក់

https://www.facebook.com/GDIOfficial 23-06-2020

នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៣២នាក់ ស្រី ១២នាក់៕

## នារីខ្មែរ៥នាក់ដែលចាញ់បោកមេខ្យល់នាំទៅលក់នៅប្រទេសចិនត្រូវបានស្ថានទូតកម្ពុជាប្រចាំប្រទេសវៀតណាមជួយសង្គ្រោះ

https://www.facebook.com/tvkchanne/ ទូរទស្សន៍ជាតិកម្ពុជា ទទក - TVK 23-06-2020

ស្ថានទូតកម្ពុជាប្រចាំប្រទេសវៀតណាមសហការជាមួយអាជ្ញាធរ មានសមត្ថកិច្ចខេត្តកាវបាង វៀតណាមបានសង្គ្រោះនារីរងគ្រោះ ៥រូប ដែលចាញ់បោកមេខ្យល់នាំទៅលក់នៅប្រទេសចិនដោយឆ្លងដែនខុសច្បាប់ចូលវៀតណាមនិងបានបញ្ជូនទៅដាក់មជ្ឈមណ្ឌលចត្តាឡីស័ករយៈពេល១៤ថ្ងៃ ព្រមទាំងបានរៀបចំបែបបទ បញ្ជូនត្រឡប់ទៅកម្ពុជាតាមរថភ្លើង ពីទីក្រុងហាណូយនៅថ្ងៃទី ២៤ ខែមិថុនា នឹងទៅដល់ទីក្រុងហូជីមិញវេលាម៉ោង ៥:០០ព្រឹក ថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ២០២០។ ដែលនៅទីនោះស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំក្រុងហូជីមិញជួយ សម្រួលការធ្វើដំណើរបន្តទៅដល់ច្រកព្រំដែនអន្តរជាតិបាវិត និងមានតំណាងក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនិតិសម្បទា និងមន្ទីរសង្គមកិច្ចខេត្តស្វាយរៀងមកទទួលរួចបញ្ជូនបន្តទៅតាម ទីលំនៅដ្ឋានរបស់គាត់រៀងៗខ្លួន។

## គណៈកម្មាធិការប្រយុទ្ធប្រឆាំងការជួញដូរមនុស្សខេត្តបានប្រគល់ទទួលសម្ភារៈសម្រាប់ផ្សព្វផ្សាយទប់ស្កាត់ការរីករាលដាលជំងឺកូវីដ ១៩ ពីអង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM) នៅសាលាខេត្តបាត់ដំបង

https://www.battambang.gov.kh/ ថ្ងៃអង្គារ, 23 ខែមិថុនា, 2020 ដោយ Sotheavy

នៅរសៀលថ្ងៃអង្គារ ៣កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី២៣ ខែមិថុនា ឆ្នាំ ២០២០ លោកស្រី ស៊ុំ ចិន្តា អភិបាលរង នៃគណៈអភិបាលខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការប្រយុទ្ធប្រឆាំការជួញដូរមនុស្សខេត្ត តំណាង ឯកឧត្តម ងួន រតនៈ អភិបាល នៃគណៈអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការប្រយុទ្ធប្រឆាំងការជួញដូរមនុស្សខេត្ត បានប្រគល់ និងទទួលសម្ភារៈផ្សព្វផ្សាយទប់ស្កាត់ការរីករាលដាលជំងឺកូវីដ ១៩ ពីអង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM) នៅសាលាខេត្តបាត់ដំបង ។

នៅក្នុងពិធីប្រគល់ និងទទួលនេះដែរ លោកស្រី សុំ ចិន្តា ក៏បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអង្គការអន្តរជាតិទេសន្តប្រវេស៍ (IOM) ដែលចូលរួមជារដ្ឋបាលខេត្តបាត់ដំបងក្នុងផ្សព្វផ្សាយការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ ១៩ នាពេលនេះ។ លោកស្រី អភិបាលរង នៃគណៈអភិបាលខេត្ត បានបន្តទៀតថា ចំពោះសម្ភារៈទាំងអស់នេះពិតជាមានសារសំខាន់ណាស់សម្រាប់មន្ត្រីយើងធ្វើការផ្សព្វផ្សាយ ដល់បងប្អូនប្រជាពលរដ្ឋនៅតាមមូលដ្ឋានផងដែរ បើទោះបច្ចុប្បន្នករណីជំងឺកូវីដ១៩ មានសភាពធូរស្រាលបន្តិចមែន ប៉ុន្តែយើងមិនអាចធ្វើការធ្វេសប្រហែសបានឡើយ ពីព្រោះថាបច្ចុប្បន្នមានកើតឡើងករណីថ្មីអ្នកផ្ទុកជំងឺកូវីដ ១៩ ផងដែរ។

សូមជម្រាបជូនដែរថា សម្ភារៈដែលបានទទួលនាពេលនោះរួមមាន ៖ ទឹកអាល់កុល ៣០ លីត្រ សាប៊ូ ២០០០ ដុំ ម៉ាសពេទ្យ ៥០ ប្រអប់ របាំងមុខ ៥០ខិត្តប័ណ្ណ និងកូនសៀវភៅផ្សព្វផ្សាយសរុប ១៩០០ សន្លឹង/ក្បាល ផងដែរ៕

## កម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលស្ទឹងកាច់ ស្រង់ស្ថិតិពលករដែលត្រឡប់មកពីប្រទេសថៃ តាមច្រកទ្វារអន្តរជាតិព្រំ

https://cambodiapolice.com/policekh/ 11:20 am 24 មិថុនា 2020

**ប៉ៃលិន៖** នៅវេលាម៉ោង១១នឹង៣០នាទីថ្ងៃអង្គារ ០៣កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស២៥៦៤ ត្រូវនឹងថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២០ កម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលស្ទឹងកាច់បានចុះស្រង់ស្ថិតិពលករដែលត្រឡប់មកពីប្រទេសថៃ តាមច្រកទ្វារអន្តរជាតិព្រំចូលមកប្រទេសកម្ពុជាវិញមានចំនួនសរុប ៦៦នាក់ ស្រី១៤នាក់ ក្មេង០៣នាក់ ស្រី០២នាក់។ បច្ចុប្បន្នពលករទាំងអស់បានបញ្ជូនទៅពិនិត្យសុខភាពនៅមណ្ឌលសុខភាពផ្សារព្រំ៕

# ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០

## តម្រួតថៃចាប់បញ្ជូនពលករខ្មែរជាង២០នាក់ត្រឡប់មកកម្ពុជាវិញ

http://ppt-news.net/ ចេញផ្សាយ ថ្ងៃទី 24/06/2020

ខេត្តសៀមរាប ៖ សមត្ថកិច្ចការពារព្រំដែនប្រទេសថៃ បានចាប់បញ្ជូនពលករខ្មែរចំនួន២២នាក់ ដែលបានឆ្លងដែនខុសច្បាប់មកប្រគល់ឲ្យអាជ្ញាធរកម្ពុជា ប្រចាំច្រកអូរបីជាន់ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យវិញ ខណៈដែលការប្រគល់ទទួលពលករខ្មែរទាំងអស់នោះធ្វើឡើងកាលពីរសៀលថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២០ ។ លោកជំទាវ យូ សុភា អភិបាលរងខេត្តសៀមរាប និងជាគណៈកម្មការទទួលប្រជាពលករមកពីក្រៅប្រទេសបានដឹកនាំប្រតិភូចុះទៅទទួលយកបងប្អូនដែលជាពលករទាំង២២នាក់វិលត្រឡប់មកកាន់ខេត្តសៀមរាប។ ប្រភពពីសមត្ថកិច្ចបានឲ្យដឹងថា ពលករទាំង២២នាក់ខាងលើនោះ (ស្រី១០នាក់) ដែលបានលួចឆ្លងដែនដោយខុសច្បាប់តាមរយៈមេខ្យល់ ចូលតាមច្រករបៀងក្នុងភូមិសាស្ត្រ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ទៅប្រទេសថៃ កាលពីយប់ថ្ងៃទី២២ មិថុនា ហើយត្រូវបានកម្លាំងសមត្ថកិច្ចការពារព្រំដែនថៃបានចាប់ និងបញ្ជូនឲ្យកម្លាំងសមត្ថកិច្ចកម្ពុជាប្រចាំការច្រកអូរបីជាន់ ៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរ ដែលឆ្លងដែនខុសច្បាប់ចំនួន ០៤នាក់ ពីសមត្ថកិច្ចថៃ

https://www.facebook.com/GDIOfficial 24-06-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម នាវេលាម៉ោង ១៧និង០០នាទី ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ ២០២០ បានទទួលពលករខ្មែរ ដែលឆ្លងដែនខុសច្បាប់ចំនួន ០៤នាក់ ពីសមត្ថកិច្ចថៃ ដោយមានការចូលរួមត្រួត

ពិនិត្យសុខភាព ពីក្រុមចត្តាឡីស័ក។ នគរបាលប៉ុស្ដិ៍បានឲ្យដឹងថា ពលករខ្មែរទាំង ០៤នាក់នេះ មាន ១-ឈ្មោះ ហាន ភាព ភេទប្រុស អាយុ ២៧ឆ្នាំ មានទីលំនៅភូមិដង្កោប្រមាង ឃុំអំពិលប្រាំដើម ស្រុកបាវិល ខេត្តបាត់ដំបង, ២-ឈ្មោះ លី ស៊ីនាត ភេទប្រុស អាយុ ២៥ឆ្នាំ មានទីលំនៅ ភូមិពពឹស ឃុំពោធិរៀង ស្រុកពារាំង ខេត្តព្រៃវែង, ៣-ឈ្មោះ ពៅ ពុំ ភេទប្រុស អាយុ ៤០ឆ្នាំ មានទីលំនៅភូមិ ទំពូង ឃុំល្វេ ស្រុកកោះសូទិន ខេត្តកំពង់ចាម និង៤-ឈ្មោះ ម៉ាត់ លី ភេទប្រុស អាយុ ៣៨ឆ្នាំ មានទីលំនៅភូមិស្ដេចគង់ ឃុំភ្នំល្វៀង ស្រុកទូកមាស ខេត្តកំពត បន្ទាប់មក កម្លាំងនគរបាលប៉ុស្ដិ៍ បានធ្វើការអប់រំណែនាំ រួចបញ្ជូនឲ្យក្រុមចត្តាឡីស័ក ដើម្បីអនុវត្តន៍បន្ត៕

## ប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្ដាំចំនួន ៤៤នាក់

https://www.facebook.com/GDIOfficial 24-06-2020

ប៉ុស្ដិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារ មិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្ដាំចំនួន ៤៤នាក់ ស្រី ១៩នាក់ និង កុមារ ០៤នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្ដិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៤៤នាក់

https://www.facebook.com/GDIOfficial 24-06-2020

នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្ដោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៤៤នាក់ ស្រី ១៩នាក់ និង ពលរដ្ឋថៃចាកចេញ មានចំនួន ០១នាក់ មានឯកសារចេញពីស្ថានទូតថៃ និងលិខិតបញ្ជាក់សុខភាព៕

## លោកជំទាវអភិបាលរងខេត្តសៀមរាប ទៅទទួលយកពលរដ្ឋរបស់ខ្លួន ដែលឆ្លងដែនខុសច្បាប់ ហើយត្រូវបានសមត្ថកិច្ចថៃ ចាប់បញ្ជូនមកវិញតាមច្រកអូរបីជាន់

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី 25 ខែ មិថុនា ឆ្នាំ 2020

AKP សៀមរាប ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ លោកជំទាវ យូ សុភា អភិបាលរងខេត្តសៀមរាប និងជាប្រធានគណៈកម្មការទទួលបន្ទុកប្រជាពលករមកពីក្រៅប្រទេស បានដឹកនាំមន្ត្រីរបស់ខ្លួន ទៅទទួលយកបងប្អូនប្រជាពលរដ្ឋចំនួន២២នាក់ ដែលបានឆ្លងដែនខុសច្បាប់ទៅរកការងារធ្វើនៅប្រទេសថៃតាមរយៈមេខ្យល់ ហើយត្រូវបានសមត្ថកិច្ចថៃចាប់បញ្ជូនមកវិញតាមច្រកអូរបីជាន់ ដែលស្ថិតនៅក្នុងឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃអង្គារ ៣កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២០ ។

ពលករទាំង២២នាក់នោះ ត្រូវបានដឹកជញ្ជូនមកដល់ខេត្តសៀមរាបអស់ហើយ ដោយក្រុមមន្ត្រីបានរៀបចំទៅដាក់នៅមណ្ឌលចត្តាឡីស័ក នៅសាលាគរុកោសល្យខេត្ត ដើម្បីធ្វើការត្រួតពិនិត្យសុខភាព និង ដាក់ឱ្យនៅដាច់ដោយឡែក ក្នុងរយៈពេល១៤ថ្ងៃ មុននឹងចូលទៅដល់លំនៅដ្ឋានជួបជុំក្រុមគ្រួសារខ្លួនវិញ។

នៅក្នុងពិធីទទួលយកពលករដែលជាពលរដ្ឋរបស់ខ្លួននោះ លោកជំទាវ យូ សុភា បានថ្លែងអំណរគុណដល់អាជ្ញាធរស្រុកអូរជ្រៅ និងកម្លាំងសមត្ថកិច្ចប្រចាំច្រកអូរបីជាន់ រួមទាំងអង្គការសង្គមស៊ីវិល ដែលបានយកចិត្តទុកដាក់ពីសុវត្ថិភាព សន្តិសុខ និងផ្គត់ផ្គង់អាហារដល់បងប្អូនប្រជាពលរដ្ឋដែលបានវិលត្រឡប់មកពីក្រៅប្រទេសនេះ ដោយក្នុងពេលនោះ លោកអភិ បាលស្រុកអូរជ្រៅ ក៏បាននាំយកនូវគ្រឿងឧបភោគបរិភោគ ចែកជូនដល់បងប្អូន កម្លាំងសមត្ថកិច្ចប្រចាំការនៅច្រកអូរបីជាន់រួមមាន៖ អង្ករ មី ទឹកត្រី ទឹកស៊ីអ៊ីវ និងថវិកា ២លានរៀល។ឆ្លៀតក្នុងឱកាសនោះដែរ លោកជំទាវក៏បានធ្វើការណែនាំដល់បងប្អូនប្រជាពលករទាំងអស់ ដែលបានចាញ់បោកមេខ្យល់ឱ្យចូលទៅធ្វើការងារនៅប្រទេសជិតខាងដោយខុសច្បាប់ ក្នុងគ្រាដែលប្រទេសជិតខាងយើង បានដាក់ប្រទេសក្នុងគ្រាអាសន្ននៅឡើយដោយសារវិបត្តិនៃជំងឺកូវីដ-១៩។ ម៉្យាងទៀតការធ្វើចំណាកស្រុករបស់បងប្អូនទៅដោយប្រថុយប្រថាន មិនបានគិតពីសុវត្ថិភាព សន្តិសុខរបស់ខ្លួននេះ វាក៏ជាអំពើជួញដូរមនុស្សទៀតផង។

នៅរសៀលថ្ងៃដដែលនោះដែរលោកជំទាវ យូ សុភា ក៏បានបន្តដំណើរទៅទទួលបងប្អូននិស្សិតចំនួន ១៦ នាក់ ដែលបានវិលត្រឡប់មកពីការធ្វើកម្មសិក្សានៅតាមរោងចក្រ របស់ក្រុមហ៊ុនមួយចំនួន នៃព្រះរាជាណាចក្រថៃ តាមច្រកអន្តរជាតិប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។ ដោយក្នុងឱកាសនោះ លោកនាយករងនៃសាលាវិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោ សែន សៀមរាប បានឱ្យដឹងថា ក្រុមនិស្សិតទាំង១៦នាក់នេះ បានទៅធ្វើកម្មសិក្សានៅតាមរោងចក្រ នៃប្រទេសថៃ តាមរយៈក្រុមហ៊ុន ចាប់តាំងពីខែកុម្ភៈ ឆ្នាំ២០២០ ហើយដល់ពេលផ្ទុះនូវវិបត្តិជំងឺកូវីដ-១៩ ត្រូវបានប្រទេសថៃប្រកាសដាក់ប្រទេសក្នុងគ្រាអាសន្ន បានធ្វើឱ្យខកខានដល់ក្រុមនិស្សិតទាំងនោះ មិនអាចវិលត្រឡប់មកកាន់មាតុប្រទេសវិញបានឡើយ។

ក្រុមនិស្សិត ទាំង១៦នាក់នេះ ក៏ត្រូវបានរៀបចំឱ្យស្នាក់នៅមណ្ឌលចត្តាឡីស័កនៅសាលាគរុកោសល្យខេត្ត ដើម្បីធ្វើការត្រួតពិនិត្យសុខភាព និងដាក់ឱ្យនៅដាច់ដោយឡែកក្នុង រយៈពេល១៤ថ្ងៃ ដូចបងប្អូនពលរដ្ឋឆ្លងដែនខុសច្បាប់ដែរ មុននឹងចូលទៅដល់លំនៅឋានជួបជុំក្រុមគ្រួសារខ្លួន៕ ដោយៈហង្ស សៀក

## ពលរដ្ឋខ្មែររួចផុតទោសចំនួន០៣នាក់ ត្រូវអាជ្ញាធរថៃយកមកប្រគល់ឲ្យភាគីកម្ពុជាយើងវិញ

http://kampucheathmey.com/ 25/6/2020 11:54 Am

**ឧត្តរមានជ័យ** ៖ អាជ្ញាធរថៃបានបញ្ជូនប្រជាពលរដ្ឋខ្មែរចំនួន០៣នាក់ រួចផុតទោសតាមច្រកអន្តរជាតិជាំ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ សមត្ថកិច្ចបានឲ្យដឹងថា នៅវេលាម៉ោង១៥និង៣៧នាទីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០។ ពលរដ្ឋរួចផុតទោសមានឈ្មោះដូចខាងក្រោម៖ ១. ឈ្មោះ គង់ ផេន ភេទប្រុស អាយុ២៣ឆ្នាំ រស់នៅភូមិសំឡូត ឃុំសំឡូត ស្រុកសំឡូត ខេត្តបាត់ដំបង។ ២. ឈ្មោះ ផុន ហុន ភេទប្រុស អាយុ២៩ឆ្នាំ រស់នៅភូមិកញ្ចាំង ឃុំស៊ិមមួយ ស្រុកសំឡូត ខេត្តបាត់ដំបង។ ៣. ឈ្មោះ ម៉ន វិត ភេទប្រុស អាយុ២៥ឆ្នាំ រស់នៅភូមិពាមឯក ឃុំពាមឯក ស្រុកឯកភ្នំ ខេត្តបាត់ដំបង។ ពលរដ្ឋខ្មែរទាំង០៣នាក់ខាងលើ ត្រូវបានទាហានថៃចាប់ខ្លួនកាលពីថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៦ ពីបទឆ្លងដែនចូលកាប់ឈើក្រញូង ក្នុងទឹកដីថៃដោយខុសច្បាប់ ជាប់គុកនៅខេត្តអំណាចចារើន ប្រទេសថៃ ចូលតាមច្រកចម្ការគរ ស្ថិតក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យ។ បច្ចុប្បន្ន ពលរដ្ឋខ្មែរចំនួន០៣នាក់ក្រោយពីសមត្ថកិច្ច ធ្វើការអប់រំ រួចបានឲ្យទៅស្រុកកំណើតវិញរៀងៗខ្លួន៕ **អត្ថបទ៖ ចាន់ ជី**

# ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០

## គ ខ ប ជ ខេត្តសៀមរាប បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលជំនាញស្តីពី "ការស៊ើបអង្កេតបទល្មើសផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណិត"

https://www.facebook.com/deputygovernoryousophear/ 25-06-2020

ខេត្តសៀមរាប ៖ នៅថ្ងៃទី២២-២៣ ខែមិថុនា ឆ្នាំ២០២០ ឧត្តមសេនីយ៍ត្រី ដួង ថាវរី ស្នងការរងនគរបាលខេត្តនិងជាអនុប្រធានលេខាធិការដ្ឋាន គ ខ ប ជ ខេត្តសៀមរាប បានអញ្ជើញចូលរួមក្នុងវគ្គបណ្តុះបណ្តាលជំនាញស្តីពី "ការស៊ើប អង្កេតបទល្មើសផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ិនធឺណិត" ដែលរៀបចំដោយអង្គការសកម្មភាពដើម្បីកុមារ (APLE) សហការជាមួយនាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ នៅសណ្ឋាគារអង្គរ ខេត្តសៀមរាប។

វគ្គបណ្តុះបណ្តាលនេះ បានផ្តល់ជូនដល់នគរបាលជំនាញមកពីនាយកដ្ឋាន និងការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជនរាជធានី ខេត្ត ចំនួន5 រួមមាន រាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តបាត់ដំបង ខេត្តកំពង់ធំ និងខេត្តបន្ទាយមានជ័យ។ វគ្គបណ្តុះបណ្តាលនេះរៀបចំឡើង ដើម្បីបង្កើនចំណេះដឹង និងបំប៉នជំនាញឆ្លើយតបបទល្មើសផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ិនធឺណិត ដល់មន្ត្រីជំនាញ សម្រាប់យកទៅអនុវត្តការងារអោយកាន់តែទទួលបានប្រសិទ្ធិភាពខ្ពស់។

## កិច្ចប្រជុំពិភាក្សាពង្រឹងប្រសិទ្ធភាពនៃប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

https://grandnewsasia.com/ 26-06-2020

សៀមរាប៖ នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ លេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តសៀមរាប (គ.ខ.ប.ជ) បានរៀបចំកិច្ចប្រជុំប្រចាំឆមាសទី១ ឆ្នាំ២០២០ ក្រោមកិច្ចដឹកនាំរបស់លោកស្រី យូ សុភា អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត តំណាង ដ៏ខ្ពង់ខ្ពស់លោក ទៀ សីហា អភិបាលនៃគណៈអភិបាលខេត្ត ជាប្រធានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តសៀមរាប ព្រមទាំងមានការអញ្ជើញចូលរួមពីលោក លោកស្រី សមាជិក សមាជិកា លេខាធិការដ្ឋាន គ.ខ.ប.ជ ពីមន្ទីរអង្គភាពពាក់ព័ន្ធ ព្រមទាំងតំណាងអង្គការ ដៃគូពាក់ព័ន្ធសរុប ៦០នាក់ ស្រី ៣៨នាក់។

ក្រោមការដឹកនាំផ្ទាល់ពីលោក ទៀ សីហា អភិបាលនៃគណៈអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តសៀមរាប ក្រុមការងារលេខាធិការដ្ឋាន បានអនុវត្តសកម្មភាព និងសម្រេចលទ្ធផលជាច្រើនលើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សតាមគ្រប់រូបភាព ដោយមានការចូលរួមសហការពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ នៅតាមមូលដ្ឋានភូមិ ឃុំ ដូចជា ធ្វើការផ្សព្វផ្សាយច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ច្បាប់ពាក់ព័ន្ធនានា គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព វេទិកាសាធារណៈ ច្បាប់ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ស្ប៉តអប់រំ ការផ្សាយតាមវិទ្យុ ទូរទស្សន៍ ជាដើម។ល។ បន្ថែមពីនេះ ក៏មានការស៊ើបអង្កេត និងបង្ក្រាបបទល្មើស ដើម្បីយកទៅផ្តន្ទាទោសតាមនីតិវិធីច្បាប់បានរាល់ករណីផងដែរ នៅក្នុងឆមាសទី១ ឆ្នាំ២០២០នេះ ។

នៅក្នុងកិច្ចប្រជុំនេះផងដែរ អង្គប្រជុំ ក៏បានលើកយកបញ្ហាជាច្រើនមកពិភាក្សា ដើម្បីស្វែងរកដំណោះស្រាយរួមគ្នា សម្រាប់ការពារជនរងគ្រោះ និងងាយរងគ្រោះ ដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ឬការរំលោភបំពានផ្សេងៗ ដែលពាក់ព័ន្ធទៅនឹងច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ ផ្អែកទៅតាមបញ្ហាប្រឈម និងស្ថានភាពជាក់ស្តែងនៅក្នុងពេលបច្ចុប្បន្ននេះ លោកស្រី យូ សុភា អភិបាលរងខេត្ត ជា

ប្រធានលេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តសៀមរាប បានកំណត់និងដាក់ចេញនូវចេញនូវអនុសាសន៍សម្រាប់ក្រុមការងារ ជាសមាជិក និងអង្គការដៃគូពាក់ព័ន្ធដើម្បីអនុវត្តបន្តរួមមាន ៖ ពិនិត្យលើបញ្ហានៃការប្រមូលផ្តុំជនអនាថា កុមារអនាថា និងការយកកុមារទៅដើរសុំទាននៅទីកន្លែងសាធារណៈដែលធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់កុមារ ពិនិត្យទៅការផ្តល់សេវាជូនជនរងគ្រោះ ពិនិត្យការផ្តល់ជំនាញវិជ្ជាជីវៈជូនប្រជាពលរដ្ឋ ពិសេសបងប្អូនក្រីក្រដែលទើបត្រឡប់ពីក្រៅប្រទេស ហើយមានតម្រូវការជំនាញ និងបានជំរុញលើការពន្លឿនរឿងក្តីលើមេខ្យល់នាំពលរដ្ឋឆ្លងដែនខុសច្បាប់ទៅក្រៅប្រទេស និងជំរុញលើការផ្សព្វផ្សាយច្បាប់ពាក់ព័ន្ធ និងទប់ស្កាត់ការធ្វើចំណាកស្រុកខុសច្បាប់។

ថ្លែងនៅក្នុងកិច្ចប្រជុំនេះផងដែរ លោកស្រី យូ សុភា ប្រធានអង្គប្រជុំ ក៏បានថ្លែងអំណរគុណដល់ក្រុមការងារមន្ទីរអង្គភាពពាក់ព័ន្ធ រដ្ឋបាលក្រុង ស្រុក ដែលបានសម្របសម្រួលជូនបងប្អូនប្រជាពលរដ្ឋដែលត្រឡប់មកពីការចំណាកស្រុកនៅប្រទេសថៃ ដែលយើងមានក្រុមការងារប្រចាំការនៅតាមច្រកជាប់ព្រំដែន និងមានក្រុមការងារសម្របសម្រួលនៅក្នុងខេត្ត និងនៅតាមមូលដ្ឋានផងដែរ ដើម្បីរួមគ្នាទប់ស្កាត់ការធ្វើចំណាកស្រុកខុសច្បាប់ និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ នៅក្នុងសហគមន៍៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត បានទទួលពលករខ្មែរ ឆ្លងដែនខុសច្បាប់ ពីអាជ្ញាធរថៃ ចំនួន ១១នាក់

https://www.facebook.com/GDIOfficial 25-06-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីអាជ្ញាធរថៃ ចំនួន ១១នាក់ និងពលរដ្ឋថៃចាកចេញមានចំនួន ០១នាក់។ ចំពោះពលករខាងលើ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែតដើម្បីធ្វើការបន្ត។ ជាមួយគ្នានេះដែរអាជ្ញាធរថៃនៅតែបន្តបិទច្រកទ្វារព្រំដែន មិនទាន់បើកឱ្យអ្នកដំណើរចេញ-ចូលឆ្លងកាត់នៅឡើយ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់និងរថយន្តដឹកទំនិញធន់ធំដំណើរការជាធម្មតា៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៦៩នាក់

https://www.facebook.com/GDIOfficial 25-06-2020

នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៦៩នាក់ ស្រី ៣៥នាក់៕

## នគរបាល បង្ក្រាបទីតាំង បង្កប់ សេវាផ្លូវភេទ ជ្រកក្រោមផ្លាកម៉ាស្សាកោសជប់

https://cambodiapolice.com/policekh/ 10:36 pm 25 មិថុនា 2020

**កំពង់ស្ពឺ៖** កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង១៦នឹង៣០នាទី កំលាំង ជំនាញការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ដឹកនាំដោយលោកស្រីវរ សេនីយ៍ទោ មួន មល្លិកា នាយការិយាល័យ បានធ្មក់ចូលបង្ក្រាបទីតាំង បង្កប់ សេវាផ្លូវភេទ ជ្រកក្រោមផ្លាកម៉ាស្សាកោសជប់ ស្ថិតក្នុងភូមិកាយៀវ ឃុំជង្រុក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ។

កិច្ចប្រតិបត្តិការកម្លាំងជំនាញឃាត់ខ្លួនម្ចាស់បើកទីតាំងម្នាក់មានឈ្មោះ ឈួន ប៊ុនថន ភេទប្រុស អាយុ៤០ឆ្នាំ មុខរបរបើកម៉ាស្សាកោសជប់។ លោកស្រី មួន មល្លិកា បានឲ្យដឹងថា ក្រោយទទួលបានព័ត៌មាន លោកស្រីបានគោរពស្នើសុំគោលការណ៍ដឹកនាំពីលោកឧត្តមសេនីយ៍ទោ សម សាមួន ស្នងការនគរបាលខេត្តកំពង់ស្ពឺ និងបានការឯកភាពពីលោកស្រី ចាតសូ រស្មី ព្រះរាជអាជ្ញាអយ្យការ អមសាលាដំបូងខេត្តកំពង់ស្ពឺ ដើម្បីប្រតិបត្តិការរំដោះនារីរងគ្រោះដោយ សារការចាញ់កលល្បិចលួងលោមពីថៅកែអោយរកស៊ីទទួលសេវាផ្លូវភេទផង និងឲ្យធ្វើជាអ្នកម៉ាស្សាកោសជប់។

បច្ចុប្បន្នម្ចាស់ទីតាំងបង្កប់ សេវា ផ្លូវភេទ ត្រូវបានជំនាញកសាងសំណុំរឿងបញ្ជូនទៅអយ្យការ អមសាលាដំបូងខេត្តកំពង់ស្ពឺចាត់ការនីតិវិធីបន្ត រីឯនារីរងគ្រោះបាន បញ្ជូនទៅជំនាញជួយដល់ស្ត្រី ងាយរងគ្រោះ៕

## គ.ខ.ប.ជ ខេត្តសៀមរាប បានចូលរួមក្នុងសិក្ខាសាលាស្តីពី " នីតិវិធី មន្ត្រីនគរបាលយុត្តិធម៌បែបកុមារមេត្រី

https://www.facebook.com/deputygovernoryousophear/ 26-06-2020

នៅថ្ងៃទី២៤-២៥ ខែមិថុនា ឆ្នាំ២០២០ ឧត្តមសេនីយ៍ត្រី ដួង ថាវរី ស្នងការរងនគរបាលខេត្តនិងជាអនុប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តសៀមរាប បានអញ្ជើញចូលរួមក្នុងសិក្ខាសាលាស្តីពី " នីតិវិធី មន្ត្រីនគរបាលយុត្តិធម៌បែបកុមារមេត្រី " ដល់នគរបាលយុត្តិធម៌ថ្នាក់ក្រោមជាតិ ចំនួន ៤០នាក់ ។ សិក្ខាសាលានេះ រៀបចំដោយអង្គការ សម្ពន្ធសិទ្ធិកុមារកម្ពុជា (ស.ស.ក) សហការជាមួយបណ្ឌិត្យសភានគរបាលកម្ពុជា ដែលមានចូលរួមគាំទ្រពីអង្គការក្លែនអន្តរជាតិ និងអង្គការដៃគូមួយចំនួនទៀតផងដែរ នៅស្នងការដ្ឋាននគរបាលខេត្តសៀមរាប។ វគ្គបណ្តុះបណ្តាលនេះ បានផ្តល់ជូនដល់នគរបាលជំនាញក្នុងការអភិវឌ្ឍន៍សមត្ថភាពបន្ថែម លើការពារ គោរពនិងបំពេញសិទ្ធិដោយអនុលោមតាមគោលការណ៍នីតិវិធីមន្ត្រីនគរបាលយុត្តិធម៌បែបកុមារមេត្រី។

## លោកឧត្តមសេនីយ៍ទោ ទិត្យ ណារ៉ុង អញ្ជើញចូលរួមពិធីប្រជុំបូកសរុបលទ្ធផលប្រតិបត្តិការរក្សាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈប្រចាំឆមាសទី១ ឆ្នាំ២០២០

http://cambodiapolice.com/policekh/ 11:18 am 26 មិថុនា 2020

**សៀមរាប៖** នៅថ្ងៃសុក្រ ០៦កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ពុទ្ធសករាជ២៥៦៤ ត្រូវនឹងថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០ លោកឧត្តមសេនីយ៍ទោ ទិត្យ ណារ៉ុង ស្នងការនៃស្នងការដ្ឋាននគរបាលខេត្តសៀមរាបបានអញ្ជើញចូលរួមជាអធិបតីភាពក្នុងពិធីប្រជុំបូកសរុបលទ្ធផលប្រតិបត្តិការរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈប្រចាំឆមាសទី១ ឆ្នាំ២០២០ ដោយមានការអញ្ជើញចូលរួមពីលោក លោកស្រី ស្នងការរង នាយការិយាល័យ និងអធិការ អធិការរងក្រុង/ស្រុកទាំង១២។ ជាកិច្ចចាប់ផ្តើមលោកវរសេនីយ៍ឯក សឿន សេន ស្នងការរងទទួលផែនការងារសេនាធិការបានឡើងមានមតិស្វាគមន៍ និងអានរបាយការណ៍សង្ខេបស្តីអំពី លទ្ធផលការងារក្នុងកិច្ចប្រតិបត្តិការ

ប្រចាំឆមាសទី១ ដែលកងកម្លាំងតាមបណ្ដាការិយាល័យ និងអធិការក្រុង/ស្រុក ចំណុះអោយស្នងការដ្ឋាននគរបាលខេត្តសៀមរាបបានអនុវត្តកន្លងមក។

ឆ្លៀតក្នុងឱកាសនោះ លោកឧត្តមសេនីយ៍ទោ ទិត្យ ណារ៉ុង ស្នងការនៃស្នងការដ្ឋាននគរបាលខេត្តសៀមរាបបានមានមតិសំណេះសំណាល វាយតម្លៃលទ្ធផលការងារតាមរយៈការប្រៀបធៀបលទ្ធផលការងារឆមាសទី១ ឆ្នាំ២០១៩ ប្រៀបធៀបជាមួយលទ្ធផលការងារឆមាសទី១ ឆ្នាំ២០២០ ដែលកងកម្លាំងអនុវត្តកន្លងមក បានសង្កេតឃើញថាករណីព្រហ្មទណ្ឌកើនឡើងចំនួន០១លើក ករណីគ្រោះអគ្គិភ័យកើនឡើងចំនួន១៩លើក ប៉ុន្តែករណីគ្រោះថ្នាក់ចរាចរណ៍មានការថយចុះគួរអោយកត់សម្គាល់។ ជាចុងក្រោយ លោកឧត្តមសេនីយ៍ទោ ស្នងការក៏ផ្តល់អនុសាសន៍មួយចំនួនដល់កងកម្លាំងទាំងអស់ត្រូវកែសម្រួល និងអនុវត្តបន្ត៖

១. បង្កើនការក្តាប់សភាពការណ៍ទូទៅក្នុងខេត្ត ពិសេសសភាពការណ៍ការងារសន្តិសុខផ្ទៃក្នុង និងការងារភេរវកម្មដែលបង្កឡើងដោយពួកអមិត្ត និងពួកប្រឆាំង។

២. ចាត់វិធានការបើកកិច្ចប្រតិបត្តការបង្ការ បង្ក្រាបបទល្មើសគ្រប់ប្រភេទអោយបានព្រមៗគ្នាបទល្មើសព្រហ្មទណ្ឌ បទល្មើសផ្លូវភេទ ការជួញដូរស្ត្រី និងកុមារ ការជួញដូរ ចែកចាយ និងប្រើប្រាស់គ្រឿងញៀន ក្រុមក្មេងទំនើង ល្បែងស៊ីសង បន្តអនុវត្តដីការចាប់ខ្លួនដែលនៅសេសសល់នៅក្នុងភូមិសាស្ត្រខេត្ត។

៣. ត្រួតពិនិត្យការចុះបញ្ជីគ្រប់គ្រងស្ថិតិប្រជាពលរដ្ឋស្នាក់នៅបណ្តោះអាសន្នក្នុងក្រុងសៀមរាប តាមតំបន់ស្នូតស្នាញ និងតាមបណ្តាស្រុក ព្រមទាំងជំរុញការផ្តល់អត្តសញ្ញាណប័ណ្ណជូនប្រជាពលរដ្ឋទូទាំងខេត្ត។

៤. ពង្រឹងសណ្តាប់ធ្នាប់សាធារណៈក្នុងខេត្តអោយបានល្អប្រសើរសណ្តាប់ធ្នាប់អ្នកលក់ដូរតាមដងផ្លូវទីប្រជុំជនសំខាន់ៗ សណ្តាប់ធ្នាប់កំពង់ផែ និងសណ្តាប់ធ្នាប់ចរាចរណ៍តាមដងផ្លូវសាធារណៈក្នុងខេត្ត។

៥. បង្កើនកិច្ចប្រតិបត្តិការល្បាត ពួនស្ទាក់ ២៤/២៤ម៉ោង និងត្រៀមអន្តរាគមន៍ទាន់ពេលវេលា។

៦. បង្កើនការសាមគ្គីភាពផ្ទៃក្នុងអោយរឹងមាំ សហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ និងប្រមូលផ្តុំកម្លាំងរក្សាសន្តិសុខ ចូលរួមការពារគណៈប្រតិភូជាន់ខ្ពស់ជាតិ-អន្តរជាតិ ភ្ញៀវទេសចរដែលមកទស្សនកិច្ចក្នុងខេត្ត។

៧. ពង្រឹងកិច្ចការពារជានាសន្តិសុខ សុវត្ថិភាព ជូនវិនិយោគិន និងអ្នកទេសចរ។

៨. បន្តចុះពង្រឹងការងារតាមបណ្តាប៉ុស្តិ៍នគរបាលរដ្ឋបាល ដើម្បីសុវត្ថិភាពសហគមន៍តាមផែនការរបស់អគ្គស្នងការនគរបាលជាតិ។

៩. ជំរុញអនុវត្តតាមខ្លឹមសារសេចក្តីណែនាំ០០២សណន របស់ក្រសួងមហាផ្ទៃ និងរបស់អគ្គស្នងការនគរបាលជាតិ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០ ស្តីពីវិធានការបន្ទាន់សម្រាប់បង្ការ និងការទប់ស្កាត់ការរាតត្បាតជម្ងឺកូវីដ-១៩ ពិសេសមានវិធានការ ទប់ស្កាត់ ការរាតត្បាតនៃជំងឺ កូវីដ ១៩ ក្នុងជួរថ្នាក់ដឹកនាំ និងមន្ត្រីនគរបាលនៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប ៕

## ពលករខ្មែរឆ្លងដែនខុសច្បាប់ មកតាមច្រកទ្វារព្រំដែនអន្តរជាតិខ្លងលឹក ប៉ោយប៉ែត

https://www.cen.com.kh/archives/ June 26, 2020

ព្រំដែន-បន្ទាយមានជ័យ៖ មន្ត្រីប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ បានទទួលពលករខ្មែរ ឆ្លងដែនខុសច្បាប់ ពីអាជ្ញាធរថៃ ចំនួន ១១នាក់ និងពលរដ្ឋថៃត្រូវបញ្ជូនចាកចេញទៅវិញមានចំនួន១នាក់។ កម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។

សូមបញ្ជាក់ថា មន្ត្រីនៃមជ្ឈមណ្ឌលរដ្ឋបាលកូវីដ-១៩ ដែលទទួលបន្ទុកផ្នែកសន្តិសុខ បានសម្រេចដាក់ប្រទេសថៃ នៅក្នុងក្រឹត្យគ្រាអាសន្នបន្ទាន់ សម្រាប់រយៈពេលមួយខែទៀត បន្ទាប់ពីការផុតកំណត់នៅចុងខែមិថុនា

ឆ្នាំ២០២០ គឺក៏បន្តបិទច្រកទ្វារព្រំដែន (សម្រាប់ពលរដ្ឋ អ្នកដំណើរនិងភ្ញៀវទេសចរ) ប៉ុន្តែ ចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធន់ធំ ដំណើរការជាធម្មតា ៕

## កម្ពុជា បន្តសហការជាមួយម៉ាឡេស៊ី ជួយពលរដ្ឋខ្មែរ ដែលចង់ធ្វើមាតុភូមិនិវត្ត

https://www.thmeythmey.com/ 26, Jun 2020 , 1:50 pm

លោក ចឺយ វិចិត្ត ឯកអគ្គរាជទូតកម្ពុជាប្រចាំម៉ាឡេស៊ី បានចូលជួបពិភាក្សាការងារ ជាមួយលោក Hishammuddin Hussein រដ្ឋមន្ត្រីការបរទេសម៉ាឡេស៊ី កាលពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០។ ទំព័រហ្វេសប៊ុករបស់ស្ថានទូតកម្ពុជាប្រចាំម៉ាឡេស៊ី សរសេរថា ជំនួបនេះ គឺផ្តោតលើការពង្រឹង ទំនាក់ទំនងទ្វេភាគី។ ភាគីទាំងពីរក៏បានពិភាក្សាគ្នាដែរ ពីការបន្តកិច្ចសហការក្នុងការសម្របសម្រួលពលករ និងនិស្សិតខ្មែរ ដែលមានបំណងធ្វើមាតុភូមិនិវត្ត នាអំឡុងជើងហោះហើយ ពុំទាន់អាចដំណើរការជាប្រក្រតីឡើងវិញ ដោយសារជំងឺកូវីដ-១៩។

ចាប់តាំងពីជំងឺកូវីដ-១៩ផ្ទុះឡើង ភាគីកម្ពុជានិងភាគីម៉ាឡេស៊ី បានជួយសម្របសម្រួលឲ្យមានជើងហោះហើរពីរលើកហើយ ក្នុងការបញ្ជូនពលរដ្ឋខ្មែរ មកស្រុកវិញ។ លើកទីមួយ កាលពីថ្ងៃទី១៦ ខែមិថុនា ពលរដ្ឋខ្មែរជាង ២០០នាក់នៅម៉ាឡេស៊ី ដែលភាគច្រើនជាពលករ បានមកដល់កម្ពុជាវិញ។ ក្នុងចំណោមជាង២០០នាក់នោះ មានម្នាក់ជាបុរសអាយុ២១ឆ្នាំ ផ្ទុកមេរោគកូវីដ-១៩ តែឥឡូវ បានជាសះស្បើយវិញហើយ។ លើកទីពីរ នៅព្រឹកថ្ងៃទី២៦ មិថុនានេះ និស្សិតនិងពលករខ្មែរជាង១០០នាក់ទៀត បានមកដល់កម្ពុជា។

ក្រៅពីម៉ាឡេស៊ី រដ្ឋាភិបាល ក៏ដូចជា ស្ថានទូតកម្ពុជានៅប្រទេស ក៏បានជួយសម្រួលនិងស្វែងរកជើងហោះហើរ ឲ្យពលរដ្ឋខ្មែរនៅប្រទេសផ្សេងទៀតដែរ ដូចជាកន្លង និស្សិតខ្មែរជាង៤០នាក់ នៅឥណ្ឌូណេស៊ី និងពលរដ្ឋខ្មែរប្រមាណ៦០នាក់នៅឥណ្ឌា បានធ្វើមាតុភូមិនិវត្ត។ យ៉ាងណា ការចំណាយលើថ្លៃធ្វើដំណើរ គឺជាបន្ទុកផ្ទាល់ខ្លួន៕

## ពលករខ្មែរជួបការលំបាកជាង ៧០គ្រួសារធ្វើការនៅប្រទេសថៃ ដែលទទួលរងគ្រោះដោយអគ្គីភ័យឆេះកន្លែងស្នាក់នៅ បានទទួលការយកចិត្តទុកដាក់ និងទទួលបានអំណោយពីស្ថានទូតកម្ពុជា ប្រចាំប្រទេសថៃ

https://www.facebook.com/tvkchannel7/ 25-06-2020

បន្ទាប់ទទួលបានដំណឹងថា៖ មានពលករខ្មែរជាង ៧០គ្រួសារជួបការលំបាកខ្វះខាត នៅថ្ងៃព្រហស្បតិ៍ទី ២៥ ខែមិថុនា ឆ្នាំ២០២០ ឯកឧត្តម អ៊ុក សោភ័ណ ឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសថៃ បានដឹកនាំមន្ត្រីស្ថានទូតដោយសហការជាមួយប៉ុស្តិ៍ប៉ូលីសម៉ាក់កាសាន់ បានចុះសួរសុខទុក្ខ និងនាំយកអំណោយ រួមមាន អង្ករ ត្រីខ មីកញ្ចប់ ទឹកស៊ីអ៊ីវ ទឹកបរិសុទ្ធ និង ម៉ាស់ការពារជំងឺកូវីដ-១៩ យកទៅផ្តល់ជូនបងប្អូនពលករខ្មែរប្រមាណជាង ៧០គ្រួសារ នៅក្នុងការដ្ឋានសំណង់របស់ក្រុមហ៊ុនរីថា(Ritta)នាបរិវេណផ្លូវលំចតុជិត២ សង្កាត់បាងកាពិ ខណ្ឌហួយខ្វាង ទីក្រុងបាងកក ដែលកំពុងជួបទុក្ខលំបាកដោយសាររងគ្រោះដោយគ្រោះអគ្គីភ័យឆាបឆេះកន្លែងស្នាក់នៅកាលពីល្ងាចថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២០កន្លងទៅ។

## រដ្ឋមន្ត្រីការបរទេសអាមេរិកនិយាយថា កូវីដ ១៩ បណ្តាលឲ្យមានការកើនឡើងនូវការជួញដូរមនុស្ស

https://www.information.gov.kh/ ថ្ងៃទី 26 ខែ មិថុនា ឆ្នាំ 2020 វិទ្យុជាតិកម្ពុជា/ អត្ថបទ ឆាយ រីកាល

រដ្ឋមន្ត្រីការបរទេសរបស់សហរដ្ឋអាមេរិក លោកម៉ែក ប៉ុមប៉េអូ បាននិយាយព្រមាននៅថ្ងៃព្រហស្បតិ៍នេះថា អស្ថេរភាពដែលបង្កឡើងដោយការរាលដាលរបស់កូវីដ ១៩ កំពុងបង្កលទ្ធភាពឲ្យការជួញដូរមនុស្សកាន់តែមានសកម្មភាពខ្លាំងឡើង ។ លោករដ្ឋមន្ត្រីការបរទេសអាមេរិក បាននិយាយទៀតថា សហរដ្ឋអាមេរិក បានបញ្ចូល

ក្នុងបញ្ជីប្រទេសដែលមានការជួញដូរមនុស្សកាន់តែច្រើនឡើង ដែលរួមមានប្រទេសអាហ្វកានីស្ថាន អាល់ហ្សេរី ឡេសូតូ និងនីការ៉ាហ្កា ។ លោករដ្ឋមន្ត្រីការបរទេសអាមេរិកបានបង្ហាញពីរបាយការណ៍ស្តីពីស្ថានភាពជួញដូរមនុស្ស ដោយបញ្ជាក់ថា "ផលវិបាកបង្កឡើងដោយកូវីដ១៩ ទាមទារឲ្យភាគីពាក់ព័ន្ធទាំងអស់ រួមគ្នា ក្នុងការប្រឆាំងនឹងការជួញដូរមនុស្ស" ។ ប្រភព ឆាណែលញូវអេស៊ីយ៉ា (២៦.០៦.២០)

## ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០

## ពិធីសំណេះសំណាល ចែកអំណោយដល់ចាស់ជរា ស្ត្រីមេម៉ាយ និងជនងាយរងគ្រោះ ចំនួន ៨០គ្រួសារ និងផ្សព្វផ្សាយអំពីផលប៉ះពាល់នៃការធ្វើចំណាកស្រុកដោយប្រថុយប្រថាន

https://grandnewsasia.com/ 28-06-2020

កំពង់ឆ្នាំង៖ នារសៀលថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) អញ្ជើញចុះជួបសំណេះសំណាល និងចែកអំណោយដល់ចាស់ជរា ស្ត្រីមេម៉ាយ កុមារកំព្រា និងគ្រួសារជនងាយរងគ្រោះ ចំនួន ៨០ គ្រួសារ ព្រមទាំងផ្សព្វផ្សាយអំពីផលប៉ះពាល់នៃការធ្វើចំណាកស្រុកដោយប្រថុយប្រថាន ការទប់ស្កាត់អំពើជួញដូរមនុស្ស និងផ្សព្វផ្សាយពីវិធានការ បង្ការទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ១៩ ដល់បងប្អូនប្រជាពលរដ្ឋ មកពីឃុំចំនួន ០៣ ក្នុងស្រុកសាមគ្គីមានជ័យ គឺឃុំសេដ្ឋី ចំនួន ២៩គ្រួសារ ឃុំស្វាយចំនួន ២៦គ្រួសារ និងឃុំត្បែងខ្ពស់ ចំនួន ២៦គ្រួសារ។

ក្នុងពិធីក៏មានការអញ្ជើញចូលរួមពី លោក នួន ដាញ៉ិល រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ លោកស្រី ឧត្តមសេនី យ៍ឯកវេជ្ជបណ្ឌិត ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ ក្រសួងមហាផ្ទៃ លោកស្រី ប៊ិន សុភី អភិបាលរងខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជ ខេត្ត លោក វន ស៊ីផា អភិបាលស្រុកសាមគ្គីមានជ័យ និងលោកប្រធានក្រុមប្រឹក្សាស្រុក លោក លោកស្រី អភិបាលរងស្រុក ក្រុមការងារថ្នាក់ស្រុក ថ្នាក់ឃុំ ថ្នាក់ភូមិ និងសមាជិក សមាជិកា ក្រុមលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត ពិធីប្រារព្ធនៅក្នុងសាលារៀនស្ពានពោធិ៍ ស្ថិតក្នុងភូមិស្ពានពោធិ៍ ឃុំសេដ្ឋី ស្រុកសាមគ្គីមានជ័យ។ អំណោយដែលបាននាំយកទៅចែកជូនក្នុងឱកាសនោះដោយក្នុង១គ្រួសារទទួលបានរួមមាន៖ អង្ករ ចំនួន ១០ គីឡូក្រាម, សាប៊ូដុំ ចំនួន ២ ដុំ, សារ៉ុង ចំនួន ២, ក្រមា ចំនួន ២, ដែលលាងដៃ ចំនួន ២ ដប, សាប៊ូបោកខោអាវ ចំនួន ២ កញ្ចប់៕

## អាមេរិកដាក់កម្ពុជាក្នុងចំណាត់ថ្នាក់ប្រឹងប្រែងតិចតួចនៃការទប់ស្កាត់ការជួញដូរមនុស្ស

https://khmer.voanews.com/ 26 មិថុនា 2020 សុខ ខេមរា

របាយការណ៍ប្រចាំឆ្នាំចុងក្រោយរបស់ក្រសួងការបរទេសសហរដ្ឋអាមេរិក ស្តីពីអំពើជួញដូរមនុស្សក្នុងពិភពលោក។ បើតាមរបាយការណ៍ចុងក្រោយសម្រាប់ឆ្នាំ២០២០ នេះដែលចេញផ្សាយនៅសប្តាហ៍នេះ ក្រសួងការបរទេសអាមេរិក បានចាប់ផ្តើមពីការបញ្ជាក់ចំៗថា រដ្ឋាភិបាលកម្ពុជា មិនបានចាត់វិធានការដល់កម្រិតស្តង់ដាអប្បរមាពេញលេញ ក្នុងការកម្ចាត់ការជួញដូរមនុស្សនៅឡើយទេ។

រដ្ឋធានីវ៉ាស៊ីនតោន៖ នៅក្នុងរបាយការណ៍ប្រចាំឆ្នាំចុងក្រោយ ស្តីពីអំពើជួញដូរមនុស្សក្នុងពិភពលោក សហរដ្ឋអាមេរិក បានចាត់ទុកប្រទេសកម្ពុជា ស្ថិតនៅក្នុងចំណាត់ថ្នាក់ ដែលមានការប្រឹងប្រែងទប់ស្កាត់អំពើជួញដូរមនុស្សដែរ តែមិនទាន់ដល់កម្រិតស្តង់ដា ឬហៅថា Tear 2 ក្រោមការឃ្លាំមើលនៅឡើយទេ។ បើតាមរបាយការណ៍ចុងក្រោយសម្រាប់ឆ្នាំ២០២០ នេះ ដែលចេញផ្សាយនៅសប្តាហ៍នេះ ក្រសួងការបរទេសអាមេរិក បានចាប់ផ្តើមពីការបញ្ជាក់ចំៗថា រដ្ឋាភិបាលកម្ពុជា មិនបានចាត់វិធានការដល់កម្រិតស្តង់ដាអប្បរមាពេញលេញ ក្នុងការកម្ចាត់ការ

ជួញដូរមនុស្សនៅឡើយទេ។ បញ្ហាទាំងនោះរាប់បញ្ចូលទាំងបញ្ហាគ្មានកិច្ចប្រឹងប្រែងប្រមូលទិន្នន័យ ឬ ចែករំលែកព័ត៌មានសំខាន់ៗអំពីកិច្ចប្រឹងប្រែងរបស់អាជ្ញាធរ អំពើពុករលួយនាំឲ្យរំខានដល់ប្រតិបត្តិការរបស់មន្ត្រីអនុវត្តន៍ច្បាប់ ដំណើរការនីតិវិធីព្រហ្មទណ្ឌ ហើយនឹងការផ្តល់សេវាកម្មដល់ជនរងគ្រោះ។

របាយការណ៍ ក៏បានបន្ថែមថា ការមិនបានស៊ើបអង្កេតទាក់ទងនឹងការជួញដូរ ការមិនបានបង្កើតប្រព័ន្ធឃ្លាំមើលតុលាការ ដែលនាំឲ្យជនសង្ស័យរួចខ្លួន ហើយនឹងបញ្ហាផ្សេងៗទៀត ដែលមិនបោះជំហានរីកចម្រើនតាំងពីពេលចេញរបាយការណ៍ឆ្នាំមុន ដែលការណ៍នេះ នាំឲ្យកម្ពុជាស្ថិតក្នុងចំណាត់ថ្នាក់ប្រឹងប្រែងតិចតួច ឬ ហៅថា Tear 2 Watchlist។ ទោះជាយ៉ាងនេះក្តី របាយការណ៍ក្រសួងការបរទេសអាមេរិក ក៏បានទទួលស្គាល់ថាអាជ្ញាធររដ្ឋាភិបាល មានការប្រឹងប្រែងលើវិស័យខ្លះដែរ ដូចជាការបន្តចាប់កាត់ទោសអ្នកជួញដូរ ការបង្កើតផែនការសកម្មភាព៥ឆ្នាំ ហើយនឹងបច្ចេកវិជ្ជាប្រមូលព័ត៌មាន។

នៅក្នុងការបើកសម្ពោធរបាយការណ៍ឆ្នាំនេះ រដ្ឋមន្ត្រីក្រសួងការបរទេសអាមេរិក លោក Mike Pompeo បានថ្លែងថា ក្នុងរយៈពេល២០ ឆ្នាំកន្លងទៅនេះ របាយការណ៍ស្តីពីការជួញដូរមនុស្ស បានបង្ហាញឲ្យសហរដ្ឋអាមេរិកជឿថា អំពើជួញដូរមនុស្ស គឺជាការគំរាមដល់ពិភពលោក ដែលតម្រូវឲ្យមានការឆ្លើយតបជាសកល។ លោកបានបន្ថែមតាមខ្លឹមសារដើមទៀតថា ក្រុមអ្នកជួញដូរ កំពុងរារាំងមនុស្សចំនួនជិត២៥ លាននាក់ ចាប់ពីសិទ្ធិជាមូលដ្ឋានរបស់ជនរងគ្រោះ ដល់សិទ្ធិសេរីភាពពួកគេ និង បង្ខំឲ្យជនរងគ្រោះរស់នៅក្នុងជីវិតទាសភាព ដើម្បីបម្រើឲ្យផលប្រយោជន៍ដល់ក្រុមអ្នកជួញដូរពួកគេ៕

## ពលករឆ្លងដែនខុសច្បាប់១១នាក់ ក្នុងនោះមានវិជ្ជមានកូវីដ-១៩ ១នាក់ សមត្ថកិច្ចថៃបញ្ជូនមកឲ្យខ្មែរ តាមច្រកប៉ោយប៉ែត

---

http://kampucheathmey.com/ 27/6/2020 3:17 Pm

បន្ទាយមានជ័យ ៖ ពលករឆ្លងដែនទៅប្រទេសថៃដោយខុសច្បាប់១១នាក់ ក្នុងនោះមានវិជ្ជមាន១នាក់ ត្រូវបានសមត្ថកិច្ចថៃបញ្ជូនមកប្រគល់ឲ្យមន្ត្រីប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត កាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០។ ក្រោយពីទទួលពលករទាំង១១នាក់រួចមក កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំ ណែនាំ។ បន្ទាប់មកប្រគល់ជូនក្រុមការងារ ទទួលពលករមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីធ្វើការបន្ត។ មន្ត្រីនៃមជ្ឈមណ្ឌលរដ្ឋបាលកូវីដ-១៩ ដែលទទួលបន្ទុកផ្នែកសន្តិសុខថា ប្រទេសថៃ បានសម្រេចដាក់ប្រទេសនៅក្នុងក្រឹត្យគ្រាអាសន្នបន្ទាន់ សម្រាប់រយៈពេលមួយខែទៀត បន្ទាប់ពីការផុតកំណត់នៅចុងខែមិថុនា ឆ្នាំ២០២០នេះ។ ពោលគឺបន្តបិទច្រកទ្វារព្រំដែនសម្រាប់ពលរដ្ឋ អ្នកដំណើរ និងភ្ញៀវទេសចរ ប៉ុន្តែចំពោះអ្នកជំងឺសង្គ្រោះបន្ទាន់ និងរថយន្តដឹកទំនិញធុនធំ ដំណើរការជាធម្មតា៕ អត្ថបទ ៖ គង្គា

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៣៣នាក់

https://www.facebook.com/GDIOfficial 28-06-2020

នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹក

ទំនិញ ដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញតាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ចំនួន៣៣នាក់ ស្រី១៣នាក់៕

## ប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ២២នាក់

https://www.facebook.com/GDIOfficial 27-06-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារ មិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ២២នាក់ ស្រី ០៩នាក់ និងកុមារ ០១នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ៦៧នាក់

https://www.facebook.com/GDIOfficial 27-06-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត នាថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០ មានពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃបញ្ជូនមក មានចំនួន ៦៧នាក់ ស្រី ២៤នាក់ និងកុមារ ០២នាក់។ ក្នុងចំណោមពលករទាំង ៦៧នាក់ខាងលើ មាន ២៨នាក់ ស្រី ១៩នាក់ ត្រូវបានអាជ្ញាធរថៃបញ្ជូនមកពីខេត្ត ប៉ាត់តានី ភាគខាងត្បូង នៃប្រទេសថៃ និងត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ ធ្វើការអប់រំណែនាំអំពីច្បាប់ឆ្លងកាត់ព្រំដែន និងរបៀប នៃការទប់ស្កាត់ការពារជម្ងឺឆ្លង covid-19 បន្ទាប់មកប្រគល់ជូនក្រុមចត្តាឡីស័ក យកទៅសម្រាកនៅមន្ទីរពេទ្យបង្អែកប៉ោយប៉ែត ជាបណ្តោះអាសន្ន ដើម្បីពិនិត្យ និងតាមដានសុខភាពពួកគាត់បន្ត ៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៤៧នាក់

https://www.facebook.com/GDIOfficial 27-06-2020

នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ធង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លង កូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៤៧នាក់ ស្រី ២៤នាក់ និងពលរដ្ឋថៃចាកចេញមានចំនួន០៣នាក់ ស្រី០១នាក់ មានឯកសារចេញពីស្ថានទូតថៃ និងលិខិតបញ្ជាក់សុខភាព៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម ខាងភាគីថៃចាប់បញ្ជូនពលករខ្មែរ ដែលឆ្លងដែនខុសច្បាប់ ចំនួន ០៥នាក់

https://www.facebook.com/GDIOfficial 27-06-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិចាំយាម នាវេលាម៉ោង ១៤និង២០នាទី ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ ខាងភាគីថៃចាប់បញ្ជូនពលករខ្មែរ ដែនឆ្លងដែនខុសច្បាប់ ចំនួន ០៥នាក់ ដោយមានការចូលរួមត្រួតពិនិត្យសុខភាពពីក្រុមចត្តាឡីស័ក។ កម្លាំងនគរបាលប៉ុស្តិ៍បានឲ្យដឹងថា ពលករខ្មែរទាំង ០៥នាក់នេះ មាន ១-ឈ្មោះ លី វុទ្ធី ភេទប្រុស មានទីលំនៅ ភូមិទី៦ ឃុំវាលវង់ ស្រុកគីរីវង្ស ខេត្តតាកែវ, ២-ឈ្មោះ វ៉ាន់ ជី ភេទប្រុស មានទីលំនៅ ភូមិទី១ ឃុំដងទង់ ស្រុកខេមរភូមិន្ទ ខេត្តកោះកុង, ៣-ឈ្មោះ ហូសា សុះព្រីន ភេទប្រុស មានទីលំនៅ ភូមិជំនីក ឃុំជំនីក ស្រុកកងមាស ខេត្តកំពង់ចាម, ៤-ឈ្មោះ សាន វិបុល ភេទប្រុស មានទីលំនៅ សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ និង៥-ឈ្មោះ ម៉ៅ កើនកុល ភេទប្រុស មានទីលំនៅ ភូមិរលៀក ឃុំតាអូរ ស្រុកគីរីវង្ស ខេត្តតាកែវ។ បន្ទាប់មកកម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំ និងណែនាំ រួចបញ្ជូនទៅឲ្យក្រុមចត្តាឡីស័ក ដើម្បីអនុវត្តបន្ត៕

ដោយឡែកភាគីថៃ នៅតែបន្តបិទច្រក មិនឲ្យអ្នកដំណើរ ចេញ-ចូល ចំណែកទំនិញទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តចំនួន ០២នាក់ ដែលទទួលបានការអនុញ្ញត និងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានយ៉ាងត្រឹមត្រូវគ្មាន COVID-19៕

## ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដាំ បានទទួលពលរដ្ឋខ្មែរ ចំនួន ០១នាក់ ពីសមត្ថកិច្ចថៃ

https://www.facebook.com/GDIOfficial 27-06-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដាំ នាថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ២០២០ បានទទួលពលរដ្ឋខ្មែរចំនួន ០១នាក់ ពីសមត្ថកិច្ចថៃ ពាក់ព័ន្ធនឹងបទឆ្លងដែនខុសច្បាប់ ទៅកាប់ឈើនៅប្រទេសថៃ ដែលចេញតាមច្រកអានសេះ ស្រុកជាំក្សាន ខេត្តព្រះវិហារ៕

## កម្ពុជា-ថៃ កត់សម្គាល់វឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការទ្វេភាគី

https://www.facebook.com/Royal-Embassy-of-Cambodia-in-Bangkok/ 29-06-2020

(បាងកក)៖ ប្រតិភូកម្ពុជា និងថៃ បានកត់សម្គាល់អំពីវឌ្ឍនភាពនៃទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការទ្វេភាគី ចាប់តាំងពីកិច្ចប្រជុំគណៈរដ្ឋមន្ត្រីចម្រុះកម្ពុជា-ថៃ លើកទី៣ នៅប្រទេសកម្ពុជា មិនថាវិស័យពាណិជ្ជកម្ម និងវិនិយោគ អប់រំ កសិកម្ម ការងារ យោធា និងកិច្ចសហប្រតិបត្តិការតាមបណ្តោយព្រំដែន។ ការកត់សម្គាល់នេះ បានធ្វើឡើងនៅក្នុងជំនួបពិភាក្សា និងពិសារអាហារថ្ងៃត្រង់រវាង ឯកឧត្តម អ៊ុក សោភ័ណ ឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសថៃឡង់ដ៍ និងឯកឧត្តម ឧត្តមសេនីយឯក ផៃរោជ វិល័យឡាក់ ប្រធាននាយកដ្ឋានកិច្ចការព្រំដែននៃអគ្គបញ្ជាការដ្ឋានកងទ័ពភូមិន្ទថៃ កាលពីព្រឹកថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ ដើម្បីអបអរខួបអនុស្សាវរីយ៍លើកទី៧០ នៃទំនាក់ទំនងការទូតប្រទេសទាំងពីរ។ នៅក្នុងឱកាសនោះដែរ ភាគីទាំងពីរបានលើកឡើងពីទំនាក់ទំនងដ៏យូរអង្វែងរវាងប្រទេសទាំងពីរ និងបានវាយតម្លៃខ្ពស់ចំពោះកិច្ចសហការកន្លងមក ជាពិសេសវិស័យសន្តិសុខតាមព្រំដែន ការផ្លាស់ប្តូរព័ត៌មាន ឬការសម្របសម្រួលបញ្ហាផ្សេងៗជូនប្រជាជនកំឡុងពេលវិបត្តិជម្ងឺកូវីដ១៩។ របៀបវារៈដែលភាគីទាំងពីរ បានពិភាក្សានៅរួមមាន៖

១. ការតម្លើងច្រកព្រំដែនអន្តរជាតិចំនួន ៤ រវាងកម្ពុជា និងថៃ ដែលថ្នាក់ដឹកនាំបានឯកភាព
២. ការរៀបចំកិច្ចប្រជុំគណៈកម្មការព្រំដែនទូទៅ
៣. កិច្ចសហប្រតិបត្តិការវិស័យការងារ និងបញ្ហាពលករឆ្លងដែន ក្រោយវិបត្តិជម្ងឺកូវីដ១៩
៤. កិច្ចសហប្រតិបត្តិការដោះមីនតាមបណ្តោយព្រំដែន
៥. ការបោះបង្គោលព្រំដែនគោក
៦. ការផ្តល់វគ្គបណ្តុះបណ្តាលផ្នែកកសិកម្ម និងកែច្នៃជូនមន្ត្រី និងប្រជាជនកម្ពុជា
៧. ការផ្តល់អាហារូបករណ៍ជូនសិក្ខាកាមយោធាថៃ មកសិក្សានៅសាកលវិទ្យាល័ការពារជាតិកម្ពុជា។

## ពលករខ្មែរចំណាយម្នាក់៣000 បាត ដើម្បីទៅរកការងារធ្វើ

http://kampucheathmey.com/ 29/6/2020 8:16 Am

ប្រទេសថៃ ៖ ពលករខ្មែរ សរុបមានចំនួន ១៣ នាក់ ត្រូវបានក្រុមតម្រួតថៃតាមប្រមាញ់ និងឈានដល់ការឃាត់ខ្លួន នៅក្នុងទឹកដីថៃ បន្ទាប់ពីពួកគេបាននាំគ្នាលបឆ្លងដែនខុសច្បាប់ចូលទៅរកការងារធ្វើ ដោយម្នាក់ៗត្រូវចំណាយ ៣ ០០០ បាត ដើម្បីអោយរថយន្តដឹកជូលអោយដល់គោលដៅ ។ នៅព្រឹកថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០២០ កន្លងទៅថ្មីៗនេះ លោក អាទិត្យ យ៉ាកែវ មន្ត្រីនៃការិយាល័យ តម្រួតអន្តោប្រវេសន៍ ខេត្តស្រះកែវ បានទទួលបញ្ជាពីថ្នាក់ដឹកនាំ ឱ្យដឹកនាំកម្លាំងចេញប្រតិបត្តិការត្រួតពិនិត្យទៅលើការលបឆ្លងដែនដោយមិនស្របច្បាប់របស់ប្រទេសជិតខាង ក្នុងបំណងចូលទៅរកការងារធ្វើនៅក្នុងប្រទេសថៃ ស្របពេលដែលក្នុងប្រទេសកំពុងទប់ស្កាត់នូវការរីរាលដាល នៃជម្ងឺ កូវីដ ១៩ ផងនោះ ។

នៅក្នុងកិច្ចប្រតិបត្តិការនេះ កម្លាំងអន្តោប្រវេសន៍ថៃ ដែលបានសហការជាមួយកម្លាំងសន្តិសុខផ្ទៃក្នុង បានប្រទះឃើញរថយន្តចំនួន ២ គ្រឿង ដែលកំពុងបើកបរតាមគ្នា នៅលើកំណាត់ផ្លូវ ពី ច័ន្ទបុរី ទៅស្រះកែវហើយកំពុងបត់ឆ្វេងចូលទៅក្នុងស្ថានីយ៍ប្រេងឥន្ទនៈមួយកន្លែង ឃីហោ ដួងសិទ្ធិ ស៊ីរ៉ុស ស្ថិតក្នុងស្រុកវ៉ាំងណាំយិន ខេត្តស្រះកែវ ទើបសមត្ថកិច្ចឃាត់ និងសុំត្រួតពិនិត្យរថយន្ត ។ នៅទីបំផុតសមត្ថកិច្ចថៃបានរកឃើញថា ក្នុងរថយន្តទាំង ២ គ្រឿងនេះ សុទ្ធតែមានផ្ទុកពលករខ្មែរដែលគ្មានច្បាប់អនុញ្ញាតទាំងអស់ ទើបនាំខ្លួនអ្នកបើកបរ និងពលករទៅសាកសួរ។ រថយន្តទី ១ ម៉ាកនីសាន់ ព៌ណប្រផេះពាក់ស្លាកលេខបាងកក ៥៧៣៥ បើកបរដោយឈ្មោះ សង្ក្រាន សែផូ ភេទប្រុស អាយុ ៥៧ ឆ្នាំ រស់នៅខេត្ត ឡាំងប៉ាង មានដឹកពលករខ្មែរចំនួន ៩ នាក់ និងរថយន្តទី ២ ម៉ាក តូយ៉ូតា ព៌ណស ពាក់ស្លាកលេខ រ៉ាក់យ៉ង ៦២១៤ បើកបរដោយឈ្មោះ ណុបដុន សែនមុខ ភេទប្រុស អាយុ ៥៨ ឆ្នាំ ដឹកពលករខ្មែរ ៤ នាក់ ។

ពលករខ្មែរទាំងអស់បានសារភាពថា ពួកគេបាននាំគ្នាដើរឆ្លងដែនតាមច្រករបៀង ក្នុងឃុំបានទ្បែម ស្រុកពោងណាំរ៉ន ខេត្តច័ន្ទបុរី និងចំណាយអោយរថយន្តក្នុងម្នាក់ ៣ ០០០ បាត ដើម្បីអោយជូនទៅរកការងារកសាងនៅក្នុងខេត្ត សមុទ្រប្រាកាន ។ ដោយឡែកអ្នកបើកបរទាំងពីរដែលជាជនជាតិថៃ បានសារភាពថា ការដឹកពលករខ្មែរនេះ គឺគ្រាន់តែស៊ីឈ្នួលអោយគេម្នាក់តែប៉ុណ្ណោះ ដោយដឹកចេញពីខេត្ត ច័ន្ទបុរី ឆ្លងកាត់ខេត្ត ស្រះកែវ ឆ្ពោះទៅកាន់ខេត្ត សមុទ្រប្រាកាន ។

បច្ចុប្បន្នទាំងអ្នកបើកបរ ក៏ដូចជាពលករខ្មែរទាំងអស់ ត្រូវបានកម្លាំងតម្រួតថៃ ប្រគល់ទៅអោយខាងជំនាញនាំយកទៅសាកសួរបន្ត ដើម្បីកសាងសំណុំរឿងបញ្ជូនតាមផ្លូវច្បាប់ ពាក់ព័ន្ធនឹងការឆ្លងដែនចូលដោយមិនស្របច្បាប់ ទៅធ្វើការ ឬស្នាក់នៅក្នុងព្រះរាជាណាចក្រថៃ ៕ អត្ថបទ៖ សោ និយមវ័ត្ន

## ពលករខ្មែរ ៤ នាក់ ត្រូវថៃបាញ់បណ្តាលឲ្យរងរបួសធ្ងន់ មិនទាន់ដឹងថាស្លាប់ឬអត់ទេ ខណៈជួបជុំផឹកស៊ីថ្ងៃបើកលុយ (វីដេអូ)

https://www.cen.com.kh/ June 29, 2020

ពលករខ្មែរ៤នាក់ ត្រូវបានអ្នកគ្រប់គ្រងជំរុំ (កន្លែងស្នាក់នៅរបស់ពលករ) ជាជនជាតិថៃ បាញ់បណ្តាលឲ្យរងរបួសធ្ងន់ធ្ងរ មិនដឹងថាស្លាប់ ឬ នៅមានជីវិតនោះទេ ខណៈឡានពេទ្យបានដឹកយកទៅសង្គ្រោះបន្ទាន់ កាលពីពេលថ្មីៗនេះ ។ រឿងរ៉ាវនេះ បានកើតឡើង គឺនៅពេលដែលពលករខ្មែរកំពុងជួបជុំផឹកស៊ី នៅថ្ងៃបើកលុយ។ បើតាមប្អូនស្រីម្នាក់ដែលជាពលករ បានរៀបរាប់ទាំងរំជួលចិត្តថា នៅយប់ថ្ងៃកើតហេតុ បងប្អូនពលករខ្មែរយើង បានជួបជុំផឹកស៊ីនៅក្នុងកន្លែងស្នាក់នៅ ក្នុងថ្ងៃបើកប្រាក់ខែ នៅពេលនោះស្រាប់តែអ្នកមើលការខុសត្រូវកន្លែងស្នាក់នៅជាជនជាតិថៃ បានរករឿង និងបាញ់គំរាម បណ្តាលឲ្យត្រូវពលករខ្មែរ ៤ នាក់ រងរបួសធ្ងន់ធ្ងរតែម្តង ដោយអ្នកខ្លះត្រូវរបួសត្រង់ដៃ ខ្លះទៀតត្រូវចំពោះ។ ប្អូនស្រីខាងលើដែលត្រូវជាក្មួយជនរងគ្រោះម្នាក់ក្នុងចំណោមនោះ បានបញ្ជាក់ផងដែរថា អ្នកដែលបានបាញ់ ក៏ត្រូវបានគេព្រួតចាប់វ៉ៃស្លាប់បាត់ទៅហើយផងដែរ។ យ៉ាងណាមិញ ហេតុការណ៍នេះផងដែរ យើងក៏ពុំទាន់ដឹងច្បាស់លើសពីនេះ និងបានកើតឡើងនៅក្នុងខេត្តណាមួយ នៃប្រទេសថៃនោះទេ ខណៈដែលវីដេអូនេះត្រូវបានចែករំលែកនៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០ នេះដោយគណនីហ្វេសប៊ុកឈ្មោះ «កូន ខ្លាតូច ឬ ទេព សូលីដា» ។

គួរបញ្ជាក់ផងដែរថា មកទល់ពេលនេះ រដ្ឋាភិបាលថៃត្រូវបានដឹងថា ពុំទាន់អនុញ្ញាតឲ្យមានការជួបជុំដូចមុនទាំងស្រុង ឬ ការចេញដើរហើរនៅពេលយប់អធ្រាត្រនោះទេ ដោយសារស្ថានភាពវីរុសឆ្លង Covid-19 នៅពុំទាន់ធូរស្រាល។ កន្លងមក ព្រះសង្ឃថៃមួយអង្គ ក៏ត្រូវអាជ្ញាធរបាញ់បណ្តាលឲ្យស្លាប់ផងដែរ ដោយសាររឿងរំលោភបំពានបម្រាមចេញចូលពេលយប់ក្នុងម៉ោងហាមឃាត់។ ហេតុនេះ សូមបងប្អូនខ្មែរដែលជាពលករទាំងអស់ ត្រូវតែបន្តមានការប្រុងប្រយ័ត្នក្នុងជួបជុំផឹកស៊ី ខណៈរាជរដ្ឋាភិបាលយើងក៏បានអំពាវនាវផងដែរ បន្ទាប់ពីមានករណីពលករខ្មែរប្រុសស្រីមួយក្រុម ត្រូវបានអាជ្ញាធរថៃចាប់ខ្លួនកាលពីពេលកន្លងទៅនេះ ដោយសាររឿងជួបជុំផឹកស៊ីល្មើសនឹងបម្រាម៕ **ដោយ៖ លឹម ហុង**

## អាមេរិក ដាក់កូរ៉េខាងជើង ជាប្រទេសមានការជួញដូរមនុស្ស ដ៏អាក្រក់បំផុត រយៈពេល ១៨ឆ្នាំជាប់គ្នា

https://dap-news.com/international/ ByVNT108 Posted on June 27, 2020

វ៉ាស៊ីនតោន៖ ក្រសួងការបរទេស សហរដ្ឋអាមេរិក បានកំណត់ប្រទេសកូរ៉េខាងជើង ជាប្រទេសមួយ ក្នុងចំណោមប្រទេស ដែលមានការជួញដូរមនុស្ស ដ៏អាក្រក់បំផុតសម្រាប់រយៈពេល ១៨ ឆ្នាំជាប់ៗគ្នា។ របាយការណ៍ស្តីពីការជួញដូរមនុស្សប្រចាំឆ្នាំ របស់ក្រសួងបានឲ្យដឹងថា រដ្ឋាភិបាលកូរ៉េខាងជើង មិនបានបំពេញ តាមបទដ្ឋានអប្បបរមា សម្រាប់ការលុបបំបាត់ការជួញដូរ ហើយមិនបានខិតខំប្រឹងប្រែងយ៉ាងខ្លាំង ក្នុងការធ្វើដូច្នេះទេ ដោយទុកប្រទេសនេះ ស្ថិតនៅក្នុងចំណាត់ថ្នាក់ទាបបំផុតទី ៣ ។ ក្នុងកំឡុងពេលរាយការណ៍ មានគោលនយោបាយរបស់រដ្ឋាភិបាល ឬគំរូនៃការបង្ខំ ឱ្យធ្វើការក្នុងការប្រមូលផ្តុំដ៏ធំ របស់មនុស្សពេញវ័យ និងកុមារនៅក្នុងជំរុំពន្ធនាគារ ដែលជាផ្នែកមួយនៃប្រព័ន្ធ ដែលបានបង្កើតឡើង នៃការបង្ក្រាបនយោបាយ នៅក្នុងមណ្ឌលបណ្តុះបណ្តាលការងារ និងតាមរយៈ ការដាក់លក្ខខណ្ឌការងារដោយបង្ខំ ស្តីពីពលករជាប់កិច្ចសន្យាកូរ៉េខាងជើង នៅឯបរទេស”៕ ដោយ៖ ឈូក បូរ៉ា

https://khmer.voanews.com/ 03 មេសា 2020

អង្គការសន្តិសុខ និងសហប្រតិបត្តិការនៅអឺរ៉ុបបានអំពាវនាវនៅថ្ងៃសុក្រនេះឱ្យពង្រឹងកិច្ចខិតខំប្រឹងប្រែងប្រយុទ្ធនឹងការជួញដូរមនុស្ស ក្នុងពេលដែលមានវិបត្តិជំងឺកូវីដ១៩ជាសាកល។ លោក Valiant Richey តំណាងពិសេសអង្គការសន្តិសុខ និងសហប្រតិបត្តិការនៅអឺរ៉ុប ទទួលបន្ទុកការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ដោយសហការជាមួយនឹងប្រទេសអាល់បានី ដែលជាប្រធានប្តូរវេន បានថ្លែងនៅក្នុងសេចក្តីថ្លែងការណ៍មួយចេញផ្សាយពីទីក្រុងវីយែនថា៖ «ជាក់ច្បាស់ណាស់នៅពេលដែលសហគមន៍ពិភពលោករបស់យើងធ្លាក់ចូលក្នុងវិបត្តិដ៏ធំដូចនេះ គឺកាតព្វកិច្ចរបស់យើងប្រយុទ្ធនឹងការកេងប្រវ័ញ្ចពលរដ្ឋរងគ្រោះនៅតែខ្លាំងក្លា»។ ជនរងគ្រោះដោយការជួញដូរមនុស្សប្រឈមមុខនឹងគ្រោះថ្នាក់កាន់តែខ្លាំងដោយសារតែអ្នកជួញដូរកាន់តែសាហាវជាងមុនហើយប្រើប្រាស់ទម្រង់នៃការកេងប្រវ័ញ្ចថ្មីៗដើម្បីរក្សាប្រាក់ចំណូលរបស់ពួកគេ។ នេះបើតាមការបញ្ជាក់នៅសេចក្តីថ្លែងការណ៍នោះ និងបានបន្ថែមថា «ក្នុងគ្រាដែលធនធាននានាត្រូវបានបង្វែរទៅដោះស្រាយបញ្ហាសុខាភិបាល ពលរដ្ឋរងគ្រោះដែលរស់ក្នុងស្ថានភាពផុយស្រួយស្រាប់កំពុងតែជួបហានិភ័យកាន់តែខ្លាំងជាងមុន ក្នុងការធ្លាក់ចូលក្នុងស្ថានភាពត្រូវគេកេងប្រវ័ញ្ច»។ ក្នុងអំឡុងពេលមានវិបត្តិពិភពលោកកម្រិតនេះ ស្ត្រី និងកុមារ ដែលមាន៩០ភាគរយនៃជនរងគ្រោះដោយសារការកេងប្រវ័ញ្ចផ្លូវភេទ និងកុមារចំណាយពេលជាច្រើនម៉ោងតាមអ៊ីនធឺណិតដោយសារតែសាលារៀនបានបិទគឺកាន់តែធ្វើឱ្យពួកគេងាយរងគ្រោះ។ សេចក្តីថ្លែងការណ៍នោះបានបន្ថែមថា៖ «ក្នុងករណីជួញដូរសរីរាង្គកាយមនុស្ស គឺផលប៉ះពាល់នៃជំងឺកូវីដ១៩កាន់តែគួរឱ្យព្រួយបារម្ភដោយសារតែការជួញដូរនេះមានទម្រង់អាក្រក់បំផុតប៉ុន្តែត្រូវបានគេយកចិត្តទុកដាក់តិចតួចបំផុត»៕

# ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០

## កូវីដ១៩៖ ថៃបានបញ្ជូនខ្មែរជាង២០០នាក់ត្រឡប់មកវិញ ក្រោយព្យាយាមឆ្លងដែនរកការងារនៅថៃ

http://www.rfi.fr/km/ ចុះផ្សាយនៅថ្ងៃ: 29/06/2020 - 08:52 ដោយ៖អេង គីមហុង

ពលរដ្ឋខ្មែរ១៣នាក់ ត្រូវបានអាជ្ញាធរថៃ ចាប់បញ្ជូនត្រឡប់មកវិញ នៅថ្ងៃទី២៨ខែមិថុនា បន្ទាប់ពីពួកគេព្យាយាមឆ្លងដែនដោយខុសច្បាប់ទៅរកការងារធ្វើនៅប្រទេសថៃ តាមច្រករបៀងមួយចំនួនស្ថិតនៅក្នុងខេត្តបន្ទាយមានជ័យ។ មន្ត្រីជំនាញបានឲ្យដឹងថា នៅគ្រប់ច្រកព្រំដែនឈមជាមួយថៃ ថៃបានចាប់បញ្ជូនពលរដ្ឋខ្មែរឆ្លងដែនខុសច្បាប់ត្រឡប់មកវិញជាង២០០នាក់ហើយ រាប់ចាប់តាំងពីថៃបានប្រកាសបិទព្រំដែនជាមួយកម្ពុជាកាលពីថ្ងៃទី២៣ខែមីនាមក។លោកស្រី ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានថ្លែងប្រាប់វិទ្យុបារាំងអន្តរជាតិនៅថ្ងៃទី២៩ខែមិថុនានេះថា ពលរដ្ឋខ្មែរនៅតែបន្តឆ្លងដែនដោយខុសច្បាប់ទៅធ្វើការនៅប្រទេសថៃ ទោះបីជាថៃបានបិទព្រំដែនដោយបារម្ភពីជំងឺកូវីដ១៩ ក៏ដោយ។ មូលហេតុដែលពលរដ្ឋខ្មែរបន្តឆ្លងដែនដោយលួចលាក់ដើម្បី ទៅរកការងារធ្វើនៅប្រទេសថៃដោយសារមានការណែនាំពីមេខ្យល់។ មេខ្យល់ដែលអះអាងថា នៅប្រទេសថៃត្រូវការកម្លាំងពលកម្មពីកម្ពុជា។

ចំណែកអាជ្ញាធរខ្មែរដែលមានព្រំដែនជាប់ជាមួយប្រទេសថៃ ត្រូវរង់ចាំទទួលពលរដ្ឋខ្លួនឯងត្រឡប់មកវិញតាមច្រកព្រំដែនដែលឈមជាមួយថៃរួមមានៈ ច្រកអូរបីជាន់ ច្រកអូរស្មាច់ និងច្រកដូងជាដើម។ ប្រឈមបែបនេះលោកស្រី ជូ ប៊ុនអេង សុំចិត្តពលរដ្ឋខ្មែរនៅផ្ទះខ្លួនឯងមួយរយៈពេលសិនដោយកុំធ្វើការសម្រេចចិត្តដោយប្រថុយប្រថានទៅរកការងារធ្វើនៅប្រទេសថៃ ព្រោះដំណាក់កាលកូវីដ១៩ ថៃមិនទាន់ស្វាគមន៍ពលករចំណាកស្រុកនៅឡើយទេ។ ជុំវិញវិធានការទប់ស្កាត់នេះដែរ កាលពីខែមុន លោក ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់បទបញ្ជាឲ្យសមត្ថកិច្ចតាមព្រំដែនបង្កើនការទប់ស្កាត់ពលរដ្ឋឆ្លងដែនខុសច្បាប់ និងតាមចាប់មេខ្យល់មកផ្តន្ទាទោសតាមច្បាប់។

បើតាមលោក ស ខេង នៅពេលច្រកព្រំដែនអន្តរជាតិបានបិទដើម្បីទប់ស្កាត់ជំងឺកូវីដ១៩ប៉ុន្តែនៅតាមច្រករបៀងតូចៗ នៅមានមេខ្យល់លួចនាំមនុស្សឆ្លងដែនខុសច្បាប់។ ដូចនេះលោកបញ្ជាឲ្យសមត្ថកិច្ចតាមព្រំដែនត្រូវបង្កើនការរឹតបន្តឹង និងតាមចាប់មេខ្យល់មកផ្តន្ទាទោសតាមច្បាប់។

លោក ស៊ុម ចាន់គា មន្ត្រីអាដហុកប្រចាំខេត្តបន្ទាយមានជ័យមើលឃើញថា គេពិបាកនឹងទប់ស្កាត់លំហូរឆ្លងដែនដោយខុសច្បាប់ទៅរកការងារធ្វើនៅប្រទេសថៃទោះបីជាពលរដ្ឋខ្មែរដឹងថា ប្រឈមនឹងគ្រោះថ្នាក់ និងការចាប់ចង់ក៏ដោយ។ នេះក៏ដោយសារកត្តាជីវភាពខ្វះខាតខ្លាំងអំឡុងពេលនៃវិបត្តកូវីដ១៩នេះ។

ប៉ុន្តែលោកស្រីជួន ប៊ុនអេង អះអាងថា យ៉ាងហោចណាស់ក្នុងចំណោមពលរដ្ឋខ្មែរជិតពាក់កណ្តាលក្នុងចំណោមមនុស្ស១០ម៉ឺននាក់ដែលសម្រុកមកពីថៃកាលពីអំឡុងខែមីនា ទទួលបានប្រាក់ឧបត្ថម្ភពីរដ្ឋាភិបាលរួចហើយដែរ៕

## ប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ១០១នាក់

https://www.facebook.com/GDIOfficial 29-06-2020

ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិដូង នាថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០ ខាងភាគីថៃនៅតែបន្តបិទទ្វារមិនអនុញ្ញាតឲ្យអ្នកដំណើរជាតិ អន្តរជាតិ ចេញ-ចូលបាននោះទេ។ ចំណែកមធ្យោបាយដឹកទំនិញគឺចេញ-ចូលធម្មតា ដោយឡែកប្រជាពលរដ្ឋខ្មែរ បានធ្វើដំណើរតាមច្រករបៀងស្លាបឆ្វេង-ស្លាបស្តាំចំនួន ១០១នាក់ ស្រី ៣៥នាក់ និងកុមារ ០៩នាក់។ ចំពោះប្រជាពលរដ្ឋខាងលើ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការណែនាំអប់រំ និងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដឹកពួកគាត់ទៅឲ្យមន្ត្រីចត្តាឡីស័ក ត្រួតពិនិត្យសុខភាពវាស់កំដៅ រួចបានអនុញ្ញាតឲ្យពួកគាត់ ទៅលំនៅដ្ឋានរៀងៗខ្លួន៕

## ពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៣៧នាក់

https://www.facebook.com/GDIOfficial 29-06-2020

នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង ១៥និង០០នាទី ភាគីថៃនៅតែបន្តបិទច្រកទ្វារព្រំដែនអន្តរជាតិ ឆង ចម ខេត្តសុរិន្ទ ទល់មុខច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្ន មិនអនុញ្ញាតឲ្យអ្នកដំណើរ គ្រប់សញ្ជាតិចេញ-ចូល ឆ្លងកាត់ ដើម្បីបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺឆ្លងកូវីដ-១៩។ ក្នុងការបិទច្រកនេះ ភាគីថៃបានលើកលែង ទំនិញដែលទទួលបានការអនុញ្ញាត និងអ្នកបើកបររថយន្តដឹកទំនិញដែលទទួលបានការអនុញ្ញាត ព្រមទាំងបានការឆ្លងកាត់ត្រួតពិនិត្យ ដោយសមត្ថកិច្ចទាំងភាគី កម្ពុជា-ថៃ បានត្រឹមត្រូវ និងពលរដ្ឋខ្មែរ ឬពលរដ្ឋថៃ ដែលត្រូវវិលត្រឡប់ចូលប្រទេសរៀងៗខ្លួន។ ចំណែកឯពលរដ្ឋខ្មែរ ដែលបន្តវិលចូលប្រទេសវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ មានចំនួន ៣៧នាក់ ស្រី ១៧នាក់៕

## ពលករខ្មែរនៅថៃជិត ១០០នាក់ ចូលរួមស្វែងយល់ពីសិទ្ធិសេរីភាពខ្លួនធ្វើការនៅប្រទេសថៃ

https://www.rfa.org/khmer/ ដោយ វ៉ែន សុមេធ 2020-06-29

ក្រុមពលករខ្មែរ ៧០នាក់ដែលធ្វើការងារនៅប្រទេសថៃ នាំគ្នាចូលរួមវគ្គបណ្តុះបណ្តាលស្វែងយល់អំពីសិទ្ធិសេរីភាពរបស់ពលករក្នុងពេលបំពេញការងារនៅប្រទេសថៃ នៅរសៀលថ្ងៃទី២៨ មិថុនា។ មន្ត្រីសង្គមស៊ីវិល យល់ថា វគ្គបណ្តុះបណ្តាលនេះជារឿងល្អ ធ្វើឱ្យពលករយល់ដឹងពីសិទ្ធិអំណាចរបស់ខ្លួន និងដើម្បីការពារកុំឱ្យថៅកែថៃកេងប្រវ័ញ្ចកម្លាំងពលកម្មពួកគាត់បានអំពើចិត្តទៀត។

តំណាងពលករខ្មែរម្នាក់ដែលបានចូលរួមអប់រំពីសិទ្ធការងារពលករ លោក ហម ចន្ថា ថ្លែងថា ការអប់រំនេះធ្វើឱ្យលោកយល់ដឹងពីសិទ្ធិសេរីភាពរបស់ពលករបានច្រើនជាងមុន ជាពិសេសបានស្គាល់ស្ថាប័នដែលពួកគាត់អាចប្ដឹងទាមទារអត្ថប្រយោជន៍ផ្សេងៗ នៅពេលដែលថៅកែរំលោភសិទ្ធិការងារ។ ពលកររូបនេះបន្តថា ពីមុនមកនៅពេលមានបញ្ហានៅកន្លែងធ្វើការពួកគាត់មិនហ៊ានតវ៉ាជាមួយថៅកែនោះទេ ពីព្រោះខ្លាចថៅកែបណ្ដេញចេញពីការងារ និងដកហូតលិខិតឆ្លងដែនពីពួកគាត់៖ «ដល់ពេលយើងដឹងច្បាប់ទម្លាប់អីចឹងយើងអត់មានការភ័យខ្លាចទេ កាលពីមុនយើងអត់ដឹងគ្រាន់តែសម្លុត ឬគេធ្វើបាបហើយសូម្បីតែប៉ូលិសចាប់យើងអត់ខុសអីសោះគេវាយទាត់ជាក់យើងក៏មានដែរ ហើយយើងអត់ដឹងទៅពឹងអ្នកណាឱ្យយើងបានទេ។ ដល់ពេលឥឡូវហ្នឹងយើងបានដឹងពីសិទ្ធយើងអីចឹងគឺយើងអាចមានមេធាវីខាងអង្គការគេជួយយើងដល់អីចឹងយើងអាចប្ដឹងគេបាន»។

ចំណែកពលករខ្មែរធ្វើការសំណង់នៅខេត្តឈុនបូរី លោក សូ សារឿន វិញ ប្រាប់ថា ក្រោយពីបានចូលរួមវគ្គបណ្ដុះបណ្ដាលនេះមក លោកបានយល់ថា ប្រសិនបើពលករត្រូវបានថៅកែរំលោភសិទ្ធិការងារ គឺពួកគេអាចប្ដឹងទៅប៉ូលិសថៃ និងក្រសួងការងារថៃ ព្រមទាំងប្ដឹងទៅស្ថានទូតខ្មែរប្រចាំទីក្រុងបាងកកឱ្យជួយអន្តរាគមន៍ពួកគាត់បាន។ លោកបញ្ជាក់ថា លោកនឹងនាំយកចំណេះដឹងទាំងនេះទៅផ្សព្វផ្សាយបន្តដល់ពលករខ្មែរដែលធ្វើការជាមួយលោក ដើម្បីកុំឱ្យថៅកែជនជាតិថៃរំលោភបំពានសិទ្ធិមកលើពួកគាត់នៅថ្ងៃខាងមុខទៀត៖ «គេប្រាប់យើងថា យើងត្រូវមានសិទ្ធិសេរីភាព បើនៅកន្លែងធ្វើការមានការរំលោភសិទ្ធិការងារដូចជាថៅកែមិនបើកលុយឱ្យ ឬលិខិតឆ្លងដែនមានបញ្ហាអីអាចប្ដឹងទៅអង្គការឱ្យជួយបាន។ ប្រទេសគេគោរពសិទ្ធិប្រជាពលរដ្ឋដែរប៉ុន្តែកន្លងមកដោយសារពលករខ្លះមិនដឹងទៅទាក់ទងកន្លែងណាឱ្យជួយនិងមិនចេះភាសាថៃមិនដឹងនិយាយថា ម៉េច»។ វគ្គបណ្ដុះបណ្ដាលនេះរៀបចំដោយសហភាពការងារពលកររបស់ប្រទេសថៃ ធ្វើឡើងនៅខេត្តសមុទ្រប្រាកាន (Samut prakan) ជាប់ទីក្រុងបាងកក ដើម្បីអប់រំដល់ពលករខ្មែរឱ្យបានយល់ដឹងអំពីសិទ្ធិពលករដែលធ្វើការនៅប្រទេសថៃ។

មន្ត្រីអង្គការសង់ត្រាល់ (CENTRAL) ទទួលបន្ទុកផ្នែកពលករ លោក ឌី ថេហូយ៉ា មានប្រសាសន៍ថា ការអប់រំពីសិទ្ធិការងារនេះ ផ្ដល់ប្រយោជន៍ច្រើនដល់ពលករខ្មែរនៅក្រៅប្រទេស ធ្វើឱ្យពួកគេមានទីពឹងផ្នែកច្បាប់ ដើម្បីទាមទារសិទ្ធិសេរីភាពរបស់ខ្លួនក្នុងពេលដែលថៅកែរំលោភបំពានសិទ្ធិការងារមកលើពួកគាត់។ លោកបន្តថា ពលករខ្មែរធ្វើការនៅប្រទេសថៃប្រមាណ ៨០ភាគរយ មិនយល់ដឹងពីសិទ្ធិរបស់ខ្លួននោះទេ ទើបជារឿយៗពួកគេត្រូវបានថៅកែជនជាតិថៃ រំលោភបំពានលើសិទ្ធិការងារជាហូរហែ ដូចជាបើកប្រាក់ខែមិនទៀងទាត់ ធ្វើការច្រើនម៉ោងមិនបើកប្រាក់ឈ្នួលឱ្យ និងមិនផ្ដល់ប្រាក់អត្ថប្រយោជន៍ពេលពួកគេធ្វើការងារនៅថ្ងៃបុណ្យជាតិ និងថ្ងៃឈប់សម្រាកថ្ងៃសៅរ៍ និងថ្ងៃអាទិត្យជាដើម៖ «ហើយមួយទៀតគាត់នៅពេលដែលមានបញ្ហាគាត់អត់ដឹងទៅរកអ្នកណាឱ្យជួយគាត់បានទេ ព្រោះកាលណាគាត់បានចូលរួមវគ្គបណ្ដុះបណ្ដាលហ្នឹង គាត់អត់ដឹងថា ស្ថាប័នណាដែលពាក់ព័ន្ធហ្នឹងការការពារសិទ្ធិរបស់គាត់ទេ។ អីចឹងអាប្រយោជន៍ទាំងពីរ ទាំងបីនេះវាត្រូវបានបាត់ហើយត្រូវបានប្រឈមនឹងការរំលោភសិទ្ធិពួកគាត់»។

លោក ឌី ថេហូយ៉ា ជំរុញឱ្យពលករខ្មែរចូលរួមក្នុងកម្មវិធីបែបនេះឱ្យបានច្រើន ដើម្បីឱ្យមានបណ្ដាញ និងត្រូវចងក្រងគ្នាជាសហគមន៍ពលករ ដើម្បីការពារសិទ្ធិនិងប្រយោជន៍របស់ខ្លួន កុំឱ្យថៅកែថៃចេះតែកេងចំណេញកម្លាំងពលកម្មរបស់ពួកគេបន្តទៀត។ របាយការណ៍របស់អង្គការសង់ត្រាល់ឱ្យដឹងថា ពលករខ្មែរដែលធ្វើការនៅប្រទេសថៃ ទាំងស្របច្បាប់និងខុសច្បាប់ មានប្រមាណ ២លាននាក់៕

## ផ្ទុះអាវុធនៅក្នុងអគារស្នាក់នៅ នៃខេត្តរ៉ាក់យ៉ង ស្លាប់ពលករខ្មែរ ១ និង របួសធ្ងន់ ២

http://kampucheathmey.com/ 30/6/2020 8:06 Am

ប្រទេសថៃ ៖ យ៉ាងហោចណាស់ក៏មានពលករខ្មែរចំនួន ១ នាក់ ដែលបានបាត់បង់ជីវិត នៅក្នុងចំណោមពលករខ្មែរ ដែលរងរបួសចំនួន ៣ នាក់ ក្រោយពេលបញ្ជូនដល់មន្ទីរពេទ្យ នៅខេត្តរ៉ាក់យ៉ង ប្រទេសថៃ ខណៈដែលពួកគេជាច្រើននាក់កំពុងជួបជុំគ្នាផឹកស្រា ក្រោយពេលសម្រាកពីការងារ ហើយត្រូវបានមេការ ដែលជាជនជាតិថៃមកហាមប្រាមឱ្យឈប់ ទើបបណ្ដាលអោយមានការទាស់សម្ដីគ្នា ហើយមេការ ដែលជាជនជាតិថៃរូបនោះ បានដកកាំភ្លើងខ្លីបាញ់សំដៅចូលវង់ផឹកស៊ីតែម្ដង ។

យោងតាមារផ្សាយរបស់គេហទំព័រ កាសែតថៃរ៉ាត់ បានលើកឡើងថា ហេតុការណ៍ ដែលឈានដល់ការផ្ទុះអាវុធនេះ បានកើតឡើងកាលពីវេលាម៉ោង ៨ និង ៤៥ នាទី យប់ ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០២០ក្នុងបរិវេណបន្ទប់ទឹករួម នៃកន្លែងស្នាក់នៅរបស់កម្មករកសាង ដែលជាកន្លែងសំណង់ ខនដូ មីនៀម ដ៏ធំមួយ ក្នុងឃុំម៉ាបតាភុតស្រុកមឿង ខេត្តរ៉ាក់យ៉ង ប្រទេសថៃ ។ គេហទំព័រ ដដែលបានស្រង់សម្ដីសាក្សីមកបញ្ជាក់ថា នៅមុនពេលកើតហេតុគឺមានពលករខ្មែរ ៤ – ៥ នាក់ បានជួបជុំនាំគ្នាផឹកស៊ី ក្រោយពេលសម្រាកពីការងារ នៅពេលនោះដែរក៏ស្រាប់តែមានអ្នកមើលការខុសត្រូវម្នាក់ឈ្មោះ ផៃរ៉ូត នួនសាង៉ា បានដើរមកហាមឱ្យឈប់ផឹក ព្រោះយប់ហើយខ្លាចស្អែកឡើងធ្វើការមិនកើត ប៉ុន្តែដោយសារអំណាចនៃជាតិសុរា ធ្វើអោយកម្មករទំាងនោះមិនស្ដាប់ ទើបឈានដល់ការប្រកែកគ្នាតឹងសសៃ ក ដោយភ្លាមៗនោះដែរ លោកមេកាបានដកកាំភ្លើងខ្លីពីចង្កេះមកបាញ់ចូលកណ្ដាលវង់ផឹកសុ ី ទើបធ្វើអោយរងរបួសទៅលើពលករខ្មែរ ចំនួន ៣ នាក់ ដោយក្នុងនោះម្នាក់ត្រូវពោះធ្លាយចេញទៅម្ខាង និងម្នាក់ទៀត ត្រូវចំកណ្ដាលដើមទ្រូង ។

នៅក្នុងហេតុការណ៍ដ៏រន្ធត់នេះ ក៏មានការភ្ញាក់ផ្អើលទៅដល់កម្មករដទៃ និងចោមរោមវាយទៅលើមេកាបណ្ដាលឱ្យមានស្នាមរបួសពេញក្បាល និងលើខ្លួនប្រាណ ព្រមទាំងបានស្លាប់នៅនឹងកន្លែងតែម្ដង។ ចំណែកពលករខ្មែរទាំង ៣ នាក់ ដែលត្រូវបានបញ្ជូនទៅកាន់មន្ទីរពេទ្យ ម៉ាបតាភុត ក៏បានស្លាប់ម្នាក់ ដែលត្រូវគ្រាប់ធ្លាយពោះដោយឡែកអ្នកដែលត្រូវចំកណ្ដាលដើមទ្រូងក៏មិនដឹងជាយ៉ាងណាដែរ ។ បច្ចុប្បន្នក្រោយពេលកើតហេតុ ក្រុមតម្រួតថៃ បានយកកាំភ្លើងទៅរក្សាទុកដើម្បីទុកជាភស្ដុតាង និងស្រាវជ្រាវឱ្យបានច្បាស់ទៅលើដើមចមនៃរឿងផ្ទុះអាវុធនេះ ៕ អត្ថបទ៖សោ និយមរ័ត្ន

## ស្ថានទូតកម្ពុជា ប្រចាំប្រទេសថៃ ចុះសួរសុខទុក្ខ និងចែកគ្រឿងឧបភោគបរិភោគ និងសម្លៀកបំពាក់ពលករខ្មែរជាង១០០នាក់

http://kampucheathmey.com/ 29/6/2020 8:36 Pm

ភ្នំពេញ ៖ លោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិកម្ពុជាបានឲ្យដឹងនៅមុននេះបន្តិចថា នៅរសៀលថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០ ស្ថានទូតកម្ពុជាប្រចាំប្រទេសថៃបានសហការជាមួយមូលនិធិលើក កម្ពស់សិទ្ធិនិងគុណភាពជីវិតពលករ (LPN) មូលនិធិកញ្ចក់ឆ្លុះបញ្ចាំង ប៉ុស្តិ៍ប៉ូលីសម៉ាក់កាសាន់ និងរដ្ឋបាលខណ្ឌឌិនដែង ចុះសួរសុខទុក្ខ និងចែកគ្រឿងឧបភោគបរិភោគ និងសំលៀកបំពាក់ដល់បងប្អូនពលករខ្មែរប្រមាណជាង១០០នាក់នៅក្នុងការដ្ឋានសំណង់របស់ក្រុមហ៊ុនរីថា នៅទីក្រុងបាងកក ដែលកំពុងជួបទុក្ខលំបាកដោយសារអគ្គីភ័យឆាបឆេះកន្លែងស្នាក់៕ កោះកែវ